**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដំណាក់កាលទី ៣**

( LASED III )

# ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់

## ( RPF )

ឧបសម្ព័ន្ធ ១ នៃក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម


រៀបចំដោយ៖

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ដោយមានជំនួយរបស់ទីប្រឹក្សាដែលទទួលបានការណែនាំ និងការចង្អុលបង្ហាញពីអគ្គនាយកដ្ឋាន

ដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ


ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០២០

| ពាក្យកាត់ | |
|---|---|
| AH | គ្រួសារដែលរងផលប៉ះពាល់ |
| AP | ជនដែលរងផលប៉ះពាល់ |
| AWPB | ផែនការការងារ និងថវិកាប្រចាំឆ្នាំ |
| C/S Fund | មូលនិធិឃុំ/សង្កាត់ |
| CC | ក្រុមប្រឹក្សាឃុំ |
| CDO | មន្ត្រីអភិវឌ្ឍន៍សហគមន៍ |
| CHM | យន្តការដោះស្រាយបណ្តឹងតវ៉ា (គម្រោងដំណាក់កាលទី ២) |
| CPR | ធនធានទ្រព្យសម្បត្តិរួម |
| DIMDM | នាយកដ្ឋានត្រួតពិនិត្យផ្ទៃក្នុង និងគ្រប់គ្រងទិន្នន័យ (MEF-GDR) |
| DMS | ការអង្កេតវាស់វែងលម្អិត |
| DP | ដៃគូអភិវឌ្ឍន៍ |
| DRP | ផែនការដោះស្រាយផលប៉ះពាល់លម្អិត |
| EA | ស្ថាប័នដឹកនាំការអនុវត្តគម្រោង |
| ESS | បទដ្ឋានបរិស្ថាន និងសង្គម |
| ESS1 | ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និងហេតុផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម |
| ESS5 | លទ្ធកម្មដីធ្លី ការរឹតត្បិតលើការប្រើប្រាស់ដី និងការតាំងទីលំនៅឡើងវិញដោយស្ម័គ្រចិត្ត |
| ESS7 | ជនជាតិដើមភាគតិច |
| FPIC | ការយល់ព្រមដោយសេរី ជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ |
| GDA | អគ្គនាយកដ្ឋានកសិកម្ម |
| GDCG | អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ |
| GDH | អគ្គនាយកដ្ឋានលំនៅដ្ឋាន |
| GDR | អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ |
| GRC | គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា |
| GRM | យន្តការដោះស្រាយបណ្តឹងតវ៉ា (គម្រោងដំណាក់កាលទី ៣) |
| IA | ស្ថាប័នអនុវត្តន៍គម្រោង |
| IC | សហគមន៍ជនជាតិដើមភាគតិច |
| ICLT | ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច |
| IP | ជនជាតិដើមភាគតិច |
| IC | សហគមន៍ជនជាតិដើមភាគតិច |
| IPM | វិធានការការពារបណ្តោះអាសន្ន (ការហាមឃាត់ប្រតិបត្តិការដីធ្លីក្នុងតំបន់ដែលស្នើឡើងសម្រាប់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច) |
| IRC-WG | ក្រុមការងារគណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ |
| JSDF | មូលនិធិអភិវឌ្ឍន៍សង្គមរបស់ជប៉ុន |

| | |
|---|---|
| LAR | លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ |
| LASED | គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MOIO | ក្រសួងមហាផ្ទៃ |
| MOU | អនុស្សារណៈយោគយល់គ្នា |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NTFP | អនុផលព្រៃឈើ |
| PDEF | មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| PIB | សៀវភៅព័ត៌មានស្តីពីគម្រោង |
| PIM | សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង |
| PDLMUPC | មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| PLUAC | គណៈកម្មាធិការប្រើប្រាស់ និងបែងចែកការប្រើប្រាស់ដីធ្លីថ្នាក់ខេត្ត |
| PPC | ទីប្រឹក្សារៀបចំគម្រោង |
| PRSC | អនុគណៈកម្មាធិការខេត្តដោះស្រាយផលប៉ះពាល់ |
| RCS | ការសិក្សាពីតម្លៃជំនួស |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| ROW | ដីចំណីផ្លូវ |
| RP | ផែនការដោះស្រាយផលប៉ះពាល់ |
| RPF | ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ |
| SLC | សម្បទានដីសង្គមកិច្ច |
| SOP-LAR | នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ |

## និយមន័យពាក្យគន្លឹះ

**គ្រួសារដែលរងផលប៉ះពាល់ (AH) ៖** គ្រួសារដែលរងផលប៉ះពាល់រូបវន្ត និង/ឬសេដ្ឋកិច្ចដោយសារលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញដោយស្ម័គ្រចិត្ត។ គ្រួសារសំដៅលើជនគ្រប់រូបដែលរស់នៅ និងហូបចុកជាមួយគ្នាក្នុងទម្រង់ជាឯកតាសង្គមមួយ។ គ្រួសារអាចសំដៅលើជនដែលរងផលប៉ះពាល់ (AP)។

**កម្មសិទ្ធិសមូហភាព ៖** ផ្ទៃដីដែលកាន់កាប់រួមដោយសហគមន៍របស់ក្រុមជនជាតិដើមភាគតិច។ ក្នុងតំបន់ដែលកាន់កាប់ដោយជាសមូហភាព ក្បាលដីដែលប្រើប្រាស់ដោយបុគ្គល ឬគ្រួសារមិនមែនជាទ្រព្យសម្បត្តិឯកជន

របស់ពួកគេទេ ហើយសហគមន៍គ្មានសិទ្ធិបោះបោលអចលនទ្រព្យដែលស្ថិតក្រោមកម្មសិទ្ធិសមូហភាពរបស់ខ្លួន និងអចលនទ្រព្យដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋដល់បុគ្គល ឬក្រុមណាមួយឡើយ។

**គណៈកម្មាធិការសហគមន៍ ៖** ស្ថាប័នគ្រប់គ្រងនៅមូលដ្ឋានដែលជ្រើសតាំងដោយសមាជិករបស់សហគមន៍ជនជាតិដើមភាគតិចទាំងមូលដើម្បីដោះស្រាយបញ្ហាក្នុងសហគមន៍ រួមទាំងការដោះស្រាយវិវាទក្នុងសហគមន៍នៅក្រៅដែនយុត្តាធិការរបស់តុលាការ។ ក្រោមដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍របស់ជនជាតិដើមភាគតិច គណៈកម្មាធិការសហគមន៍មួយត្រូវបានបង្កើតឡើងនៅដំណាក់កាលទី ២ ដំណាក់កាលទី៣ និងទន្ទឹមគ្នានឹងការអនុម័តលក្ខន្តិកៈសហគមន៍។ លក្ខន្តិកៈនេះជាវិធានផ្ទៃក្នុងដែលជានាការប្រើប្រាស់ និងគ្រប់គ្រងដីកម្មសិទ្ធិសមូហភាពប្រកបដោយសមធម៌ និងដោះស្រាយវិវាទផ្ទៃក្នុង ព្រមទាំងជួយអភិរក្សអត្តសញ្ញាណ វប្បធម៌ និងប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច និងទំនៀមទម្លាប់ល្អប្រសើរពាក់ព័ន្ធនឹងការប្រើប្រាស់ និងគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

**ការពិគ្រោះយោបល់ ៖** ដំណើរការដែល ១) ចាប់ផ្តើមតាំងពីដំបូងនៅដំណាក់កាលរៀបចំគម្រោង និងត្រូវបានអនុវត្តនៅដំណាក់កាលផ្សេងៗរបស់គម្រោង និងវដ្តលទ្ធកម្មដីធ្លី ២) ផ្តល់ការផ្សព្វផ្សាយទាន់ព័ត៌ពេលវេលានូវព័ត៌មានពាក់ព័ន្ធ និងគ្រប់គ្រាន់ជាភាសាខ្មែរ (ហើយក្នុងករណីប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍របស់ជនជាតិដើមភាគតិច ត្រូវបានផ្សព្វផ្សាយជាភាសារបស់សហគមន៍ជនជាតិដើមភាគតិចដែលជាអ្នកទទួលផល) ដែលអាចយល់បាន និងងាយស្រួលប្រើប្រាស់ដោយជនដែលរងផលប៉ះពាល់ ៣) ត្រូវបានធ្វើឡើងក្នុងបរិយាកាសដែលគ្មានការបំភិតបំភ័យ ឬការបង្ខិតបង្ខំ ដោយគោរពខ្ជាប់ខ្ជួននូវនិយាមវប្បធម៌ និង ៤) មានលក្ខណៈបរិយាប័ន និងឆ្លើយតបនឹងយេនឌ័រ និងត្រូវបានកែសម្រួលទៅតាមតម្រូវការរបស់ក្រុមជួបការលំបាក និងងាយរងគ្រោះ។

**សំណង ៖** ការទូទាត់ជាសាច់ប្រាក់ ឬមិនមែនជាសាច់ប្រាក់ សម្រាប់ទ្រព្យសម្បត្តិ ឬធនធានដែលត្រូវបានធ្វើលទ្ធកម្ម ឬរងផលប៉ះពាល់ដោយសារប្លង់/ការរចនាសម្រាប់គោលបំណងសម្បទានដីសង្គមកិច្ច ឬការផ្តល់ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍របស់ជនជាតិដើមភាគតិច។

**កាលបរិច្ឆេទឱសានវាទសម្រាប់សម្បទានដីសង្គមកិច្ច** ដែលគាំទ្រដោយគម្រោងដំណាក់កាលទី ៣ គឺជាកាលបរិច្ឆេទនៃការចេញសេចក្តីសម្រេចដោយអភិបាលខេត្តដើម្បីចាត់នីតិវិធីលើការបែងចែកប្រភេទដីរដ្ឋ នៅពេលដីធ្លីដែលត្រូវបានកំណត់អត្តសញ្ញាណ និងគូសផែនទីសម្រាប់សម្បទានដីសង្គមកិច្ចត្រូវបានចុះបញ្ជីជាដីឯកជនរបស់រដ្ឋ (ជំហានទី ៤ ក្នុងដំណើរការសម្បទានដីសង្គមកិច្ចថ្នាក់ឃុំដែលមាន ១០ ដំណាក់កាល)។ ខណៈដែលកាលបរិច្ឆេទនេះអាចមិនដូចគ្នានឹងកាលបរិច្ឆេទជំរឿន ដែលកំណត់អត្តសញ្ញាណជន/គ្រួសារដែលរងផលប៉ះពាល់អវិជ្ជមានដោយសារគម្រោង គម្លាតរវាងកាលបរិច្ឆេទដែលសម្បទានដីសង្គមកិច្ចត្រូវបានចុះបញ្ជីជានីតិបុគ្គល និងកាលបរិច្ឆេទបន្តបន្ទាប់នៃជំរឿន មិនត្រូវបានរំពឹងថាមានទំហំធំធេងទេ ហើយក្នុងការអនុវត្តជាក់ស្តែង ការចុះបញ្ជី និងជំរឿនអាចធ្វើឡើងក្នុងពេលតែមួយ (មើលតារាង ២)។ ក្រុមប្រឹក្សាឃុំនឹងប្រើប្រាស់កំណត់ត្រាមានស្រាប់ស្តីពីការរស់នៅ និងការប្រើប្រាស់ដីធ្លីក្នុងឃុំដើម្បីផ្តល់ទិន្នន័យដើមគ្រាស្តីពីការកាន់កាប់ដោយគ្មានការអនុញ្ញាតក្នុងតំបន់សម្បទានដីសង្គមកិច្ចដែលស្នើឡើង។ ព័ត៌មានទាំងនេះនឹងត្រូវបានផ្ទៀងផ្ទាត់ដោយក្រុមប្រឹក្សាឃុំ និងគណៈកម្មាធិការប្រើប្រាស់ និងបែងចែកការប្រើប្រាស់ដីធ្លីថ្នាក់ខេត្ត និងតាមរយៈកិច្ចប្រជុំជាសាធារណៈក្នុងដំណើរការរៀបចំផែនការសម្បទានដីសង្គមកិច្ច។

**កាលបរិច្ឆេទឱសានវាទសម្រាប់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច** ដែលទ្រគាំទ្រដោយគម្រោងដំណាក់កាលទី ៣ គឺជាកាលបរិច្ឆេទដែលសហគមន៍ជនជាតិដើមភាគតិច បានឆ្លងកាត់ដំណើរការរៀបចំផែនការដោយមានការចូលរួម ជាដំណាក់កាលដែលពួកគេបានប្រមូលទិន្នន័យ និងផ្តល់ផែនទីបឋមដែលកំណត់ព្រំប្រទល់តំបន់ដែលស្នើឡើងសម្រាប់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍របស់ជនជាតិដើមភាគតិច (នៅដំណាក់កាលទី ២ ក្រោមជំហាន ២.៥ ក្នុងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍របស់ជនជាតិដើមភាគតិច) និងដាក់ពាក្យភ្ជាប់ជាមួយនឹងផែនទីនេះសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍របស់ជនជាតិដើមភាគតិចទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដំណាក់កាលទី ៣ ក្រោមជំហាន ២.៥)។ ផែនទីបឋមនឹងត្រូវបានផ្សព្វផ្សាយជាសាធារណៈ ហើយនឹងមានរយៈពេល ៣០ ថ្ងៃសម្រាប់ដាក់បណ្តឹងទៅគណៈកម្មាធិការតំណាងសហគមន៍។

**ការអង្កេតវាស់វែងលម្អិត៖** ការវាស់វែងការបាត់បង់ដីធ្លី សំណង់ ទ្រព្យសម្បត្តិផលិតកម្មផ្សេងទៀត និងរបរចិញ្ចឹមជីវិតរបស់ជនម្នាក់ៗ/គ្រួសារនីមួយៗដែលរងផលប៉ះពាល់ដោយសារលទ្ធកម្មដីធ្លី។ ការអង្កេតវាស់វែងលម្អិតជាជំរឿងដែលផ្តល់ទិន្នន័យស្តីពីការខាតបង់ និងផលប៉ះពាល់ដើម្បីកំណត់សំណង និងកញ្ចប់ជំនួយសម្រាប់ផែនការដោះស្រាយផលប៉ះពាល់ក្នុងអនុគម្រោង។ ការវាស់វែងនេះ ត្រូវបានធ្វើឡើងដោយមានការចូលរួមពេញលេញដោយ ជនបាត់បង់ទីលំនៅ ដើម្បីបញ្ចៀសវិវាទលើការវាស់វែង ឬការគណនាមិនត្រឹមត្រូវ និងផ្តល់ការទូទាត់សំណង។

**ការខាតបង់ផ្នែកសេដ្ឋកិច្ច៖** ជាការបាត់បង់ដីធ្លី ទ្រព្យសម្បត្តិ លទ្ធភាពប្រើប្រាស់ទ្រព្យសម្បត្តិ ប្រភពប្រាក់ចំណូល ឬមធ្យោបាយប្រកបរបរចិញ្ចឹមជីវិតដោយសារ ១) លទ្ធកម្មដីធ្លីដោយមិនស្ម័គ្រចិត្ត ឬ ២) ការរឹតត្បិតដោយមិនស្ម័គ្រចិត្តលើការប្រើប្រាស់ដី ឬលទ្ធភាពចេញចូលឧទ្យាន និងតំបន់ការពារដែលកំណត់ដោយច្បាប់។

**សិទ្ធិពិសេស ៖** សិទ្ធរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រើប្រាស់អំណាចអធិបតេយ្យភាពរបស់ខ្លួនដើម្បីធ្វើលទ្ធកម្មដីធ្លីសម្រាប់គោលបំណងសាធារណៈ។ ច្បាប់ជាតិបានកំណត់ពីស្ថាប័នសាធារណៈដែលមានបុព្វសិទ្ធិក្នុងការប្រើប្រាស់សិទ្ធិពិសេស។

**សិទ្ធិ និងអត្ថប្រយោជន៍ដែលត្រូវទទួលបាន ៖** សិទ្ធិទទួលបានដំណោះស្រាយចំពោះផលប៉ះពាល់ ពាក់ព័ន្ធនឹងប្រភេទនៃការបំពេញតាមលក្ខណៈសម្បត្តិសមស្របណាមួយ សំដៅលើចំនួនសរុបនៃសំណងទូទាត់ និងជំនួយក្នុងទម្រង់ផ្សេងទៀត ដែលត្រូវបានផ្ដល់ដល់ជនដែលរងផលប៉ះពាល់ទៅតាមប្រភេទលក្ខណៈសមស្របនីមួយៗ។

**អស្សាមិករណ៍ ៖** ដំណើរការដែលអាជ្ញាធរសាធារណៈ តម្រូវឱ្យបុគ្គល គ្រួសារ ឬសហគមន៍បោះបង់សិទ្ធិដីធ្លីដែលខ្លួនកាន់កាប់ ឬប្រើប្រាស់ និងជាទូទៅ មានការផ្ដល់សំណង។ អស្សាមិករណ៍ក្រោមច្បាប់កម្ពុជាសំដៅលើការដកហូតកម្មសិទ្ធិលើអចលនវត្ថុ ឬសិទ្ធិប្រត្យក្សលើអចលនវត្ថុរបស់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈរួមមាន ដី សំណង់ និងដំណាំដាំដុះសម្រាប់បម្រើការស្ថាបនា ស្ដារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដែលបម្រើប្រយោជន៍សាធារណៈ និងប្រយោជន៍ជាតិ ព្រមទាំងផ្ដល់នូវសំណងជាមុនដោយសមរម្យ និងយុត្តិធម៌។

**ការយល់ព្រមដោយសេរី ជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ ៖** ក្នុងករណីដែលជនជាតិដើមភាគតិចរងផលប៉ះពាល់ដោយសារគម្រោងដែលទ្រទ្រង់ដោយធនាគារពិភពលោក ធនាគារពិភពលោកនឹងតម្រូវឱ្យអ្នកខ្ចីទទួលបានការយល់ព្រមដោយសេរី ជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវពីជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ ពាក់ព័ន្ធនឹងការរចនាគម្រោង ការអនុវត្ត និងលទ្ធផលរំពឹងទុកពាក់ព័ន្ធនឹងហានិភ័យ និងផលប៉ះពាល់។ គ្មាននិយមន័យរួមមួយទេ ប៉ុន្តែការយល់ព្រមដោយសេរី ជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវមិនតម្រូវឱ្យមានអនាមិកភាប និងអាចសម្រេចបានសូម្បីតែនៅពេលដែលបុគ្គល ឬក្រុមនានាក្នុង ឬក្នុងចំណោមជនជាតិដើមភាគតិច បង្ហាញការមិនយល់ព្រម។ ការយល់ព្រមសំដៅលើការទ្រទ្រង់ជាសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចលើសកម្មភាពគម្រោង ដែលប៉ះពាល់ដល់ពួកគេ និងទទួលបានតាមរយៈដំណើរការសមស្របក្នុងវប្បធម៌។

**សហគមន៍ម្ចាស់ស្រុក ៖** ជាសហគមន៍ដែលទទួលជនដែលរងផលប៉ះពាល់ផ្នែករូបវន្តដោយសារគម្រោងក្នុងនាមជាអ្នកតាំងទីលំនៅថ្មី។

**ការទ្រទ្រង់ប្រាក់ចំណូល ៖** ជាសិទ្ធិ និងអត្ថប្រយោជន៍ដែលត្រូវទទួលបាន ដែលផ្ដល់ជូនដើម្បីបង្កើតឡើងវិញនូវបរចិញ្ចឹមជីវិតដែលមានផលិតភាពរបស់ជនបាត់បង់ទីលំនៅដើម្បីអាចបង្កើតប្រាក់ចំណូលដែលស្មើ ឬប្រសិនបើអាច ល្អប្រសើរជាងប្រាក់ចំណូលដែលពួកគេរកបានមុនពេលតាំងលំនៅឡើងវិញ។

**ជនជាតិដើមភាគតិច៖** យោងតាមក្របខណ្ឌបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក ពាក្យ "ជនជាតិដើមភាគតិច" ត្រូវបានប្រើប្រាស់ក្នុងន័យទូទៅដើម្បីសំដៅតែលើក្រុមសង្គម និងវប្បធម៌ដាច់ដោយឡែកមួយដែលមានលក្ខណៈសម្បត្តិទាំងអស់ទៅតាមកម្រិតផ្សេងៗ ដូចខាងក្រោម៖

ក. ការកំណត់អត្តសញ្ញាណដោយខ្លួនឯងជាសមាជិករបស់របស់ក្រុមសង្គម និងវប្បធម៌ជនជាតិដើមភាគតិចដាច់ដោយឡែកមួយ និងការទទួលស្គាល់អត្តសញ្ញាណនេះដោយអ្នកដទៃ និង

ខ. អារម្មណ៍ផ្សារភ្ជាប់ជាសមូហភាពទៅនឹងដែនជម្រកដែលមានលក្ខណៈពិសេសក្នុងភូមិសាស្ត្រ ទឹកដីដូនតា ឬតំបន់សម្រាប់ការប្រើប្រាស់ ឬកាន់កាប់តាមរដូវកាល និងធនធានធម្មជាតិក្នុងតំបន់ទាំងនេះ

គ. ស្ថាប័នវប្បធម៌ទំនៀមទម្លាប់ សេដ្ឋកិច្ច សង្គម ឬនយោបាយដែលមានលក្ខណៈពិសេស ឬដាច់ដោយឡែកពីស្ថាប័នរបស់សង្គម ឬវប្បធម៌ទាំងមូល និង

ឃ. ភាសាពិសេស ឬគ្រាមភាសា ដែលជាញឹកញាប់ខុសប្លែកពីភាសាផ្លូវការ ឬភាសារបស់ប្រទេស ឬតំបន់ដែលពួកគេរស់នៅ។

ច្បាប់ភូមិបាល (២០០១) កំណត់និយមន័យសហគមន៍ជនជាតិដើមភាគតិចជា "ក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទំលាប់នៃការប្រើប្រាស់ជាសមូហភាព"។ សម្រាប់គោលបំណងជាក់ស្តែងទាំងអស់ បុគ្គលិកលក្ខណៈរបស់ជនជាតិដើមភាគតិចក្នុងច្បាប់ភូមិបាលគឺស្រដៀងគ្នា និងត្រួតគ្នានឹងលក្ខណៈវិនិច្ឆ័យទាំង ៤ ដែលប្រើប្រាស់ដោយបទដ្ឋានបរិស្ថាន និងសង្គមទី ៧ ក្នុងការកំណត់និយមន័យជនជាតិដើមភាគតិច បើទោះបីជាច្បាប់ភូមិបាលផ្តោតជាសំខាន់លើកម្មសិទ្ធិដីធ្លីក្នុងទំនៀមទំលាប់ ឬកម្មសិទ្ធិដីធ្លីជាសមូហភាពដែលជាលក្ខណៈវិនិច្ឆ័យទី ២ សម្រាប់ជនជាតិដើមភាគតិចក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៧ ក្តី។

**វិធានការការពារបណ្តោះអាសន្ន៖** លិខិតបង្កករាល់ការទិញ លក់ និងផ្ទេរសិទ្ធិដីធ្លីក្នុងតំបន់ដែលត្រូវបានស្នើឱ្យចុះបញ្ជីជាប័ណ្ណកម្មសិទ្ធិដីសមូហភាព របស់សហគមន៍ជនជាតិដើមភាគតិច។ ឯកសារនេះមានសារៈសំខាន់ណាស់ព្រោះវាបានហាមឃាត់ប្រតិបត្តិការដីធ្លីគ្រប់ទម្រង់ក្នុងតំបន់នេះ ដោយការពារដីធ្លីទាំងនោះពីការទន្ទ្រានកាន់កាប់រហូតទាល់តែសហគមន៍បានទទួលប័ណ្ណកម្មសិទ្ធិផ្លូវការលើដីធ្លីរបស់ខ្លួន ហើយវាគឺជាឯកសារផ្លូវការដំបូងដែលផ្តល់សន្តិសុខសិទ្ធិកាន់កាប់ដល់សហគមន៍ជនជាតិដើមភាគតិច។ ក្រោមដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច វិធានការការពារបណ្តោះអាសន្នធ្វើឡើងក្នុងដំណាក់កាលទី ៣ ជំហានទី ៣។

**ការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត៖** ការតាំងទីលំនៅឡើងវិញត្រូវបានចាត់ទុកថាមិនស្ម័គ្រចិត្តនៅពេលជន ឬសហគមន៍ដែលរងផលប៉ះពាល់ផ្ទាល់ គ្មានសិទ្ធិបដិសេធគម្រោងដែលពាក់ព័ន្ធនឹងលទ្ធកម្មដីធ្លី ឬការរឹតត្បិតលើការប្រើប្រាស់ដីធ្លីដែលធ្វើឱ្យពួកគេបាត់បង់ទីលំនៅ។

**លទ្ធកម្មដីធ្លី ៖** សំដៅលើមធ្យោបាយទាំអអស់នៃការទទួលបានដីធ្លីសម្រាប់គោលបំណងគម្រោង ដែលអាចរួមបញ្ចូលការទិញទាំងស្រុង ការដកហូតទ្រព្យសម្បត្តិ និងលទ្ធកម្មសិទ្ធិប្រើប្រាស់ ដូចជា សិទ្ធិប្រើប្រាស់ដីធ្លី ឬដីចំណីផ្លូវ។ លទ្ធកម្មដីធ្លីអាចរួមបញ្ចូល ១) លទ្ធកម្មដីធ្លីដែលគ្មានមនុស្សកាន់កាប់ ឬប្រើប្រាស់ មិនថាម្ចាស់ដីអាស្រ័យផលពីដីនោះដើម្បីទទួលបានប្រាក់ចំណូល ឬរបរចិញ្ចឹមជីវិតនោះទេ ២) ការយកមកវិញនូវដីសាធារណៈដែលត្រូវបានប្រើប្រាស់ ឬកាន់កាប់ដោយបុគ្គល ឬគ្រួសារ និង ៣) ផលប៉ះពាល់របស់គម្រោងដែលធ្វើឱ្យដីធ្លីលិចលង់ ឬមិនអាចប្រើប្រាស់ ឬចេញចូលបាន។ លទ្ធកម្មដីធ្លីសំដៅលើអ្វីៗដែលលូតលាស់ ឬតាំងនៅជាអចិន្ត្រៃយ៍លើដីធ្លី ដូចជា ដំណាំ អគារ និងការកែលម្អផ្សេងៗទៀត។

**ការបាត់បង់ផ្នែករូបវន្ត ៖** ការតាំងទីលំនៅថ្មី ការបាត់បង់ដីលំនៅដ្ឋាន ឬការបាត់បង់ទីជម្រក ដោយសារ ១) លទ្ធកម្មដីធ្លីដោយមិនស្ម័គ្រចិត្ត ឬ ២) ការរឹតត្បិតដោយមិនស្ម័គ្រចិត្តលើការប្រើប្រាស់ដីធ្លី ឬលទ្ធភាពប្រើប្រាស់ឧទ្យាន និងតំបន់ការពារដែលកំណត់ដោយច្បាប់។

**ជំនួយសម្រាប់ការតាំងទីលំនៅថ្មី ៖** ការទ្រទ្រង់ដែលផ្តល់ជូនអ្នកដែលបាត់បង់ទីលំនៅរូបវន្តដោយសារគម្រោង។ ជំនួយនេះអាចរួមមានមធ្យោបាយធ្វើដំណើរ ស្បៀងអាហារ ទីជម្រក និងសេវាសង្គមដែលត្រូវបានផ្តល់ជូនជនបាត់បង់ទីលំនៅក្នុងពេលតាំងទីលំនៅថ្មី។ ជំនួយនេះក៏អាចរួមបញ្ចូលផងដែរនូវប្រាក់ឧបត្ថម្ភដែលជាសំណងសម្រាប់ជនបាត់បង់ទីលំនៅដោយសារការលំបាកដែលពាក់ព័ន្ធនឹងការតាំងទីលំនៅឡើងវិញ និងចេញចំណាយលើការផ្លាស់ទៅទីតាំងថ្មី ដូចជា ចំណាយលើការរើផ្ទះ និងចំនួនថ្ងៃធ្វើការដែលខាតបង់។

**តម្លៃជំនួស ៖** មធ្យោបាយវាយតម្លៃសំណងប៉ះប៉ូវគ្រប់គ្រាន់ដើម្បីជំនួសទ្រព្យសម្បត្តិ បូករួមនឹងចំណាយប្រតិបត្តិការចាំបាច់ដែលពាក់ព័ន្ធនឹងការជំនួសទ្រព្យសម្បត្តិ។ ក្នុងករណីដែលមានទីផ្សារសកម្ម តម្លៃជំនួសជាតម្លៃទីផ្សារដែលត្រូវបានកំណត់តាមរយៈការវាយតម្លៃអចលនទ្រព្យដែលមានសមត្ថភាព និងឯករាជ្យ បូករួមនឹងចំណាយប្រតិបត្តិការ។ ក្នុងករណីដែលគ្មានទីផ្សារសកម្ម តម្លៃជំនួសអាចត្រូវបានកំណត់តាមរយៈមធ្យោបាយផ្សេងទៀត ដូចជាការគណនាតម្លៃទិន្នផលសម្រាប់ដីធ្លី ឬទ្រព្យដែលមានផលិតភាព ឬតម្លៃមិនបញ្ចុះថ្លៃនៃសម្ភារជំនួស និងកម្លាំងពលកម្មសម្រាប់ការសាងសង់សំណង់ ឬអចលនទ្រព្យផ្សេងតៀត បូករួមនឹងចំណាយប្រតិបត្តិការ។

**ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ ៖** ត្រូវបានរៀបចំឡើងនៅពេលគេមិនដឹងពីទីតាំង និងផលប៉ះពាល់នៃលទ្ធកម្មដីធ្លីរបស់អនុគម្រោង (ឧ. អនុគម្រោងសម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងទីតាំងជាក់លាក់) ហើយលទ្ធកម្មដីធ្លីមិនអាចកំណត់អត្តសញ្ញាណបាន។ ក្របខណ្ឌនេះនឹងក្លាយជាផែនទីបង្ហាញផ្លូវសម្រាប់ការរៀបចំផែនការដោះស្រាយផលប៉ះពាល់នៅថ្ងៃអនាគត ប្រសិនបើចាំបាច់។

**ផែនការដោះស្រាយផលប៉ះពាល់ ៖** ត្រូវបានរៀបចំឡើងនៅពេលដែលក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់តម្រូវឱ្យមានផែនការនេះដើម្បីគ្រប់គ្រង និងកាត់បន្ថយផលប៉ះពាល់នៃលទ្ធកម្មដីធ្លី ដោយសារប្លង់/ការរចនាសម្រាប់សម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគ

តិចជាក់លាក់។ ផែនការនេះនឹងត្រូវបានដាក់ជូនធនាគារពិភពលោកពិនិត្យឡើងវិញ និងអនុវត្ត មុនពេលបញ្ចប់ការរចនាលម្អិត និង/ឬការគូសផែនទីកំណត់ព្រំប្រទល់ដីធ្លីសម្រាប់សម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចជាក់លាក់។

**ផែនទីព្រាង និងផែនទីបឋមសម្រាប់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ៖** "ផែនទីព្រាង" ជាផែនទីគូសដោយដៃដែលបង្ហាញពីព្រំប្រទល់ភូមិ និងប្រភេទនៃការប្រើប្រាស់ដីធ្លី ដោយមិនបញ្ជាក់ពីទំហំតំបន់ដែលស្ថិតក្រោមការទាមទារ ឬទីតាំងជាក់លាក់របស់តំបន់នោះ។ ក្នុងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ផែនទីនេះត្រូវបានអភិវឌ្ឍទៅជា "ផែនទីបឋម" ឌីជីថល ហើយផែនទីទាំងពីរនេះត្រូវបានបង្កើតឡើងនៅដំណាក់កាល ២.៥ ជំហានទី ២។

**ដីរដ្ឋ ៖** ជាផ្នែកមួយនៃទ្រព្យសម្បត្តិរដ្ឋ និងរួមមានដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ។ ដីសាធារណៈរបស់រដ្ឋរួមមាន ១) ទ្រព្យសម្បត្តិដែលត្រូវបានបង្កើតឡើងជាពិសេសសម្រាប់ការប្រើប្រាស់ទូទៅ និង ២) ទ្រព្យសម្បត្តិដែលផ្តល់ជូន អាចស្ថិតក្នុងស្ថានភាពធម្មជាតិ ឬស្ថានភាពក្រោយការអភិវឌ្ឍសម្រាប់ការប្រើប្រាស់ជាសាធារណៈ។ ដីសាធារណៈរបស់រដ្ឋក្លាយជាដីឯកជនរបស់រដ្ឋនៅពេលដីនោះលែងមានប្រយោជន៍សម្រាប់ការប្រើប្រាស់ជាសាធារណៈ ហើយដីឯកជនរបស់រដ្ឋប្រហែលជាអាចផ្ទេរកម្មសិទ្ធិបាន និងប្រហែលជាត្រូវបានផ្តល់ជូនសម្រាប់គោលបំណងសង្គម (ដូចជា សម្បទានសង្គម ឬផ្នែកនានារបស់តំបន់សម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច)។

**អនុគម្រោង ៖** ជាសកម្មភាពសរុបដែលពាក់ព័ន្ធនឹងនឹងការរៀបចំ និងការអនុវត្តដំណើរកាសម្បទានដីសង្គមកិច្ច ឬប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងទីតាំងជាក់លាក់ បូករួមនឹងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ និងការទ្រទ្រង់កសិកម្ម/របរចិញ្ចឹមជីវិត ព្រមទាំងការរៀបចំ និងការអនុវត្តឧបករណ៍ធានាសុវត្ថិភាពបរិស្ថាន ឬសង្គមចាំបាច់។

**ការផ្តល់អំណោយដោយស្ម័គ្រចិត្ត ៖** សំដៅលើការប្រគល់ទ្រព្យសម្បត្តិដោយម្ចាស់ដែល ក) ទទួលបានព័ត៌មានត្រឹមត្រូវស្តីពីគម្រោង និងសិទ្ធិរបស់ពួកគេក្នុងការស្វែងរកសំណង និង ខ) អាចបដិសេធមិនផ្តល់អំណោយ។

**ក្រុមងាយរងគ្រោះ ៖** ជាក្រុមមនុស្សដែលងាយនឹងរងផលប៉ះពាល់អវិជ្ជមានដោយសារលទ្ធកម្មដីធ្លី ជាងអ្នកផ្សេងទៀត និងច្រើនតែមិនសូវមានសមត្ថភាពក្នុងការបង្កើតរបរចិញ្ចឹមជីវិតរបស់ខ្លួនឡើងវិញ ឬកែលម្អស្ថានភាពរបស់ខ្លួន។ ជនងាយរងគ្រោះត្រូវបានបែងចែកជា ១) គ្រួសារដែលរស់នៅក្រោមអត្រាភាពក្រីក្រ ដែលកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា ២) គ្រួសារដែលមានមនុស្សចាស់ជាមេគ្រួសារ ដែលគ្មានមធ្យោបាយចិញ្ចឹមជីវិត ៣) គ្រួសារដែលមានស្ត្រីជាមេគ្រួសារដែលមានមនុស្សក្នុងបន្ទុក ដែលរស់នៅក្រោមអត្រាភាពក្រីក្រ ៤) គ្រួសារដែលមានជនពិការជាមេគ្រួសារ និង ៥) ជនជាតិដើមភាគតិច (ដែលជាញឹកញាប់មានសិទ្ធិដីធ្លីបែបប្រពៃណី ប៉ុន្តែគ្មានប័ណ្ណកម្មសិទ្ធិផ្លូវការ)។

## មាតិកា

**ពាក្យភាគ់**..........ii
**និយមន័យពាក្យគន្លឹះ**..........iii
**១.សេចក្តីផ្តើម**..........13
១.១ បេនាសម្ព័ន្ធនៃក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់..........13
១.២ សាវតាគម្រោង..........14
១.៣ គោលបំណង និងសមាសភាគគម្រោង..........17
១.៤ សមាសភាគគម្រោង និងការកំណត់គោលដៅ..........17
**២.មេរៀនពីការអនុវត្តគម្រោងដំណាក់កាលដំបូង និងគម្រោងដំណាក់កាលទី ២**..........21
**៣.ក្របខណ្ឌច្បាប់សម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ**..........24
៣.១ បទប្បញ្ញត្តិមូលដ្ឋាននៃច្បាប់កម្ពុជា..........24
៣.២ អនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ..........26
៣.៣ បទប្បញ្ញត្តិក្នុងក្របខណ្ឌគតិយុត្តិស្តីពីសម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច..........29
**៤. ការវិភាគចំណុចខ្វះខាតរវាងបទដ្ឋានបរិស្ថាន និងសង្គមទី ៥ របស់ធនាគារពិភពលោក និងនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញរបស់រាជរដ្ឋាភិបាលកម្ពុជា** 31
**៥. ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ ៖ គោលបំណង គោលការណ៍ និងវិធីសាស្ត្រកាត់បន្ថយលទ្ធកម្មដីធ្លី**..........34
៥.១ គោលបំណង..........34
៥.២ ជន និងគ្រួសារដែលមានសិទ្ធទទួលបានអត្ថប្រយោជន៍..........36
៥.៣ វិធានការកាត់បន្ថយលទ្ធកម្មដីធ្លី និងស្ថានភាពដែលមិនអាចបញ្ចៀសលទ្ធកម្មដីធ្លីបាន..........37
**៦.កាលបរិច្ឆេទឱសានវាទសម្រាប់លក្ខណៈសម្បត្តិទទួលបានសំណង និងជំនួយ**..........41
៦.១ គោលការណ៍នៃកាលបរិច្ឆេទឱសានវាទ..........41
៦.២ កាលបរិច្ឆេទឱសានវាទសម្រាប់សម្បទានដីសង្គមកិច្ច..........42
៦.៣ កាលបរិច្ឆេទឱសានវាទសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច..........43
៦.៤ ដីធ្លីបន្ថែមដែលស្ថិតនៅក្រៅសម្បទានដីសង្គមកិច្ច ឬទីតាំងផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងចាំបាច់សម្រាប់ហេដ្ឋារចនាសម្ព័ន្ធ..........45
**៧.ដំណើរការរៀបចំផែនការសម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច**..........46

៧.១ ការធ្វើអត្តសញ្ញាណកម្មដីធ្លី ការផាត់ចេញដីឯកជន ការផ្តល់ដីសម្បទានដីសង្គមកិច្ចជាសំណង និងការវាយតម្លៃភាពចាំបាច់នៃលទ្ធកម្មដីធ្លីក្នុងក្របខណ្ឌរៀបចំផែនការសម្បទានដីសង្គមកិច្ច.....46
៧.២ ការធ្វើអត្តសញ្ញាណកម្មដីធ្លី ការផាត់ចេញដីឯកជន និងការវាយតម្លៃភាពចាំបាច់នៃលទ្ធកម្មដីធ្លីក្នុងក្របខណ្ឌរៀបចំផែនការប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច.....50
៧.៣ ជនរងផលប៉ះពាល់ដែលត្រូវបានកំណត់អត្តសញ្ញាណក្រោយការបញ្ចប់ផែនការសម្បទានដីសង្គមកិច្ច ឬផែនការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច.....54
៧.៤ ក្របខណ្ឌសម្រាប់ការផ្តល់អំណោយដីដោយស្ម័គ្រចិត្ត.....55
**៨.ការរៀបចំផែនការដោះស្រាយផលប៉ះពាល់**.....57
៨.១ ក្របខណ្ឌសម្រាប់ផែនការដោះស្រាយផលប៉ះពាល់.....57
៨.២ ប្រភេទជនដែលរងផលប៉ះពាល់ និងលក្ខណៈសម្បត្តិទទួលបានសំណង.....58
៨.៣ មូលដ្ឋានសម្រាប់ការផ្តល់សំណង.....60
៨.៤ ការរៀបចំផ្នែកស្ថាប័ន.....62
៨.៥ ការរៀបចំផែនការដោះស្រាយផលប៉ះពាល់.....66
៨.៦ ការពិគ្រោះយោបល់ជាសាធារណៈ ការចូលរួម និងការផ្សព្វផ្សាយព័ត៌មាន.....71
៨.៦.១ ការផ្សព្វផ្សាយព័ត៌មាន.....71
៨.៦.២ កិច្ចប្រជុំពិគ្រោះយោបល់.....71
**៩.ការអនុវត្តផែនការដោះស្រាយផលប៉ះពាល់**.....73
៩.១ ទម្រង់កិច្ចសន្យាការអង្កេតវាស់វែងលម្អិតសម្រាប់សំណង.....73
៩.២ សកម្មភាពកម្មវិធីស្តារប្រាក់ចំណូលឡើងវិញ.....75
៩.៣ កាលបរិច្ឆេទផ្លាស់ទីលំនៅចេញពីដី.....76
៩.៤ ការពិនិត្យតាមដានផែនការដោះស្រាយផលប៉ះពាល់.....76
**១០.យន្តការដោះស្រាយបណ្តឹងតវ៉ា**.....78
១០.១ គម្រោងដំណាក់កាលទី ៣ និងយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ.....78
១០.២ ការពិពណ៌នាពីយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងគម្រោងដំណាក់កាលទី ៣.....79
១០.៣ ការពិពណ៌នាពីយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ.....82
១០.៤ សេវាដោះស្រាយបណ្តឹងរបស់ធនាគារពិភពលោក.....84
**១១.ការរៀបចំផ្តល់មូលនិធិ**.....84

**១២.ការពិគ្រោះយោបល់អ្នកពាក់ព័ន្ធ និងការផ្សព្វផ្សាយពីក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់** ........ 85

**ឧបសម្ព័ន្ធ ១ ៖ បទប្បញ្ញត្តិបន្ថែមលើអនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ** ........ 88

**ឧបសម្ព័ន្ធ ២ ៖ ដំណើការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច**92

**ឧបសម្ព័ន្ធ ៣ ៖ ទម្រង់ការផ្តល់អំណោយទ្រព្យសម្បត្តិដោយស្ម័គ្រចិត្ត** ........ 94

**ឧបសម្ព័ន្ធ ៤ ៖ ទម្រង់របាយការណ៍សម្រាប់ផែនការដោះស្រាយផលប៉ះពាល់ក្នុងអនុគម្រោង** ........ 96

**ឧបសម្ព័ន្ធ ៥ ៖ របាយការណ៍រួមស្តីពីការអនុវត្តផែនការដោះស្រាយផលប៉ះពាល់** ........ 99

## ១.សេចក្តីផ្តើម

### ១.១ របនាសម្ព័ន្ធនៃក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់

1. ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ រៀបរាប់ពីរបៀបដែលហានិភ័យដែលបណ្តាលមកពីលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ និងផលប៉ះពាល់អវិជ្ជមានពាក់ព័ន្ធលើជនដែលរងផលប៉ះពាល់ដោយសារគម្រោង នឹងត្រូវបានគ្រប់គ្រងក្នុងគម្រោងដំណាក់កាលទី ៣។ ហានិភ័យ និងផលប៉ះពាល់អវិជ្ជមាននឹងត្រូវបានគ្រប់គ្រងដោយអនុលោមតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា និងលក្ខខណ្ឌតម្រូវនៃក្របខណ្ឌបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក និងជាពិសេសបទដ្ឋានបរិស្ថាន និងសង្គមទី ១ ទី ៥ និងទី ៧។

2. គម្រោងដំណាក់កាលដំបូង និងគម្រោងដំណាក់កាលទី ២ បានគ្រប់គ្រងហានិភ័យលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញតាមរយៈការបញ្ចៀសតម្រូវការលទ្ធកម្មដីធ្លី និងការចុះកិច្ចសន្យាដោយស្ម័គ្រចិត្តជាមួយអ្នកប្រើប្រាស់ដីដែលជាអ្នកទទួលផលពីគម្រោងនេះ ក្នុងករណីចាំបាច់។ គម្រោងដំណាក់កាលទី ៣ ត្រូវបានរំពឹងថានឹងបញ្ចៀសតម្រូវការលទ្ធកម្មដីធ្លីក្នុងករណីភាគច្រើន។

3. រាជរដ្ឋាភិបាលកម្ពុជាទើបតែបានចេញអនុក្រឹត្យលេខ ២២ ដែលកំណត់ពីនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ (នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ) ក្នុងគម្រោងដែលទទួលបានហិរញ្ញប្បទានទីខាងក្រៅម និងបានគូសបញ្ជាក់ថា នីតិវិធីប្រតិបត្តិស្តង់ដារគួរអនុវត្តចំពោះលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញក្នុងគម្រោងដំណាក់កាលទី ៣។ ក្នុងក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ គម្រោងនេះនឹងអនុម័តបទប្បញ្ញត្តិបន្ថែមមួយចំនួនដើម្បីជានាការអនុលោមពេញលេញតាមបទដ្ឋានបរិស្ថាន និងសង្គមទី ១ និងទី ៥។

4. ឯកសារនេះរៀបរាប់ពីគម្រោងដំណាក់កាលទី ៣ មេរៀនពីគម្រោងដំណាក់កាលដំបូង និងគម្រោងដំណាក់កាលទី២ ក្របខណ្ឌច្បាប់សម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ និងការវិភាគចំណុចខ្វះខាតលើផ្នែកដែលនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ មិនជានាការអនុលោមពេញលេញតាមបទដ្ឋានបរិស្ថាន និងសង្គមទី ១, ទី ៥ និង ទី ៧។ ផ្នែកផ្សេងទៀតនៃឯកសារនេះរៀបរាប់ពីវិធានការបញ្ចៀស ឬកាត់បន្ថយលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ ហើយក្នុងករណីមិនអាចអនុវត្តដូច្នេះបាន នឹងមានការរៀបចំ និងអនុវត្តផែនការដោះស្រាយផលប៉ះពាល់ រួមបញ្ចូលការវិភាគចំណុចខ្វះខាតរវាងនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ និងលក្ខខណ្ឌតម្រូវក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ១, ទី ៥ និង ទី ៧។ កិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទានដល់គម្រោងដំណាក់កាលទី ៣ នឹងក្របខណ្ឌគោលនយោបាយនេះដែលត្រូវបានអនុម័តដោយធនាគារពិភពលោក និងឯកភាពដោយរាជរដ្ឋាភិបាលកម្ពុជាសម្រាប់ប្រើប្រាស់ជាឧបករណ៍ដែលអាចអនុវត្តបានសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញក្នុងគម្រោងនេះ។ ប្រសិនបើរកឃើញថា អនុគម្រោងក្នុងសម្បទានដីសង្គមកិច្ចឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច តម្រូវឱ្យមានផែនការដោះស្រាយផលប៉ះពាល់ដើម្បីដោះ

ស្រាយផលប៉ះពាល់នៃលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ ផែនការទាំងនេះនឹងត្រូវបានរៀបចំឡើងក្រោមកិច្ចពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងធនាគារពិភពលោក។ សកម្មភាពគម្រោងដែលនឹងធ្វើឱ្យមានការខាតបង់ជារូបវន្ត និង/ឬការខាតបង់ផ្នែកសេដ្ឋកិច្ច នឹងអាចចាប់ផ្តើមទៅបានលុះត្រាតែផែនការដាក់លាក់ខាងលើត្រូវបានបញ្ចប់ និងអនុម័តដោយធនាគារពិភពលោក។

## ១.២ សាវតាគម្រោង

5. លទ្ធភាពប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព និងសន្តិសុខ ដោយសហគមន៍ជនបទ និងលទ្ធភាពប្រើប្រាស់ដីធ្លីដោយកសិករដែលមានដីធ្លីតិចតួចគឺជាចំណុចស្នូលនៃយុទ្ធសាស្ត្រសម្រាប់វិស័យជនបទរបស់រាជរដ្ឋាភិបាលកម្ពុជា។ នៅឆ្នាំ ២០០១ កម្ពុជាបានអនុម័តច្បាប់ភូមិបាលដែលរួមបញ្ចូលក្របខណ្ឌច្បាប់សម្រាប់សម្បទានដីសង្គមកិច្ចសម្រាប់ការផ្ទេរកម្មសិទ្ធិដីរដ្ឋដែលគ្មានការប្រើប្រាស់ដល់គ្រួសារក្រីក្រប្រកបដោយសមធម៌សណ្តាប់ធ្នាប់ និងផ្អែកតាមគោលការណ៍ច្បាប់ច្បាស់លាស់។

6. ក្របខណ្ឌសម្រាប់ការដាក់ឱ្យដំណើរការសម្បទានដីសង្គមកិច្ចត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៣ តាមរយៈការចេញអនុក្រឹត្យលេខ ១៩ ដែលកំណត់លក្ខណៈវិនិច្ឆ័យ និងនីតិវិធីសម្រាប់ការផ្តល់សម្បទានដីសង្គមកិច្ច។ មាត្រា ២ (ក) កំណត់សម្បទានដីសង្គមកិច្ចជា "យន្តការផ្ទេរដីឯកជនរបស់រដ្ឋ[1]តាមផ្លូវច្បាប់សម្រាប់គោលបំណងសង្គមកិច្ចដល់ជនក្រីក្រដែលខ្វះខាតដីសម្រាប់សង់លំនៅដ្ឋាន និង/ឬធ្វើកសិកម្មជាលក្ខណៈគ្រួសារ"។ សម្បទានដីសង្គមកិច្ច ២ ប្រភេទត្រូវបានបង្កើតឡើងដោយអនុក្រឹត្យនេះ ៖ មាត្រា ៥ និង ៦ បានបង្កើតសម្បទានដីសង្គមកិច្ច "ថ្នាក់មូលដ្ឋាន" ដែលត្រូវបានផ្តួចផ្តើមឡើង និងធ្វើតាមរយៈក្រុមប្រឹក្សាឃុំ និងសម្រាប់តែពលរដ្ឋក្នុងឃុំនោះតែប៉ុណ្ណោះ ចំណែកមាត្រា ៧ បានបង្កើតកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិដែលសម្បទានដីសង្គមកិច្ចអាចត្រូវបានបង្កើតឡើងដោយស្ថាប័នជាតិសម្រាប់គោលបំណងនានា។ ក្នុងការអនុវត្តជាក់ស្តែង សម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ហាក់ត្រូវបានប្រើប្រាស់សម្រាប់ការតាំងទីលំនៅឡើងវិញរបស់អតីតយុទ្ធជន។

7. ក្រោយការចាប់ផ្តើមនៅឆ្នាំ ២០០៨ ធនាគារពិភពលោកបានផ្តល់ហិរញ្ញប្បទានដល់កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ឃុំរបស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈគម្រោងពីរ (គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច)។ គម្រោងដំណាក់កាលដំបូង (២០០៨-២០១៣) ទទួលបានហិរញ្ញប្បទានពី ធនាគារពិភព

---

[1] ដីរដ្ឋទាំងអស់ក្នុងប្រទេសកម្ពុជាត្រូវបានបែងចែកជា "ដីសាធារណៈរបស់រដ្ឋ" និង "ដីឯកជនរបស់រដ្ឋ"។ មាត្រា ៤ នៃអនុក្រឹត្យលេខ ១១៨ ស្តីពីការគ្រប់គ្រងដីរដ្ឋ (២០០៥) ចែងថា "ដីសាធារណៈរបស់រដ្ឋជាដីដែលមានជាប់ផលប្រយោជន៍សាធារណៈ និងរួមបញ្ចូលព្រៃឈើ បឹងធម្មជាតិ ព្រលានយន្តហោះ។ល។"។ មាត្រា ៥ ចែងថា "ដីឯកជនរបស់រដ្ឋរួមមានដីទាំងអស់ដែលមិនមែនជាដីសាធារណៈរបស់រដ្ឋ និងមិនមែនជាដីដែលកាន់កាប់ជាភោគៈស្របច្បាប់ ឬជាកម្មសិទ្ធិដោយបុគ្គលឯកជន ឬដោយសមូហភាពស្របច្បាប់ច្បាប់ភូមិបាលឆ្នាំ ២០០១"។ មាត្រា ៥៨ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១ ចែងថា "សម្បទានដីអាចធ្វើឡើងបានតែនៅលើដីដែលជាចំណែកនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ ដីសាធារណៈរបស់រដ្ឋមួយចំនួន ដូចជា ព្រៃរេចរឹលដែលមិនអាចបង្វែរមកវិញបាន ក៏អាចត្រូវបានប្រែក្លាយទៅជាដីឯកជនរបស់រដ្ឋ និងបែងចែកជាសម្បទានដីសង្គមកិច្ចបានផងដែរ។

លោក និង JSDF និងត្រូវបានចូលរួមផ្តល់ហិរញ្ញប្បទានដោយ GIZ។ គម្រោងនេះបានសាកល្បងការអនុវត្តអនុក្រឹត្យលេខ ១៩ ស្តីពីទីតាំងសម្បទានដីសង្គមកិច្ច ដែលគ្របដណ្តប់លើផ្ទៃដី ១៤.១១០ ហិចតា និងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជន ៤.៤៤១ គ្រួសារ។ គម្រោងដំណាក់កាលទី ២ បានចាប់ផ្តើមការអនុវត្តនៅឆ្នាំ ២០១៦ និងរំពឹងថានឹងបិទបញ្ចប់នៅឆ្នាំ ២០២១។ គម្រោងដំណាក់កាលទី ២ ផ្តល់ការទ្រទ្រង់ជាបន្តបន្ទាប់ដល់ទីតាំងសម្បទានដីសង្គមកិច្ចចំនួន ១៣ ដែលបង្កើតឡើងដោយគម្រោងដំណាក់កាលដំបូង និងទីតាំងសម្បទានដីសង្គមកិច្ចថ្មី ១ កន្លែងនៅខេត្តកំពង់ធំ។ គម្រោងនេះគ្របដណ្តប់លើផ្ទៃដី ១៧.០០០ ហិចតា និងផ្តល់ប្រយោជន៍ដល់ប្រជាជន ៥.០១០ គ្រួសារក្រៅពីអ្វីដែលបានសម្រេចកន្លងមក។

8. ច្បាប់ភូមិបាលឆ្នាំ ២០០១ បានកំណត់ឱ្យសហគមន៍ជនជាតិដើមភាគតិចបង្កើតកម្មសិទ្ធិសមូហភាពលើដីសហគមន៍ប្រពៃណីតាមរយៈប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ក្របខណ្ឌរបស់រដ្ឋាភិបាលសម្រាប់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច[2] ត្រូវបានផ្តល់សច្ចាប័ននៅឆ្នាំ ២០០៩ តាមរយៈអនុក្រឹត្យលេខ ៨៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។

9. កម្ពុជាមានជនជាតិភាគតិចប្រហែល ២៤ ប្រភេទផ្សេងៗគ្នា និងសរុបមានចំនួន ២០០.២១៦ នាក់[3] ឬប្រហែល ១.២% នៃប្រជាជនកម្ពុជាសរុប (១៦,៥ លាននាក់)។ ជនជាតិដើមភាគតិចប្រមូលផ្តុំក្នុងខេត្តរតនគិរី (ប្រហែល ៤៥% នៃចំនួនប្រជាជនសរុបប្រមាណ ២០០.០០០ នាក់) និងមណ្ឌលគិរី (ប្រហែល ៧៥% នៃប្រជាជនសរុបប្រមាណ ៨៩.០០០ នាក់)។ ក្រៅពីនេះ ក៏មានជនជាតិដើមមួយចំនួនរស់នៅរប៉ាត់រប៉ាយក្នុងខេត្ត ១៣ ទៀត។ នៅឆ្នាំ ២០០៩ ក្រសួងមហាផ្ទៃបានចងក្រងបញ្ជីភូមិ ១១៥ នៅកម្ពុជាដែលចំនួនជនជាតិដើមភាគតិចប្រមាណ ៦%-១០០%។ ការស្រាវជ្រាវថ្មីមួយដោយអង្គការជនជាតិដើមភាគតិចកម្ពុជា បង្ហាញថាមានភូមិជនជាតិដើមភាគតិចយ៉ាងតិច ៥៧៣ ភូមិនៅកម្ពុជា[4]។ សន្តិសុខសិទ្ធិកាន់កាប់ដីធ្លី មានសារៈសំខាន់ណាស់ដែលអាចឱ្យពួកគេរក្សាវប្បធម៌ និងអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួន។ ការព្រួយបារម្ភដ៏ធំគឺជនជាតិដើមភាគតិចកំពុងបាត់បង់ការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិរបស់ខ្លួនយ៉ាងលឿន។ ចំណុចនេះត្រូវបានសបញ្ជាក់ក្នុងបរិបទនៃការកើនឡើងការធ្វើចំណាកស្រុករបស់អ្នកមិនមែនជាជនជាតិដើមភាគតិចទៅក្នុងតំបន់របស់ជនជាតិដើមភាគតិច។ ឱកាសតិចតួចរបស់ជនជាតិដើមភាគតិចក្នុងការជះឥទ្ធិពលលើកាលៈទេសៈដែលមានសារៈសំខាន់ចំពោះពួកគេ និងចំពោះការបាត់បង់ដីធ្លី និងបរចិញ្ចឹមជីវិត បានធ្វើឱ្យពួកគេក្លាយជាក្រុមដែលជាប់ការលំបាក និងងាយរងគ្រោះបំផុតនៅកម្ពុជា ដែលមានស្តង់ដាររស់នៅទាប។

[2] សៀវភៅណែនាំស្តីពីការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ការចុះបញ្ជីជានីតិបុគ្គល និងដំណើរការចុះបញ្ជីដីសមូហភាពនៅកម្ពុជា ត្រូវបានទ្រទ្រង់ដោយ UNHOCHR ដោយសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងមហាផ្ទៃ និងក្រសួងអភិវឌ្ឍន៍ជនបទ។

[3] មើលឯកសារដែលមានចំណងជើងថា "ស្ថិតិនៃប្រភេទជនជាតិដើមភាគតិចនៅកម្ពុជា"។

[4] Phnom Penh Post - 27 Oct 2016

10. ច្បាប់ភូមិបាលឆ្នាំ ២០០១ បានកំណត់និយមន័យសហគមន៍ជនជាតិដើមភាគតិចសម្រាប់គោលបំណងនៃលក្ខណៈសម្បត្តិក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព ជា "ក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទំលាប់នៃការប្រើប្រាស់ជាសមូហភាព"។ ក្របខណ្ឌរៀបចំផែនការជនជាតិដើមភាគតិច ដែលត្រូវបានរៀបចំឡើងសម្រាប់គម្រោងដំណាក់កាលទី ៣ កត់សម្គាល់ថា និយមន័យរបស់ជនជាតិដើមភាគតិចក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៧ អាចរួមបញ្ចូលក្រុមជាតិពន្ធុមួយចំនួនដែលស្ថិតនៅក្រៅនិយមន័យនេះ និង/ឬ មិនត្រូវបានចាត់ទុកថាមានលក្ខណៈសម្បត្តិទទួលបានប័ណ្ណកម្មសិទ្ធដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចដោយរាជរដ្ឋាភិបាលកម្ពុជា។ ក្រុមជាតិពន្ធុទាំងនោះអាចរួមមាន ជនជាតិឡាវ និងចាម ដែលអាចមានវត្តមានក្នុងតំបន់គោលដៅរបស់គម្រោង។ ក្របខណ្ឌរៀបចំផែនការជនជាតិដើមភាគតិចកត់សម្គាល់បន្ថែមទៀតថា ជនជាតិដើមភាគតិចអាចរស់នៅលាយឡំជាមួយសហគមន៍ជនជាតិខ្មែរ និងក្នុងសហគមន៍ប្រពៃណីរបស់ជនជាតិដើមភាគតិច។

11. គម្រោងដំណាក់កាលទី ៣ នឹងទ្រទ្រង់ដល់ជនជាតិដើមភាគតិចដែលត្រូវបានទទួលស្គាល់ជា "នីតិបុគ្គល" ពីក្រសួងមហាផ្ទៃក្នុងដំណាក់កាលទី ២ នៃដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច ឬដែលប្រហែលជាបានឈានដល់ដំណាក់កាលបន្ទាប់ណាមួយក្នុងដំណើរការនេះ រួមទាំងសហគមន៍ជនជាតិដើមភាគតិចដែលបានបញ្ចប់ការផ្តល់ប័ណ្ណកម្មសិទ្ធដីធ្លី ប៉ុន្តែត្រូវការជំនួយអភិវឌ្ឍន៍ជនបទ (ជំហាន ២.៥ និងជំហានទី ៣ ក្នុងតារាង ២ ខាងក្រោម)។ ដូច្នេះ លក្ខណៈសម្បត្តិរបស់សហគមន៍ជនជាតិដើមភាគតិចសម្រាប់ការដាក់បញ្ចូលក្នុងកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច នឹងត្រូវបានកំណត់ជាក់ស្តែងដោយលក្ខណៈវិនិច្ឆ័យដែលអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា (ពុំនោះទេនឹងមិនមានការទទួលស្គាល់ពីក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងមហាផ្ទៃឡើយ)។ សម្រាប់គោលបំណងផ្សេងទៀតក្នុងគម្រោងដំណាក់កាលទី ៣ ពាក្យ "ជនជាតិដើមភាគតិច" គួរត្រូវបានស្វែងយល់ដោយបុគ្គល ឬក្រុមឋិតក្រៅនិយមន័យក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៧។

12. ជនដែលរងផលប៉ះពាល់ដោយសារគម្រោងនៅទីតាំងសម្រាប់សម្បទានដីសង្គមកិច្ច និងសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច អាចរួមមានសហគមន៍ដែលលាយឡំដោយជនជាតិដើមភាគតិច និងអ្នកដែលមិនមែនជាជនជាតិដើមភាគតិច។ ក្រៅពីនេះ ជនដែលរងផលប៉ះពាល់ដោយសារគម្រោង នៅទីតាំងសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចអាចរួមបញ្ចូលជនជាតិដើមភាគតិចដែលមិនមែនជាសមាជិករបស់សហគមន៍ដែលទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីដោយសារតែពួកគេជាសមាជិករបស់ក្រុមដាច់ដោយឡែកមួយ ឬដោយសារតែមូលហេតុផ្ទាល់ខ្លួន (មិនចង់ចូលរួម)។ ក្របខណ្ឌរៀបចំផែនការជនជាតិដើមភាគតិច ពិភាក្សាពីស្ថានភាពខុសៗគ្នាទាំងនេះ និងកាលៈទេសៈដែលនឹងមានការអនុវត្តបទដ្ឋានបរិស្ថាន និងសង្គមទី ៧។ ក្រៅពីនេះ ប្រសិនបើដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចធ្វើឱ្យមានការខាតបង់ផ្នែករូបវន្ត ឬសេដ្ឋកិច្ចរបស់ PAP អ្នក

ដែលមិនមែនជាជនជាតិដើមភាគតិច ពួកគេប្រហែលជាមានសិទ្ធិទទួលបានសំណងក្រោមបទដ្ឋានបរិស្ថាន និង សង្គមទី ៥។

13. កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច ត្រូវបានរៀបចំឡើងដើម្បីជួយដល់ជនជាតិដើមភាគតិចក្នុងការគ្រប់គ្រងដីប្រពៃណីរបស់ខ្លួន ក្នុងកាលៈទេសៈនៃការប្រែប្រួលសេដ្ឋកិច្ច និងសង្គម សកម្មភាពចំណូលស្រុករបស់ជនជាតិខ្មែរមកកាន់តំបន់របស់ជនជាតិដើមភាគតិច និងការបំពេញតម្រូវការដីធ្លី។ ការបង្កើតប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចជាដំណើរការមាន ៣ ដំណាក់កាលដូចតទៅ។ ដំណាក់កាលទី ១ ការទទួលស្គាល់ជាសហគមន៍ជនជាតិដើមភាគតិចដោយក្រសួងអភិវឌ្ឍន៍ជនបទ។ ដំណាក់កាលទី ២ ការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជានីតិបុគ្គល ដោយក្រសួងមហាផ្ទៃ។ ដំណាក់កាលទី ៣ ការចុះបញ្ជីដីធ្លីជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (មើលឧបសម្ព័ន្ធ ២)។ ដំណើរការនេះចំណាយពេលច្រើន និងបន្តរហូតដល់ឆ្នាំ ២០០៦ ហើយមានសហគមន៍ជនជាតិដើមភាគតិចតែង ១១ ប៉ុណ្ណោះដែលទទួលបានប័ណ្ណកម្មសិទ្ធ[5]។ ដំណើរការនេះត្រូវបានពន្លឿនភាគច្រើនតាមរយៈការប្តេជ្ញាចិត្តជាថ្មីរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ នៅខែ ធ្នូ ឆ្នាំ ២០១៩ មានសហគមន៍ជនជាតិដើមភាគតិចចំនួន ១៥០ ដែលត្រូវបានទទួលស្គាល់ដោយក្រសួងអភិវឌ្ឍន៍ជនបទ (ដំណាក់កាលទី ១) ហើយសហគមន៍ជនជាតិដើមភាគតិចចំនួន ១៤១ សម្រេចបានស្ថានភាពផ្លូវច្បាប់ (ដំណាក់កាលទី ២) ហើយសហគមន៍ជនជាតិដើមភាគតិចចំនួន ៣០ ទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។

14. គម្រោងដំណាក់កាលទី ៣ នឹងអនុវត្តវិធីសាស្ត្រមុខពីរ ៖ ១) ការបូកសរុបតាមរយៈសកម្មភាពបំពេញបន្ថែមលើកម្មវិធីសម្បទានដីសង្គមកិច្ចបច្ចុប្បន្នក្រោមគម្រោងដំណាក់កាលទី ២ និងពង្រីកសកម្មភាពឱ្យគ្របដណ្តប់លើទីតាំងសម្បទានដីសង្គមកិច្ចថ្មីៗ និង ២) ការអនុវត្តវិធីសាស្ត្រដែលត្រូវបានកែសម្រួលក្នុងសហគមន៍ជនជាតិដើមភាគតិចនៅតាមខេត្តគម្រោងថ្មីៗ។

## ១.៣ គោលបំណង និងសមាសភាគគម្រោង

15. **គោលបំណងនៃការអភិវឌ្ឍ**គម្រោងដំណាក់កាលទី ៣ គឺដើម្បីផ្តល់លទ្ធភាពទទួលបានសន្តិសុខកម្មសិទ្ធិដីធ្លី សេវាកសិកម្ម និងសង្គម និងហេដ្ឋារចនាសម្ព័ន្ធមួយចំនួនដល់កសិករខ្នាតតូច និងសហគមន៍ក្នុងតំបន់គម្រោង។

## ១.៤ សមាសភាគគម្រោង និងការកំណត់គោលដៅ

[5] CCHR (2016): Access to Collective Land Titles for Indigenous People Communities in Cambodia

16. **សមាសភាគទី ១ ៖ ការជ្រើសរើស និងរៀបចំផែនការអភិវឌ្ឍន៍សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។** គម្រោងដំណាក់កាលទី ៣ នឹងទ្រទ្រង់ដល់ការដាក់ពាក្យសុំសម្បទានដីសង្គមកិច្ច ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងជំនួយអភិវឌ្ឍន៍ដល់សហគមន៍ជនជាតិដើមភាគតិច ក្រោមគោលការណ៍ "អ្នកមកមុន បានមុន"។ សម្រាប់សម្បទានដីសង្គមកិច្ចថ្មី ឃុំត្រូវដាក់សំណើ ហើយបន្ទាប់ពីគម្រោងបានកំណត់ពីទីតាំងដីទំនេរធៀបនឹងតម្រូវការរបស់សហគមន៍ នឹងមានការរៀបចំផែនការស្តីពីការប្រើប្រាស់ដីធ្លី និងការវាយតម្លៃបរិស្ថាន និងសង្គមគ្រប់ជ្រុងជ្រោយ មុននឹងអនុម័តទីតាំងនោះសម្រាប់ការអនុវត្តគម្រោង។ សម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងជំនួយអភិវឌ្ឍន៍ដល់សហគមន៍ជនជាតិដើមភាគតិច ពួកគេត្រូវមកសុំជំនួយដោយខ្លួនឯង។ សម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច គម្រោងនឹងផ្តល់ជំនួយដល់ជំហានចាំបាច់ផ្សេងៗដើម្បីបញ្ចប់ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ។ ចំណុចនេះរួមមានសហគមន៍ជនជាតិដើមភាគតិចដែលបានដាក់ពាក្យសុំចុះបញ្ជីដីធ្លី ហើយពាក្យសុំទាំងនោះត្រូវបានទទួលយកដោយមន្ទីរភូមិបាលខេត្តប៉ុន្តែការចុះបញ្ជីដីធ្លីមិនទាន់បានចាប់ផ្តើម (ចាប់ផ្តើមដំណាក់កាលទី ៣) និងសហគមន៍ជនជាតិដើមភាគតិចដែលមានការទទួលស្គាល់ផ្លូវច្បាប់ពីក្រសួងមហាផ្ទៃ (លទ្ធផលនៃដំណាក់កាលទី ២) ប៉ុន្តែមិនទាន់បានបង្កើត និងប្រមែប្រមូលឯកសារចាំបាច់ទាំងអស់សម្រាប់ដាក់ពាក្យសុំចុះបញ្ជីដីធ្លី (សកម្មភាព និងលទ្ធផលនៃដំណាក់កាល ២.៥)។ សម្រាប់សហគមន៍ជនជាតិដើមភាគតិចដែលបានបញ្ចប់ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅពេលគម្រោងចាប់ផ្តើមដំបូង គម្រោងនឹងផ្តល់ជំនួយអភិវឌ្ឍន៍ក្នុងទម្រង់ជាជំនួយហេដ្ឋារចនាសម្ព័ន្ធ និងសេវាដែលនឹងត្រូវបានផ្តល់តាមរយៈសមាសភាគទី ២ និងទី ៣។ គម្រោងនឹងជួលជំនួយការបច្ចេកទេសអន្តរជាតិ និងជំនួយការបច្ចេកទេសក្នុងស្រុកដែលមានបទពិសោធន៍ ដើម្បីរៀបចំផែនការក្នុងសហគមន៍ជនជាតិដើមភាគតិច។

17. **សមាសភាគទី ២ ៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសហគមន៍។** សមាសភាគនេះនឹងទ្រទ្រង់ដល់ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធជាអាទិភាព និងអាចអនុវត្តទៅបាននៅទីតាំងគម្រោងថ្មីៗ ដូចជា ការផ្តល់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសហគមន៍ដែលផ្តល់ផលិតភាព/ពាក់ព័ន្ធនឹងសេដ្ឋកិច្ច និងសង្គមកិច្ច (ឧ. ផ្លូវជនបទ ប្រព័ន្ធបង្ហូរទឹកពីចំហៀង កងលូ ការផ្គត់ផ្គង់ទឹក និងមូលដ្ឋានអនាម័យ ប្រព័ន្ធធារាសាស្ត្រខ្នាតតូច អគារសិក្សា ផ្ទះគ្រូ ប៉ុស្តិ៍សុខភាព និងមជ្ឈមណ្ឌលសហគមន៍។ល។)។

18. **សមាសភាគទី ៣ ៖ ការអភិវឌ្ឍកសិកម្ម និងរបរចិញ្ចឹមជីវិត។** សមាសភាគនេះនឹងជួយដល់ដំណើរការតាំងទីលំនៅរបស់គ្រួសារអ្នកទទួលផល ការកសាងធនធានសង្គម-សេដ្ឋកិច្ច (ក្រុមអ្នកផលិត/សហករណ៍) និងការអភិវឌ្ឍប្រព័ន្ធផលិតកម្មកសិកម្មដោយផ្អែកតាមតម្រូវការទីផ្សារ និងធន់នឹងការប្រែប្រួលអាកាសធាតុ។ សកម្មភាពទាំងនេះរួមមានការផ្តល់ជំនួយដល់ ១) ការតាំងទីលំនៅថ្មីដល់អ្នកដែលទើបទទួលបានដីធ្លី និងជំនួយលើការរៀបចំដីធ្លីសម្រាប់ការដាំដំណាំគម្របជាលើកដំបូង និង/ឬការដាំកូនឈើហូបផ្លែ ដូចជា ស្វាយចន្ទី ដើម្បីអាចឱ្យអ្នកទទួលបានដីធ្លីអាចចាប់ផ្តើមការរស់នៅ និងប្រើប្រាស់ដីកសិកម្មថ្មីរបស់ខ្លួន ២) ការអនុវត្តយុទ្ធសាស្ត្រសេវាកសិកម្មគ្រប់ជ្រុងជ្រោយ ដោយផ្តោតសំខាន់លើបច្ចេកទេសធ្វើកសិកម្មដែលធន់នឹងអាកាសធាតុ

និងប្រើប្រាស់វិធីសាស្ត្រអ្នកផ្ដល់សេវាចម្រុះ ដោយទាញប្រយោជន៍ពីបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ទំនើប និងការផ្សព្វផ្សាយពីការអនុវត្តការបង្ហាញលើក្បាលដីក្រោមការគ្រប់គ្រងរបស់កសិករស្តីពីបច្ចេកវិទ្យា និងការអនុវត្តល្អប្រសើរ ៣) ការបង្កើត និង/ឬពង្រឹងអង្គការកសិករលើសកម្មភាពផលិតកម្ម និងការធ្វើទីផ្សារ និងក្រុមចំណាប់អារម្មណ៍ផ្សេងទៀតក្នុងសហគមន៍ និង ៤) ការផ្តល់មូលនិធិសម្រាប់ការអភិវឌ្ឍសហគមន៍ ដើម្បីពង្រីកគំនិតផ្តួចផ្តើមជោគជ័យក្នុងមូលដ្ឋាន។

19. **សមាសភាគទី ៤ ៖ ការគ្រប់គ្រង ការសម្របសម្រួល និងការពិនិត្យតាមដាន និងវាយតម្លៃគម្រោង** នឹងជានាទូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាព និងទាន់ពេលវេលា លំហូរមូលនិធិ លទ្ធកម្ម ការធ្វើសវនកម្ម និងរាយការណ៍។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គឺជាស្ថាប័នដឹកនាំការអនុវត្តគម្រោង ដោយមានការចូលរួមពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងនាមជាស្ថាប័នអនុវត្តន៍គម្រោង។

20. **សមាសភាគទី ៥ ៖ ការឆ្លើយតបនឹងគ្រោះអាសន្នឬថាហេតុ។** ក្រោមគោលការណ៍គ្មានការបែងចែកបណ្ដោះអាសន្ន សមាសភាគនេះនឹងអនុញ្ញាតឱ្យមានការបែងចែកមូលនិធិគម្រោងឡើងវិញដើម្បីឆ្លើយតបនឹងគ្រោះអាសន្ន ឬវិបត្តិណាមួយ។

21. **ទីតាំងភូមិសាស្ត្រគោលដៅ ៖** តាមគោលការណ៍ គម្រោងអាចត្រូវបានអនុវត្តនៅទូទាំងប្រទេស លើកឡើងតែទីក្រុងភ្នំពេញ អាស្រ័យលើតម្រូវការ និងឱកាសអភិវឌ្ឍន៍ក្នុងទីតាំងសម្បទានដីសង្គមកិច្ច និងទីតាំងសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ទោះជាយ៉ាងណា កិច្ចព្រមព្រៀងបច្ចុប្បន្ន (និងទំនងជាកិច្ចព្រមព្រៀងចុងក្រោយ) ជាមួយអាជ្ញាធរ បានរឹតត្បិតវិសាលភាពរបស់គម្រោងឱ្យគ្របដណ្តប់លើខេត្តត្រឹមតែ ១៤[6] ដែលមានទីតាំង និងសហគមន៍ជនជាតិដើមភាគតិចប្រហែល ៧១។ នៅដំណាក់កាលដំបូងរបស់គម្រោង យ៉ាងហោចណាស់សកម្មភាពនានានឹងប្រមូលផ្តុំនៅតាមទីតាំងភូមិសាស្ត្រដូចខាងក្រោម ៖

ក. ខេត្តដែលមានទីតាំងសម្បទានដីសង្គមកិច្ចស្រាប ៖ កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ ក្រចេះ និងត្បូងឃ្មុំ។

ខ. ខេត្តដែលសំបូរដោយសហគមន៍ជនជាតិដើមភាគតិច ៖ រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង និងព្រះវិហារ (និងខេត្តក្រចេះ ដែលជាខេត្តអនុវត្តគម្រោងដំណាក់កាលទី ២)។

---

[6] រចនាសម្ព័ន្ធរដ្ឋបាលនៅកម្ពុជាចែកចេញជា រាជធានីភ្នំពេញ និង ២៥ ខេត្ត ហើយខេត្តចែកចេញជាក្រុង និងស្រុក។ ស្រុកចែកចេញជាឃុំដែលគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំដែលត្រូវបានជ្រើសតាំងដោយការបោះឆ្នោត និងជាកម្រិតទាបបំផុតនៃរដ្ឋបាលថ្នាក់ក្រោមជាតិផ្លូវការ។ មេភូមិ និងជំនួយការ រាយការណ៍ទៅក្រុមប្រឹក្សាឃុំ។

គ. ខេត្តដែលមានដីទំនេរសម្រាប់សម្បទានដីសង្គមកិច្ចថ្មី។ អាចជាខេត្តណាមួយក្នុងប្រទេសកម្ពុជា ប៉ុន្តែបណ្តាខេត្តដែលសំបូរធនធានដីធ្លីច្រើនជាងគេជាបណ្តាខេត្ត ដែលស្ថិតនៅតំបន់ភាគឦសាន នៃប្រទេស ជាពិសេសខេត្តកំពង់ធំ ក្រចេះ និងព្រះវិហារ។

22. **អ្នកទទួលផលគោលដៅ ៖** វិធីសាស្ត្រអនុវត្តន៍គម្រោងដំណាក់កាលទី ៣ ដែលពាក់ព័ន្ធនឹងសម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចគឺ "ផ្អែកតាមតម្រូវការ"។ ពោលគឺការបែងចែកទីតាំងសម្រាប់សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច គឺផ្អែកតាមឃុំ ឬសហគមន៍ជនជាតិដើមភាគតិច មិនមែនកំណត់ទុកជាមុនដោយគម្រោងនោះទេ។ ចំណុចនេះធានាបានថា គម្រោងឆ្លើយតបនឹងតម្រូវការរបស់អ្នកទទួលបានដីធ្លី និងសមត្ថភាពរបស់ឃុំ/សហគមន៍ និងសហគមន៍ជនជាតិដើមភាគតិច និងអ្នកទទួលផល ដើម្បីឱ្យពួកគេមានភាពម្ចាស់ការកាន់តែខ្លាំងលើសកម្មភាពក្នុងគម្រោងនេះ។ ដូច្នេះ គម្រោងនឹងទ្រទ្រង់ដល់ ១) សហគមន៍ជនជាតិដើមភាគតិច ១៥ ក្នុងការអនុវត្តដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ២) សហគមន៍ជនជាតិដើមភាគតិចប្រហែល ៣០ ដែលបានបញ្ចប់ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ តាមរយៈសកម្មភាពអភិវឌ្ឍន៍ ៣) ទីតាំងសម្បទានដីសង្គមកិច្ចថ្មី ១២ ទាំងក្នុងខេត្តគោលដៅបច្ចុប្បន្ន និងខេត្តគោលដៅថ្មីសម្រាប់សកម្មភាពបែងចែកដី និងអភិវឌ្ឍន៍ និង ៤) ទីតាំងសម្បទានដីសង្គមកិច្ច ១៤ ក្រោមគម្រោងដំណាក់កាលទី ២ ដែលមានសកម្មភាពតិចតួច ដាច់ដោយឡែក និងបំពេញបន្ថែម ដូចជា ធារាសាស្ត្រខ្នាតតូច និងច្រកចេញចូលទីតាំងកសិកម្មក្នុងតំបន់សម្បទានដីសង្គមកិច្ច។ ប៉ុន្តែគេមិនរំពឹងថាអាចកំណត់អត្តសញ្ញាណ និងពិពណ៌នាលម្អិតពីទីតាំងថ្មី និងសហគមន៍ទាំង ៥៧ បានឡើយ ហើយក៏មិនអាចបញ្ចប់ការបែងចែកប្រភេទឡើងវិញ និង/ឬការបែងចែកឡើងវិញដែលចាំបាច់ទាំងអស់ មុនពេលចាប់ផ្តើមគម្រោងបានដែរ។ ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមនឹងរួមបញ្ចូលការណែនាំចាំបាច់ដើម្បីធានាថា ទីតាំង និងសហគមន៍ទាំងអស់ដែលមានការជ្រើសរើសអ្នកទទួលផលពីគម្រោង នឹងអនុលោមតាមច្បាប់ភូមិបាល និងលក្ខខណ្ឌតម្រូវក្នុងក្របខណ្ឌបរិស្ថាន និងសង្គម នៅពេលអនុវត្តគម្រោង។ ចំនួនអ្នកទទួលផលផ្ទាល់ពីគម្រោងដំណាក់កាលទី ៣ គឺប្រជាជនជនបទប្រហែល ១៥.០០០ គ្រួសារ។ ភាពអាចរកបាន និងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធដែលបានកែលម្អ នឹងផ្តល់អត្ថប្រយោជន៍បន្ថែមទៀតដល់ប្រជាជនកាន់តែច្រើន ក្រៅពីគ្រួសារគោលដៅក្នុងតំបន់អនុវត្តន៍គម្រោង។

រូប ១ ៖ ខេត្តក្នុងប្រទេសកម្ពុជា




## ២.មេរៀនពីការអនុវត្តគម្រោងដំណាក់កាលដំបូង និងគម្រោងដំណាក់កាលទី ២

23. គម្រោងដំណាក់កាលដំបូង និងគម្រោងដំណាក់កាលទី២ បានទ្រទ្រង់ដល់ការអភិវឌ្ឍសម្បទានដីសង្គមកិច្ចតាំងពីឆ្នាំ ២០០៧។ គម្រោងដំណាក់កាលទី ២ មានក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ ដែលបំពេញលក្ខខណ្ឌតម្រូវក្នុងគោលនយោបាយ ៤.១២ របស់ធនាគារពិភពលោកស្តីពីការតាំងទីលំនៅឡើងវិញដោយស្ម័គ្រចិត្ត ដែលផ្នែកខ្លះគឺខុសគ្នាពីលក្ខខណ្ឌតម្រូវក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៥។ យ៉ាងណាមិញ ដំណើរការកំណត់អត្តសញ្ញាណដីធ្លីសម្រាប់សម្បទានដីសង្គមកិច្ច ការពិនិត្យបឋម ការគូសផែនទី និងការផ្តល់ប័ណ្ណកម្មសិទ្ធិ និងនីតិវិធីសម្រាប់ការរៀបចំផែនការ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធក្នុងគម្រោងដំណាក់កាលទី ៣ នឹងមានលក្ខណៈស្រដៀងគ្នាបំផុតទៅនឹងដំណើរការ និងនីតិវិធីក្នុងគម្រោងដំណាក់កាលទី ២។ ការទ្រទ្រង់ដល់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចគឺជាសកម្មភាពថ្មីក្នុងគម្រោងដំណាក់កាលទី ៣ ប៉ុន្តែដំណើរការនេះមានលក្ខណៈសំខាន់ៗមួយចំនួនដែលស្រដៀងគ្នានឹងដំណើរការសម្បទានដីសង្គមកិច្ច ចំណែកដំណើរការសម្រាប់អនុគម្រោង ហេដ្ឋារចនាសម្ព័ន្ធនឹងមានលក្ខណៈស្រដៀងគ្នានៅប្រភេទទីតាំងទាំង ២។ ដូច្នេះ មេរៀនស្តីពីលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញក្នុងគម្រោងដំណាក់កាលទី ២ មានភាពពាក់ព័ន្ធ និងអាចអនុវត្តបានចំពោះគម្រោងដំណាក់កាលទី ៣។

24. គម្រោងដំណាក់កាលដំបូង និងគម្រោងដំណាក់កាលទី ២ បានផ្តោតអាទិភាពលើការបញ្ចៀសការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត និងផ្តល់លទ្ធផលដែលមិនតម្រូវឱ្យមានអនុគម្រោងក្នុងផែនការសកម្មភាពស្តីពីតាំងទីលំនៅឡើងវិញ ដែលត្រូវបានកំណត់សម្រាប់ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ក្នុងគម្រោងដំណាក់កាលទី ២។ ការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្តត្រូវបានបញ្ចៀសតាមរយៈការផាត់ចេញតំបន់ដែលកំពុងមានការទាមទារកម្មសិទ្ធិឯកជន មុនការប្រកាសកាលបរិច្ឆេទឱសានវាទជាសាធារណៈ ពីតំបន់នៃសម្បទានដីសង្គមកិច្ច។ ដីទំនេរត្រូវបានបម្រុងទុកសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងសម្រាប់គោលបំណងសាធារណៈ ដូចជា ព្រៃសហគមន៍ក្នុងសកម្មភាពរៀបចំផែនការប្រើប្រាស់ដីធ្លី។

25. មានករណីដែលគ្មានការរកឃើញការទាមទារលើដីធ្លីដែលស្ថិតនៅក្រៅសម្បទានដីសង្គមកិច្ច រហូតដល់ក្រោយការបញ្ចប់ការរៀបចំផែនការប្រើប្រាស់ដីធ្លី និងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីឯកជនរបស់រដ្ឋ។ ដូច្នេះ ទីតាំងសម្បទានដីសង្គមកិច្ចរួមបញ្ចូលដីបម្រុងដែលអាចប្រើប្រាស់សម្រាប់ការផ្តល់សំណងមិនមែនប្រាក់ដើម្បីដោះស្រាយការទាមទារទាំងនេះ ហើយក្នុងករណីខ្លះ អ្នកទាមទារដីបច្ចុប្បន្នបានយល់ព្រមបោះបង់ដីរបស់ខ្លួនជាថ្នូរនឹងការដាក់បញ្ចូលជាអ្នកទទួលបានដីធ្លីក្នុងក្របខណ្ឌសម្បទានដីសង្គមកិច្ច។

26. ក្នុងករណីសម្បទានដីសង្គមកិច្ចនៅឃុំដុង ដែលជាសម្បទានដីសង្គមកិច្ចថ្មីតែមួយគត់ដែលទ្រទ្រង់ដោយគម្រោងដំណាក់កាលទី ៣ ការជូនដំណឹងពីសេចក្តីប្រកាសពីទ្រព្យសម្បត្តិស្របច្បាប់របស់បុគ្គល និងស្ថាប័នរដ្ឋ ដែលបានបិទផ្សាយពីថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៧ រហូតដល់ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៧ បានធ្វើឱ្យមានពាក្យបណ្តឹង ៧៣២ ករណីពីបុគ្គលដែលទាមទារកាន់កាប់ក្បាលដីដែលស្ថិតនៅក្រៅ ឬត្រួតគ្នានឹងតំបន់ដែលត្រូវបានគូសផែនទីជាដីរដ្ឋ និងទុកសម្រាប់សម្បទានដីសង្គមកិច្ច។ ក្រោយការស៊ើបអង្កេត ក្បាលដីពាក់ព័ន្ធចំនួន ៣១៨ ត្រូវបានរកឃើញថាកំពុងធ្វើកសិកម្ម និងត្រូវបានផាត់ចេញពីតំបន់សម្បទានដីសង្គមកិច្ច។ អ្នកដាក់បណ្តឹងចំនួន ២៩ នាក់ត្រូវបានរកឃើញថាពាក់ព័ន្ធនឹងក្បាលដីដែលស្ថិតនៅក្រៅតំបន់សម្បទានដីសង្គមកិច្ចដែលស្នើឡើង។ អ្នកដាក់បណ្តឹង ៣៥៩ នាក់ត្រូវបានសម្រេចថាគ្មានសុពលភាព និងប្រានចោល។ អ្នកដាក់បណ្តឹង ២៦ នាក់មិនបានចូលរួមក្នុងដំណើរការដោះស្រាយ។

27. យន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងគម្រោងដំណាក់កាលទី ២ ខិតខំដោះស្រាយបណ្តឹងយ៉ាងច្រើន ហើយដំណើរការដោះស្រាយត្រូវការពេលវេលា ១១ ខែ ខណៈដែលស្តង់ដារកំណត់ថាត្រូវដោះស្រាយបណ្តឹងក្នុងរយៈពេល ៤០ ថ្ងៃ។

28. នៅសម្បទានដីសង្គមកិច្ចឃុំដុង ផែនទីព្រាងបឋមនៃទីតាំងដីសម្រាប់សម្បទានដីសង្គមកិច្ចត្រូវបានបិទផ្សាយជាសាធារណៈនៅខែ វិច្ឆិកា ឆ្នាំ ២០១៤ ពោលគឺរយៈពេលជាង ២ ឆ្នាំមុនពេលមានការជូនដំណឹងពីសេចក្តីប្រកាសផ្លូវការ។ ទំនងជាមានការរុះរើយ៉ាងច្រើនក្នុងទីតាំងដីសម្រាប់សម្បទានដីសង្គមកិច្ចក្នុងអំឡុងពេលនេះ។ ការណ៍នេះធ្វើឱ្យមានបណ្តឹងជាច្រើន ដែលបានបង្កជាផលវិបាកសំខាន់ៗសម្រាប់កាលបរិច្ឆេទឱសានវាទទាំងនៅទីតាំងសម្បទានដីសង្គមកិច្ច និងទីតាំងផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ក្នុងអំឡុងពេលដ៏វែងអន្លាយនេះ នៅចន្លោះពេលដែលសម្បទានដីសង្គមកិច្ច ឬការផ្តល់ប័

ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចត្រូវបានផ្សព្វផ្សាយជាសាធារណៈ និងកាលបរិច្ឆេទឱសានវាទផ្លូវការ ប្រហែលជាអាចជំរុញឱ្យមានការទន្ទ្រានកាន់កាប់នៅទីតាំងដីនោះ។

29. ផ្អែកលើបទពិសោធន៍នៅសម្បទានដីសង្គមកិច្ចឃុំដុង និងលក្ខណៈក្រៅផ្លូវការ ឬបង្កការកេន្ត្រទ្រង់នៃសិទ្ធិកាន់កាប់ដីធ្លីក្នុងតំបន់ដីព្រៃរេចរឹល និងដីសម្រាប់សម្បទានដីសេដ្ឋកិច្ចដែលត្រូវបានលុបចោល ដែលច្រើនត្រូវបានបែងចែកសម្រាប់សម្បទានដីសង្គមកិច្ច គេអាចប៉ាន់ស្មានបានថា ស្ថានភាពស្រដៀងៗគ្នាអាចនឹងលេចឡើងក្នុងគម្រោងដំណាក់កាលទី ៣។ យន្តការដោះស្រាយបណ្ដឹងតវ៉ាក្នុងគម្រោងដំណាក់កាលទី ៣ ប្រាកដជាអាចដោះស្រាយបណ្ដឹងយ៉ាងច្រើន ក៏ដូចជារក្សាបាននូវគុណភាពនៃការដោះស្រាយបណ្ដឹង និងបញ្ចៀសការពន្យារពេលលើសពីក្របខណ្ឌពេលវេលាកំណត់នៃការឆ្លើយតប និងដំណោះស្រាយ។

30. ក្នុងគម្រោងដំណាក់កាលទី ២ មានករណីដែលជនឆ្លៀតឱកាសចូលមកតាំងលំនៅដ្ឋានក្រោយកាលបរិច្ឆេទឱសានវាទ។ ការណ៍នេះតម្រូវឱ្យមានដំណើរការចរចា និងសម្របសម្រួលដើម្បីផាត់ចេញជនចូលទន្ទ្រានយកដីទាំងនោះ (ពួកគេនឹងមិនត្រូវបានចាត់ទុកជាអ្នកទាមទារស្របច្បាប់ក្នុងវិសាលភាពនៃបទដ្ឋានបរិស្ថាន និងសង្គមទី ៥)។

31. មិនច្បាស់ថាតើផលប៉ះពាល់នៃការរឹតត្បិតលទ្ធភាពប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួម ត្រូវបានចាត់ទុកជាបញ្ហានៃការតាំងទីលំនៅឡើងវិញក្នុងគម្រោងដំណាក់កាលដំបូង និងគម្រោងដំណាក់កាលទី ២ ឬយ៉ាងណានោះទេ ប៉ុន្តែវិធីសាស្ត្របែបជំរុញការចូលរួម និងការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយអ្នកពាក់ព័ន្ធស្ដីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងរៀបចំផែនការប្រើប្រាស់ដីធ្លីក្នុងទីតាំងសម្បទានដីសង្គមកិច្ច ត្រូវបានរំពឹងថានឹងប្រឈមនឹងបញ្ហាមួយចំនួន ប៉ុន្តែហាក់គ្មានបញ្ហាអ្វីនោះទេ។ គ្មានការកត់ត្រាពីបណ្ដឹងដែលបានដាក់តាមរយៈយន្តការដោះស្រាយបណ្ដឹងតវ៉ាក្នុងគម្រោងដំណាក់កាលទី ២ ឬបញ្ហាប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួមឡើយ។

32. អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធក្នុងសម្បទានដីសង្គមកិច្ចត្រូវបានសាងសង់ឡើងលើដីគ្មានការប្រើប្រាស់ដែលបម្រុងទុកសម្រាប់គោលបំណងនេះ និងគ្មានករណីលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញក្នុងពេលអនុវត្តអនុគម្រោងឡើយ។ អាចមានការលើកលែងចំពោះករណីនេះ ប្រសិនបើមានការសិក្សាសមិទ្ធិលទ្ធភាពផ្នែកបច្ចេកទេសនៅកាលបរិច្ឆេទក្រោយ បង្ហាញពីភាពចាំបាច់នៃការផ្លាស់ប្ដូរទីតាំងដែលស្នើឡើងរបស់ហេដ្ឋារចនាសម្ព័ន្ធ ចេញឆ្ងាយពីដីបម្រុងសម្រាប់គោលបំណងនេះ (ឧទាហរណ៍មួយនៃករណីនេះកើតឡើងនៅទីតាំងសម្បទានដីសង្គមកិច្ចកក្នុងខេត្តកំពង់ឆ្នាំង ដែលផ្លូវចេញចូលត្រូវបានសាងសង់ឡើងដោយគម្រោង IPLR)។ ជាធម្មតា ផ្លូវចេញចូលទីតាំងត្រូវបានសាងសង់លើផ្លូវចាស់។ ដូច្នេះ តម្រូវការលទ្ធកម្មដីធ្លីមានកម្រិតតិចតួចបំផុត ដូចជា សម្រាប់ការពង្រីកផ្លូវ ឬការសាងសង់ច្រាំង។ អាចមានករណីមួយដែលច្រកចេញចូលទីតាំងសម្បទានដីសង្គមកិច្ច ឬទីតាំងផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចគឺត្រូវសាងសង់ផ្លូវឆ្លងកាត់ដីកម្មសិទ្ធិឯកជន។

33. មេរៀនពីគម្រោងដំណាក់កាលដំបូង និងគម្រោងដំណាក់កាលទី ២ លើកឡើងថា បញ្ហាលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញនៅទីតាំងផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចគឺស្រដៀងគ្នានឹងបញ្ហានៅទីតាំងសម្បទានដីសង្គមកិច្ច (ឧ. ក្នុងកម្រិតដែលចាំបាច់ត្រូវមានលទ្ធកម្មដីធ្លី ឬការតាំងទីលំនៅឡើងវិញ ករណីនេះនឹងមានទំហំតូច និងភាគច្រើនពាក់ព័ន្ធនឹងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ ឬសំណង់ធារាសាស្ត្រ) នៅក្រៅតំបន់ទីតាំងផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ឬតំបន់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ដែលអាចមានវិសាលភាពតូចសម្រាប់ការផ្តល់អំណោយដីដោយស្ម័គ្រចិត្ត។ ទន្ទឹមនឹងនេះ មេរៀនបង្ហាញផងដែរថា គួរផ្តោតកិច្ចខិតខំប្រឹងប្រែងបន្ថែមនៅដំណាក់កាលដំបូងនៃការរៀបចំផែនាការដើម្បីវាយតម្លៃការទាមទារដីធ្លីមានស្រាប់នៅក្រៅទីតាំងសម្បទានដីសង្គមកិច្ច/ទីតាំងផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ដើម្បីពង្រឹងការធ្វើអត្តសញ្ញាណកម្មអ្នកទទួលផល និងជន ឬគ្រួសារដែលអាចរងផលប៉ះពាល់អវិជ្ជមានដោយសារការកំណត់ព្រំប្រទល់ទីតាំងសម្បទានដីសង្គមកិច្ច/ទីតាំងផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ចំណុចចុងក្រោយគឺ ដើម្បីដោះស្រាយបណ្តឹងដែលបណ្តាលមកពីលទ្ធកម្មដីធ្លីដែលអាចកើតឡើង និងការកំណត់ព្រំប្រទល់ និងការគូសផែនទីតំបន់ដែលត្រូវបានផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ចាំបាច់ត្រូវមានយន្តការដោះស្រាយបណ្តឹងតវ៉ាដែលមានប្រសិទ្ធភាព និងងាយស្រួលប្រើប្រាស់។

## ៣.ក្របខណ្ឌច្បាប់សម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ

### ៣.១ បទប្បញ្ញត្តិមូលដ្ឋាននៃច្បាប់កម្ពុជា

34. *ក្របខណ្ឌច្បាប់ជាតិស្តីពីការផ្តល់សំណង ៖* **រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣)** ចែងថា "ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ" និងមានសិទ្ធិទទួលបានសំណងយុត្តិធម៌"។ **ច្បាប់ភូមិបាល (២០០១)** ចែងថា "គ្មានបុគ្គលណាមួយត្រូវបានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារណៈ"។ ច្បាប់នេះទទួលស្គាល់ថា ការដកហូតកម្មសិទ្ធិ មានសិទ្ធិទទួលបានសំណងជាមុនដោយសមរម្យ និងយុត្តិធម៌"។

35. **ច្បាប់ស្តីពីអស្សាមិករណ៍ (២០១០)** "មានគោលដៅកំណត់ពីអស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយកំណត់ពីគោលការណ៍ យន្តការ នីតិវិធីនៃអស្សាមិករណ៍ និងសំណងឱ្យបានសមរម្យ និងយុត្តិធម៌សម្រាប់គម្រោងស្ថាបនា ស្តារ និងគម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈបម្រើឱ្យផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និងការអភិវឌ្ឍរបស់ព្រះរាជាណាចក្រកម្ពុជា"។ ច្បាប់នេះបានបង្កើតរចនាសម្ព័ន្ធនៃគណៈកម្មាធិការអស្សាមិករណ៍ និងអនុគណៈកម្មាធិការដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅថ្នាក់ជាតិ និងគណៈអភិបាលខេត្តនៅថ្នាក់ក្រោមជាតិ។ ច្បាប់នេះចែងពីយន្តការដោះស្រាយបណ្តឹងដែលដឹកនាំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ លក្ខណៈសំខាន់ៗនៃច្បាប់នេះរួមមាន ៖

- សម្រាប់ផ្នែកភាគច្រើន អ្នកដែលមានសិទ្ធិទទួលបានសំណងគឺ "ម្ចាស់ និងម្ចាស់ពេញសិទ្ធិ" នៃដីធ្លី និងអចលនទ្រព្យ
- ម្ចាស់ទ្រព្យសម្បត្តិអាចទទួលបានសំណងដោយផ្អែកលើតម្លៃទីផ្សារសម្រាប់ទ្រព្យសម្បត្តិដែលត្រូវបានដកហូត
- ម្ចាស់អាជីវកម្មដែលធ្វើអាជីវកម្មលើដីជួល អាចមានសិទ្ធិទទួលបានសំណងសម្រាប់ផលប៉ះពាល់លើអាជីវកម្មរបស់ខ្លួន (ច្បាប់នេះមិនសូវច្បាស់ត្រង់ចំណុចដែលបទប្បញ្ញត្តិនេះក៏អនុវត្តចំពោះអាជីវកម្មដែលធ្វើប្រតិបត្តិការដោយម្ចាស់ទ្រព្យសម្បត្តិ)។
- សេចក្ដីសម្រេចអស្សាមិករណ៍អាចត្រូវបានដេញដោលតាមរយៈគណៈកម្មាធិការដោះស្រាយបណ្ដឹង ឬតុលាការ។ គ្មានការចែងច្បាស់ថា សេចក្ដីសម្រេចដោយគណៈកម្មាធិការនេះនឹងធ្វើមោឃភាពការដេញដោលជាបន្តបន្ទាប់ក្នុងតុលាការនោះទេ។
- មានទណ្ឌកម្មព្រហ្មទណ្ឌសម្រាប់អ្នកដែលរាំងស្ទះដំណើរការអស្សាមិករណ៍ ឬទន្ទ្រានកាន់កាប់លើដីដែលត្រូវបានដកហូត។

36. *ក្របខណ្ឌច្បាប់ស្ដីពីការទន្ទ្រានកាន់កាប់ដីរដ្ឋ ៖* ច្បាប់ភូមិបាលឆ្នាំ ២០០១ ការញែកយ៉ាងច្បាស់រវាងអ្នកដែលត្រួសត្រាយដីសម្រាប់សង់លំនៅដ្ឋាន ឬធ្វើកសិកម្ម មុនថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ និងអ្នកដែលបានត្រួសត្រាយដីនៅក្រោយកាលបរិច្ឆេទនេះ។ ក្នុងករណីទីមួយ អ្នកកាន់កាប់អាចត្រូវបានទទួលស្គាល់ជាអ្នកកាន់កាន់ស្របច្បាប់លើដីរដ្ឋនាពេលខាងមុខ នៅពេលដែលដីនោះត្រូវបានចុះបញ្ជីជាដីឯកជនរបស់រដ្ឋ។ ក្នុងករណីទីពីរ អ្នកកាន់កាប់គឺខុសច្បាប់។ មាត្រា ១៨ នៃច្បាប់ភូមិបាលបានផ្ដល់ឧបករណ៍រឹងមាំសម្រាប់ការបណ្ដេញអ្នកទន្ទ្រានកាន់កាប់។ "ពួកគេមិនអាចទាមទារសំណងទូទាត់ ឬសាហ៊ុយសម្រាប់ការថែទាំ ឬការរៀបចំដែលបានធ្វើនៅលើអចលនវត្ថុ ដែលបានកាន់កាប់ដោយខុសច្បាប់បានឡើយ" (មាត្រា ១៩)។

37. សារាចរលេខ ០២ របស់រាជរដ្ឋាភិបាលកម្ពុជាស្ដីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ ចែងថា ខណៈដែលការកាន់កាប់ដីក្រោមទម្រង់ជាកម្មសិទ្ធិ ប្រែក្លាយជាខុសច្បាប់ក្រោយថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ រដ្ឋត្រូវផ្ដល់សម្បទានដីសង្គមកិច្ចដល់ប្រជាជនក្រីក្រ និងក្រុមជួបការលំបាកដើម្បីបំពេញតម្រូវការដីធ្លីរបស់ពួកគេដោយសារកំណើនប្រជាជន ការរំសាយកងទ័ព និងការបាត់បង់ដីធ្លីដោយសារគ្រោះមហន្តរាយធម្មជាតិ។ ប៉ុន្តែការរំលោភកាន់កាប់ដីរដ្ឋខុសច្បាប់យ៉ាងអនាធិបតេយ្យក៏បានផ្ដល់ឱកាសដល់អ្នកទិញលក់ដីធ្លីដើម្បីបានប្រាក់ចំណេញ និងជនមានអំណាចក្នុងការកាន់កាប់ដោយខុសច្បាប់លើដីរដ្ឋតាមមធ្យោបាយផ្សេងៗ។ ដើម្បីដោះស្រាយស្ថានភាពនេះ សារាចរលេខ ២ បានកំណត់ថា ៖

- ជាទូទៅ អ្នកដែលកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ជាពិសេសអ្នកទិញលក់ដីធ្លីដើម្បីបានប្រាក់ចំណេញ គ្មានសិទ្ធិទាមទារសំណងទេ (កថាខណ្ឌ ៦.១ ក្នុងសារាចរលេខ ២)
- គ្រួសារក្រីក្រគ្មានដី ឬខ្វះដី និងជនងាយរងគ្រោះ ដែលកាន់កាប់ដីរដ្ឋដោយខុសច្បាប់ គ្មានសិទ្ធិទាមទារសំណង ប៉ុន្តែអាចទទួលបានការអនុគ្រោះក្នុងការទទួលបានដី ដែលមានទំហំសមស្របដើម្បីប្រកបរបរចិញ្ចឹមជីវិត (កថាខណ្ឌ ៦.២ ក្នុងសារាចរលេខ ០២)។

38. សម្រាប់ដីឯកជនរបស់រដ្ឋ ចំណុចនេះអាចកើតឡើងតាមរយៈការលក់ ការជួល ការធ្វើប្រទានកម្ម ការផ្តល់សិទ្ធិផលុបភោគ (សិទ្ធិប្រើប្រាស់ និងយកផលល្អានុផលលើដីដើម្បីចិញ្ចឹមជីវិត) សម្បទានដីសង្គមកិច្ច សម្បទានដីសេដ្ឋកិច្ច ឬការអនុញ្ញាតឱ្យប្រើប្រាស់។ ការសម្រេចអំពីជម្រើសជាក់លាក់ណាមួយត្រូវធ្វើឡើងផ្អែកលើការសម្របសម្រួលរបស់អាជ្ញាធរដែនដី រវាងអាជ្ញាធរកាន់កាន់ដីធ្លី និងបុគ្គលដែលកាន់កាប់ដី និងផ្អែកលើផែនការប្រើប្រាស់ដី (កថាខណ្ឌ ៧.១ ក្នុងសារាចរលេខ ០២)។

## ៣.២ អនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ

39. អនុក្រឹត្យលេខ ២២ ចុះខែ កុម្ភៈ ឆ្នាំ ២០១៨ តម្រូវឱ្យមានការប្រើប្រាស់នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្តសម្រាប់គម្រោងដែលផ្តល់ហិរញ្ញប្បទានទីខាងក្រៅនៅកម្ពុជា (ហៅកាត់ថា អនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ)។ ឯកសារនេះបំពេញបន្ថែមលើឯកសារនីតិវិធីប្រតិបត្តិស្តង់ដារមានស្រាប់ដែលផ្តោតលើការគ្រប់គ្រងគម្រោង ការគ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្មសម្រាប់គម្រោងដែលផ្តល់ហិរញ្ញប្បទានពីខាងក្រៅ ដែលអនុវត្តចំពោះគម្រោងដែលទ្រទ្រង់ដោយកម្ចីពីធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី IFAD និងស្ថាប័នផ្សេងទៀត។ អនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ គឺជាឯកសារថ្មី (ដូច្នេះ វាត្រូវបានរៀបចំឡើងក្រោយក្របខណ្ឌដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងដំណាក់កាលទី ២) ប៉ុន្តែផ្អែកភាគច្រើនតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដូចជា ច្បាប់ស្តីពីអស្សាមិករណ៍ (២០១០)។ អនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ ចែងថា គម្រោងហេដ្ឋារចនាសម្ព័ន្ធដែលផ្តល់ហិរញ្ញប្បទានពីខាងក្រៅ ត្រូវអនុលោមតាមគោលនយោបាយធានាសុវត្ថិភាពរបស់ដៃគូអភិវឌ្ឍន៍ដែលផ្តល់ហិរញ្ញប្បទានដល់គម្រោងនោះ ហើយកាតព្វកិច្ចទាំងនេះត្រូវបញ្ជាក់ច្បាស់ក្នុងកិច្ចព្រមព្រៀងហិរញ្ញប្បទានគម្រោង។ ការទូទាត់សំណងត្រូវផ្តល់ហិរញ្ញប្បទានពីមូលនិធិរាជរដ្ឋាភិបាលកម្ពុជា ដែលញែកចេញ និងបន្ថែមលើការផ្តល់មូលនិធិបដិភាគពីគម្រោងដែលមានបង្ហាញក្នុងតារាងចំណាយរបស់គម្រោង។

40. អនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ ១) កំណត់ពីតួនាទី និងការទទួលខុសត្រូវរបស់ក្រសួង និងស្ថាប័នសំខាន់ៗ ជាពិសេសផ្អែកតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីអស្សាមិករណ៍ ២) សង្ខេបពីក្របខណ្ឌច្បាប់ និងគោលនយោបាយ ៣) ពិពណ៌នាពីដំណើរការរៀបចំផែនការដោះស្រាយផលប៉ះពាល់ និងការវាយតម្លៃផលប៉ះពាល់សង្គម ៤) កំណត់ពីការណែនាំលម្អិតសម្រាប់ការគណនាសំណង ៥) តម្រូវឱ្យមានដំណើរការពិគ្រោះយោបល់ជាសាធារណៈ ការផ្សព្វផ្សាយព័ត៌មាន និងយន្តការដោះស្រាយបណ្តឹងតវ៉ា និង ៦) ពិពណ៌នាពីការរៀបចំការអនុវត្ត រួមមាន ការចំណាយថវិកា និងការពិនិត្យតាមដាន និងរាយការណ៍។

41. អនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញផ្តោតសំខាន់លើតម្រូវការលទ្ធកម្មដីធ្លីនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធ។ ក្នុងបរិបទនេះ នីតិវិធីប្រតិបត្តិស្តង់ដារកំណត់ពីកម្រិតនៃដីធ្លីដែលត្រូវបានចាត់ទុកជា "ដីចំណីផ្លូវ" និងដីសាធារណៈដែលស្ថិតនៅជិតផ្លូវថ្នល់ ផ្លូវដែក និងផ្លូវ

ទឹក។ ជាទូទៅ គ្មានការផ្តល់សំណងដល់ដីដែលស្ថិតក្នុងដីចំណីផ្លូវមានស្រាប់នោះទេ ប៉ុន្តែអាចមានករណីលើកលែង ដូចជា ការផ្តល់ជំនួយដល់ក្រុមក្រីក្រ និងងាយរងគ្រោះ ឬក្នុងករណីដែលដីចំណីផ្លូវមានស្រាប់ត្រូវបានពង្រីកដោយសារគម្រោង។ នីតិវិធីប្រតិបត្តិស្តង់ដារទទួលស្គាល់ថា ក្នុងករណីមួយចំនួន ការធ្វើកសិកម្មចិញ្ចឹមក្រពះ ត្រូវបានអនុញ្ញាតលើដីសាធារណៈដែលបង្កើតបានជាផ្នែកមួយនៃដីចំណីផ្លូវ ដូចជា ស្ថិតនៅជិតផ្លូវថ្នល់ឬប្រឡាយ ប៉ុន្តែគ្មានការផ្តល់សំណងដល់ការបាត់បង់ការប្រើប្រាស់ដីក្នុងប្រភេទនេះទេ។

42. អនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ កំណត់ពីកម្រិតនៃដីចំណីផ្លូវសម្រាប់ផ្លូវជាតិ (ក្រៅតំបន់ទីប្រជុំជន) ផ្លូវដែក និងផ្លូវទឹក។ ពាក់ព័ន្ធនឹងគម្រោងដំណាក់កាលទី ៣ ដីដែលស្ថិតក្នុងរង្វង់ ១០ ម៉ែត្រពីប្រឡាយមេ ឬ ៥ ម៉ែត្រពីប្រឡាយរង ត្រូវបានកំណត់ជាដីចំណីផ្លូវ និងជាដីសាធារណៈរបស់រដ្ឋ។ ប៉ុន្តែអនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ ហាក់មិនផ្តល់ការណែនាំស្តីពីដីចំណីផ្លូវសម្រាប់ផ្លូវជនបទទេ។ ជាទូទៅ ក្រសួងអភិវឌ្ឍន៍ជនបទកំណត់ថា ដីចំណីផ្លូវសម្រាប់ផ្លូវជនបទរួមមានដីដែលស្ថិតក្នុងចម្ងាយ ១៥ ម៉ែត្រពីអក្សផ្លូវ។

43. អនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ កំណត់ថា ការរៀបចំផែនការដោះស្រាយផលប៉ះពាល់ ត្រូវផ្អែកតាមគោលការណ៍ខាងក្រោម ៖

- បញ្ចៀសការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត ឬនៅពេលមិនអាចបញ្ចៀសបាន កាត់បន្ថយការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្តជាអតិបរមា តាមរយៈការស្វែងរកការរៀបចំគម្រោងផ្សេងទៀត
- សម្រាលផលប៉ះពាល់អវិជ្ជមានដែលមិនអាចបញ្ចៀសបានលើសង្គម និងសេដ្ឋកិច្ច ដោយសារលទ្ធកម្មដីធ្លី តាមរយៈការផ្តល់សំណងទាន់ពេលវេលាសម្រាប់ការបាត់បង់ទ្រព្យសម្បត្តិទៅតាមតម្លៃជំនួស និងការជួយដល់ជនបាត់បង់ទីលំនៅដើម្បីស្តារបរចិញ្ចឹមជីវិតរបស់ខ្លួនយ៉ាងហោចណាស់ត្រឹមកម្រិតមុនពេលមានគម្រោង។
- ផ្តល់ជំនួយ និងឱកាសដល់ក្រុមក្រីក្រ និងក្រុមជួបការលំបាកនៃជនដែលបាត់បង់ទីលំនៅរូបវន្ត ដើម្បីបង្កើនស្តង់ដារជីវិតរស់នៅរបស់ពួកគេ។

44. អនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញផ្តល់ការណែនាំ និងគំរូឯកសារសម្រាប់ការរៀបចំផែនការដោះស្រាយផលប៉ះពាល់កម្រិតមូលដ្ឋាន (ដែលមានព័ត៌មានគ្រប់គ្រាន់ស្តីពីជនដែលរងផលប៉ះពាល់) ឬក្របខណ្ឌដោះស្រាយផលប៉ះពាល់ដែលត្រូវរៀបចំឡើងនៅពេលរៀបចំគម្រោង បូករួមនឹងផែនការដោះស្រាយផលប៉ះពាល់លម្អិត ដែលត្រូវរៀបចំឡើងនៅពេលអនុវត្តគម្រោង។ ខ្លឹមសារសំខាន់ៗនៃផែនការដោះស្រាយផលប៉ះបាល់ រួមមាន ១) សាវតាសេដ្ឋកិច្ចសង្គមរបស់ជនបាត់បង់ទីលំនៅ និងការវាយតម្លៃផលប៉ះពាល់សង្គម រួមទាំងការព្រួយបារម្ភពីយេនឌ័រ ២) ការផ្សព្វផ្សាយព័ត៌មាន ការពិគ្រោះយោបល់ និងការចូលរួម ៣) សិទ្ធិទទួលបានសំណង ៤) យុទ្ធសាស្ត្រទ្រទ្រង់ចំណូលនិងបរចិញ្ចឹមជីវិត ៥) ការរៀបចំផ្នែកស្ថាប័ន ៦) យន្តការដោះស្រាយបណ្តឹងតវ៉ា ៧) ការពិនិត្យតាមដាន និងរាយការណ៍ ៨)

ថវិកា ៩) កាលវិភាគអនុវត្តន៍ និង ១០) ក្របខណ្ឌច្បាប់រួមទាំងការកំណត់រកចំណុចខ្វះខាតរវាងច្បាប់ជាតិ និងលក្ខខណ្ឌតម្រូវរបស់ដៃគូអភិវឌ្ឍន៍។

45. នីតិវិធីប្រតិបត្តិស្តង់ដារ កំណត់ពីគ្រួសារដែលរងផលប៉ះពាល់ជា "គ្រួសារដែលបាត់បង់ទីកន្លែង និង/ឬ រងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចដោយសារលទ្ធកម្មដីធ្លីនិងការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត"។ ប្រភេទជនដែលរងផលប៉ះពាល់រួមមាន ម្ចាស់ស្របច្បាប់ អ្នកជួល និងអ្នកកាន់កាប់ដែលគ្មានសិទ្ធិផ្លូវការ។ ប្រការ ៤៨ ចែងថា ជនបាត់បង់ទីលំនៅរួមមាន " អ្នកដែលនឹងបាត់បង់ទ្រព្យសម្បត្តិរូបវន្ត និងមិនមែនរូបវន្តទាំងស្រុង ឬដោយផ្នែក រួមមានផ្ទះសម្បែង ដីធ្លី អគារ/សំណង់ ទ្រព្យសម្បត្តិពាណិជ្ជកម្ម ដំណាំ ធនធាន ការជួល ឱកាសរកប្រាក់ចំណូលចិញ្ចឹមក្រពះ សហគមន៍ និងបណ្តាញសង្គម និងវប្បធម៌។ ការបាត់បង់អាចមានលក្ខណៈបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍"។

46. អនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញកំណត់ពីប្រភេទពិសេសៗនៃជនដែលរងផលប៉ះពាល់ ៖ ១) ក្រុមក្រីក្រ និងងាយរងគ្រោះ និង ២) ជនជាតិដើមភាគតិច ។ ក្រុមក្រីក្រ និងងាយរងគ្រោះ មានសិទ្ធិទទួលបានជំនួយបន្ថែមសម្រាប់ការតាំងទីលំនៅឡើងវិញ និងការស្តារបេរចិញ្ចឹមជីវិត ក្នុងករណីដែលពួកគេគ្មានការទាមទារផ្លូវច្បាប់លើដីពាក់ព័ន្ធ។ នីតិវិធីប្រតិបត្តិស្តង់ដារកត់សម្គាល់ពីលទ្ធភាពនៃភាពខុសគ្នាផ្នែកយេនឌ័រលើរបៀបដែលមនុស្សរងផលប៉ះពាល់ដោយសារការតាំងទីលំនៅឡើងវិញ ប៉ុន្តែក្របខណ្ឌនេះផ្តោតសំខាន់លើគ្រួសារដែលជាឯកសារគោលសម្រាប់ការវាយតម្លៃការខាតបង់ និងសំណង។

47. អាស្រ័យលើកាលៈទេសៈ សំណងអាចត្រូវបានផ្តល់ជូន ១) ម្ចាស់ស្របច្បាប់ និងម្ចាស់ប័ណ្ណកម្មសិទ្ធិ ឬសិទ្ធិដីធ្លី រួមទាំងសិទ្ធិទំនៀមទំលាប់ ២) អ្នកជួល រួមទាំងនិយោជក កម្មករ និងអ្នកដើរលក់របស់របរ ៣) អ្នកដែលគ្មានប័ណ្ណកម្មសិទ្ធិ ឬសិទ្ធិផ្លូវការលើដីធ្លី (ការកាន់កាប់ដោយខុសច្បាប់) ដែលពាក់ព័ន្ធក្នុងការធ្វើកសិកម្ម ឬអាជីវកម្ម និង ៤) ក្រុមក្រីក្រ និងក្រុមងាយរងគ្រោះ។

48. ការផ្តល់សំណង និងជំនួយដល់ជនដែលរងផលប៉ះពាល់អាចរួមមាន ១) សំណងសម្រាប់ការបាត់បង់ដីធ្លី និងទ្រព្យសម្បត្តិរូបវន្ត ដែលត្រូវបានគណនាតាមតម្លៃទីផ្សារ ២) សំណងសម្រាប់ការបាត់បង់របេចិញ្ចឹមជីវិត និងប្រាក់ចំណូល រួមទាំងការបាត់បង់ប្រាក់ចំណូលពីអាជីវកម្មដែលស្ថិតនៅលើដី ៣) ចំណាយលើការធ្វើដំណើរ ៤) ជំនួយរបេចិញ្ចឹមជីវិតបណ្តោះអាសន្ន ដែលត្រូវបានគណនាជាប្រាក់ចំណូល ៣ ខែដែលច្រើនជាងអត្រាភាពក្រីក្រថ្នាក់ជាតិ ៣ ដង ឬ ៦ ខែ សម្រាប់គ្រួសារក្រីក្រ និងងាយរងគ្រោះ និង ៥) ជម្រើសសម្រាប់ការស្តារចំណូលឡើងវិញសម្រាប់អ្នកដែលប្រឈមនឹងការបាត់បង់របេចិញ្ចឹមជីវិតជាអចិន្ត្រៃយ៍។

49. អនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញមានបទប្បញ្ញត្តិសម្រាប់ដាក់ទណ្ឌកម្មលើការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ដែលអាចគុណទ្វេដងក្នុងករណីដែលការ

កាន់កាប់ខុសច្បាប់ធ្វើឱ្យមានការពន្យារពេលលើគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងទណ្ឌកម្មសម្រាប់ការរាំងស្ទះដល់ដំណើរការដកហូត។

50. អនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញផ្តល់រចនាសម្ព័ន្ធស្ថាប័នសម្រាប់រៀបចំ និងអនុវត្តផែនការដោះស្រាយផលប៉ះពាល់ ដែលត្រូវបានសង្ខេបដូចខាងក្រោម ៖

- គណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ ដែលប្រើប្រាស់អំណាចរបស់គណៈកម្មាធិការអស្សាមិករណ៍ក្រោមច្បាប់ស្តីពីអស្សាមិករណ៍។ គណៈកម្មាធិការអន្តរក្រសួងនេះធ្វើជាប្រធានដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មាធិការអន្តរក្រសួង
- ស្ថាប័នដឹកនាំការអនុវត្តគម្រោង/ស្ថាប័នអនុវត្តន៍គម្រោងដែលទទួលខុសត្រូវលើការរៀបចំផែនការដោះស្រាយផលប៉ះពាល់
- អនុគណៈកម្មាធិការខេត្តដោះស្រាយផលប៉ះពាល់ ដែលទទួលខុសត្រូវលើការបែងចែកសំណង
- ក្រុមការងាររបស់អនុគណៈកម្មាធិការខេត្តដោះស្រាយផលប៉ះពាល់។

## ៣.៣ បទប្បញ្ញត្តិក្នុងក្របខណ្ឌគតិយុត្តិស្តីពីសម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច

51. អនុក្រឹត្យលេខ ១១៨ (ខែ តុលា ឆ្នាំ ២០០៥) ស្តីពីការគ្រប់គ្រងដីរដ្ឋ មានដំណើរការដែលត្រូវអនុវត្តតាមក្នុងការធ្វើអត្តសញ្ញាណកម្មដីជាដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋ (ដីឯកជនរបស់រដ្ឋអាចផ្តល់ជូនសម្រាប់ការបែងចែកជាសម្បទានដីសង្គមកិច្ច ឬសេដ្ឋកិច្ច)។ អនុក្រឹត្យនេះកំណត់ពីគោលការណ៍ទូទៅដូចខាងក្រោម ៖

- ជាទូទៅ រដ្ឋគឺជាម្ចាស់នៃដីទាំងអស់ដែលមិនឋិតនៅក្រោមការកាន់កាប់ជាភោគៈស្របច្បាប់ ឬជាកម្មសិទ្ធិដោយបុគ្គលឯកជន ឬដោយសមូហភាពស្របតាមច្បាប់ភូមិបាលឆ្នាំ ២០០១
- ដីរដ្ឋរួមមាន ដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ
- ក្បាលដីរដ្ឋនីមួយៗត្រូវចុះបញ្ជីជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ នៅក្នុងសៀវភៅគោលបញ្ជីដីធ្លី
- ដីរដ្ឋអាចផ្តល់ឱ្យជាសម្បទានដីសង្គមកិច្ច ជាសម្បទានដីសេដ្ឋកិច្ច ឬជាសម្បទានផ្សេងៗទៀតបាន លុះត្រាតែដីនោះត្រូវបានចុះបញ្ជីថា ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ នឹងត្រូវបានអនុវត្តតាមនីតិវិធីច្បាប់។

52. មានក្រុមការងារដីរដ្ឋថ្នាក់ស្រុក ក្រោមការដឹកនាំរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត និងទទួលខុសត្រូវលើការកំណត់អត្តសញ្ញាណដីរដ្ឋតាមរយៈដំណើរការដែលមានតម្លាភាព ដូចខាងក្រោម ៖

- ទីតាំង និងព្រំប្រទល់ប្រហាក់ប្រហែលនៃដីរដ្ឋ
- ព័ត៌មាននានាដែលមានប្រយោជន៍សម្រាប់ការចុះបញ្ជីដីរដ្ឋថា ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ
- ព័ត៌មានអំពីប្រភេទដី និងការប្រើប្រាស់បច្ចុប្បន្ន ប្រសិនបើមាន។

53. អនុក្រឹត្យនេះកំណត់ថា ដីរដ្ឋមិនរាប់បញ្ចូលដីដែលជាកម្មសិទ្ធិឯកជនក្រោមស្របតាមច្បាប់ភូមិបាលឆ្នាំ ២០០១ ប៉ុន្តែមិនបានផ្តល់ដំណើរការលម្អិតសម្រាប់ការធ្វើអត្តសញ្ញាណកម្ម ឬផ្ទៀងផ្ទាត់ការទាមទារឯកជនលើកម្មសិទ្ធិដីធ្លីឡើយ។ អនុក្រឹត្យនេះចែងថា "មុននឹងដាក់របាយការណ៍ការងារជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុមការងារដីរដ្ឋថ្នាក់ស្រុកត្រូវធ្វើការបិទផ្សាយជាសាធារណៈរយៈពេល ៣០ ( សាមសិប ) ថ្ងៃ នូវសេចក្តីសង្ខេបអំពីការអះអាងអំពីផែនទីបង្ហាញពីការអះអាង និងសេចក្តីពន្យល់ច្បាស់លាស់អំពីគោលបំណងនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋសម្រាប់ឱ្យសាធារណជនចូលរួមផ្តល់មតិយោបល់ និងត្រូវផ្តល់ជូនតាមការស្នើសុំនូវសំណៅថតចម្លងនៃឯកសារដែលបានបិទផ្សាយ ដោយតម្រូវឱ្យបង់ថ្លៃសមស្រប"។ អនុក្រឹត្យនេះមិនបានពិពណ៌នាលម្អិតពីនីតិវិធីសម្រាប់ដោះស្រាយបណ្តឹងតវ៉ាឡើយ។

54. ក្របខណ្ឌសម្រាប់សម្បទានដីសង្គមកិច្ចត្រូវបានកំណត់ដោយអនុក្រឹត្យលេខ ១៩ ចុះខែ មីនា ឆ្នាំ ២០០៣ និងប្រកាសលេខ ២០០ ចុះខែ វិច្ឆិកា ឆ្នាំ ២០០៣ ប៉ុន្តែឯកសារទាំងនេះពិពណ៌នាលម្អិតពីដំណើរការសម្រាប់ការបែងចែកដីដែលត្រូវបានកំណត់ជាស្រេចជាដីឯកជនរបស់រដ្ឋ និងមិនផ្តល់ព័ត៌មានលម្អិតស្តីពីដំណើរការធ្វើអត្តសញ្ញាណកម្មដី ឬការធានាសុវត្ថិភាពសម្រាប់ម្ចាស់ ឬអ្នកប្រើប្រាស់ដីមានស្រាប់នោះទេ។

55. សិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការកាន់កាប់ដីជាសមូហភាពត្រូវបានចែងក្នុងច្បាប់ភូមិបាលឆ្នាំ ២០០១។ ច្បាប់ស្តីពីព្រៃឈើ ( ២០០២ ) ទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការប្រើប្រាស់ធនធានព្រៃឈើ។ នីតិវិធីសម្រាប់ការរៀបចំប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់ជនជាតិដើមភាគតិច ត្រូវបានកំណត់តាមផ្លូវច្បាប់ដោយឧបករណ៍ខាងក្រោម ៖

- អនុក្រឹត្យលេខ ៨៣ ( ២០០៩ ) ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច
- ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សារាចរអន្តរក្រសួងស្តីពីវិធានការការពារបណ្តោះអាសន្នដែលការពារដីរបស់ជនជាតិដើមភាគតិច ( ២០១១ )
- សេចក្តីណែនាំលេខ ១៥ ចុះថ្ងៃទី ៤ ខែ កក្កដា ឆ្នាំ ២០១២ និងសេចក្តីណែនាំលេខ ១៧ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១២ ស្តីពីការអនុវត្តបន្ថែមទៀតនូវការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីជនជាតិដើមភាគតិច និងសហគមន៍
- សៀវភៅណែនាំស្តីពីការកំណត់អត្តសញ្ញាណ ការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា ( ខែ ធ្នូ ឆ្នាំ ២០១៨ ) ដែលបោះពុម្ពផ្សាយដោយក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រោមជំនួយរបស់ UN-OHCHR។

## ៤. ការវិភាគចំណុចខ្វះខាតរវាងបទដ្ឋានបរិស្ថាន និងសង្គមទី ៥ របស់ធនាគារពិភពលោក និងនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញរបស់រាជរដ្ឋាភិបាលកម្ពុជា

56. បទដ្ឋានបរិស្ថាន និងសង្គមទី ៥ របស់ធនាគារពិភពលោកទទួលស្គាល់ថា លទ្ធកម្មដីធ្លីដែលពាក់ព័ន្ធនឹងគម្រោង និងការរឹតត្បិតលើការប្រើប្រាស់ដី អាចជះផលអវិជ្ជមានលើសហគមន៍ និងបុគ្គលម្នាក់ៗ។ បទដ្ឋាននេះ និងនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញរបស់រាជរដ្ឋាភិបាលកម្ពុជា សុទ្ធតែគ្របដណ្តប់លើគោលបំណង និងគោលការណ៍នៃលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត ហើយគោលការណ៍របស់ឧបករណ៍ទាំងពីរនេះគឺដូចគ្នាភាគច្រើន។ ដូច្នេះ គ្មានចំណុចខ្វះខាតច្រើនរវាងគោលនយោបាយទាំងពីរនេះទេ មានតែចំណុចខ្វះខាតដ៏ធំមួយពាក់ព័ន្ធនឹងការផ្តល់អំណោយដោយស្ម័គ្រចិត្ត និងការបញ្ជាក់អះអាងតិចតួចមួយចំនួនតូច ដូចមានបង្ហាញក្នុងតារាង ១ក និង ១ខ ខាងក្រោម[7]។

**តារាង ១ក ៖ ខ្លឹមសារសង្ខេបចំណុចខ្វះខាតសំខាន់ៗ និងការបញ្ជាក់រវាងនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញរបស់រាជរដ្ឋាភិបាលកម្ពុជា និងបទដ្ឋានបរិស្ថាន និងសង្គមទី ៥ របស់ធនាគារពិភពលោក**

| ផ្នែកដែលមានចំណុចខុសគ្នា | នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញរបស់រាជរដ្ឋាភិបាលកម្ពុជា | បទដ្ឋានបរិស្ថាន និងសង្គមទី ៥ របស់ធនាគារពិភពលោក | វិធានការលុបបំបាត់ភាពខុសគ្នា |
|---|---|---|---|
| ការផ្តល់អំណោយដោយស្ម័គ្រចិត្ត | • នីតិវិធីប្រតិបត្តិស្តង់ដារផ្តោតលើលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត ប៉ុន្តែមិនផ្តល់ការណែនាំស្តីពីការផ្តល់អំណោយដោយស្ម័គ្រចិត្តទេ។ | • បទដ្ឋានបរិស្ថាន និងសង្គមទី ៥ របស់ធនាគារពិភពលោកអាចអនុវត្តបានចំពោះករណីដែលជនដែលរងផលប៉ះពាល់សម្រេចផ្តល់អំណោយដី ឬទ្រព្យសម្បត្តិដោយស្ម័គ្រចិត្ត ដោយផ្អែកលើលក្ខខណ្ឌដែលបានកំណត់ក្នុងជើងទំព័រទី ១០ នៃបទដ្ឋាននេះ ៖ ក) អ្នកដែលអាចក្លាយជាម្ចាស់ជំនួយ ឬម្ចាស់ជំនួយទទួលបានព័ត៌មាន និងការពិគ្រោះយោបល់គ្រប់គ្រាន់ស្តីពីគម្រោង និងជម្រើសដែលមាន ខ) អ្នកដែលអាចក្លាយជាម្ចាស់ជំនួយបានដឹងពីជម្រើសបដិសេធ និងបានបញ្ជាក់ជាលាយលក្ខណ៍អក្សរនូវឆន្ទៈរបស់ខ្លួនក្នុងការផ្តល់អំណោយ គ) ទំហំដីដែលត្រូវបានផ្តល់អំណោយគឺតិចតួច ហើយនឹងមិនកាត់បន្ថយទំហំដីនៅសល់របស់ម្ចាស់ជំនួយ ក្រោមទំហំ | ក្របខណ្ឌដោះស្រាយផលប៉ះពាល់ផ្តល់ការណែនាំដែលស៊ីសង្វាក់គ្នានឹងបទដ្ឋានបរិស្ថាន និងសង្គមទី ៥ ស្តីពីពេលវេលាសមស្របនៃការផ្តល់អំណោយដោយស្ម័គ្រចិត្ត និងដំណើរការផ្តល់អំណោយ រួមទាំងការចងក្រងឯកសារដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវយកទៅអនុវត្ត។ |

[7] ការវិភាគចំណុចខ្វះខាតនេះស៊ីសង្វាក់គ្នានឹងការវិភាគចំណុចខ្វះខាតក្នុងក្របខណ្ឌដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងតភ្ជាប់ផ្លូវថ្នល់នៅកម្ពុជា ដែលធនាគារពិភពលោកធ្លាប់ឯកភាពកន្លងមក។

| | | | |
|---|---|---|---|
| | | ចាំបាច់ដើម្បីរក្សារបរចិញ្ចឹមជីវិតរបស់ម្ចាស់ជំនួយនៅកម្រិតបច្ចុប្បន្ន ឃ) មិនពាក់ព័ន្ធនឹងការផ្លាស់ទីតាំងគ្រួសារ ង) ម្ចាស់ជំនួយត្រូវបានរំពឹងថានឹងទទួលបានប្រយោជន៍ផ្ទាល់ពីគម្រោង និង ច) សម្រាប់ដីសហគមន៍ ឬដីសមូហភាព ការផ្តល់អំណោយអាចធ្វើឡើងបានដោយមានការយល់ព្រមរបស់បុគ្គលដែលប្រើប្រាស់ ឬកាន់កាប់ដីនោះ។ | |

| តារាង ១២ ៖ ខ្លឹមសារសង្ខេបការបញ្ជាក់រវាងនីតិវិធីប្រតិបត្តិស្តង់ដាររបស់រាជរដ្ឋាភិបាលកម្ពុជា និងបទដ្ឋានបរិស្ថាន និងសង្គមទី ៥ របស់ធនាគារពិភពលោក | | | |
|---|---|---|---|
| **ផ្នែកសម្រាប់ការបញ្ជាក់** | **នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញរបស់រាជរដ្ឋាភិបាលកម្ពុជា** | **បទដ្ឋានបរិស្ថាន និងសង្គមទី ៥ របស់ធនាគារពិភពលោក** | **ការបញ្ជាក់** |
| ការស្តាររបរចិញ្ចឹមជីវិតឡើងវិញ និងជំនួយ | • នីតិវិធីប្រតិបត្តិស្តង់ដារលម្អិតពីវិធានការដាក់លាក់ក្នុងការស្តាររបរចិញ្ចឹមជីវិតឡើងវិញ ដែលផ្អែកតាមដីធ្លី ការងារ និងអាជីវកម្ម។ | ការផ្តល់ការស្តាររបរចិញ្ចឹមជីវិតឡើងវិញ និងជំនួយដើម្បីសម្រេចបានគោលបំណងក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៥ របស់ធនាគារពិភពលោកដើម្បីជួយដល់ជនបាត់បង់ទីលំនៅក្នុងការកែលម្អ ឬយ៉ាងហោចណាស់ស្តាររបរចិញ្ចឹមជីវិត និងកម្រិតជីវភាពរបស់ពួកគេឡើងវិញ។ | • ផ្អែកលើនីតិវិធីប្រតិបត្តិស្តង់ដារកម្មវិធីស្តារចំណូលឡើងវិញនឹងត្រូវបានផ្តល់ជូនដើម្បីបង្កើតប្រភពរបរចិញ្ចឹមជីវិតឡើងវិញរបស់ជនដែលរងផលប៉ះពាល់ដែលបាត់បង់ប្រភពរបរចិញ្ចឹមជីវិតរបស់ខ្លួនជាអចិន្ត្រៃយ៍។ ប្រសិនបើអាចអនុវត្តបានក្នុងគម្រោងដំណាក់កាលទី ៣ Dផែនការដោះស្រាយផលប៉ះពាល់ នឹងរួមបញ្ចូលបទប្បញ្ញត្តិនានាដើម្បីធានាថា កម្មវិធីស្តាររបរចិញ្ចឹមជីវិតឡើងវិញមានភាពគត់មត់ និងអាចបំពេញបានយ៉ាងត្រឹមត្រូវតាមគោលបំណងស្តាររបរចិញ្ចឹមជីវិតឡើងវិញដែលស្របតាមបទដ្ឋានបរិស្ថាន និងសង្គមទី ៥ របស់ធនាគារពិភពលោក។ |
| យន្តការដោះស្រាយបណ្តឹងតវ៉ា | • ឧបសម្ព័ន្ធ ៨ នៃនីតិវិធីប្រតិបត្តិស្តង់ដារមានរចនា | • ឧបសម្ព័ន្ធ ១ នៃបទដ្ឋានបរិស្ថាន និងសង្គមទី ១០ រួមមានខ្លឹមសារ | • នីតិវិធីប្រតិបត្តិស្តង់ដារចែងថា នឹងមានការពិគ្រោះយោបល់ |

| | | | |
|---|---|---|---|
| | សម្ព័ន្ធ និងព័ត៌មានលម្អិតស្តីពីគោលការណ៍ណែនាំប្រតិបត្តិ និងនីតិវិធីនៃការដំណើរការយន្តការដោះស្រាយបណ្តឹងតវ៉ាដោយប្រសិទ្ធភាព និងដំណើរការ ៣ ជំហាន ដែលរួមមានការចុះបញ្ជី និងការកត់ត្រាបណ្តឹង និងដំណើរការតុលាការប្រសិនបើបណ្តឹងនៅតែមិនត្រូវបានដោះស្រាយនៅកម្រិតរដ្ឋបាល។ នីតិវិធីលម្អិតសម្រាប់ជំហានទីមួយៗ ក៏មានរៀបរាប់ក្នុងនីតិវិធីប្រតិបត្តិស្តង់ដារផងដែរ។ | លម្អិតស្តីពីដំណើរការរដ្ឋបាល និងតុលាការស្តីពីយន្តការដោះស្រាយបណ្តឹងតវ៉ាដើម្បីដោះស្រាយបណ្តឹងតវ៉ា/សាទុក្ខស្របតាមបទដ្ឋានបរិស្ថាន និងសង្គមនេះ។ ការចូលរួមការរៀបចំផែនការដោះស្រាយផលប៉ះពាល់ និងការអនុវត្ត រួមទាំងការបង្កើតយន្តការដោះស្រាយបណ្តឹងតវ៉ាសមស្របដែលមានអត្ថប្រយោជន៍ និងងាយស្រួលប្រើប្រាស់សម្រាប់ប្រជាជនមូលដ្ឋាន។ | ជាមួយជនដែលរងផលប៉ះពាល់នៅដំណាក់កាលផ្សេងៗ ដូចជាក្នុងអំឡុងពេលរៀបចំ B ផែនការដោះស្រាយផលប៉ះពាល់ និង Dផែនការដោះស្រាយផលប៉ះពាល់។ មុនរៀបចំ Dផែនការដោះស្រាយផលប៉ះពាល់ នឹងមានការពិគ្រោះយោបល់ដើម្បីបញ្ជាក់ពីលក្ខណៈវិនិច្ឆ័យនៃលក្ខណៈសម្បត្តិ និងពិភាក្សាពីតារាងសិទ្ធិទទួលបាន និងបង្ហាញពីយន្តការដោះស្រាយបណ្តឹងតវ៉ា។ក្រៅពីនេះ សំណៅឯកសារគោលការណ៍ណែនាំសម្រាប់យន្តការនេះត្រូវបានបកប្រែជាភាសាខ្មែរ និងត្រូវបានផ្តល់ជូន និងពន្យល់លម្អិតដល់ជនដែលរងផលប៉ះពាល់ក្នុងដំណើរការពិគ្រោះយោបល់។ មានយន្តការច្បាស់លាស់សម្រាប់ដោះស្រាយបណ្តឹងតវ៉ាក្នុងនីតិវិធីប្រតិបត្តិស្តង់ដារ។<br>• ខណៈដែលយន្តការទាំងនេះត្រូវបានកំណត់ឡើងយ៉ាងច្បាស់ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់នឹងធានាថា យន្តការនេះងាយស្រួលប្រើប្រាស់សម្រាប់ជនដែលរងផលប៉ះពាល់ទាំងអស់ ជនរងផលប៉ះពាល់ដែលងាយរងគ្រោះ និងស្ត្រី។ |
| ការពិគ្រោះយោបល់ និងការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ | • នីតិវិធីប្រតិបត្តិស្តង់ដារលម្អិតពីចំនួនជំហានក្នុងការអនុវត្តការពិគ្រោះយោបល់នៅដំណាក់កាលផ្សេងៗនៃដំណើរការលទ្ធកម្មដីធ្លី និងការតាំងទី | • បទដ្ឋានបរិស្ថាន និងសង្គមទី ១ តម្រូវឱ្យមានការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធជាមួយអ្នករងផលប៉ះពាល់ និងអ្នកមានចំណាប់អារម្មណ៍ក្នុងវដ្តគម្រោង ស្របតាមផែនការជំរុញការចូលរួមរបស់អ្នក | • ការពិគ្រោះយោបល់ប្រកបដោយអត្ថន័យដែលមានកំណត់ក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ១០ របស់ធនាគារពិភពលោក គួរត្រូវបានធ្វើឡើង ដោយផ្តោតការយកចិត្ត |

| | | | |
|---|---|---|---|
| | លំនៅឡើងវិញ និងការផ្តល់សំណង។<br>• កថាខណ្ឌ ១២៦ លើកឡើងថា ការពិគ្រោះយោបល់ត្រូវបានធ្វើឡើងក្នុងវដ្តគម្រោង។<br>• នីតិវិធីប្រតិបត្តិស្តង់ដារកំណត់ពីការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត។<br>• នីតិវិធីប្រតិបត្តិស្តង់ដារចែងពីការផ្សព្វផ្សាយក្របខណ្ឌដោះស្រាយផលប៉ះពាល់ដល់អ្នកពាក់ព័ន្ធ និងសាធារណជន មុនពេលអនុម័តគម្រោង។ ទន្ទឹមនឹងនេះ Dផែនការដោះស្រាយផលប៉ះពាល់ ត្រូវបានផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ និងសាធារណជនក្រោយការអនុម័តដោយដៃគូអភិវឌ្ឍន៍។ | ពាក់ព័ន្ធរបស់គម្រោងរួមទាំងការពិគ្រោះយោបល់ជាបន្តបន្ទាប់ និងការផ្សព្វផ្សាយពីឯកសារ។ | ទុកដាក់លើការធានាបាននូវដំណើរការមាន ២ វិធី ដែលអាចឱ្យមានការផ្តល់យោបល់ត្រឡប់ពីជនដែលរងផលប៉ះពាល់ ហើយពួកគេទទួលបានព័ត៌មានពីរបៀបដាក់បញ្ចូលយោបល់ត្រឡប់របស់ខ្លួន។ |

## ៥. ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល៖ គោលបំណង គោលការណ៍ និងវិធីសាស្ត្រកាត់បន្ថយលទ្ធកម្មដីធ្លី

### ៥.១ គោលបំណង

57. ដោយសារតែការជ្រើសរើសឃុំអ្នកទទួលផលសម្រាប់សម្បទានដីសង្គមកិច្ច និងសហគមន៍ជនជាតិដើមភាគតិចសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច នឹងផ្អែកតាម "តម្រូវការ" គេនឹងអាចដឹងពីទីតាំងរបស់ឃុំទាំងនោះ និងផលប៉ះពាល់នៃលទ្ធកម្មដីធ្លីដែលអាចកើតឡើងដោយសារសកម្មភាពផ្តល់ប័ណ្ណកម្មសិទ្ធិ ឬសកម្មភាពហេដ្ឋារចនាសម្ព័ន្ធក្នុងពេលអនុវត្តគម្រោង។ ដូច្នេះ ចាំបាច់ត្រូវមានក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ ដែលត្រូវបានរៀបចំឡើងក្រោមការណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការគ្រប់គ្រង និងកាត់បន្ថយផលប៉ះពាល់នៃលទ្ធកម្មដីធ្លីដែលបណ្តាលមកពីសកម្មភាពគម្រោងនៅតាមទីតាំងសម្បទានដីសង្គមកិច្ច ឬទីតាំងការផ្តល់ប័ណ្ណកម្មសិទ្ធិដីស

មូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ផ្អែកតាមក្របខណ្ឌនេះ បន្ទាប់ពីបានកំណត់អត្តសញ្ញាណទីតាំងសម្បទានដីសង្គមកិច្ច ឬ ទីតាំងផ្តល់បណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ហើយការពិនិត្យបឋមបានបញ្ជាក់ពីពីផលប៉ះពាល់អវិជ្ជមានដែលអាចកើតឡើងដោយសារលទ្ធកម្មដីធ្លី ផែនការដោះស្រាយផលប៉ះពាល់នឹងត្រូវបានរៀបចំឡើងក្រោមការពិគ្រោះយោបល់ជាគត់មត់ជាមួយអ្នកពាក់ព័ន្ធ និងធនាគារពិភពលោក។ សកម្មភាពគម្រោងដែលនឹងធ្វើឱ្យមានការខាតបង់អត្ថប្រយោជន៍ផ្នែករូបវន្ត និង/ឬសេដ្ឋកិច្ច នឹងអាចអនុវត្តទៅបានលុះត្រាតែបានបញ្ចប់ផែនការខាងលើ និងត្រូវបានអនុម័តដោយធនាគារពិភពលោក។

58. គោលបំណងនៃក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់គឺជាគោលបំណងក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៥ និងស៊ីសង្វាក់គ្នានឹងគោលបំណងដែលបានកំណត់ក្នុងកថាខណ្ឌ ២៦ នៃអនុក្រឹត្យលេខ ២២ និងនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ ៖

- ដើម្បី បញ្ចៀសលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត ឬនៅពេលដែលមិនអាចបញ្ចៀសបាន កាត់បន្ថយលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្តតាមរយៈការរិះរកជម្រើសផ្សេងទៀតសម្រាប់ការរៀបចំគម្រោង
- ដើម្បីបញ្ចៀសការជម្លៀសចេញដោយបង្ខំ
- ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានផ្នែកសង្គម និងសេដ្ឋកិច្ចដែលមិនអាចបញ្ចៀសបានដោយសារលទ្ធកម្មដីធ្លី ឬការរឹតត្បិតការប្រើប្រាស់ដី តាមរយៈ ១) ការផ្តល់សំណងទាន់ពេលវេលាសម្រាប់ការបាត់បង់ទ្រព្យសម្បត្តិទៅតាមតម្លៃជំនួស និង ២) ការជួយដល់ជនបាត់បង់ទីលំនៅដើម្បីបង្កើន ឬយ៉ាងហោចណាស់ស្តាររបរចិញ្ចឹមជីវិត និងកម្រិតជីវភាពរបស់ពួកគេឡើងវិញ ឱ្យដល់កម្រិតមុនពេលជម្លៀសចេញ ឬត្រឹមកម្រិតទូទៅមុនពេលចាប់ផ្តើមការអនុវត្តគម្រោង ៖ យកកម្រិតមួយណាដែលល្អប្រសើរជាង
- ដើម្បីបង្កើនស្ថានភាពរស់នៅរបស់ជនក្រីក្រ ឬងាយរងគ្រោះដែលទទួលរងការខាតបង់ផ្នែករូបវន្តតាមរយៈការផ្តល់លំនៅដ្ឋានគ្រប់គ្រាន់ លទ្ធភាពទទួលបានសេវា និងហេដ្ឋារចនាសម្ព័ន្ធ និងសន្តិសុខសិទ្ធិកាន់កាប់
- ដើម្បីប៉ាន់ប្រមាណ និងអនុវត្តសកម្មភាពតាំងទីលំនៅឡើងវិញក្នុងទម្រង់ជាកម្មវិធីអភិវឌ្ឍន៍ដែលមាននិរន្តរភាពដែលផ្តល់ធនធានវិនិយោគ ដើម្បីធ្វើយ៉ាងណាឱ្យជនបាត់បង់ទីលំនៅអាចទទួលបានអត្ថប្រយោជន៍ផ្ទាល់ពីគម្រោង ទៅតាមលក្ខណៈជាក់លាក់របស់គម្រោង និង
- ដើម្បីធានាថា សកម្មភាពតាំងទីលំនៅឡើងវិញត្រូវបានគ្រោងឡើង និងអនុវត្តដោយមានការផ្សព្វផ្សាយព័ត៌មានសមស្រប ការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ និងការចូលរួមរបស់អ្នករងផលប៉ះពាល់ដោយផ្អែកតាមព័ត៌មានត្រឹមត្រូវ។

59. ផ្អែកតាមការអនុវត្តកន្លងមកក្នុងគម្រោងដំណាក់កាលដំបូង និងគម្រោងដំណាក់កាលទី ២ គម្រោងដំណាក់កាលទី ៣ នឹងបញ្ចៀសលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត ទៅតាមភាពអាចធ្វើបាន ដោយអនុវត្តវិធានការ ២ ដែលពាក់ព័ន្ធនឹងការធ្វើផែនទី និងការកំណត់ព្រំប្រទល់ទីតាំងសម្បទានដីស

ង្គមកិច្ច និងទីតាំងផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងការកំណត់ទីតាំងហេដ្ឋារចនាសម្ព័ន្ធ។ វិធានការទីមួយរួមមានការធ្វើអត្តសញ្ញាណកម្មដីធ្លីដែលស្ថិតក្រោមការប្រើប្រាស់ស្របច្បាប់ដោយឯកជន (រួមមានដីដែលកាន់កាប់ដោយឯកជនដោយគ្មានប័ណ្ណកម្មសិទ្ធិដីធ្លីផ្លូវការ) និងផាត់ចេញដីទាំងនោះពីតំបន់ទីតាំងសម្រាប់សម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ឬផាត់ចេញពីតំបន់ទីតាំងហេដ្ឋារចនាសម្ព័ន្ធសម្រាប់តំបន់សម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ វិធានការទីពីររួមមានកិច្ចព្រមព្រៀងស្តីពីការផ្តល់អំណោយដីដោយស្ម័គ្រចិត្ត ក្រោមការចរចារបស់គម្រោងជាមួយអ្នកប្រើប្រាស់ដី ដែលនឹងក្លាយជាអ្នកទទួលផលពីគម្រោង[8] ឱ្យតែកិច្ចព្រមព្រៀងទាំងនោះផ្អែកតាមការយល់ព្រមដោយផ្អែកតាមព័ត៌មានត្រឹមត្រូវ ធ្វើឱ្យអ្នកទទួលផលមានជីវភាពធូរជា និងមានការចងក្រងឯកសារច្បាស់លាស់ (មើលផ្នែក ៧.៣ ស្តីពីគោលការណ៍សម្រាប់ការផ្តល់អំណោយដីដោយស្ម័គ្រចិត្ត)។ ក្នុងករណីដែលមិនអាចអនុវត្តវិធានការណាមួយបាន និងចាំបាច់ត្រូវធ្វើលទ្ធកម្មដីធ្លីសម្រាប់ការអនុវត្តគម្រោង ផែនការដោះស្រាយផលប៉ះពាល់នឹងត្រូវបានរៀបចំឡើង និងអនុវត្តក្នុងក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់នេះ។

## ៥.២ ជន និងគ្រួសារដែលមានសិទ្ធទទួលបានអត្ថប្រយោជន៍

60. ខាងក្រោមនេះប្រភេទជន និងគ្រួសារដែលអាចចាត់ទុកថារងផលប៉ះពាល់ និងមានសិទ្ធិទទួលបានអត្ថប្រយោជន៍សម្រាប់គោលបំណងនៃលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ ៖

- ជន និងគ្រួសារដែលជាម្ចាស់ដីស្របច្បាប់ (ក្នុងអត្ថន័យនៃច្បាប់ភូមិបាល ២០០១ ដោយមិនគិតថាតើពួកគេមាន "ប្លង់រឹង" យ៉ាងអត់នោះទេ) និងជន និងគ្រួសារដែលដីធ្លីត្រូវបានដាក់បញ្ចូលក្នុងតំបន់សម្បទានដីសង្គមកិច្ច ឬទីតាំងផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ឬត្រូវបានធ្វើលទ្ធកម្មសម្រាប់ការសាងសង់ផ្លូវចេញចូល ឬហេដ្ឋារចនាសម្ព័ន្ធចាំបាច់ផ្សេងទៀតសម្រាប់ទីតាំងនោះ
- ជន ឬគ្រួសារដែលមិនមែនជាម្ចាស់ដីស្របច្បាប់ក្នុងអត្ថន័យនៃច្បាប់ភូមិបាល ២០០១ ប៉ុន្តែបានកាន់កាប់ដីនោះសម្រាប់រស់នៅ ធ្វើកសិកម្ម ឬគោលបំណងផ្សេងទៀត មុនកាលបរិច្ឆេទឱសានវាទសម្រាប់ការទាមទារដីក្នុងតំបន់សម្បទានដីសង្គមកិច្ច ឬតំបន់សម្រាប់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។
- ជន និងគ្រួសារដែលកំពុងជួលដី ដែលត្រូវបានដាក់បញ្ចូលក្នុងតំបន់សម្បទានដីសង្គមកិច្ច ឬតំបន់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ឬដែលត្រូវបានជួលជាកម្មករលើដីនោះ មិនចំពោះថា ដីនោះត្រូវបានកាន់កាប់ស្របច្បាប់ដោយអ្នកជួល ឬនិយោជក ឬយ៉ាងណានោះទេ។

---

[8] ឧ. សម្រាប់ការដោះដូរក្បាលដីមួយជាមួយក្បាលដីមួយផ្សេងទៀតក្នុងសម្បទានដីសង្គមកិច្ច ឬការរួមចំណែកផ្តល់ដីបន្តិចបន្តួចសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធដែលអ្នកប្រើប្រាស់ដីនឹងទទួលបានអត្ថប្រយោជន៍។

- ជន និងគ្រួសារដែលប្រកបរបរចិញ្ចឹមជីវិតទាំងស្រុង ឬមួយផ្នែកពីការប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួមលើដីដែលត្រូវបានដាក់បញ្ចូលក្នុងតំបន់សម្បទានដីសង្គមកិច្ច ឬតំបន់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ដូចជា វាលស្មៅសម្រាប់ឱ្យសត្វស៊ី ការប្រមូលអនុផលព្រៃឈើ អុស នេសាទ។ល។

## ៥.៣ វិធានការកាត់បន្ថយលទ្ធកម្មដីធ្លី និងស្ថានភាពដែលមិនអាចបញ្ចៀសលទ្ធកម្មដីធ្លីបាន

61. តាមគោលការណ៍ លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញក្នុងវិសាលភាពនៃបទដ្ឋានបរិស្ថាន និងសង្គមទី ៥ អាចបណ្តាលមកពីសកម្មភាពក្នុងគម្រោងជំណាក់កាលទី ៣ ក្រោមស្ថានភាពដូចខាងក្រោម ៖

ក. ដីដែលកាន់កាប់ គ្រប់គ្រង ឬប្រើប្រាស់ដោយឯកជន មិនថាស្របច្បាប់ ឬយ៉ាងណានោះទេ ត្រូវបានធ្វើចំណាត់ថ្នាក់ជាដីឯកជនរបស់រដ្ឋ និងត្រូវបានដាក់បញ្ចូលក្នុងតំបន់សម្រាប់សម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច

ខ. ដីសាធារណៈរបស់រដ្ឋដែលត្រូវបានប្រើប្រាស់សម្រាប់គោលបំណងធនធានទ្រព្យសម្បត្តិរួម ដូចជាសកម្មភាពចិញ្ចឹមជីវិតពីអនុផលព្រៃឈើ ត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញជាដីឯកជនរបស់រដ្ឋ និងត្រូវបានដាក់បញ្ចូលក្នុងតំបន់សម្រាប់សម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ គេរំពឹងថា ភាគច្រើននៃអ្នកដែលប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួមទាំងនេះ នៅពេលធនធាននោះគឺជាដីសាធារណៈរបស់រដ្ឋ នឹងបន្តធ្វើដូច្នេះក្នុងនាមជាអ្នកទទួលបានដីពីសម្បទានដីសង្គមកិច្ច ឬសមាជិកសហគមន៍សម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ប៉ុន្តែលទ្ធភាពប្រើប្រាស់មួយចំនួនប្រហែលជាត្រូវបានរឹតត្បិត ដូចជា អ្នកដែលមិនចង់ចូលរួមក្នុងសម្បទានដីសង្គមកិច្ច ឬអ្នកដែលមិនបំពេញលក្ខណៈវិនិច្ឆ័យនៃលក្ខណៈសម្បត្តិ ឬក្នុងករណីនៃការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច មិនមែនជាសមាជិករបស់សហគមន៍ជនជាតិដើមភាគតិច។

គ. ដីដែលកាន់កាប់ គ្រប់គ្រង ឬប្រើប្រាស់ដោយឯកជន មិនថាស្របច្បាប់ ឬយ៉ាងណានោះទេ ត្រូវការជាចាំបាច់សម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ។ ក្នុងករណីមួយចំនួន ចំណុចនេះអាចរួមបញ្ចូលដីដែលស្ថិតនៅក្រៅព្រំប្រទល់នៃសម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ដូចជាដីដែលត្រូវការជាចាំបាច់សម្រាប់ការសាងសង់ ឬការពង្រីកផ្លូវចេញចេញ ឬសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ។

62. ពាក់ព័ន្ធនឹងស្ថានភាព ក ខាងលើ ដំណើការធ្វើអត្តសញ្ញាណកម្មដីសម្រាប់សម្បទានដីសង្គមកិច្ច ការពិនិត្យបឋម ការធ្វើផែនទី និងផ្តល់ប័ណ្ណកម្មសិទ្ធិក្រោមគម្រោងជំណាក់កាលទី ៣ អាចផាត់ចេញដីដែលស្ថិតក្រោមការទាមទារដោយឯកជន។ គម្រោងជំណាក់កាលទី ៣ នឹងអនុវត្តតាមនីតិវិធីទាំងនេះ ហើយនឹងបន្តការអនុវត្តពីគម្រោងជំណាក់កាលដំបូង និងគម្រោងជំណាក់កាលទី ២ ដោយមានការចរចាជាមួយអ្នកទទួលផលពីគម្រោងដើម្បីរៀបចំកិច្ចព្រមព្រៀងដោយស្ម័គ្រចិត្ត ក្នុងការដោះដូរក្បាលដីរបស់ពួកគេ ជាមួយក្បាលដីក្នុង

សម្បទានដីសង្គមកិច្ច ដោយស្មើគ្នា ឬច្រើនជាង។ ក្នុងការធ្វើផែនទីសម្បទានដីសង្គមកិច្ច ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច នឹងផាត់ចេញដីកាន់កាប់ដោយឯកជនពីតំបន់ដែលស្នើឡើងសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ក្នុងករណីលើកលែង សមាជិករបស់ក្រុមជនជាតិដើមភាគតិចដែលកំពុងកាន់កាប់ដីដោយមានប័ណ្ណកម្មសិទ្ធិផ្ទាល់ខ្លួន ឬកាន់កាប់ គ្រប់គ្រង ឬប្រើប្រាស់ជាលក្ខណៈឯកជន ក្នុងតំបន់ដែលស្នើឡើងសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ប្រហែលជារើសយកជម្រើសចូលរួមដោយស្ម័គ្រចិត្តក្នុងការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីសមូហភាព ដោយអនុវត្តតាមការណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ មានតែក្នុងកាលៈទេសៈពិសេសបំផុតប៉ុណ្ណោះដែលមិនពាក់ព័ន្ធនឹងដីខាងលើ សម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនឹងមិនអាចអនុវត្តទៅបាន ទើបលទ្ធកម្មដីធ្លីតាមរយៈការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត ត្រូវបានប្រើប្រាស់ដើម្បីទទួលបានដីធ្លីសម្រាប់សម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច (ឧ. ប្រសិនបើច្រកផ្លូវចេញចូលតែមួយត្រូវឆ្លងកាត់ដីដែលកាន់កាប់ដោយឯកជន[9])។

63. ស្ថានភាព ខ ដែលពាក់ព័ន្ធនឹងផលប៉ះពាល់ដែលអាចកើតមានលើអ្នកប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួម អាចនឹងកើតឡើងដែរ ប៉ុន្តែគេមិនដឹងពីកម្រិត និងភាពធ្ងន់ធ្ងរនោះទេ ព្រោះបញ្ហានេះមិនទាន់បានសិក្សាក្រោមគម្រោងមុនៗ។ គម្រោងដំណាក់កាលទី ៣ នឹងរួមបញ្ចូលផ្នែកនេះក្នុងការពិនិត្យបឋមនៅទីតាំង ហើយនឹងធានាថា ភាគីរងផលប៉ះពាល់ដែលប្រឈមនឹងការខាតបង់ ទទួលបានសំណង (ឧ. តាមរយៈការដាក់បញ្ចូលជាអ្នកទទួលផលពីគម្រោង ឬតាមរយៈការផ្តល់លទ្ធភាពផ្សេងទៀតក្នុងការប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួមដែលមានតម្លៃស្មើ ឬតាមរយៈសំណង)។

64. ក្នុងករណីដែលដីក្នុងតំបន់ដែលស្នើឡើងសម្រាប់សម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចដែលគ្មានការកាន់កាប់ដោយស្របច្បាប់ ប៉ុន្តែកាន់កាប់ និងប្រើប្រាស់ដោយឯកជន នឹងមានការពិភាក្សាជាមួយអ្នកប្រើប្រាស់ដីដើម្បីស្វែងរកដំណោះស្រាយដែលបញ្ចៀសលទ្ធកម្មដីធ្លី។ ជម្រើសរួមមាន ៖

- ដីធ្លីពាក់ព័ន្ធត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញជាដីឯកជន និងត្រូវបានផាត់ចេញពីសម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។
- អ្នកប្រើប្រាស់ដីនោះ យល់ព្រមបោះបង់ដីជាថ្នូរនឹងការដាក់បញ្ចូលជាអ្នកទទួលបានដីក្នុងសម្បទានដីសង្គមកិច្ច ឬជាសមាជិករបស់សហគមន៍សម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។
- ការផ្តល់អំណោយដីបន្តិចបន្តួចដោយស្ម័គ្រចិត្តសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ ដែលអ្នកប្រើប្រាស់ដីនឹងទទួលបានអត្ថប្រយោជន៍ពីគម្រោង ហើយនឹងទទួលបានអត្ថប្រយោជន៍ផុលតែម្តង (មើលផ្នែក ៧.៣ ខាងក្រោម)។

[9] គ្មានឧទាហរណ៍នៃលទ្ធកម្មដីកាន់កាប់ដោយឯកជនក្រោមគម្រោងជំហានដំបូង ឬគម្រោងជំហានទី ២ ឡើយ។

65. ការផ្តល់សំណងដល់អ្នកប្រើប្រាស់ដីដែលគ្មានសិទ្ធិស្របច្បាប់ (ដូចជា អ្នកជួល និយោជិតធ្វើការលើដីធ្លីពាក់ព័ន្ធ និងអ្នកប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួម) តាមរយៈការដាក់បញ្ចូលជាអ្នកទទួលផលពីគម្រោង (ចំណុចទី ២ ក្នុងកថាខណ្ឌខាងលើ) នឹងធ្វើឡើងដោយស្ម័គ្រចិត្ត និងឆ្លងកាត់ការយល់ព្រមដោយផ្អែកតាមព័ត៌មានត្រឹមត្រូវពីអ្នកប្រើប្រាស់ដី។ អាចមានករណីដែលអ្នកប្រើប្រាស់ដីមិនទទួលយកជម្រើសនេះ និងអាចមានករណីដែលជម្រើសនេះមិនអាចអនុវត្តបាន ព្រោះអ្នកប្រើប្រាស់ដីមិនបំពេញលក្ខណៈវិនិច្ឆ័យនៃលក្ខណៈសម្បត្តិសម្រាប់ជាអ្នកទទួលបានដីពីសម្បទានដីសង្គមកិច្ច ឬដោយសារតែពួកគេមិនមែនជាសមាជិករបស់សហគមន៍ជនជាតិដើមភាគតិចសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ក្នុងករណីណាមួយខាងលើ លទ្ធកម្មដីធ្លីនឹងត្រូវបានចាត់ទុកជាការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត ហើយអ្នកប្រើប្រាស់ដីនឹងមានសិទ្ធិទទួលបានសំណង ស្របតាមបទដ្ឋានបរិស្ថាន និងសង្គមទី ១ និង ទី ៥។

66. ពាក់ព័ន្ធនឹងស្ថានភាព គ នឹងមានកិច្ចខិតខំប្រឹងប្រែងក្នុងដំណើរការរៀបចំផែនការសម្បទានដីសង្គមកិច្ចសម្រាប់គោលបំណងហេដ្ឋារចនាសម្ព័ន្ធក្នុងព្រំប្រទល់សម្បទានដីសង្គមកិច្ច[10]។ គម្រោងដំណាក់កាលទី ៣ នឹងធ្វើការជាមួយសហគមន៍ជនជាតិដើមភាគតិច ដើម្បីធ្វើយ៉ាងណាឱ្យមានដីទំនេរសមស្របក្នុងតំបន់ដែលគ្រោងឡើងសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ត្រូវបានកំណត់អត្តសញ្ញាណសម្រាប់អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ។ អាចមានការលើកលែងប្រសិនបើការសិក្សាសមិទ្ធិលទ្ធភាពបង្ហាញពីភាពចាំបាច់ក្នុងការផ្លាស់ទីតាំងហេដ្ឋារចនាសម្ព័ន្ធទៅឆ្ងាយពីការកំណត់ទីតាំង ដែលបានគ្រោង និងស្ថិតនៅលើដីដែលត្រូវបានបែងចែកសម្រាប់ការប្រើប្រាស់ជាលក្ខណៈឯកជន ឬក្នុងករណីដែលមិនអាចអនុវត្តបានក្នុងផ្នែកបច្ចេកទេស (ឧ. សម្រាប់ហេដ្ឋារចនាសម្ព័ន្ធជារាសាស្ត្រ) ដើម្បីផ្លាស់ប្តូរការកំណត់ទីតាំង និងបញ្ចៀសផលប៉ះពាល់លើដីដែលកាន់កាប គ្រប់គ្រង ឬប្រើប្រាស់ដោយឯកជន។ ក្នុងករណីទាំងនេះ គេរំពឹងថាបញ្ហានឹងអាចដោះស្រាយបានតាមរយៈការបែងចែកដីផ្សេងទៀតពីដីបម្រុងទុក ឬតាមរយៈការផ្តល់អំណោយដីដោយស្ម័គ្រចិត្ត។ ប្រសិនបើជម្រើសទាំងនេះមិនអាចអនុវត្តបាន លទ្ធកម្មដីធ្លីនឹងត្រូវបានចាត់ទុកជាការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត ហើយអ្នកប្រើប្រាស់ដីនឹងមានសិទ្ធិទទួលបានសំណងស្របតាមបទដ្ឋានបរិស្ថានទី ១ និង ទី ៥។

67. ករណីដែលងាយនឹងកើតឡើងគឺតម្រូវការលទ្ធកម្មដីធ្លីសម្រាប់ការសាងសង់ផ្លូវចេញចូល ឬហេដ្ឋារចនាសម្ព័ន្ធជារាសាស្ត្រនៅក្រៅព្រំប្រទល់តំបន់សម្បទានដីសង្គមកិច្ច ឬតំបន់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ទាំងផ្លូវចេញចូល និងហេដ្ឋារចនាសម្ព័ន្ធជារាសាស្ត្រអាចនឹងបង្កផលប៉ះពាល់តិចតួចលើលទ្ធកម្មដីធ្លី។ ខណៈដែលហេដ្ឋារចនាសម្ព័ន្ធជារាសាស្ត្រនឹងតម្រូវឱ្យមានការតម្រឹមតម្រង់ជាថ្មី ផ្លូវ

[10] តម្រូវការដីសម្រាប់ហេដ្ឋារចនាសម្ព័ន្ធក្រោមគម្រោងជំហានទី ៣ ប្រហែលជាមានទំហំធំជេងជាគម្រោងមុនៗ ដោយសារតែ ១) ក្នុងគម្រោងជំហានទី ៣ នឹងមានប្រភេទហេដ្ឋារចនាសម្ព័ន្ធផ្សេងៗជាច្រើន ដូចជា ផ្លូវចេញចូល (មានកងលូ ប្រព័ន្ធបង្ហូរទឹកពីចំហៀង។ល។) ប្រព័ន្ធជារាសាស្ត្រខ្នាតតូច អគារសិក្សា និងផ្ទះគ្រូ ប៉ុស្តិ៍សុខភាព មជ្ឈមណ្ឌលសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹក និងអនាម័យ និង ២) ហេដ្ឋារចនាសម្ព័ន្ធនឹងមានលក្ខណៈបន្សាំនឹងការប្រែប្រួលអាកាសធាតុ ពោលគឺផ្លូវត្រូវមានលើកប្រាំងទប់ និងសំណង់បង្ហូរទឹកចំហៀង និងកាត់។ ផ្លូវចេញចូលការដ្ឋាននឹងមានទទឹង ៣០ ម៉ែត្រ ចំណែកផ្លូវលំនៅដ្ឋាន និងផ្លូវចេញចូលមានទទឹង ២៤ ម៉ែត្រ (PAD, កថាខណ្ឌ ៣១-៣៤)។

ចេញចូលនឹងត្រូវបានសាងសង់ទាំងស្រុង ឬមួយផ្នែកធំលើគន្លងផ្លូវចាស់។ អ្នកប្រើប្រាស់ដីប្រហែលជាទទួលយកការបាត់បង់ដីធ្លីតិចតួចតាមរយៈការផ្តល់អំណោយដោយស្ម័គ្រចិត្ត ឬការផ្លាស់ទីតាំងក្នុងមូលដ្ឋានជាថ្នូរនឹងការកែលម្អ និងបង្កើនតម្លៃទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងការអភិវឌ្ឍ ( ឧ. ការកែលម្អផ្លូវចេញចូល )។

68. ស្ថានភាពដែលត្រូវមានលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញដោយស្ម័គ្រចិត្ត និងទាមទារឱ្យមានការរៀបចំផែនការដោះស្រាយផលប៉ះពាល់ រួមមាន ៖

ក. ទីតាំងដែលគ្រោងឡើងសម្រាប់សម្បទានដីសង្គមកិច្ច ឬទីតាំងសម្រាប់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច រួមបញ្ចូលដីដែលគ្មានកម្មសិទ្ធិស្របច្បាប់ ប៉ុន្តែត្រូវបានកាន់កាប់ និងប្រើប្រាស់មុនកាលបរិច្ឆេទឱសានវាទ ហើយអ្នកប្រើប្រាស់ដីមិនអាចទទួលបានសំណងគ្រប់គ្រាន់ តាមរយៈការដាក់បញ្ចូលពួកគេជាអ្នកទទួលបានដីពីសម្បទានដីសង្គមកិច្ច ឬសមាជិកសហគមន៍សម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។

ខ. ករណីដែលគ្មានផ្លូវចេញចូលទៅកាន់ទីតាំងសម្បទានដីសង្គមកិច្ច ឬទីតាំងផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ហើយទីតាំងនោះអាចដំណើរការបានលុះត្រាតែសាងផ្លូវចេញចូលកាត់ដីឯកជន ( ដែលមាន ឬគ្មានប្លង់រឹង )

គ. ករណីដែលផ្លូវចេញចូលអាចកែលម្អឱ្យមានស្តង់ដារគ្រប់គ្រាន់តែតាមរយៈការផ្លាស់ទីតាំង ឬកំទេចអគារនៅតាមដងផ្លូវ ( ឧ. ក្នុងតំបន់មានអគារច្រើន )។

ឃ. ករណីដែលការកំណត់ទីតាំងហេដ្ឋារចនាសម្ព័ន្ធជារាសាស្ត្រអាចអនុវត្តទៅបានក្នុងផ្នែកបច្ចេកទេសតែតាមរយៈការធ្វើលទ្ធកម្មដីដែលកាន់កាប់ គ្រប់គ្រង ឬប្រើប្រាស់ដោយឯកជន។

ង. ករណីដែលម្ចាស់ដីរងផលប៉ះពាល់គ្មានឆន្ទៈផ្តល់អំណោយដីដោយស្ម័គ្រចិត្តសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ មិនថានៅក្នុងឬក្រៅទីតាំងគ្រោងឡើងសម្រាប់សម្បទានដីសង្គមកិច្ចឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ឬយ៉ាងណានោះទេ។

69. ក្នុងករណីដែលមិនអាចបញ្ចៀសផលប៉ះពាល់អវិជ្ជមាននៃលទ្ធកម្មដីធ្លីដែលពាក់ព័ន្ធនឹងស្ថានភាពខាងលើបាន ផែនការដោះស្រាយផលប៉ះពាល់នឹងត្រូវបានរៀបចំឡើងដើម្បីគ្រប់គ្រង និងកាត់បន្ថយផលប៉ះពាល់នានា ដើម្បីធ្វើយ៉ាងណាឱ្យបុគ្គលគ្រប់រូបដែលរងផលប៉ះពាល់អវិជ្ជមានដោយសារគម្រោង អាចរក្សា ឬកែលម្អកម្រិតជីវភាពរបស់ខ្លួនឱ្យដូចមុនពេលមានគម្រោង។ ក្នុងករណីដែលដីធ្លីទាំងអស់ស្ថិតក្រោមការកាន់កាប់ គ្រប់គ្រង ឬប្រើប្រាស់ដោយឯកជន ( មិនថាស្របច្បាប់ ឬយ៉ាងណានោះទេ ) ដែលត្រូវកំណត់សម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចដែលអាចអនុវត្តបាន នឹងត្រូវបានផ្តល់អំណោយដោយស្ម័គ្រចិត្តដោយបុគ្គល/គ្រួសារ មិនចាំបាច់រៀបចំផែនការដោះស្រាយផលប៉ះពាល់លម្អិតឡើយ ប៉ុន្តែក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់នេះនឹងតម្រង់ទិសដំណើរការសម្រាប់ការវាយតម្លៃ និងចងក្រងឯកសារយ៉ាងគត់មត់ស្តីពីការផ្តល់អំណោយដោយស្ម័គ្រចិត្ត( ផ្នែក ៧.៣ ខាងក្រោម )។ ការចង

ក្រុងឯកសារនេះនឹងត្រូវបានដាក់បញ្ចូលជាឧបសម្ព័ន្ធក្នុងផែនការដោះស្រាយផលប៉ះពាល់ ឬជាឯកសារដាច់ដោយឡែក។

## ៦.កាលបរិច្ឆេទឱសានវាទសម្រាប់លក្ខណៈសម្បត្តិទទួលបានសំណង និងជំនួយ

### ៦.១ គោលការណ៍នៃកាលបរិច្ឆេទឱសានវាទ

70. កាលបរិច្ឆេទឱសានវាទសម្រាប់ការទាមទារដែលមានលក្ខណៈសម្បត្តិទទួលបានសំណង និងជំនួយពីផលប៉ះពាល់អវិជ្ជមានដោយសារលទ្ធកម្មដីធ្លី នឹងត្រូវបានប្រកាសជាសាធារណៈនៅដំណាក់កាលដំបូងនៃដំណើរការធ្វើអត្តសញ្ញាណកម្មដីធ្លី និងរៀបចំផែនការសម្រាប់អនុគម្រោងនីមួយៗក្នុងសម្បទានដីសង្គមកិច្ច ឬការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ដោយសារតែមានដំណើរការខុសគ្នាសម្រាប់ការបង្កើតសម្បទានដីសង្គមកិច្ច ឬការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និយមន័យកាលបរិច្ឆេទឱសានវាទសម្រាប់សម្បទានដីសង្គមកិច្ច និងការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចក៏ខុសគ្នាដែរ។ កាលបរិច្ឆេទឱសានវាទមួយនឹងត្រូវបានប្រើប្រាស់សម្រាប់សម្បទានដីសង្គមកិច្ច ឬការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចទាំងមូល និងដីដែលអាចត្រូវការជាចាំបាច់នៅក្រៅតំបន់សម្បទានដីសង្គមកិច្ច ឬតំបន់ផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចសម្រាប់ការផ្ដល់ ឬកែលម្អហេដ្ឋារចនាសម្ព័ន្ធ (ឧ. ផ្លូវចេញចូល)។ ប្រភេទដែលពាក់ព័ន្ធនឹងកាលបរិច្ឆេទឱសានវាទរួមមាន ដីសម្រាប់ហេដ្ឋារចនាសម្ព័ន្ធដែលស្ថិតនៅក្រៅសម្បទានដីសង្គមកិច្ច ឬការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច នឹងត្រូវបានបង្ហាញច្បាប់ក្នុងការប្រកាសជាសាធារណៈ និងផែនទីភ្ជាប់។ កាលបរិច្ឆេទឱសានវាទមានគោលបំណងជួយទប់ស្កាត់ការទន្ទ្រានកាន់កាប់ និងការទាមទារសំណងដោយជនឆ្លៀតឱកាស។ ក្នុងករណីលើកលែង ប្រហែលជាចាំបាច់ត្រូវប្រកាសកាលបរិច្ឆេទឱសានវាទបន្ទាប់បន្ថែមទៀត ប្រសិនបើត្រូវធ្វើលទ្ធកម្មដីធ្លីបន្ថែមទៀត។ ឧ. ប្រសិនបើត្រូវមានការកែប្រែហេដ្ឋារចនាសម្ព័ន្ធដែលស្នើឡើងក្នុងទីតាំងសម្បទានដីសង្គមកិច្ចទាំង ១៤ ដែល works បានចាប់ផ្ដើមក្នុងគម្រោងដំណាក់កាលទី ៣ និងក្នុងករណីដែលគម្រោងដំណាក់កាលទី ៣ នឹងទ្រទ្រង់ដល់ការបញ្ចប់សកម្មភាពអភិវឌ្ឍន៍។ វាអាចជាករណីពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍ជនជាតិដើមភាគតិច ៣០ ដែលបានបញ្ចប់ការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងក្នុងករណីដែលគម្រោងដំណាក់កាលទី ៣ នឹងទ្រទ្រង់ដល់សកម្មភាពអភិវឌ្ឍន៍ចាំបាច់។

71. ក្នុងគម្រោងវិនិយោគដែលទ្រទ្រង់ដោយធនាគារពិភពលោក ដែលតម្រូវឱ្យមានលទ្ធកម្មដីធ្លី កាលបរិច្ឆេទឱសានវាទតែងត្រូវបានកំណត់ដោយផ្អែកតាមជំរឿន ដែល ១) កំណត់អត្តសញ្ញាណបុគ្គល/គ្រួសារដែលរងផលប៉ះពាល់ដោយសារលទ្ធកម្មដីធ្លីក្នុងគម្រោង ២) បង្កើតបញ្ជីសារពើភ័ណ្ឌដី និងទ្រព្យសម្បត្តិដែលនឹងរងផលប៉ះពាល់ និង ៣) កំណត់អ្នកដែលនឹងមានលក្ខណៈសម្បត្តិទទួលបានសំណង និងជំនួយ។ ប៉ុន្តែកាលបរិច្ឆេទឱសានវាទសម្រាប់សម្បទានដីសង្គមកិច្ច និងការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច នឹងមិនត្រូវបានជំរុញដោយការកំណត់ពេលវេលាជំរឿងឡើយ (ដំណើរការអង្កេតវាស់វែងលម្អិត)

ដើម្បីកំណត់អត្តសញ្ញាណអ្នកដែលរងផលប៉ះពាល់ដោយសារលទ្ធកម្មដីធ្លីក្នុងគម្រោង។ សម្រាប់សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ការកំណត់ព្រំប្រទល់តំបន់ពាក់ព័ន្ធ និងការរៀបចំប្លង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តកើតចេញពីការជ្រើសរើសសហគមន៍អ្នកទទួលផលដោយផ្អែកតាមតម្រូវការ បូករួមនឹងការពង្រីកដំណើរការៀបចំផែនការដោយមានការចូលរួម។ ដូច្នេះ ការដឹងលឺក្នុងមូលដ្ឋានស្តីពីព្រំប្រទល់តំបន់សម្បទានដីសង្គមកិច្ច ឬតំបន់សម្រាប់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច គឺនៅយូរទៀត រហូតទាល់តែបានបញ្ចប់ និងអនុវត្តផ្លូវការលើការកំណត់ព្រំប្រទល់ចុងក្រោយ និងមុនពេលការធ្វើជំរឿនស្តីពីផលប៉ះពាល់នៃលទ្ធកម្មដីធ្លី។ ដូច្នេះ សម្រាប់សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ការកំណត់កាលបរិច្ឆេទឱសានភាពត្រូវពិចារណាពីការគ្រប់គ្រងហានិភ័យ និងការរក្សាតុល្យភាពហានិភ័យរវាងជម្រើសទាំងពីរ ៖ ការកំណត់ជាមុននូវកាលបរិច្ឆេទឱសានវាទ (និងអាចប៉ះពាល់ដល់មនុស្សមួយចំនួនដែលបានចូលមករស់នៅ ដាំដុះ ឬសាងសង់ប្រកបដោយសុចន្ទៈក្នុងតំបន់សម្បទានដីសង្គមកិច្ច/តំបន់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ក្រោយកាលបរិច្ឆេទឱសានវាទដំបូងនេះ) ឬការកំណត់កាលបរិច្ឆេទសម្រាប់ការធ្វើផែនទីតំបន់សម្បទានដីសង្គមកិច្ច ឬតំបន់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច (អាចក្នុងទម្រង់បឋម ឬត្រូវបានអនុម័តផ្លូវការ) ហើយការវាយតម្លៃ (ឬជំរឿន) លើផលប៉ះពាល់អាចធ្វើឡើង (ដែលនឹងទុកពេលវេលាយ៉ាងច្រើនសម្រាប់ការទន្ទ្រានកាន់កាប់ ព្រោះនឹងមានការដឹងលឺជាយូរណាស់មកហើយពីការរៀបចំសម្បទានដីសង្គមកិច្ច/ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច មុននឹងបញ្ចប់ការធ្វើផែនទីផ្ទៃដីបន្ថែម និងប្លង់ហេដ្ឋារចនាសម្ព័ន្ធ)។

## ៦.២ កាលបរិច្ឆេទឱសានវាទសម្រាប់សម្បទានដីសង្គមកិច្ច

72. កាលបរិច្ឆេទឱសានវាទសម្រាប់លក្ខណៈសម្បត្តិទាមទារសំណង និងជំនួយដែលពាក់ព័ន្ធនឹងលទ្ធកម្មដីធ្លីក្រោមសម្បទានដីសង្គមកិច្ច គឺជាកាលបរិច្ឆេទនៃការចេញសេចក្តីសម្រេចដោយអភិបាលខេត្តក្នុងការដំណើរការការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ពោលគឺពេលដែលដីដែលបានកំណត់អត្តសញ្ញាណសម្រាប់សម្បទានដីសង្គមកិច្ចត្រូវបានចុះបញ្ជីជាដីឯកជនរបស់រដ្ឋ (ជំហានទី ៤ ក្នុងខ្លឹមសារសង្ខេបស្តីពីដំណើរការសម្បទានដីសង្គមកិច្ចថ្នាក់ឃុំដែលមាន ១០ ជំហាន ៖ តារាង ២ ខាងក្រោម) និងត្រូវបានអនុម័តជាផ្លូវការសម្រាប់សម្បទានដីសង្គមកិច្ច។ កាលបរិច្ឆេទឱសានវាទនឹងអនុវត្តចំពោះដីដែលត្រូវបានស្នើឡើងសម្រាប់សម្បទានដីសង្គមកិច្ច និងសម្រាប់សម្បទានដីសង្គមកិច្ចដែលពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធដែលស្ថិតនៅក្រៅតំបន់សម្បទានដីសង្គមកិច្ច ដូចជាដីដែលត្រូវធ្វើលទ្ធកម្មសម្រាប់ផ្លូវចេញចូល ឬហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ[11]។ ដីនេះនឹងត្រូវបានកត់សម្គាល់ក្នុងផែនទីព្រាង ដែលនឹងបិទផ្សាយលើក្តារប្រកាសព័ត៌មានសាធារណៈក្នុងតំបន់សម្បទានដីសង្គមកិច្ច និងនៅជិតផ្លូវចេញចូល ឱ្យបានឆាប់បំផុត ក្រោយការប្រកាសដោយអភិបាលខេត្ត។ មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវបានជូនដំណឹងដើម្បីធានាថា គ្មានការទាមទារដីធ្លីតាមផ្លូវច្បាប់ក្រោយកាលបរិច្ឆេទឱសានវាទ។ ការប្រកាសនឹងជូនដំណឹងដល់ប្រជាជនថា ពួកគេអាចដាក់បណ្តឹងតវ៉ាពាក់ព័ន្ធ

[11] និយមន័យដីចំណីផ្លូវរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ៖ ផ្លូវជនបទគឺមានចម្ងាយ ១៥ ម៉ែត្រពីអ័ក្សផ្លូវ បើទោះបីជាចំណុចនេះមិនត្រូវបានលើកឡើងក្នុងនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញក្តី។

នឹងការកំណត់ព្រំប្រទល់តំបន់សម្បទានដីសង្គមកិច្ច និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ តាមរយៈយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងរយៈពេល ៣០ ថ្ងៃ។ ក្នុងអំឡុងពេលនេះ មន្ត្រីខេត្តនឹងមានវត្តមាននៅសាលាឃុំដើម្បីចុះបញ្ជីការទាមទារដីធ្លី។

73. គួរកត់សម្គាល់ថា ការកំណត់កាលបរិច្ឆេទឱសានវាទដូច្នេះគឺខុសគ្នាពីការកំណត់កាលបរិច្ឆេទឱសានវាទក្នុងគម្រោងដំណាក់កាលទី ២ ដែលត្រូវបានកំណត់ជាកាលបរិច្ឆេទរយៈពេល ២ ខែមុនកិច្ចប្រជុំផ្សព្វផ្សាយព័ត៌មានជាសាធារណៈលើកទីមួយស្តីពីសម្បទានដីសង្គមកិច្ច (ជំហានទី ១ ក្នុងខ្លឹមសារសង្ខេបស្តីពីដំណើរការសម្បទានដីសង្គមកិច្ចថ្នាក់ឃុំដែលមាន ១០ ជំហាន)។ សនិទានភាពសម្រាប់កាលបរិច្ឆេទឱសានវាទដែលកំណត់ទុកជាមុននេះ ដែលកំណត់មុនការចាប់ផ្តើមដំណើរការរៀបចំផែនការសម្បទានដីសង្គមកិច្ចជាក់ស្តែង (និងការដឹងលឺពីកាលបរិច្ឆេទនេះ) ដែលប៉ាន់ប្រមាណជាមុនដោយប្រសិទ្ធភាពនូវហានិភ័យនៃការឆ្លៀតឱកាសទន្ទ្រានកាន់កាប់ដើម្បីទទួលបានសំណងពីលទ្ធកម្មដីធ្លីក្រោមដំណើរការសម្បទានដីសង្គមកិច្ច។ ប៉ុន្តែការកំណត់កាលបរិច្ឆេទឱសានវាទជាមុន (រយៈពេល ២ ខែ) នឹងបង្កហានិភ័យនៅចន្លោះកាលបរិច្ឆេទឱសានវាទនេះ និងពេលធ្វើជំរឿង ដែលអាចមានការទិញដោយសុឆន្ទៈ និង/ឬការសាងសង់ទ្រព្យសម្បត្តិ ដែលអាចរងផលប៉ះពាល់អវិជ្ជមានដោយសារលទ្ធកម្មដីធ្លីដែលពាក់ព័ន្ធនឹងសម្បទានដីសង្គមកិច្ច ហើយដោយសារតែសកម្មភាពនេះកើតឡើងក្រោយ កាលបរិច្ឆេទឱសានវាទដែលកំណត់នៅពេលក្រោយ ប្រហែលជាមិនត្រូវបានទទួលស្គាល់ថាមានលក្ខណៈសម្បត្តិទទួលបានសំណងឡើយ។ ការកំណត់កាលបរិច្ឆេទឱសានវាទក្នុងគម្រោងដំណាក់កាលទី ៣ ជាកាលបរិច្ឆេទដែលដីដែលត្រូវបានកំណត់អត្តសញ្ញាណសម្រាប់សម្បទានដីសង្គមកិច្ចជាដីឯកជនរបស់រដ្ឋ ត្រូវបានរំពឹងថានឹងអាចដោះស្រាយហានិភ័យទាំងនេះបាន។

74. ដើម្បីកាត់បន្ថយការឆ្លៀតឱកាសទន្ទ្រានកាន់កាប់ក្នុងអំឡុងពេលមុនកាលបរិច្ឆេទឱសានវាទ ក្រុមប្រឹក្សាឃុំនឹងប្រើប្រាស់កំណត់ត្រាមានស្រាប់ស្តីពីការរស់នៅ និងការប្រើប្រាស់ដីក្នុងឃុំ ដើម្បីផ្តល់ទិន្នន័យដើមគ្រាស្តីពីការកាន់កាប់ដោយគ្មានការអនុញ្ញាតក្នុងតំបន់ដែលស្នើឡើងសម្រាប់សម្បទានដីសង្គមកិច្ច។ ព័ត៌មានទាំងនេះនឹងត្រូវបានផ្ទៀងផ្ទាត់ដោយក្រុមប្រឹក្សាឃុំ និងគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត និងតាមរយៈកិច្ចប្រជុំជាសាធារណៈក្នុងដំណើរការរៀបចំផែនការសម្បទានដីសង្គមកិច្ច។

75. ក្រោមជំនួយពីគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត និងក្រុមការងារថ្នាក់ស្រុក ក្រុមប្រឹក្សាឃុំ នឹងខិតខំធ្វើយ៉ាងណាឱ្យគណៈកម្មាធិការពាក់ព័ន្ធបានដឹងពីកាលបរិច្ឆេទឱសានវាទ និងផលវិបាកចំពោះពួកគេ។ វិធានការទាំងនេះអាចរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹម ១) ផ្ទាំងបដាសាធារណៈក្នុងសហគមន៍/ភូមិ) ២) កូនសៀវភៅព័ត៌មាន ៣) ការផ្តល់ព័ត៌មានដល់គ្រួសារពាក់ព័ន្ធ ការជំរុញការចូលរួមរបស់ក្រុមទ្រទ្រង់សហគមន៍ដើម្បីដើរតួនាទីក្នុងការផ្សព្វផ្សាយព័ត៌មាន និងការណែនាំបន្ថែម។

### ៦.៣ កាលបរិច្ឆេទឱសានវាទសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច

76. ដំណើរការធ្វើអត្តសញ្ញាណកម្មដីសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច[12] មិនរួមបញ្ចូលកាលបរិច្ឆេទឱសានវាទដាក់លាក់សម្រាប់ការទាមទារដីធ្លីចម្រូងចម្រាស់ឡើយ (មើលឧបសម្ព័ន្ធ ២ ដែលមានដ្យាក្រាមបង្ហាញពីដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច)។ ក្រោយជំហានទី ៣ ក្រោមដំណាក់កាល ២.៥ នៃដំណើរការនេះ (សហគមន៍ជនជាតិដើមភាគតិចដាក់ពាក្យសុំទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់) សុំប័ណ្ណកម្មសិទ្ធដីសហគមន៍) អភិបាលខេត្ត/ស្រុកនឹងចេញការជូនដំណឹងជាសាធារណៈក្នុងរយៈពេល ២០ ថ្ងៃមុនកាលបរិច្ឆេទនៃការចុះវាស់វែងដីផ្លូវការ (ដែលជាជំហានទី១ នៃដំណាក់កាលទី៣)។ បន្ទាប់ពីការធ្វើអត្តសញ្ញាណកម្ម និងការដោះស្រាយការទាមទារដីធ្លីរួច អភិបាលខេត្តនឹងចេញវិធានការការពារបណ្តោះអាសន្ន ដែលហាមឃាត់ប្រតិបត្តិការដីធ្លីគ្រប់ទម្រង់ក្នុងតំបន់ដែលស្នើឡើងសម្រាប់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។

77. ដើម្បីទប់ស្កាត់វិសាលភាពនៃការឆ្លៀតឱកាសទន្ទ្រានកាន់កាប់ក្រោយការធ្វើផែនទី និងការកំណត់ព្រំប្រទល់តំបន់ដែលស្នើឡើងសម្រាប់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ប៉ុន្តែមុនពេលចេញវិធានការការពារបណ្តោះអាសន្ន កាលបរិច្ឆេទឱសានវាទសម្រាប់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចក្រោមគម្រោងដំណាក់កាលទី ៣ គឺជាកាលបរិច្ឆេទដែលសហគមន៍ជនជាតិដើមភាគតិចបានធ្វើផែនទីបឋមនៃព្រំប្រទល់តំបន់ដែលស្នើឡើងសម្រាប់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច (ជំហានទី ២ នៃដំណាក់កាល ២.៥) និងបានដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ជំហានទី ៣ នៃដំណាក់កាល ២.៥)។ កាលបរិច្ឆេទឱសានវាទនឹងត្រូវបានប្រកាសជាសាធារណៈ (ឧ. ការជូនដំណឹងជាសាធារណៈបន្ទាប់ពីជំហានទី ៣ ក្នុងដំណាក់កាល ២.៥) ដូចជា តាមរយៈការជូនដំណឹងទៅមន្ទីររៀបចំដែនដី និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងតាមរយៈការបិទសេចក្តីជូនដំណឹងលើក្តារប្រកាសព័ត៌មាន ដោយមានផែនទីព្រាងនៃតំបន់ដែលស្នើឡើងសម្រាប់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ការប្រកាសនឹងជូនដំណឹងដល់ប្រជាជនថា ពួកគេអាចដាក់បណ្តឹងពាក់ព័ន្ធនឹងការកំណត់ព្រំប្រទល់តំបន់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច តាមរយៈយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងរយៈពេល ៣០ ថ្ងៃ។

78. កាលបរិច្ឆេទឱសានវាទសម្រាប់ដីធ្លីដែលអាចត្រូវការជាចាំបាច់សម្រាប់ធ្វើផ្លូវចេញចូលទីតាំងផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច គឺដូចគ្នានឹងកាលបរិច្ឆេទនៃការជូនដំណឹងជាសាធារណៈពីការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ដីធ្លីដែលរងផលប៉ះពាល់គឺដីដែលមានចម្ងាយ ១៥ ម៉ែត្រពីអ័ក្សផ្លូវចេញចូលដែលស្នើឡើង។ ព័ត៌មានទាំងនេះបូករួមនឹងផែនទីព្រាង នឹងត្រូវបានបិទផ្សាយលើក្តារប្រកាសព័ត៌មាននៅជិតផ្លូវនោះ។

---

[12] ការធ្វើអត្តសញ្ញាណកម្មសហគមន៍ជនជាតិដើមភាគតិច ការចុះបញ្ជីជានីតិបុគ្គល និងដំណើរការចុះបញ្ជីដីសមូហភាពនៅកម្ពុជា (២០២៨)

## ៦.៤ ដីធ្លីបន្ថែមដែលស្ថិតនៅក្រៅសម្បទានដីសង្គមកិច្ច ឬទីតាំងផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងចាំបាច់សម្រាប់ហេដ្ឋារចនាសម្ព័ន្ធ

79. ក្នុងករណីលើកលែង នៅពេលកំណត់បានភាពចាំបាច់នៃលទ្ធកម្មដីធ្លីសម្រាប់អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលមិនត្រូវបានព្យាករក្នុងអំឡុងពេលរៀបចំផែនការប្រើប្រាស់ដីធ្លី ឬស្ថិតនៅក្រៅព្រំប្រទល់នៃសម្បទានដីសង្គមកិច្ច ឬទីតាំងផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច អាចមានភាពចាំបាច់ក្នុងការប្រកាសកាលបរិច្ឆេទឱសានវាទបន្ថែមទៀតសម្រាប់ការទាមទារដីធ្លី ស្របតាមអនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងលំនៅឡើងវិញ។ ករណីដែលអាចកើតឡើងគឺផ្លូវដែលត្រូវបានស្នើឡើងដំបូងសម្រាប់ធ្វើជាច្រកចេញចូល ត្រូវបានផ្លាស់ប្តូរដោយសារតែការសិក្សាពីសមិទ្ធិលទ្ធភាពផ្នែកបច្ចេកទេស។ ក្រៅពីនេះ ការងារសាងសង់ធារាសាស្ត្រអាចនឹងប៉ះពាល់ដល់ដីធ្លីដែលស្ថិតនៅក្រៅព្រំប្រទល់សម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។

80. ក្នុងករណីនេះ កាលបរិច្ឆេទឱសានវាទសម្រាប់ការទាមទារដី គឺជាកាលបរិច្ឆេទនៃការប្រកាសជាសាធារណៈស្តីពីដំណើរដែលកំណត់អត្តសញ្ញាណជន/គ្រួសារដែលនឹងរងផលប៉ះពាល់ដោយសារលទ្ធកម្មដីធ្លី ហើយការប្រកាសនេះនឹងធ្វើឡើងឆាប់បំផុតបន្ទាប់ពីការកំណត់តម្រូវការដីធ្លីដោយការសិក្សាបច្ចេកទេស។ កាលបរិច្ឆេទឱសានវាទនឹងត្រូវបានប្រកាសដោយអភិបាលខេត្ត និងបិទផ្សាយលើក្តារប្រកាសព័ត៌មាន រួមជាមួយនឹងផែនទីដែលរៀបរាប់ពីផលប៉ះពាល់នៃលទ្ធកម្មដីធ្លីដែលស្ថិតនៅជិតផ្លូវ ឬហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតដែលត្រូវបានស្នើឡើង និងតាមរយៈការជូនដំណឹងរបស់មន្ទីររៀបចំដែនដី និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

# ៧.ដំណើរការរៀបចំផែនការសម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច

## ៧.១ ការធ្វើអត្តសញ្ញាណកម្មដីធ្លី ការផាត់ចេញដីឯកជន ការផ្តល់ដីសម្បទានដីសង្គមកិច្ចជាសំណង និងការវាយតម្លៃភាពចាំបាច់នៃលទ្ធកម្មដីធ្លីក្នុងក្របខណ្ឌរៀបចំផែនការសម្បទានដីសង្គមកិច្ច

តារាង ២ ៖ ខ្លឹមសារសង្ខេបស្តីពីជំហានទាំង ១០ ក្នុងដំណើរការផ្តល់សម្បទានដីសង្គមកិច្ចនៅថ្នាក់ឃុំ

| ជំហាន | ការពិពណ៌នា | លទ្ធផល |
|---|---|---|
| ១ | ផ្តួចផ្តើម និងពិនិត្យបឋមលើសម្បទានដីសង្គមកិច្ច | ក្រុមប្រឹក្សាឃុំដាក់ស្នើសម្បទានដីសង្គមកិច្ច (ការរៀបចំផែនទីព្រាង និងប្រវត្តិនៃការប្រើប្រាស់ដីធ្លី) |
| | | ការអនុញ្ញាតឱ្យអនុវត្ត |
| ២ | គ្រោងការសិក្សាផ្នែកបច្ចេកទេស | ផែនការការងារសម្រាប់ដំណើរការផ្តល់សម្បទានដីសង្គមកិច្ច |
| ៣ | ការកសាងការយល់ដឹងដោយក្រុមប្រឹក្សាឃុំ | ប្រជាពលរដ្ឋមូលដ្ឋានយល់ពីសម្បទានដីសង្គមកិច្ច |
| | | មធ្យោបាយជ្រើសរើសអ្នកដែលត្រូវទទួលបានដីធ្លី ត្រូវបានសម្រេចយក |
| | | ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងអ្នកកាន់កាប់ដីធ្លីដោយខុសច្បាប់ |
| ៤ | កិច្ចប្រជុំស្តីពីដីរដ្ឋ | ធ្វើបច្ចុប្បន្នភាពផែនទីព្រាង ធៀបនឹងដីកម្មសិទ្ធិបុគ្គល និងដីសមូហភាព |
| | | ការគូសផែនទីសម្បទានដីសង្គមកិច្ចចុងក្រោយ ដោយអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ៖ នេះជាមូលដ្ឋានសម្រាប់កាលបរិច្ឆេទឱសានវាទ។ |
| | | កំណត់រកច្រកចេញចូល និងកំណត់ថាតើចាំបាច់ត្រូវមានលទ្ធកម្មដីធ្លីសម្រាប់ការសាងសង់/ការកែលម្អផ្លូវចេញចូល ឬទេ។ |
| | | ប៉ាន់ប្រមាណផលប៉ះពាល់លើអ្នកប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួម ដូចជាវាលស្មៅចិញ្ចឹមសត្វ អុស អនុផលព្រៃឈើនៅលើទីតាំងដីសម្បទានដីសង្គមកិច្ច។ ជានានូវ ១) លទ្ធភាពទទួលបានជម្រើសសមមូល ២) ការរួមបញ្ចូលអ្នកប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួមជាអ្នកទទួលផលពីសម្បទានដីសង្គមកិច្ច ឬ ៣) ការរៀបចំការផ្តល់សំណងសមស្រប។ |
| | | ការពិនិត្យឡើងវិញលើលទ្ធកម្មដីធ្លី និងផលប៉ះពាល់នៃការតាំងទីលំនៅថ្មីដោយស្ម័គ្រចិត្ត |

ជំហានទី ៣, ៤ និង ៥ អនុវត្តក្នុងពេលតែមួយ

| | | |
|---|---|---|
| | | ក្នុងករណីមានការកំណត់ថាត្រូវមានលទ្ធកម្មដីធ្លី អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំ និងអនុវត្តផែនការដោះស្រាយផលប៉ះពាល់។ |
| | | ដីសម្រាប់សម្បទានដីសង្គមកិច្ចត្រូវបានចុះបញ្ជីជាដីឯកជនរបស់រដ្ឋ។ |
| ៥ | ការរៀបចំផែនការ និងការគូសផែនទីស្តីពីការប្រើប្រាស់ដីធ្លីតាមបែបជំរុញការចូលរួម | ការវិភាគកសិ-ប្រព័ន្ធអេកូឡូស៊ី |
| | | ការវាយតម្លៃតម្រូវការហេដ្ឋារចនាសម្ព័ន្ធ |
| | | ការធានាសុវត្ថិភាពសង្គម និងបរិស្ថាន |
| | | របាយការណ៍សម្បទានដីសង្គមកិច្ច |
| ៦ | ការពិនិត្យឡើងវិញលើរបាយការណ៍សម្បទានដីសង្គមកិច្ច | ការបែងចែកហេដ្ឋារចនាសម្ព័ន្ធ និងសេវានៅជនបទ |
| ៧ | ការជ្រើសរើសអ្នកដែលត្រូវទទួលបានដីធ្លី | តារាងពាក្យស្នើសុំអាទិភាព |
| | | តារាងពាក្យស្នើសុំបម្រុង |
| ៨ | ផែនការពេញលេញសម្រាប់សម្បទានដីសង្គមកិច្ច | ការចែកក្បាលដី |
| | | ផែនការពេញលេញសម្រាប់សម្បទានដីសង្គមកិច្ច ត្រូវបានអនុម័ត |
| ៩ | ការរៀបចំទីតាំង | ការកំណត់ព្រំប្រទល់ក្បាលដីក្នុងទីតាំងសម្បទានដីសង្គមកិច្ច |
| | | ការផ្គត់ផ្គង់ទឹកស្អាតនៅជនបទ |
| | | ការសម្អាតទីតាំង |
| | | ច្រកចេញចូល |
| | | ការផ្ទេរកម្មសិទ្ធិដីធ្លីជាផ្លូវការ |
| ១០ | ការតាំងទីលំនៅ និងការអភិវឌ្ឍជនបទ | ការតាំងទីលំនៅដោយទទួលបានជំនួយ |
| | | ហេដ្ឋារចនាសម្ព័ន្ធ និងសេវានៅជនបទ |
| | | សហគមន៍ដែលមាននិរន្តរភាព |

81. តារាង ២ សង្ខេបពីដំណើរការ ១០ ជំហានសម្រាប់ការរៀបចំ និងអនុវត្តសម្បទានដីសង្គមកិច្ចថ្នាក់ឃុំ។ តារាងនេះត្រូវបានរៀបចំឡើងវិញដោយផ្អែកតាមសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងសម្រាប់គម្រោងជំហានទី ៣ និងឆ្លុះបញ្ចាំងពីដំណើរការដែលមានកំណត់ក្នុងច្បាប់ និងអនុនីតិកម្ម។ គម្រោងដំណាក់កាលទី ៣ នឹងផ្តួចផ្តើមសកម្មភាពថ្មីៗនៅជំហានទី ៤ នៃដំណើរការនេះ ៖

- ការកំណត់ថាតើស្ថានភាពដែលបានកំណត់ក្នុងផ្នែក ៥.៣ ខាងលើ កថាខណ្ឌ ៦២ ក, ខ និង គ អនុវត្តចំពោះដីដែលមិនអាចផាត់ចេញពីតំបន់ដែលស្នើឡើងសម្រាប់សម្បទានដីសង្គមកិច្ច ឬទេ។
- ក្នុងករណីដែលមានការកំណត់ដូច្នេះ ការរៀបចំ និងអនុវត្តផែនការដោះស្រាយផលប៉ះពាល់ដោយអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

82. ដូចការលើកឡើងក្នុងផ្នែក ៥.៣ ខាងលើ ការអនុវត្តដំណើរការរៀបចំផែនការសម្បទានដីសង្គមកិច្ចក្នុងករណីភាគច្រើននឹងជួយបញ្ចៀសភាពចាំបាច់នៃលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត។ ក្រៅពីនេះ ដំណើរការនេះនឹងបំពេញតាមលក្ខខណ្ឌតម្រូវជាច្រើនក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៥ (ការពិគ្រោះយោបល់ជាមួយជនដែលរងផលប៉ះពាល់ដោយសារគម្រោង)។ សកម្មភាពសំខាន់ៗក្នុងជំហាននីមួយៗដើម្បីធានាសុវត្ថិភាពសិទ្ធិរបស់អ្នកប្រើប្រាស់ដី និងបញ្ចៀសលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ មានរៀបរាប់ក្នុងកថាខណ្ឌខាងក្រោម។

83. ជំហានទី ១ ៖ សំណើសម្បទានដីសង្គមកិច្ចត្រូវបានផ្តួចផ្តើមឡើងដោយក្រុមប្រឹក្សាឃុំ បន្ទាប់ពីកិច្ចប្រជុំជាមួយពលរដ្ឋក្នុងឃុំ។ ក្រុមប្រឹក្សាឃុំរៀបចំផែនទីព្រាងធម្មតាមួយ និងប្រវត្តិប្រើប្រាស់ដីនៅដំណាក់កាលនេះ។ អភិបាលខេត្តនឹងដឹកនាំកិច្ចប្រជុំរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តដើម្បីពិនិត្យឡើងវិញលើសំណើនេះ។ ផែនទីព្រាងត្រូវបានពិនិត្យឡើងវិញនៅដំណាក់កាលនេះ ហើយតំបន់ដែលគ្មានលក្ខណៈសម្បត្តិនឹងត្រូវបានដាក់បញ្ចូលក្នុងសម្បទានដីសង្គមកិច្ច ត្រូវបានផាត់ចេញ។ ក្រុមវាយតម្លៃនឹងចុះទៅកាន់ឃុំនោះដើម្បីកែសម្រួលផែនទីព្រាង។

84. ជំហានទី ៣ ៖ ក្រោមជំនួយពីគម្រោង ក្រុមប្រឹក្សាឃុំនឹងធ្វើយុទ្ធនាការផ្សព្វផ្សាយក្រោមគោលបំណង ២ ៖ ១) ធានាថា អ្នកដែលអាចនឹងមានលក្ខណៈសម្បត្តិទទួលបានដី បានដឹងពីដំណើរការនេះ និង ២) ធានាថា ម្ចាស់ដី និងអ្នកប្រើប្រាស់ដី បានដឹងពីសំណើសម្បទានដីសង្គមកិច្ច និងផលប៉ះពាល់ដែលអាចកើតឡើងចំពោះពួកគេ។ ក្នុងជំហាននេះ គ្រួសារក្រីក្រក្នុងឃុំត្រូវបានកំណត់អត្តសញ្ញាណដោយប្រើប្រាស់វិធីសាស្ត្រអត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់ក្រសួងផែនការ។ ក្រៅពីការកំណត់អត្តសញ្ញាណអ្នកដែលអាចក្លាយជាអ្នកទទួលបានដី ជំហាននេះនឹងកំណត់រកថាតើអ្នកដែលកំពុងកាន់កាប់ដីដោយខុសច្បាប់ អាចនឹងត្រូវបានចាត់ទុកជាគ្រួសារក្រីក្រ និងងាយរងគ្រោះ និងមានលក្ខណៈសម្បត្តិក្នុងការទទួលបានសំណង និងការទ្រទ្រង់បន្ថែម ប្រសិនបើពួកគេបាត់បង់ទីលំនៅដោយសារគម្រោង ទៅតាមលក្ខខណ្ឌតម្រូវក្នុងអនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងលំនៅឡើងវិញ ឬទេ។

85. ក្នុងដំណាក់ទី ៤ មានការអង្កេតលម្អិតលើតំបន់ដែលស្នើឡើងសម្រាប់សម្បទានដីសង្គមកិច្ច។ ការអង្កេតនេះគួរកំណត់អត្តសញ្ញាណដីដែលកាន់កាប់ និង/ឬប្រើប្រាស់ដោយឯកជនជាដីលំនៅដ្ឋាន ឬដីកសិកម្ម និងដីដែលកាន់កាប់ជាសមូហភាពដោយសហគមន៍ជនជាតិដើមភាគតិច។ ជាទូទៅ ដីទាំងអស់នេះ និងដីដែលត្រូវការជាចាំបាច់សម្រាប់គោលបំណងសាធារណៈ (ផ្លូវទឹក ដីដែលស្ថិតក្រោមការការពារបរិស្ថាន ទីតាំងបុរាណវត្ថុ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ) ត្រូវបានផាត់ចេញពីតំបន់សម្បទានដីសង្គមកិច្ច។ ព្រំប្រទល់ត្រូវបានកំណត់ចំណាំជាបណ្ដោះអាសន្នដោយលាយពណ៌ ឬបោះស្នឹងឈើនៅដំណាក់កាលនេះ។ ផែនទីព្រាងនៃទីតាំងសម្បទានដីសង្គមកិច្ច ដែលត្រូវបានធ្វើបច្ចុប្បន្នភាពក្រោយការអង្កេត បូករួមនឹងតារាងដីកាន់កាប់ជាលក្ខណៈបុគ្គល និងជាសមូហភាព ត្រូវបានបិទបង្ហាញនៅសាលាឃុំរយៈពេល ៣០ ថ្ងៃ។ ក្នុងអំឡុងពេលនេះ មន្ត្រីខេត្តនឹងមានវត្តមាននៅសាលាឃុំដើម្បីចុះបញ្ជីការទាមទារដី។ ការទាមទារត្រូវបានចុះបញ្ជី និងឆ្លងកាត់ការស៊ើបអង្កេតដោយមានជំនួយពីអង្គការមិនមែនរដ្ឋាភិបាល និងក្រុមសហគមន៍។ ក្រុមការងារថ្នាក់ស្រុករៀបចំរបាយការណ៍មួយ ហើយផែនទីព្រាងត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីឆ្លុះបញ្ចាំងពីការទាមទារស្របច្បាប់។

86. កាលបរិច្ឆេទឱសានវាទសម្រាប់ការទាមទារដីក្នុងតំបន់សម្បទានដីសង្គមកិច្ចគឺជាកាលបរិច្ឆេទនៃការផ្សព្វផ្សាយជាសាធារណៈនូវផែនទីព្រាងនៅសាលាឃុំ។

87. ក្នុងគម្រោងដំណាក់កាលទី ៣ ក្រៅពីនីតិវិធីដែលបានអនុវត្តក្នុងគម្រោងដំណាក់កាលដំបូង/គម្រោងដំណាក់កាលទី ២ ការអង្កេតផ្ទៃដីសម្រាប់សម្បទានដីសង្គមកិច្ច នឹងកំណត់អត្តសញ្ញាណអ្នកដែលអាចរងផលប៉ះពាល់ដោយសារលទ្ធកម្មដីធ្លីដែលមិនមែនជាម្ចាស់ដី ឬអ្នកកាន់កាប់ផ្ទាល់។ បុគ្គលក្នុងប្រភេទនេះអាចរួមមានអ្នកជួល និយោជិតនៅលើដី និងអ្នកប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួម (វាលស្មៅចិញ្ចឹមសត្វ អនុផលព្រៃឈើ នេសាទ។ល។)។ ប្រសិនបើអ្នកប្រើប្រាស់ដីក្នុងប្រភេទនេះត្រូវបានកំណត់អត្តសញ្ញាណ គម្រោងនឹងវាយតម្លៃកម្រិតផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានចំពោះពួកគេ ដោយសារសម្បទានដីសង្គមកិច្ច។ អ្នកប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួមប្រហែលជាទទួលបានសំណងតាមរយៈការធានាថា ១) ពួកគេអាចទទួលបានធនធានជាជម្រើសដែលសមមូល ២) ការដាក់បញ្ចូលជាអ្នកទទួលបានដីពីសម្បទានដីសង្គមកិច្ច ឬ ៣) សំណងសមស្រប។

88. បន្ទាប់ពីការរៀបចំរបាយការណ៍ស្ដីពីការទាមទារដីក្នុងតំបន់សម្បទានដីសង្គមកិច្ច ក្រុមមួយដែលត្រូវបានចាត់តាំងដោយប្រធានគម្រោងដំណាក់កាលទី ៣ និងរួមបញ្ចូលទីប្រឹក្សាគ្រប់គ្រងហានិភ័យសង្គម និងមន្ត្រីបង្គោលគ្រប់គ្រងហានិភ័យសង្គមរបស់ក្រសួងរៀបចំដែនដី នឹងពិនិត្យរបាយការណ៍នេះ រួចចុះត្រួតពិនិត្យតំបន់សម្បទានដីសង្គមកិច្ច។ ផ្អែកលើការពិនិត្យ និងការចុះពិនិត្យនេះ ក្រុមននឹងផ្ដល់អនុសាសន៍ដល់ប្រធានគម្រោងថាតើការអភិវឌ្ឍសម្បទានដីសង្គមកិច្ច លើផ្ទៃដីដែលស្នើឡើង នឹងបង្កជាស្ថានភាពដែលបានកំណត់ក្នុងផ្នែក ៥.៣ ខាងលើ កថាខណ្ឌ ៦២ ក, ខ និង គ ឬទេ។ ក្នុងស្ថានភាពណាមួយ ចាំបាច់ត្រូវមានការរៀបចំផែនការដោះស្រាយផលប៉ះពាល់។ ប្រសិនបើអាច ការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្តនឹងត្រូវបានបញ្ចៀសដោយផាត់ចេញក្បាលដីដែលអាចរងផលប៉ះពាល់ដោយសារសម្បទានដីសង្គមកិច្ច។

89. ក្នុងករណីដែលមានការកំណត់ថា ការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្តមានភាពចាំបាច់សម្រាប់ការអភិវឌ្ឍសម្បទានដីសង្គមកិច្ច ប្រធានគម្រោងនឹងស្នើឱ្យក្រសួងរៀបចំដែនដីធ្វើលិខិតទៅអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីស្នើឱ្យមានការរៀបចំ និងអនុវត្តផែនការដោះស្រាយផលប៉ះពាល់។ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងរៀបចំ និងអនុវត្តផែនការដោះស្រាយផលប៉ះពាល់ដែលរួមបញ្ចូលការផ្តល់សំណងស្របតាមក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់។ នីតិវិធីទាំងនេះមានរៀបរាប់ក្នុងផ្នែក ៩ ខាងលើ។

90. បន្ទាប់ពីដំណើរការនេះ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តនឹងដាក់សំណើជូនអភិបាលខេត្តសុំឱ្យអនុញ្ញាត ឬបដិសេធសម្បទានដីសង្គមកិច្ចដែលស្នើឡើង។ ប្រសិនបើមានសេចក្តីសម្រេចឱ្យអនុញ្ញាត នឹងមានការវាស់វែងយ៉ាងសុក្រឹតដោយអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្ររបស់ក្រសួងរៀបចំដែនដី។ ផែនទីព្រាងត្រូវបានធ្វើបច្ចុប្បន្នភាពបន្ថែមទៀត និងក្លាយជាផែនទីសម្បទានដីសង្គមកិច្ច។ ផែនទីនេះត្រូវបានបិទបង្ហាញរយៈពេល ៣០ ថ្ងៃនៅសាលាឃុំ។ ដូច្នេះមានឱកាសបន្ថែមទៀតដើម្បីដាក់ការទាមទារ។ លុះត្រាតែបានស៊ើបអង្កេតការទាមទារទាំងនេះ ទើបអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រចេញប័ណ្ណកម្មសិទ្ធិដីធ្លីជាដីឯកជនរបស់រដ្ឋ ដែលជាមូលដ្ឋានសម្រាប់ការបែងចែកដីក្នុងសម្បទានដីសង្គមកិច្ច។

91. ក្នុងជំហានទី ៥ មានការរៀបចំផែនការប្រើប្រាស់ដីដែលជំរុញការចូលរួម ដើម្បីរៀបចំផែនទីប្រើប្រាស់ដីក្នុងតំបន់សម្បទានដីសង្គមកិច្ច ដែលគូសបញ្ជាក់ពីដីលំនៅដ្ឋាន ដីកសិកម្ម និងដីដែលត្រូវបម្រុងទុកសម្រាប់គោលបំណងសាធារណៈ ដូចជា ហេដ្ឋារចនាសម្ព័ន្ធ ព្រៃសហគមន៍។ល។

92. ការពិនិត្យបន្ថែមទៀតលើការអនុលោមតាមលក្ខខណ្ឌតម្រូវក្នុងបទដ្ឋានបរិស្ថាន និងសង្គម ( ទី ១ និង ទី ៥ ) ត្រូវបានធ្វើឡើងនៅជំហានទី ៦។

93. ការកំណត់ព្រំប្រទល់ជាក់ស្តែងលើក្បាលដីក្នុងសម្បទានដីសង្គមកិច្ចដោយប្រើប្រាស់វត្ថុសម្គាល់ព្រំប្រទល់ត្រូវបានធ្វើឡើងនៅជំហានទី៩ មុនការផ្ទេរកម្មសិទ្ធិដីធ្លីផ្លូវការដល់អ្នកទទួលបានដី។

94. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក៏នឹងចាប់ផ្តើមឡើងផងដែរដោយមានសកម្មភាពអាទិភាពក្នុងជំហានទី ៩ និងបន្តជាមួយនឹងអនុគម្រោងរបរចិញ្ចឹមជីវិតក្នុងជំហានទី ១០។

## ៧.២ ការធ្វើអត្តសញ្ញាណកម្មដីធ្លី ការផាត់ចេញដីឯកជន និងការវាយតម្លៃភាពចាំបាច់នៃលទ្ធកម្មដីធ្លីក្នុងក្របខណ្ឌរៀបចំផែនការប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច

95. តារាង ៣ សង្ខេបពីជំហានក្នុងការធ្វើអត្តសញ្ញាណកម្ម និងចុះបញ្ជីដីធ្លីក្រោមដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច (សម្រាប់ខ្លឹមសារលម្អិត មើលឧបសម្ព័ន្ធ ២ ស្តីពីដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច)។ គម្រោងដំណាក់កាលទី៣

នឹងផ្តល់ការទ្រទ្រង់ដល់សហគមន៍ជនជាតិដើមភាគតិចដែលត្រូវបានទទួលស្គាល់ជាសហគមន៍ជនជាតិដើមភាគតិចដោយក្រសួងអភិវឌ្ឍន៍ជនបទ (ដំណាក់កាលទី ១) និងជានីតិបុគ្គលដោយក្រសួងមហាផ្ទៃ (ដំណាក់កាលទី ២)។ ដូច្នេះ គម្រោងដំណាក់កាលទី ៣ នឹងផ្តល់ការទ្រទ្រង់ពីដំណាក់កាល ២.៥ (ការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីធ្លីជាលើកដំបូងទៅក្រសួងរៀបចំដែនដី) ឬធ្វើអន្តរាគមន៍នៅដំណាក់កាលក្រោយទៀតនៃដំណើរការនេះ[13]។

| តារាង ៣ ៖ ជំហានក្នុងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច | | |
|---|---|---|
| ដំណាក់កាលទី | ការពិពណ៌នា | មតិយោបល់ |
| ១ | លទ្ធផលចុងក្រោយនៃសកម្មភាពក្នុងដំណាក់កាលទី ១ គឺក្រសួងអភិវឌ្ឍន៍ជនបទចេញវិញ្ញាបនបត្រអត្តសញ្ញាណដល់សហគមន៍ជនជាតិដើមភាគតិច | |
| ២ | លទ្ធកម្មចុងក្រោយនៃសកម្មភាពក្នុងដំណាក់កាលទី ២ គឺក្រសួងមហាផ្ទៃ ៖ ចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជាផ្លូវការជា "នីតិបុគ្គល" | |
| ២.៥ | **សហគមន៍ជនជាតិដើមភាគតិច ៖ ការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** | ការទ្រទ្រង់ពីគម្រោងដំណាក់កាលទី៣ នឹងចាប់ផ្តើមនៃជំហាននេះ ឬជំហានក្រោយ។ |
| ជំហានទី ១ | សហគមន៍ជនជាតិដើមភាគតិចបង្កើតវិធានផ្ទៃក្នុង ក្រោមការសម្របសម្រួលដោយអង្គការមិនមែនរដ្ឋាភិបាល (ព្រាងដោយក្រសួងមហាផ្ទៃ) | ការផ្តោតសំខាន់លើការយល់ព្រមដោយសេរី ជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវដែលពាក់ព័ន្ធនឹងផ្នែកកាត់ក្តីរបស់សហគមន៍ជនជាតិដើមភាគតិច |
| ជំហានទី ២ | ប្រមូលទិន្នន័យ និងផលិតផែនទីបឋមដោយកំណត់ប្រភេទព្រំប្រទល់ដែលចូលរួមដោយម្ចាស់ដីទាំងអស់។ | • ផែនទីព្រាងនៃតំបន់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចត្រូវបានរៀបចំឡើងតាមរយៈដំណើរការដែលចូលរួមដោយសមាជិកសហគមន៍ និងអ្នកភូមិជិតខាង។<br>• ការផ្តោតសំខាន់លើការយល់ព្រមដោយសេរីជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវដែលពាក់ព័ន្ធនឹងផ្នែកកាត់ក្តីរបស់សហគមន៍ជនជាតិដើមភាគតិច និងការពិគ្រោះយោបល់ជាមួយសហគមន៍ជនជាតិដើមភាគតិចជិតខាង។<br>• វាយតម្លៃទាំងក្នុងតំបន់ដែលស្នើឡើងសម្រាប់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និង |

[13] សម្រាប់ខ្លឹមសារលម្អិត មើលក្របខណ្ឌរៀបចំផែនការជនជាតិដើមភាគតិច ផ្នែក ៧.៣ តារាង ៣ ស្តីពីដំណាក់កាល ២.៥និងផ្នែក ៧.៥ តារាង ៤ ស្តីពីដំណាក់កាលទី ៣។

| | | |
|---|---|---|
| | | ក្នុងសហគមន៍ជនជាតិដើមភាគតិចជិតខាង (ប្រសិនបើមាន) ផលប៉ះពាល់ដែលអាចកើតឡើង ទៅតាមលក្ខខណ្ឌតម្រូវក្នុងក្របខណ្ឌការពារបេតិកភណ្ឌវប្បធម៌។ |
| ជំហានទី ៣ | សហគមន៍ជនជាតិដើមភាគតិចដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពទៅក្រសួងរៀបចំដែនដី។ | • រួមបញ្ចូលតារាងឈ្មោះសមាជិកសហគមន៍ទាំងអស់ និងស្នាមមេដៃ។ សហគមន៍ជនជាតិដើមភាគតិចដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពដោយមានផែនទីព្រាងដែលកំណត់កាលបរិច្ឆេទឱសានវាទ (មើលកថាខណ្ឌ ៧៨)។<br>• អភិបាលខេត្តចេញសេចក្តីជូនដំណឹងរយៈពេល ២០ ថ្ងៃមុនពេលធ្វើការវាស់វែងផ្លូវការ។ ចេញវិធានការការពារបណ្តោះអាសន្ន និងកំណត់កាលបរិច្ឆេទឱសានវាទ។ |
| ៣ | **ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៖ វាស់វែង ផ្សព្វផ្សាយព័ត៌មានជាសាធារណៈ បែងចែកប្រភេទដីឡើងវិញ និង ចេញប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច** | |
| ជំហានទី ១ | ការវាស់វែង និងការប្រមូលទិន្នន័យស្តីពីព្រំប្រទល់ដី ទៅតាមប្រភេទនៃការប្រើប្រាស់ ការកំណត់ព្រំប្រទល់ និងការកំណត់អត្តសញ្ញាណដីរដ្ឋ (នៅចំណុចនេះ ត្រូវផ្តោតសំខាន់លើការយល់ព្រមដោយសេរី ជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ)។ | ចូលរួមដោយក្រុមមន្ទីររៀបចំដែនដី និងអ្នកភូមិ និងអង្គការមិនមែនរដ្ឋាភិបាល |
| ជំហានទី ២ | ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈនូវឯកសារវាយតម្លៃដីធ្លី | ឯកសារត្រូវបានបិទបង្ហាញរយៈពេល ៣០ ថ្ងៃ មានបទប្បញ្ញត្តិសម្រាប់ការដាក់បណ្តឹងទៅក្រុមការងារបច្ចេកទេស ប៉ុន្តែដំណើរការមិនច្បាស់លាស់។ |
| ជំហានទី ៣ | ការរាយការណ៍ពីលទ្ធផលចេញពីការផ្សព្វផ្សាយឯកសារវាយតម្លៃដីធ្លី | ដឹងលឺពីចំនួន និងខ្លឹមសារនៃបណ្តឹងដែលពាក់ព័ន្ធនឹងការគូសផែនទីសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច |
| ជំហានទី ៤ | កិច្ចប្រជុំជាមួយ PSLC ដើម្បីសម្រេចយករបាយការណ៍ចេញពីលទ្ធផលនៃការផ្សព្វផ្សាយជាសាធារណៈស្តីពីការវាយតម្លៃដីធ្លី និងការស្នើឱ្យក្រសួងរៀបចំដែនដី ចេញប័ណ្ណកម្មសិទ្ធិដីដល់សហគមន៍ជនជាតិដើមភាគតិច | ជាទូទៅ ជំហាននេះចំណាយពេលយ៉ាងតិច ៦ ខែដើម្បីទទួលបានការឆ្លើយតបពីក្រសួងរៀបចំដែនដី។ ការណ៍នេះធ្វើឱ្យដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចអូសបន្លាយពេល។<br>**ការកំណត់ថាតើចាំបាច់ត្រូវមានផែនការដោះស្រាយផលប៉ះពាល់នឹងធ្វើឡើងនៅជំហាននេះ។ ក្នុងករណីត្រូវមានផែនការដោះស្រាយផលប៉ះពាល់ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងត្រូវបានស្នើឱ្យរៀបចំ និងអនុវត្តផែនការនេះ។**In case an |

| | | |
|---|---|---|
| ជំហានទី ៥ | ក្រសួងរៀបចំផែនដីផ្ញើលិខិតទៅក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសុំឱ្យមានការពិនិត្យ និងអនុម័តដីធ្លីពាក់ព័ន្ធ។ | គោលការណ៍ណែនាំសំដៅលើការធ្វើចំណាត់ថ្នាក់ដីធ្លីដោយក្រសួងបរិស្ថាន (តំបន់ការពារធម្មជាតិ) និងក្រសួងកសិកម្ម (ដីកសិកម្ម ព្រៃសហគមន៍ និងដីព្រៃ) |
| ជំហានទី ៦ | ក្រសួងរៀបចំផែនដីផ្ញើលិខិតទៅគណៈរដ្ឋមន្ត្រីដើម្បីស្នើឱ្យមានការបែងចែកប្រភេទដីធ្លីដែលត្រូវចុះបញ្ជីជាដីសមូហភាពឡើងវិញ ដោយផ្អែកតាមសេចក្តីសម្រេចរបស់ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម។ | |
| ជំហានទី ៧ | ចេញប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច | គួរកត់សម្គាល់ថា ដំណើរការមូលដ្ឋាននៃការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចមិនបានរួមបញ្ចូលដីបម្រុងទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធឡើយ។ |

96. តារាង ៣ សង្ខេបពីដំណើរការកំណត់សហគមន៍ជនជាតិដើមភាគតិចដែលបានចុះបញ្ជី និងការចេញប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ តារាងនេះផ្អែកលើបទប្បញ្ញត្តិ និងការអនុវត្តមានស្រាប់ក្នុងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ក្នុងគម្រោងដំណាក់កាលទី ៣ សកម្មភាពបន្ថែមខាងក្រោមនឹងត្រូវបានធ្វើឡើងនៅដំណាក់កាលទី ៣ ជំហានទី ៤ មុននឹងផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។

- ការកំណត់ថាតើស្ថានភាពដែលបានកំណត់ក្នុងផ្នែក ៥.៣ ខាងលើ កថាខណ្ឌ ៦២ ក, ខ និង គ អនុវត្តចំពោះដីដែលមិនអាចផាត់ចេញពីតំបន់ដែលស្នើឡើងសម្រាប់សម្បទានដីសង្គមកិច្ច ឬទេ។
- ក្នុងករណីដែលមានការកំណត់ដូច្នេះ ការរៀបចំ និងអនុវត្តផែនការដោះស្រាយផលប៉ះពាល់ដោយអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

97. ដំណើរការដែលមានសង្ខេបក្នុងតារាង ៣ មានលក្ខណៈបើកទូលាយ និងជំរុញការចូលរួម និងមានភាពគ្រប់គ្រាន់ក្នុងការធានាការកំណត់អត្តសញ្ញាណការទាមទារលើដីធ្លីដែលស្នើឡើងសម្រាប់សម្បទានដីសង្គមកិច្ច។ ក្នុងគោលការណ៍ណែនាំស្តីពីការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច មានការសន្មតជាមុនថា ដីដែលស្ថិតក្រោមការទាមទារតវ៉ា នឹងត្រូវបានផាត់ចេញពីប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ដូច្នេះ ប្រហែលជាគ្មានលទ្ធកម្មដីធ្លីដែលកាន់កាប់ដោយឯកជនតាមរយៈដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចទេ។

98. គោលការណ៍ណែនាំស្តីពីការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចមិនលើកឡើងច្បាស់ពីការប្រកាសកាលបរិច្ឆេទឱសានវាទសម្រាប់ការទាមទារលើដីដែលត្រូវបានស្នើឡើងសម្រាប់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ សម្រាប់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចដែលទ្រទ្រង់ដោយគម្រោងដំណាក់កាលទី ៣ កាលបរិច្ឆេទឱសាននឹងត្រូវបានកំណត់ជាកាលបរិច្ឆេទដែលសហគមន៍ជនជាតិដើមភាគតិចដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហ

គមន៍ជនជាតិដើមភាគតិច ជាមួយនឹងផែនទីព្រាងដែលកំណត់ពីព្រំប្រទល់ដីសហគមន៍ ទៅក្រសួងរៀបចំដែនដី (ជំហានទី ៣ នៃដំណាក់កាល ២.៥)។

99. ក្រោយការរៀបចំរបាយការណ៍ ស្តីពីការទាមទារដីក្នុងតំបន់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច (ដំណាក់កាលទី ៣ ជំហានទី ៤) ក្រុមការងារមួយដែលត្រូវបានចាត់តាំងដោយប្រធានគម្រោងដំណាក់កាលទី ៣ និងរួមបញ្ចូលទីប្រឹក្សាគ្រប់គ្រងហានិភ័យសង្គម និងមន្ត្រីបង្គោលគ្រប់គ្រងហានិភ័យសង្គមរបស់ក្រសួងរៀបចំដែនដី នឹងពិនិត្យរបាយការណ៍នេះរួចចុះត្រួតពិនិត្យតំបន់សម្បទានដីសង្គមកិច្ច។ ផ្អែកលើការពិនិត្យ និងការចុះពិនិត្យនេះ ក្រុមនឹងផ្តល់អនុសាសន៍ដល់ប្រធានគម្រោងថាតើមានបញ្ហាដីធ្លីពាក់ព័ន្ធនឹងតំបន់ដែលស្នើឡើងសម្រាប់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចផ្ទាល់ ឬការសាងសង់ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធដែលបានស្នើឡើង (ឧ.ផ្លូវចេញចូល) លើដីនោះដែលនឹងបង្កជាស្ថានភាពដែលបានកំណត់ក្នុងផ្នែក ៥.៣ ខាងលើ កថាខណ្ឌ ៦២ ក, ខ និង គ ឬទេ។ ក្នុងស្ថានភាពណាមួយ ចាំបាច់ត្រូវមានការរៀបចំផែនការដោះស្រាយផលប៉ះពាល់។

100. ក្នុងករណីដែលមានការកំណត់ថា ការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្តមានភាពចាំបាច់សម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ប្រធានគម្រោងនឹងស្នើឱ្យក្រសួងរៀបចំដែនដីផ្ញើលិខិតទៅអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីស្នើឱ្យមានការរៀបចំ និងអនុវត្តផែនការដោះស្រាយផលប៉ះពាល់។ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងរៀបចំ និងអនុវត្តផែនការដោះស្រាយផលប៉ះពាល់ដែលរួមបញ្ចូលការផ្តល់សំណងស្របតាមក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់។ នីតិវិធីទាំងនេះមានរៀបរាប់ក្នុងផ្នែក ៩ ខាងក្រោម។

## ៧.៣ ជនរងផលប៉ះពាល់ដែលត្រូវបានកំណត់អត្តសញ្ញាណក្រោយការបញ្ចប់ផែនការសម្បទានដីសង្គមកិច្ច ឬផែនការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច

101. អាចមានករណីដែលការធ្វើអត្តសញ្ញាណកម្មដីសម្រាប់សម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ឬដំណើរការរៀបចំផែនការមិនបានកំណត់អត្តសញ្ញាណជនដែលរងផលប៉ះពាល់ទាំងអស់។ ពួកគេអាចជាកសិករពនេចរណ៍ ដែលមិនបានដឹងពីដំណើរការសម្បទានដីសង្គមកិច្ច/ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ឬមិនបានរាយការណ៍ពីការទាមទារដីក្នុងពេលវាស់វែងដី និងការគូសផែនទីលម្អិត។ ការរៀបចំផែនការប្រើប្រាស់ដីក្នុងទីតាំងសម្បទានដីសង្គមកិច្ច/ទីតាំងផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច នឹងរួមបញ្ចូលដីបម្រុងទុកដែលអាចត្រូវបានបែងចែកក្នុងករណីទាំងនេះ។ គម្រោងនឹងសិក្សាពីរបៀបដែលជនរងផលប៉ះពាល់ក្នុងស្ថានភាពនេះអាចចូលរួម និងទទួលបានអត្ថប្រយោជន៍ពីអនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងរបរចិញ្ចឹមជីវិត។

102. ក្នុងករណីកើតឡើងម្តងម្កាល អាចមានតម្រូវការលទ្ធកម្មដីធ្លីតិចតួចសម្រាប់អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលមិនត្រូវបានកំណត់អត្តសញ្ញាណក្នុងដំណើរការរៀបចំផែនការប្រើប្រាស់ដី។ ចំណុចនេះអាចកើតឡើងក្នុងព្រំប្រទល់ទីតាំងសម្បទានដីសង្គមកិច្ច ឬទីតាំងផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ប្រសិនបើលក្ខណៈបច្ចេកទេសកំណត់ថា ត្រូវរើទីតាំងហេដ្ឋារចនាសម្ព័ន្ធទៅកន្លែងផ្សេងទៀតពីទីតាំងដែលបានគ្រោង ឬប្រសិនបើបានកំណត់តម្រូវការហេដ្ឋារចនាសម្ព័ន្ធបន្ថែមក្រោយបញ្ចប់ការរៀបចំផែនការប្រើប្រាស់ដី។ ករណីនេះអាចកើតឡើងនៅពេលមានតម្រូវការលទ្ធកម្មដីធ្លីនៅក្រៅព្រំប្រទល់សម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ដែលភាគច្រើនគឺដើម្បីធ្វើផ្លូវចេញចូល។ គន្លងផ្លូវចេញចូលសម្រាប់សម្បទានដីសង្គមកិច្ចនឹងត្រូវបានកំណត់អត្តសញ្ញាណជានិច្ចក្នុងដំណាក់កាលរៀបចំផែនការប្រើប្រាស់ដី ហើយក្នុងករណីភាគច្រើននឹងជាន់លើគន្លងផ្លូវចាស់ ប៉ុន្តែប្រហែលជាត្រូវការដីបន្ថែមដែលនៅជិតគន្លងផ្លូវចាស់សម្រាប់ការពង្រីក លើកប្រាំងជម្រាល និងប្រឡាយបង្ហូរទឹកពីចំហៀង ឬការសាងសង់សំណង់ប្រឡាយបង្ហូរទឹកតាមផ្លូវ។

103. ប្រសិនបើដីធ្លីពាក់ព័ន្ធជាដីសម្រាប់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ហើយជនរងផលប៉ះពាល់ ជាសមាជិករបស់សហគមន៍ជនជាតិដើមភាគតិច សហគមន៍នោះនឹងត្រូវខិតខំដោះស្រាយបញ្ហានោះជាមុនសិន ដោយផ្អែកតាមលក្ខន្តិកៈ និងវិធានផ្ទៃក្នុងរបស់ខ្លួន។ ក្នុងករណីនេះ គម្រោងនឹងផ្ទៀងផ្ទាត់ថា ដំណោះស្រាយដែលលើកឡើង អនុលោមតាមគោលការណ៍យុត្តិធម៌ និងសមធម៌។ ដីធ្លីដែលទទួលបានពីបុគ្គល ត្រូវស្ថិតក្រោមវិសាលភាពដែលបានអនុញ្ញាតក្នុងក្របខណ្ឌសម្រាប់ការផ្តល់អំណោយដីដោយស្ម័គ្រចិត្ត ( ផ្នែក ៧.៣ ខាងក្រោម ) ឬត្រូវផ្តល់សំណងតាមរយៈការផ្តល់ដីជាថ្នូរដែលមានតម្លៃស្មើគ្នា។

## ៧.៤ ក្របខណ្ឌសម្រាប់ការផ្តល់អំណោយដីដោយស្ម័គ្រចិត្ត

104. ដូចការរៀបរាប់ខាងលើក្នុងផ្នែក ៥.៣ និងផ្នែក ៧ នឹងមានកិច្ចខិតខំប្រឹងប្រែងរៀបចំ និងគ្រោងសម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ដើម្បីបញ្ចៀសលទ្ធកម្មដីធ្លី តាមដែលអាចធ្វើទៅបាន ពាក់ព័ន្ធនឹងការកំណត់ព្រំប្រទល់តំបន់សម្បទានដីសង្គមកិច្ច/តំបន់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធដែលស្ថិតនៅក្នុង និងក្រៅតំបន់សម្បទានដីសង្គមកិច្ច/តំបន់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ប្រភេទខុសៗគ្នានៃហេដ្ឋារចនាសម្ព័ន្ធ ដែលត្រូវសាងសង់ឡើងសម្រាប់ការអនុវត្តសម្បទានដីសង្គមកិច្ច/ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច មានវិសាលភាពតូច ដែលតម្រូវឱ្យមានដីធ្លីតិចតួចបំផុត និងត្រូវបានកំណត់អត្តសញ្ញាណតាមរយៈដំណើរការរៀបចំផែនការនៅមូលដ្ឋានដែលជំរុញការចូលរួម។

105. ក្នុងក្រោមដែលអាចអនុវត្តបាន ដីទាំងនោះនឹងទទួលបានតាមរយៈការផ្តល់អំណោយដោយស្ម័គ្រចិត្តក្រោមកាលៈទេសៈដែលបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

ក) អ្នកដែលអាចក្លាយជាម្ចាស់ជំនួយ ឬម្ចាស់ជំនួយទទួលបានព័ត៌មាន និងការពិគ្រោះយោបល់គ្រប់គ្រាន់ដោយមន្ទីររៀបចំដែនដីស្តីពីគម្រោង និងជម្រើសដែលមាន
ខ) អ្នកដែលអាចក្លាយជាម្ចាស់ជំនួយបានដឹងពីជម្រើសបដិសេធ (ករណីដែលដីអាចត្រូវបានដកហូត និងមានការផ្តល់សំណង) និងបានបញ្ជាក់ជាលាយលក្ខណ៍អក្សរនូវឆន្ទៈរបស់ខ្លួនក្នុងការផ្តល់អំណោយ
គ) ទំហំដីដែលត្រូវបានផ្តល់អំណោយគឺតិចតួច (តិចជាង១០% នៃទ្រព្យសម្បត្តិផលិតភាពដែលបាត់បង់) ហើយនឹងមិនកាត់បន្ថយទំហំដីនៅសល់របស់ម្ចាស់ជំនួយ ក្រោមទំហំចាំបាច់ដើម្បីរក្សាបរចិញ្ចឹមជីវិតរបស់ម្ចាស់ជំនួយនៅកម្រិតបច្ចុប្បន្ន
ឃ) មិនពាក់ព័ន្ធនឹងការផ្លាស់ទីតាំងគ្រួសារ
ង) ម្ចាស់ជំនួយត្រូវបានរំពឹងថានឹងទទួលបានប្រយោជន៍ផ្ទាល់ពីគម្រោង និង
ច) សម្រាប់ដីសហគមន៍ ឬដីសមូហភាព ការផ្តល់អំណោយអាចធ្វើឡើងបានដោយមានការយល់ព្រមរបស់បុគ្គលដែលប្រើប្រាស់ ឬកាន់កាប់ដីនោះ។
ឆ) មន្ទីររៀបចំដែនដីនឹងរក្សាទុកកំណត់ត្រាការពិគ្រោះយោបល់ និងកិច្ចព្រមព្រៀងទាំងអស់ប្រកបដោយតម្លាភាព។
ជ) អ្នកដែលយល់ថាទទួលរងផលប៉ះពាល់អវិជ្ជមានដោយសារការផ្តល់អំណោយដី នឹងមានសិទ្ធិដាក់បណ្តឹងតាមរយៈយន្តការដោះស្រាយបណ្តឹងតវ៉ារបស់គម្រោង។

106. កំណត់ត្រាដំណើរការដែលបានអនុវត្តកន្លងមក នឹងត្រូវបានរក្សាទុកសម្រាប់ការផ្តល់អំណោយដីដោយស្ម័គ្រចិត្តនីមួយៗ ហើយនឹងរួមបញ្ចូលចំណុចដូចខាងក្រោម ៖
ក) ការជូនដំណឹងដែលគូសបញ្ជាក់ពីទីតាំង និងទំហំដីដែលចង់បាន និងការប្រើប្រាស់សម្រាប់គោលបំណងគម្រោង ដោយមានការកត់ត្រាពីពេល និងកន្លែងផ្សព្វផ្សាយជាសាធារណៈ
ខ) កំណត់ត្រាស្តីពីការពិគ្រោះយោបល់ដែលបានធ្វើឡើង និងចំណុចដែលលើកមកពិភាក្សា
គ) ច្បាប់ចម្លងការពិនិត្យផ្ទៀងផ្ទាត់បញ្ជាក់ភាពត្រឹមត្រូវ ដែលបានធ្វើឡើងពាក់ព័ន្ធនឹងអ្នកដែលមានសិទ្ធិផ្តល់អំណោយទ្រព្យសម្បត្តិ និងការទាមទារនានា
ឃ) ច្បាប់ចម្លងសេចក្តីថ្លែងការណ៍ផ្លូវការពីការផ្តល់អំណោយដោយបង្កើតការយល់ព្រមដោយផ្អែកតាមព័ត៌មានត្រឹមត្រូវ ដូចការរៀបរាប់ខាងលើ និងចុះហត្ថលេខាដោយម្ចាស់ដី ឬអ្នកប្រើប្រាស់ដីម្នាក់ៗ
ង) ច្បាប់ចម្លងរាល់ឯកសារ ការចុះបញ្ជី ឬកំណត់ត្រាដែលបញ្ជាក់ពីការផ្ទេរដីធ្លីដោយស្របច្បាប់
ច) ផែនទីដែលបង្ហាញពីក្បាលដីនីមួយ។

107. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដែលជាស្ថាប័នដឹកនាំការអនុវត្តគម្រោង នឹងរក្សាទុកកំណត់ត្រាឯកសារសម្រាប់ក្បាលដីនីមួយៗដែលបានផ្តល់អំណោយ (មើលឧបសម្ព័ន្ធ ៣ ស្តីពីទម្រង់ផ្តល់អំណោយទ្រព្យសម្បត្តិដោយស្ម័គ្រចិត្ត)។ ឯកសារទាំងនេះនឹងផ្តល់ជូនធនាគារពិភពលោកសម្រាប់ការពិនិត្យឡើងវិញ និងការពិនិត្យឡើងវិញពាក់ព័ន្ធនឹងបណ្តឹងតវ៉ាដែលអាចលេចឡើង។

## ៨.ការរៀបចំផែនការដោះស្រាយផលប៉ះពាល់

### ៨.១ ក្របខណ្ឌសម្រាប់ផែនការដោះស្រាយផលប៉ះពាល់

108. សម្រាប់សម្បទានដីសង្គមកិច្ច ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ឬអនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដែលចាំបាច់ត្រូវមានលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ ដោយមិនស្ម័គ្រចិត្ត ផែនការដោះស្រាយផលប៉ះពាល់នឹងត្រូវបានរៀបចំឡើងដោយអនុលោមតាមលក្ខខណ្ឌតម្រូវនៃក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់នេះ។ ស្របតាមអនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ ផ្នែក ឃ មានការអនុម័តបទប្បញ្ញត្តិបន្ថែមដើម្បីធានាការអនុលោមពេញលេញតាមលក្ខខណ្ឌតម្រូវក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ១ និងទី ៥។ បទប្បញ្ញត្តិទាំងនេះទទួលបានពីការវិភាគចំណុចខ្វះខាតក្នុងផ្នែក ៤ ខាងលើ។ បទប្បញ្ញត្តិទាំងនេះត្រូវបានឆ្លុះបញ្ចាំងក្នុងការពិពណ៌នាពីដំណើរការខាងក្រោម និងមានសង្ខេបក្នុងឧបសម្ព័ន្ធ ១។ ក្នុងផ្នែកទី ៤ កិច្ចព្រមព្រៀងហិរញ្ញប្បទានក្នុងគម្រោងដំណាក់កាលទី ៣ នឹងផ្អែកតាមក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ដែលអនុម័តដោយធនាគារពិភពលោក និងព្រមព្រៀងដោយរាជរដ្ឋាភិបាលកម្ពុជាជាឧបករណ៍ដែលអាចអនុវត្តបានសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញក្នុងគម្រោងនេះ។

109. ផែនការដោះស្រាយផលប៉ះពាល់នឹងត្រូវបានរៀបចំឡើង និងអនុវត្តដោយអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលដំណើរការតាមរយៈរចនាសម្ព័ន្ធស្ថាប័នដែលមានរៀបរាប់ក្នុងអនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ និងសង្ខេបក្នុងផ្នែកខាងក្រោម។ អគ្គនាយកដ្ឋាននេះនឹងសហការជាមួយស្ថាប័នអនុវត្តន៍គម្រោងដំណាក់កាលទី ៣ ដើម្បីធ្វើការផ្សព្វផ្សាយព័ត៌មាន និងការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ។

110. ការរៀបចំផែនការដោះស្រាយផលប៉ះពាល់នឹងត្រូវបានផ្តួចផ្តើមឡើងទៅតាមសំណើថ្នាក់ជាតិរបស់ក្រសួងរៀបចំដែនដី ដាក់ជូនអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់របស់ក្រសួងសេដ្ឋកិច្ច។ សំណើនេះនឹងមានទម្រង់ជាលិខិតផ្លូវការដែលភ្ជាប់ជាមួយផែនទីព្រាង និងខ្លឹមសារលម្អិតដូចខាងក្រោម ៖

- ទីតាំង និងទំហំដីដែលត្រូវធ្វើលទ្ធកម្ម
- គោលបំណងនៃលទ្ធកម្មដីធ្លី ដែលបង្ហាញថា លទ្ធកម្មដីធ្លីត្រូវការជាចាំបាច់ដោយសារតែសម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចពាក់ព័ន្ធមិនអាចអនុវត្តបាន
- ការប្រើប្រាស់ដី និងស្ថានភាពកាន់កាប់ដីបច្ចុប្បន្ន
- ចំនួនប៉ាន់ស្មាននៃអ្នកប្រើប្រាស់ដីដែលរងផលប៉ះពាល់ ធ្វើចំណាត់ថ្នាក់តាមប្រភេទ ដោយស៊ីសង្វាក់គ្នានឹងការបែងចែកជាប្រភេទដែលមានរៀបរាប់ខាងក្រោម និងរួមបញ្ចូលអ្នកដែលប្រើប្រាស់ដីសម្រាប់គោលបំណងនានា ដូចជា វាលស្មៅសម្រាប់សត្វស៊ី អនុផលព្រៃឈើ នេសាទ។ល។
- ក្របខណ្ឌពេលវេលាដែលស្នើឡើងសម្រាប់ការអនុវត្តសម្បទានដីសង្គមកិច្ច ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ឬអនុគម្រោង។

111. លិខិតស្នើសុំដាក់ជូនអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់នឹងត្រូវបានថតចម្លងសម្រាប់ផ្តល់ជូនធនាគារពិភពលោក។

112. បន្ទាប់ពីសំណើសុំឱ្យរៀបចំផែនការដោះស្រាយផលប៉ះពាល់ត្រូវបានទទួលយកដោយអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ នឹងមានការអនុវត្តតាមនីតិវិធីនៃក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់។ ផ្នែកខាងក្រោមនៃជំពូក ៨៨ នៃក្របខណ្ឌគោលនយោបាយនេះ ១) សង្ខេបពីបទប្បញ្ញត្តិសំខាន់ៗនៃអនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ និង ២)បទប្បញ្ញត្តិបន្ថែមដែលត្រូវអនុវត្តតាមដើម្បីធានាការអនុលោមតាមលក្ខខណ្ឌតម្រូវនៃបទដ្ឋានបរិស្ថាន និងសង្គមទី ១ និងទី ៥។

## ៨.២ ប្រភេទជនដែលរងផលប៉ះពាល់ និងលក្ខណៈសម្បត្តិទទួលបានសំណង

### តារាង ៤ ៖ សេចក្តីសង្ខេបប្រភេទជនដែលរងផលប៉ះពាល់

តារាង ៤ ៖ ប្រភេទជនដែលរងផលប៉ះពាល់

| ប្រភេទជន ឬក្រុមដែលរងផលប៉ះពាល់ | ការពិពណ៌នាសង្ខេប |
|---|---|
| ជនដែលរងផលប៉ះពាល់ | អ្នកដែលនឹងបាត់បង់ទ្រព្យសម្បត្តិរូបវន្ត និងមិនមែនរូបវន្តរបស់ខ្លួនទាំងស្រុង ឬដោយផ្នែក រួមមានផ្ទះសម្បែង ដីធ្លី អគារ/សំណង់ ទ្រព្យសម្បត្តិពាណិជ្ជកម្ម ដំណាំ ធនធាន ការជួល ការចិញ្ចឹមជីវិត ឱកាសរកប្រាក់ចំណូល សហគមន៍ និងបណ្តាញសង្គម និងវប្បធម។ ការបាត់បង់អាចមានលក្ខណៈបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍។ |
| ជន/ក្រុមក្រីក្រ និងងាយរងគ្រោះ | អ្នកដែលត្រូវបានសន្មតថាងាយរងគ្រោះជាអ្នកផ្សេងទៀត ដូចជា ១) គ្រួសារដែលមានតែម្តាយជាមេគ្រួសារក្រីក្រ និងរងផលប៉ះពាល់ មនុស្សចាស់ កុមារកំព្រា ជនពិការ។ល។ និង ២) ជនជាតិដើមភាគតិច។ ស្ត្រីត្រូវបានចាត់ទុកថាអាចមានតម្រូវការ និងសិទ្ធិជាក់លាក់ដែលត្រូវលើកមកពិភាក្សាក្នុងដំណើរការតាំងទីលំនៅឡើងវិញ។ |
| ជនជាតិដើមភាគតិច | អ្នកដែលមានកម្មសិទ្ធិដីធ្លីជាសមូហភាពបែបប្រពៃណីដែលផ្តល់ដោយរាជរដ្ឋាភិបាលកម្ពុជា និងមានលក្ខណៈវិនិច្ឆ័យ ៤ ក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ៧ ដែលកំណត់បានជាជនជាតិដើមភាគតិច។ |

113. ប្រភេទខាងក្រោមនៃជនដែលរងផលប៉ះពាល់ មានសិទ្ធិទទួលបានសំណងសម្រាប់ការបាត់បង់ទ្រព្យសម្បត្តិ និងជំនួយផ្សេងទៀតទៅតាមភាពចាំបាច់ដើម្បីជួយឱ្យពួកគេកែលម្អ ឬយ៉ាងហោចណាស់ស្តារកម្រិតជីវភាពឡើងវិញ ៖

- ជន និងគ្រួសារដែលជាម្ចាស់ដីស្របច្បាប់ (ក្នុងអត្ថន័យនៃច្បាប់ភូមិបាល ២០០១ ដោយមិនគិតថាតើពួកគេមាន "ប្លង់រឹង" ឬយ៉ាណានោះទេ) និងជន និងគ្រួសារដែលដីធ្លីត្រូវបានដាក់បញ្ចូលក្នុងតំបន់សម្បទានដីសង្គមកិច្ច ឬទីតាំងផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើម

ភាគតិច ឬត្រូវបានធ្វើលទ្ធកម្មសម្រាប់ការសាងសង់ផ្លូវចេញចូល ឬហេដ្ឋារចនាសម្ព័ន្ធចាំបាច់ផ្សេងទៀតសម្រាប់ទីតាំងនោះ

- ជន ឬគ្រួសារដែលមិនមែនជាម្ចាស់ដីស្របច្បាប់ក្នុងអត្ថន័យនៃច្បាប់ភូមិបាល ២០០១ ប៉ុន្តែបានកាន់កាប់ដីនោះសម្រាប់រស់នៅ ធ្វើកសិកម្ម ឬគោលបំណងផ្សេងទៀត មុនកាលបរិច្ឆេទឱសានវាទសម្រាប់ការទាមទារដីក្នុងតំបន់សម្បទានដីសង្គមកិច្ច ឬតំបន់សម្រាប់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។
- ជន និងគ្រួសារដែលកំពុងជួលដី ដែលត្រូវបានដាក់បញ្ចូលក្នុងតំបន់សម្បទានដីសង្គមកិច្ច ឬតំបន់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ឬដែលត្រូវបានជួលជាកម្មករលើដីនោះ មិនចំពោះថា ដីនោះត្រូវបានកាន់កាប់ស្របច្បាប់ដោយអ្នកជួល ឬនិយោជក ឬយ៉ាងណានោះទេ។
- ជន និងគ្រួសារដែលប្រកបរបរចិញ្ចឹមជីវិតទាំងស្រុង ឬមួយផ្នែកពីការប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួមលើដីដែលត្រូវបានដាក់បញ្ចូលក្នុងតំបន់សម្បទានដីសង្គមកិច្ច ឬតំបន់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ដូចជា វាលស្មៅសម្រាប់ឱ្យសត្វស៊ី ការប្រមូលអនុផលព្រៃឈើ អុស នេសាទ។ល។

114. ជនដែលរងផលប៉ះពាល់នឹងរួមបញ្ចូល ៖

- អ្នកដែលមានប័ណ្ណកម្មសិទ្ធិដីផ្លូវការ "ប្លង់រឹង"
- អ្នកដែលមាន "ប្លង់ទន់" ពោលគឺប្រភេទឯកសារដែលចេញដោយអាជ្ញាធរមូលដ្ឋាន ដែលទទួលស្គាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដីធ្លី និងមិនបញ្ជាក់ច្បាស់លាស់ថា ដីនោះនឹងត្រូវផ្លាស់ទីកន្លែងនៅពេលចាំបាច់សម្រាប់ប្រយោជន៍សាធារណៈនោះទេ
- បុគ្គលផ្សេងទៀតដែលអាចបង្ហាញការទាមទារដែលមានសុពលភាពលើការកាន់កាប់ ឬគ្រប់គ្រងដីស្របតាមច្បាប់ភូមិបាលឆ្នាំ ២០០១ និងបទប្បញ្ញត្តិផ្សេងទៀត
- បុគ្គលដែលកាន់កាប់/ជាអ្នកកាន់កាប់ខុសច្បាប់លើដីរដ្ឋមុនកាលបរិច្ឆេទឱសានវាទ។

115. អ្នកដែលរបរចិញ្ចឹមជីវិតមួយផ្នែកពឹងផ្អែកលើធនធានទ្រព្យសម្បត្តិរួម ដូចជា អនុផលព្រៃឈើ វាលស្មៅសម្រាប់សត្វស៊ី នេសាទ។ល។ នៅលើដីនោះ មានសិទ្ធិទទួលបានសំណងដោយសារការបាត់បង់របរចិញ្ចឹមជីវិតរបស់ខ្លួន។

116. បទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ កថាខណ្ឌ ១០៤ "គ្មានសំណងសម្រាប់អ្នករស់នៅបែបអាណាធិបតេយ្យលើដីចំណីផ្លូវមានស្រាប់" នឹងអនុវត្តតែក្នុងករណីណាមួយខាងក្រោម ៖

- មានការចងក្រងឯកសារថា អ្នកកាន់កាប់ត្រូវបានណែនាំឱ្យរើចេញពីដីចំណីផ្លូវ មុនកាលបរិច្ឆេទឱសានវាទ និងសម្រាប់មូលហេតុដែលមិនពាក់ព័ន្ធផ្ទាល់នឹងសកម្មភាពគម្រោងដែលស្នើឡើង និង

- ជនដែលរងផលប៉ះពាល់កំពុងប្រើប្រាស់ដីចំណីផ្លូវជាបណ្តោះអាសន្ន និង/ឬក្រោមការរឹតត្បិតស្របតាមកិច្ចព្រមព្រៀងដែលបានចងក្រងទុក ដែលចែងថា ពួកគេត្រូវរើចេញពីដីនោះប្រសិនបើជាការចាំបាច់សម្រាប់ប្រយោជន៍សាធារណៈ

## ៨.៣ មូលដ្ឋានសម្រាប់ការផ្តល់សំណង

117. សិទ្ធិទទួលបានសំណង និងជំនួយផ្សេងទៀតដែលអនុវត្តក្នុងគម្រោងដំណាក់កាលទី ៣ មានសង្ខេបក្នុងតារាង ៥ ខាងក្រោម ៖

| តារាង ៥ ៖ សិទ្ធិទទួលបានសំណង និងជំនួយ | | |
|---|---|---|
| **ប្រភេទនៃការបាត់បង់** | **ប្រភេទជនរងផលប៉ះពាល់ដែលមានលក្ខណៈសម្បត្តិ** | **មូលដ្ឋានសម្រាប់ការគណនាសំណង** |
| ដីធ្លី | ម្ចាស់ស្របច្បាប់ និងអ្នកកាន់កាប់ស្របច្បាប់ ផ្អែកតាមច្បាប់ភូមិបាល ២០០១ និងបទប្បញ្ញត្តិផ្សេងទៀតដោយមាន ឬគ្មាន "ប្លង់រឹង"<br><br>អ្នកដែលកាន់កាប់ ឬជាអ្នកកាន់កាប់ខុសច្បាប់លើដីរដ្ឋមុនកាលបរិច្ឆេទឱសានវាទ | តម្លៃជំនួសពេញលេញ (អាចខុសពីតម្លៃទីផ្សារក្នុងករណីមួយចំនួន) ឬ<br>ការជំនួសដីដែលមានតម្លៃសមមូល ដែលម្ចាស់ដីអាចទទួលយកបាន<br>គ្មានសំណងសម្រាប់ការបាត់បង់ដី ប៉ុន្តែផ្តល់តម្លៃជំនួសពេញលេញសម្រាប់ទ្រព្យសម្បត្តិមិនមែនដីធ្លីដែលរងផលប៉ះពាល់ និងជំនួយផ្សេងទៀតសម្រាប់ការតាំងទីលំនៅឡើងវិញ |
| ដីធ្លី | ម្ចាស់បែបទំនៀមទំលាប់ (ជនជាតិដើមភាគតិច) | ការជំនួសដីដែលមានភាពសមស្របសមមូលដើម្បីធានានិរន្តភាពរបរចិញ្ចឹមជីវិត និងជីវភាពរស់នៅ ទៅតាមតម្លៃនៃការផ្លាស់ទីតាំង។ |
| ការប្រើប្រាស់ដីធ្លី | រាល់ជនរងផលប៉ះពាល់ដែលពាក់ព័ន្ធនឹងការធ្វើកសិកម្ម ដូចជា ម្ចាស់ស្របច្បាប់ អ្នកជួល។ | ដីដាំដំណាំ ៖ ប្រាក់ចំណូលដុល/ឆ្នាំ។ ដំណាំដែលនៅដុះនឹងត្រូវបានប្រមូលផល។<br>ដើមឈើហូបផ្លែ ៖ តម្លៃជំនួសពេញលេញ ដោយផ្អែកលើ maturity និងទិន្នផល។ |
| | ម្ចាស់អាជីវកម្មរួមទាំងម្ចាស់ស្របច្បាប់ អ្នកជួល | អាជីវកម្ម ៖ ប្រសិនបើត្រូវបានផ្លាស់ទីតាំង ស្មើនឹងចំណូលសរុបរយៈពេល ២ ខែ។ ប្រសិនបើមិនត្រូវបានផ្លាស់ទីតាំង (ឧ. រំកិលថយក្រោយចេញពីផ្លូវ) ស្មើនឹងប្រាក់ចំណូលសរុបរយៈពេល ១ ខែ។ |
| លំនៅដ្ឋាន និងសំណង់ | ម្ចាស់ស្របច្បាប់ ផ្អែកតាមច្បាប់ភូមិបាល ២០០១ ដោយមាន ឬគ្មានប្លង់រឹង និង<br>គ្រួសាររងផលប៉ះពាល់ទាំងអស់ដែលមានដី ឬទ្រព្យសម្បត្តិក្នុងដីដែលរងផលប៉ះពាល់ មុនកាលបរិច្ឆេទឱសានវាទនឹង | តម្លៃជំនួសពេញលេញនៃសំណង់ជាអចលនវត្ថុ<br>ចំណាយលើការរុះរើ ដឹកជញ្ជូន ឬតម្លើងឡើងវិញនូវសំណង់ជាចលនវត្ថុ<br>សាហ៊ុយដឹកជញ្ជូនសម្រាប់គ្រួសារ និងទំនិញផ្ទាល់ខ្លួន |

| | | |
|---|---|---|
| | មានលក្ខណៈសម្បត្តិទទួលបានសំណង ដោយមិនគិតពីស្ថានភាពផ្លូវច្បាប់របស់ពួកគេ។ | |
| | អ្នកជួល | សាហ៊ុយដឹកជញ្ជូនសម្រាប់គ្រួសារ និងទំនិញផ្ទាល់ខ្លួន ប្រាក់ឧបត្ថម្ភសម្រាប់ការរំខាន ដែលស្មើនឹងថ្លៃជួលរយៈពេល ១ ខែ។ |
| របរចិញ្ចឹមជីវិត | ជនបាត់បង់ទីលំនៅដែលបាត់បង់របរចិញ្ចឹមជីវិតក្នុងអំឡុងពេលអន្តរកាល | • អត្រានៃភាពក្រីក្រប្រចាំខែ X ចំនួនសមាជិកក្នុងគ្រួសារដែលរងផលប៉ះពាល់ X ៣ ខែ<br>• ក្រីក្រ និងងាយរងគ្រោះ ៖ អត្រានៃភាពក្រីក្រប្រចាំខែ X ចំនួនសមាជិកក្នុងគ្រួសារដែលរងផលប៉ះពាល់ X ៦ ខែ |
| | ជនបាត់បង់ទីលំនៅដែលបាត់បង់របរចិញ្ចឹមជីវិតជាអចិន្ត្រៃយ៍ | • ការស្តារប្រាក់ចំណូលឡើងវិញ/កម្មវិធីទ្រទ្រង់ ៖ ការស្តារប្រាក់ចំណូលដោយផ្អែកលើដីធ្លី ឬការស្តារប្រាក់ចំណូលឡើងវិញដោយផ្អែកលើការងារ ឬអាជីវកម្ម<br>• ជំនួយជាសាច់ប្រាក់<br>• ក្រុមក្រីក្រ និងងាយរងគ្រោះ ៖ ជំនួយជាសាច់ប្រាក់ទ្វេដង និងអាទិភាពក្នុងឱកាសការងារក្នុងគម្រោង ប្រសិនបើមាន។ |
| | ការបាត់បង់លទ្ធភាពប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួម | ការផ្តល់លទ្ធភាពទទួលបានធនធានសមមូលផ្សេងទៀត ឬសំណងផ្សេងទៀតដែលមានតម្លៃសមមូលនឹងការបាត់បង់ |

118. ពាក្យ "ម្ចាស់បែបទំនៀមទំលាប់" មិនត្រូវបានកំណត់ច្បាស់ក្នុងអនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញឡើយ និងហាក់មិនឆ្លើយតបទៅនឹងប្រភេទនៃកម្មសិទ្ធិដីធ្លីដែលកំណត់ដោយច្បាប់ភូមិបាល ២០០១ ទេ។ សម្រាប់គម្រោងដំណាក់កាលទី ៣ "កម្មសិទ្ធិបែបទំនៀមទំលាប់" នឹងសំដៅលើដីដែលស្ថិតក្រោមប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ឬដីដែលស្ថិតក្រោមសំណើធ្វើចំណាត់ថ្នាក់ជាដីសម្រាប់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចដោយសហគមន៍ជនជាតិដើមភាគតិចដែលទទួលស្គាល់ដោយក្រសួងអភិវឌ្ឍន៍ជនបទ។ ជនជាតិដើមភាគតិច និងគ្រួសាររបស់ពួកគេនឹងមានសិទ្ធិដូចអ្នកផ្សេងទៀតក្នុងការកាន់កាប់ដីធ្លីជាលក្ខណៈបុគ្គល និងទទួលបានសំណងជាសាច់ប្រាក់ប្រសិនបើមានលក្ខណៈសម្បត្តិ។

119. ក្នុងគម្រោងដំណាក់កាលទី ៣ សិទ្ធិទទួលបានសំណងសម្រាប់ការបាត់បង់ដីសម្រាប់គោលបំណងកសិកម្ម ឬសម្រាប់អាជីវកម្ម (ក្រៅពីសកម្មភាពខុសច្បាប់ ដូចជា ល្បែងស៊ីសង ពេស្យាចារ គ្រឿងញៀន ឬសកម្មភាពដែលមានលក្ខណៈស្រដៀងគ្នា) នឹងមិនរងផលប៉ះពាល់ដោយសារស្ថានភាពស្របច្បាប់នៃការកាន់កាប់ដីធ្លីឡើយ។

120. អនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ ទទួលស្គាល់ថា និយោជិតនៅលើដីដែលត្រូវធ្វើលទ្ធកម្ម អាចមានសិទ្ធិទទួលបានសំណង និងបង្ហាញថា ចំណុចនេះអាចអនុវត្តចំពោះប្រភេទជនរងផលប៉ះពាល់ផ្សេងទៀតដែលមានសិទ្ធិទទួលបានតម្លៃរើសចេញ ដូចអ្នកជួលដីជាដើម។ និយោជិត និងប្រភេទអ្នកប្រើប្រាស់ដីផ្សេងទៀតដែលរបរចិញ្ចឹមជីវិតពឹងផ្អែកមួយផ្នែកលើដីនោះរួមទាំងអ្នកប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួម នឹងមានសិទ្ធិទទួលបានសំណងសម្រាប់ការបាត់បង់របរចិញ្ចឹមជីវិត។

121. ការស្តារប្រាក់ចំណូលឡើងវិញ/កម្មវិធីទ្រទ្រង់សម្រាប់ជន ដែលរងផលប៉ះពាល់នឹងត្រូវបានអនុវត្តក្នុងក្របខណ្ឌនៃអនុគម្រោងទ្រទ្រង់របរចិញ្ចឹមជីវិតរបស់គម្រោងដំណាក់កាលទី ៣។ គម្រោងដំណាក់កាលទី ៣ នឹងខិតខំធានាថា ជនរងផលប៉ះពាល់ដែលក្រីក្រ និងងាយរងគ្រោះអាចទទួលបានអត្ថប្រយោជន៍ពីសកម្មភាពគម្រោង។ ចំណុចនេះអាចរួមមានអនុគម្រោងដែលត្រូវបានអនុវត្តក្នុងផែនការការងារ និងថវិកានៃសម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ប៉ុន្តែស្ថិតនៅក្រៅតំបន់សម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងត្រូវបានរៀបចំឡើងដើម្បីផ្តល់សំណងដល់អ្នកប្រើប្រាស់ដីដែលរងផលប៉ះពាល់។ ចំណាយនៃអនុគម្រោងទាំងនេះនឹងទទួលបានហិរញ្ញប្បទានតាមរយៈផែនការការងារ និងថវិកាប្រចាំឆ្នាំរបស់គម្រោងដំណាក់កាលទី ៣។

## ៨.៤ ការរៀបចំផ្នែកស្ថាប័ន

122. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលជាស្ថាប័នដឹកនាំការអនុវត្តគម្រោងដំណាក់កាលទី ៣ ទទួលខុសត្រូវលើការអនុវត្តក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ ហើយនឹងសហការជាមួយក្រុមគម្រោងថ្នាក់ខេត្ត ៖

- ធ្វើជាតំណាងក្នុងក្រុមការងារគណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ និងអនុគណៈកម្មាធិការខេត្តដោះស្រាយផលប៉ះពាល់
- ទទួលខុសត្រូវលើការជូនដំណឹងពេញលេញដល់ធនាគារពិភពលោកស្តីពីវឌ្ឍនភាពនៃការរៀបចំ និងអនុវត្តផែនការដោះស្រាយផលប៉ះពាល់ និងបញ្ហាប្រឈមនានា
- ធ្វើការពិនិត្យបឋមនៅទីតាំង និងការវាយតម្លៃផលប៉ះពាល់ ដើម្បីរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គមសម្រាប់សម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនីមួយៗ ដូចជា ផលប៉ះពាល់លើអ្នកប្រើប្រាស់ដី
- គ្រោង និងអនុវត្តវិធានការបញ្ចៀស ឬកាត់បន្ថយការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត ដូចការរៀបរាប់ក្នុងផ្នែក ៥.៣ និង ៨ ខាងលើ
- ប្រកាសពីកាលបរិច្ឆេទឱសានវាទ (ផ្នែក ៦ ខាងក្រោម)
- ជូនដំណឹងដល់អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ នៅពេលត្រូវមានការតាំងទីលំនៅឡើងវិញ ដូចជា ១) ទីតាំង និងទំហំដៃដែលត្រូវធ្វើលទ្ធកម្ម ២) គោលបំណងនៃការធ្វើលទ្ធកម្មដី ដែលបង្ហាញថាត្រូវធ្វើលទ្ធកម្មដីធ្លីជាចាំបាច់ដោយសារតែសម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចពាក់ព័ន្ធ មិនអាចអនុវត្តទៅបាន ៣) ស្ថានភាព

នៃការប្រើប្រាស់ និងកាន់កាប់ដីមានស្រាប់ ៤) ចំនួនប៉ាន់ស្មាននៃអ្នកប្រើប្រាស់ដីដែលរងផលប៉ះពាល់ បែងចែកតាមប្រភេទដោយស៊ីសង្វាក់គ្នានឹងប្រភេទក្នុងតារាង ៤ និង ៥ ខាងលើ និងរួមបញ្ចូលអ្នកប្រើប្រាស់ដីសម្រាប់គោលបំណងនានា ដូចជា វាលស្មៅសម្រាប់សត្វស៊ី អនុផលព្រៃឈើ នេសាទ។ល។ និង ៥) ក្របខណ្ឌពេលវេលាដែលស្នើឡើងសម្រាប់ការអនុវត្តសម្បទានដីសង្គមកិច្ច ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ឬអនុគម្រោង

- វាស់វែង និងកំណត់ព្រំប្រទល់ដីដែលត្រូវធ្វើលទ្ធកម្ម រួមគ្នាជាមួយអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់
- ក្នុងករណីមានតម្រូវការដីសម្រាប់អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ ផ្តល់កាលវិភាគសាងសង់ដែលស្នើឡើងដល់អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ ដោយកំណត់រកកាលវិភាគសម្រាប់ការបញ្ចប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ និងការប្រគល់ទីតាំងតាមផ្នែកទៅក្រុមហ៊ុនម៉ៅការ យ៉ាងហោចណាស់រយៈពេល ៦ ខែ មុនកាលបរិច្ឆេទចុះកិច្ចសន្យាដែលគ្រោងឡើង
- ជូនដំណឹងដល់អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ឱ្យបានទាន់ពេលវេលាថាតើវឌ្ឍនភាពនៃការសាងសង់ត្រូវបានរាំងស្ទះដោយលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ ឬក្នុងករណីប៉ាន់ស្មានពីឧបសគ្គណាមួយ
- ជួយជ្រោមជ្រែង និងសហការជាមួយអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ក្នុងការរិះរកដំណោះស្រាយបញ្ហាប្រឈមក្នុងពេលអនុវត្តគម្រោង
- អញ្ជើញឱ្យអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ចូលរួមក្នុងបេសកកម្មត្រួតពិនិត្យ និងកិច្ចប្រជុំបូកសរុបជាមួយដៃគូអភិវឌ្ឍន៍ និងធានាដាក់បញ្ចូលយោបល់ត្រឡប់របស់អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ស្តីពីបញ្ហាលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញក្នុង AMs, MOUs ឬ MODs
- ទទួលខុសត្រូវលើការធានាថាគ្មានការទន្ទ្រានកាន់កាប់បន្ថែមទៀតលើដីចំណីផ្លូវ ក្រោយការប្រគល់ឱ្យគ្រប់គ្រងដោយអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់។

123. តាមរយៈអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងទទួលខុសត្រូវរួមលើការរៀបចំ និងអនុវត្តផែនការដោះស្រាយផលប៉ះពាល់ដូចខាងក្រោម ៖

- ចាត់តាំងក្រុមការងារនៃគណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់នៅកម្រិតគម្រោង
- ផ្តួចផ្តើមការបង្កើតអនុគណៈកម្មាធិការខេត្តដោះស្រាយផលប៉ះពាល់
- អនុម័តគោលនយោបាយ វិធានអនុវត្តន៍ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ
- បញ្ជាក់ និងផ្តល់ការណែនាំស្តីពីការអនុវត្តវិធាន និងបទប្បញ្ញត្តិ ទៅតាមភាពចាំបាច់
- ពិនិត្យឡើងវិញ អនុម័ត និងបែងចែកថវិកាសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ រួមទាំងចំណាយលើការរៀបចំ និងអនុវត្តផែនការដោះស្រាយផលប៉ះពាល់។

124. ផ្អែកតាមសេចក្តីសម្រេចរបស់នាយករដ្ឋមន្ត្រី គណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ ប្រើប្រាស់អំណាចរបស់គណៈកម្មាធិការអស្សាមិករណ៍ស្របតាមច្បាប់ស្តីពីអស្សាមិករណ៍ និងជាស្ថាប័នសមូហភាពមួយ ដែលធ្វើជាប្រធាន និងដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានសមាជិកមកពីក្រសួងសាមីផ្សេងៗ។ គណៈកម្មាធិការនេះបំពេញតួនាទី និងការទទួលខុសត្រូវតាមរយៈក្រុមការងាររបស់ខ្លួន ដែលត្រូវបានបង្កើតឡើងសម្រាប់គម្រោងវិនិយោគសាធារណៈនីមួយៗដោយក្រសួងសេដ្ឋកិច្ច។ អំណាចរបស់គណៈកម្មាធិការនេះត្រូវបានធ្វើប្រតិភូកម្មទៅប្រធានអចិន្ត្រៃយ៍។ ការទទួលខុសត្រូវសំខាន់ៗរបស់គណៈកម្មាធិការនេះរួមមាន ៖

- ផ្តល់ការត្រួតពិនិត្យយ៉ាងមានប្រសិទ្ធភាព និងធានាថា លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ អនុលោមតាមច្បាប់ និងវិធានអនុវត្តន៍ និងបទប្បញ្ញត្តិនានា
- ធានាការសម្របសម្រួលដោយប្រសិទ្ធភាពរវាងក្រសួងសាមី អាជ្ញាខេត្ត/មូលដ្ឋាន និងអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ក្នុងការអនុវត្តលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ
- ផ្តល់ការណែនាំជារួមស្តីពីវិធានអនុវត្តន៍ និងបទប្បញ្ញត្តិសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ ផ្តល់ព័ត៌មានបច្ចុប្បន្នភាពទៅតាមភាពចាំបាច់
- ផ្តួចផ្តើមការបង្កើតគណៈកម្មាធិការខេត្តដោះស្រាយបណ្តឹងតវ៉ា
- អនុម័តក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ក្នុងគម្រោង និងផែនការដោះស្រាយផលប៉ះពាល់ក្នុងអនុគម្រោង (និងក្នុងបរិបទផ្សេងទៀត ហៅថា ផែនការដោះស្រាយផលប៉ះពាល់មូលដ្ឋាន ក្របខណ្ឌដោះស្រាយផលប៉ះពាល់ ផែនការដោះស្រាយផលប៉ះពាល់លម្អិត និងផែនការដោះស្រាយផលប៉ះពាល់លម្អិតបច្ចុប្បន្នភាព។

125. អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ គឺជាលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ និងជាស្ថាប័នដឹកនាំទទួលបន្ទុកលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញសម្រាប់គម្រោងវិនិយោគសាធារណៈ។ ស្ថាប័ននេះទទួលខុសត្រូវលើការរៀបចំ អនុវត្ត ពិនិត្យតាមដាន និងរាយការណ៍ពីផែនការដោះស្រាយផលប៉ះពាល់ដោយអនុលោមតាមច្បាប់ និងវិធានអនុវត្តន៍ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ និងលក្ខខណ្ឌតម្រូវនៃគោលនយោបាយធានាសុវត្ថិភាពរបស់ដៃគូអភិវឌ្ឍន៍។ ស្ថាប័ននេះក៏ទទួលខុសត្រូវផងដែរលើការបង្កើតបទប្បញ្ញត្តិថ្មីៗ ឬការធ្វើបច្ចុប្បន្នភាពពីនីតិវិធីប្រតិបត្តិស្តង់ដារ និងមានអំណាចបកស្រាយ និងបញ្ជាក់ពីបទប្បញ្ញត្តិនៃនីតិវិធីនេះ (ចុងក្រោយ)។ ការទទួលខុសត្រូវសំខាន់ៗរបស់ស្ថាប័ននេះរួមមាន ៖

- សម្របសម្រួល និងសហការជាមួយក្រសួងសាមី ស្ថាប័នដឹកនាំការអនុវត្តគម្រោង ស្ថាប័នអនុវត្តន៍គម្រោង និងស្ថាប័នផ្សេងទៀតដែលពាក់ព័ន្ធក្នុងសកម្មភាពលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ
- ដើរតួនាទីជាសមភាគីបង្គោលរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់សកម្មភាពលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញទាំងអស់ ដើម្បីធានាកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍

- ណែនាំស្ថាប័នដឹកនាំការអនុវត្ត/ស្ថាប័នអនុវត្តន៍គម្រោង និង/ឬទីប្រឹក្សារៀបចំគម្រោង ក្នុងការធ្វើការអង្កេតសង្គមសេដ្ឋកិច្ចគំរូ និងការរៀបចំក្របខណ្ឌផែនការដោះស្រាយផលប៉ះពាល់ក្នុងពេលសិក្សាសមិទ្ធិលទ្ធភាពគម្រោង
- ពិនិត្យឡើងវិញ និងអនុម័តពង្រាងក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ដែលរៀបចំឡើងដោយស្ថាប័នដឹកនាំការអនុវត្ត/ស្ថាប័នអនុវត្តន៍គម្រោង ក្នុងដំណាក់កាលរៀបចំគម្រោងដាក់ជូនរាជរដ្ឋាភិបាលអនុម័ត
- ពិនិត្យឡើងវិញ និងអនុម័តបញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញដែលមានក្នុង Aide Memoires, អនុស្សារណៈយោគយល់គ្នា និងកំណត់ហេតុកិច្ចពិភាក្សាដែលរៀបចំឡើងដោយដៃគូអភិវឌ្ឍន៍ក្នុងពេលរៀបចំគម្រោង ការចរចាកម្ចី និងដំណាក់កាលអនុវត្តន៍គម្រោង
- ពិនិត្យឡើងវិញ និងអនុម័តកតិកាសញ្ញាដែលពាក់ព័ន្ធនឹងលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញក្នុងពង្រាងសៀវភៅណែនាំស្តីពីការគ្រប់គ្រងគម្រោង/សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង និងពង្រាងកិច្ចព្រមព្រៀងហិរញ្ញប្បទាន និងចូលរួមក្នុងការចរចារបស់ពួកគេ ទៅតាមភាពចាំបាច់
- រៀបចំ និងធានាថវិកាចាំបាច់សម្រាប់ការអនុវត្តផែនការដោះស្រាយផលប៉ះពាល់ក្នុងអនុគម្រោង
- អនុវត្តសកម្មភាពលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញទាំងអស់ដោយអនុលោមតាមក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ និងផែនការដោះស្រាយផលប៉ះពាល់ក្នុងអនុគម្រោង (ឬផែនការដោះស្រាយផលប៉ះពាល់បច្ចុប្បន្នភាព)
- គណនា រៀបចំកិច្ចសន្យា និងទូទាត់សំណងសម្រាប់គ្រួសារដែលរងផលប៉ះពាល់ដោយផ្អែកលើតារាងសិទ្ធិទទួលបានក្នុងផែនការដោះស្រាយផលប៉ះពាល់ក្នុងអនុគម្រោង(ឬផែនការដោះស្រាយផលប៉ះពាល់បច្ចុប្បន្នភាព)
- ធានាការបំពេញមុខងារសមស្របនៃយន្តការដោះស្រាយបណ្តឹងតវ៉ា
- ត្រួតពិនិត្យ ពិនិត្យតាមដាន និងរាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តផែនការដោះស្រាយផលប៉ះពាល់ក្នុងអនុគម្រោង (ឬផែនការដោះស្រាយផលប៉ះពាល់បច្ចុប្បន្នភាព) និងរាយការណ៍ជូនធនាគារពិភពលោក
- រៀបចំសិក្ខាសាលាកសាងការយល់ដឹងសម្រាប់ក្រសួងសាមី និងអាជ្ញាធរមូលដ្ឋានស្តីពីវិធានអនុវត្តន៍ និងបទប្បញ្ញត្តិដែលមានកំណត់ក្នុងក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ និងគោលការណ៍ណែនាំពាក់ព័ន្ធដែលរៀបចំឡើងដោយអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ជាបន្តបន្ទាប់
- ដើរតួនាទីជាមជ្ឈមណ្ឌលផ្តល់ចំណេះដឹងស្តីពីលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ។

126. អនុគណៈកម្មាធិការខេត្តដោះស្រាយផលប៉ះពាល់ នឹងត្រូវបានបង្កើតឡើងដោយអភិបាលខេត្តទៅតាមសំណើរបស់គណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ សម្រាប់គម្រោងនីមួយៗ និងរួមមាន ១) អភិបាលខេត្ត ឬអភិបាលរងខេត្តជាប្រធាន និង ២) ប្រធានមន្ទីររបស់ក្រសួងសាមីដែលធ្វើជាតំណាងក្នុងគណៈ

កម្មាធិការខាងលើ និង ៣) អភិបាលស្រុក និងមេឃុំនៅតាមទីតាំងដែលរងផលប៉ះពាល់ដោយសារគម្រោង ជាសមាជិក។ តួនាទីសំខាន់ៗរបស់ស្ថាប័ននេះរួមមាន ៖

- ផ្តល់ការសម្របសម្រួល និងការទ្រទ្រង់ដល់អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ គណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ និងក្រុមការងាររបស់គណៈកម្មាធិការនេះ សម្រាប់ការរៀបចំ អនុវត្ត និងពិនិត្យតាមដានផែនការដោះស្រាយផលប៉ះពាល់នៅតាមវាល និងមូលដ្ឋាន និង
- ធានាថា អាជ្ញាធររដ្ឋាភិបាលថ្នាក់ខេត្ត និងមូលដ្ឋានពាក់ព័ន្ធទាំងអស់ផ្តល់ជំនួយសមស្របសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ
- គ្រប់គ្រងកិច្ចប្រជុំពិគ្រោះយោបល់សាធារណៈនៅថ្នាក់ខេត្ត
- ជួយដល់ក្រុមការងាររបស់គណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ក្នុងការជ្រើសរើសទីតាំងសមស្របសម្រាប់ការតាំងទីលំនៅឡើងវិញ
- ត្រួតពិនិត្យ និងតាមដានការងាររបស់ក្រុមការងាររបស់អនុគណៈកម្មាធិការ
- ទទួលខុសត្រូវលើការរៀបចំការទូទាត់នៅថ្នាក់ខេត្ត។

127. ក្រុមការងាររបស់អនុគណៈកម្មាធិការខេត្តដោះស្រាយផលប៉ះពាល់ ត្រូវបានបង្កើតឡើងដោយអភិបាលខេត្ត និងទទួលខុសត្រូវលើមុខងារផ្នែកបច្ចេកទេសរបស់អនុគណៈកម្មាធិការនេះ និងសហការជាមួយក្រុមការងាររបស់គណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ក្នុងការអនុវត្តសកម្មភាពលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញនៅថ្នាក់ខេត្ត។ ក្រៅពីការទ្រទ្រង់ដល់អនុគណៈកម្មាធិការ ក្រុមការងារនេះមានមុខងារជាក់លាក់ដូចខាងក្រោម ៖

- សម្របសម្រួលការពិគ្រោះយោបល់ និងកិច្ចប្រជុំផ្សព្វផ្សាយព័ត៌មានជាសាធារណៈទាំងអស់ និងធ្វើការកត់ត្រា
- សហការជាមួយក្រុមការងារគណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ក្នុងការអនុវត្តការអង្កេតវាស់វែងលម្អិត និងរៀបចំបញ្ជីសារពើភណ្ឌនៃការខាតបង់ និងក្នុងការអនុវត្តផែនការដោះស្រាយផលប៉ះពាល់ក្នុងអនុគម្រោងដែលបានអនុម័ត
- ដឹកនាំការទូទាត់សំណងដល់ជនដែលរងផលប៉ះពាល់
- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំខែស្តីពីសកម្មភាពលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញទាំងអស់នៅថ្នាក់ខេត្ត និងដាក់ជូនអនុគណៈកម្មាធិការខេត្តដោះស្រាយផលប៉ះពាល់ និងអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់។

## ៨.៥ ការរៀបចំផែនការដោះស្រាយផលប៉ះពាល់

128. ការរៀបចំ និងការទទួលខុសត្រូវលម្អិតលើការរៀបចំផែនការដោះស្រាយផលប៉ះពាល់ក្នុងអនុគម្រោងក្រោមគម្រោងដំណាក់កាលទី ៣ មានរៀបរាប់ក្នុងតារាង ៦ ខាងក្រោម ៖

| តារាង ៦ ៖ កិច្ចការសំខាន់ៗក្នុងការរៀបចំផែនការដោះស្រាយផលប៉ះពាល់ | | | |
|---|---|---|---|
| សកម្មភាព | | | ស្ថាប័នទទួលខុសត្រូវ |
| ១ | ការរៀបចំផ្នែកស្ថាប័ន | • ការបង្កើតគណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ និងក្រុមការងារ<br>• ការបង្កើតអនុគណៈកម្មាធិការខេត្តដោះស្រាយផលប៉ះពាល់ និងក្រុមការងារ | • ក្រសួងសេដ្ឋកិច្ច (ចាត់តាំងក្រុមការងារគណៈកម្មាធិការអន្តរក្រសួង) ក្រសួងរៀបចំដែនដី ក្រសួងកសិកម្ម លេខាធិការដ្ឋាន គជអប<br>• អភិបាលខេត្ត |
| ២ | ការអង្កេតវាស់វែងលម្អិត | • ការកំណត់ព្រំប្រទល់ដី<br>• ការអង្កេតវាស់វែងលម្អិត (ការអង្កេតគ្រួសារ ១០០%, IOL ១០០% និងជំរឿនពេញលេញតាមរយៈកម្រងសំណួរក្នុងការអង្កេតនេះ)<br>• ការរៀបចំពង្រាងកិច្ចសន្យាក្នុងការអង្កេតវាស់វែងលម្អិត | • ក្រុមការងាររបស់អនុគណៈកម្មាធិការដោះស្រាយផលប៉ះពាល់ថ្នាក់ខេត្ត<br>• ទីប្រឹក្សាសម្រាប់ការអង្កេតដែលចុះកិច្ចសន្យាដោយអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់<br>• នាយកដ្ឋានត្រួតពិនិត្យផ្ទៃក្នុង និងគ្រប់គ្រងទិន្នន័យ |
| ៣ | យេនឌ័រ | • ធ្វើបច្ចុប្បន្នភាពព័ត៌មានយេនឌ័រ<br>• រៀបចំផែនការសម្រាប់ការផ្តល់ជំនួយផ្នែកសង្គម សេវាការងារ និងមធ្យោបាយចិញ្ចឹមជីវិតសម្រាប់ការទ្រទ្រង់ប្រាក់ចំណូលដល់គ្រួសារដែលមានស្ត្រីជាមេគ្រួសារ | • ក្រុមការងាររបស់អនុគណៈកម្មាធិការថ្នាក់ខេត្តដោះស្រាយផលប៉ះពាល់ |
| ៤ | ក្រុមក្រីក្រ និងងាយរងគ្រោះ | • ធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យដោយផ្អែកលើការអង្កេតវាស់វែងលម្អិត<br>• កំណត់ប្រភេទផ្សេងៗ និងលក្ខណៈសម្បត្តិក្នុងការទទួលបានកញ្ចប់ជំនួយបន្ថែម<br>• សម្រេចបញ្ចប់កញ្ចប់ជំនួយបន្ថែម | • ក្រុមការងាររបស់អនុគណៈកម្មាធិការថ្នាក់ខេត្តដោះស្រាយផលប៉ះពាល់ |
| ៥ | ការសិក្សាតម្លៃជំនួស | • ធ្វើការសិក្សាតម្លៃជំនួសដើម្បីកំណត់អត្រាទីផ្សារទូទៅសម្រាប់ការជំនួសទ្រព្យសម្បត្តិដែលបាត់បង់សម្រាប់ជនដែលរងផលប៉ះពាល់ម្នាក់ៗ | • ក្រុមការងាររបស់អនុគណៈកម្មាធិការថ្នាក់ខេត្តដោះស្រាយផលប៉ះពាល់<br>• ទីប្រឹក្សាសម្រាប់ការអង្កេតដែលចុះកិច្ចសន្យាដោយក្រុមការងាររបស់អនុគណៈកម្មាធិការថ្នាក់ខេត្តដោះស្រាយផលប៉ះពាល់ |
| ៦ | កញ្ចប់សំណង | • ធ្វើបច្ចុប្បន្នភាពតារាងសិទ្ធិទទួលបានដើម្បីបង្ហាញកញ្ចប់សំណងពេញលេញ និងគ្រប់ជ្រុងជ្រោយសម្រាប់ផ្តល់ជូនជនបាត់បង់ទីលំនៅ | • ក្រុមការងាររបស់អនុគណៈកម្មាធិការថ្នាក់ខេត្តដោះស្រាយផលប៉ះពាល់<br>• ក្រុមការងាររបស់គណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ |
| ៧ | ទីតាំងសម្រាប់ការតាំងទីលំនៅឡើងវិញ (ទៅតាមភាពចាំបាច់) | • បញ្ចប់លទ្ធកម្មដីធ្លីដែលចាំបាច់សម្រាប់ទីតាំងសម្រាប់ការតាំងទីលំនៅឡើងវិញ<br>• រៀបចំផែនការទីតាំងសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាមូលដ្ឋាន<br>• គម្រោងដំណាក់កាលទី ៣ ៖ គ្មានការរំពឹងថា ត្រូវមានទីតាំងសម្រាប់ការតាំងទីលំនៅឡើងវិញឡើយ លើក | • ក្រុមការងាររបស់អនុគណៈកម្មាធិការថ្នាក់ខេត្តដោះស្រាយផលប៉ះពាល់ |

| | | | |
|---|---|---|---|
| | | លែងតែក្នុងករណីដែលជនបាត់បង់ទីលំនៅត្រូវបានតាំងទីលំនៅឡើងវិញក្នុងដីសម្រាប់សម្បទានដីសង្គមកិច្ច ឬការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ | |
| ៨ | ផែនការទ្រទ្រង់របរចិញ្ចឹមជីវិត | • រៀបចំផែនការសម្រាប់កម្មវិធីទ្រទ្រង់របរចិញ្ចឹមជីវិតសម្រាប់ការបាត់បង់ប្រភពរបរចិញ្ចឹមជីវិតជាអចិន្ត្រៃយ៍ | • ក្រុមការងាររបស់អនុគណៈកម្មាធិការថ្នាក់ខេត្តដោះស្រាយផលប៉ះពាល់<br>• ក្រុមគម្រោងថ្នាក់ខេត្តក្នុងគម្រោងដំណាក់កាលទី ៣ (ដែលសកម្មភាពទ្រទ្រង់របរចិញ្ចឹមជីវិតត្រូវបានផ្ដល់តាមរយៈអនុគម្រោងក្នុងគម្រោងដំណាក់កាលទី ៣) |
| ៩ | យន្តការដោះស្រាយបណ្ដឹងតវ៉ា | • ដំណើរការយន្តការដោះស្រាយបណ្ដឹងតវ៉ានៅថ្នាក់ខេត្ត<br>• គ្រោងនីតិវិធីសម្រាប់ការដោះស្រាយបណ្ដឹង<br>• ផ្សព្វផ្សាយព័ត៌មានស្ដីពីយន្តការនេះដល់ប្រជាជនក្នុងតំបន់សម្រាប់សម្បទានដីសង្គមកិច្ច/ការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច | • គណៈកម្មាធិការដោះស្រាយបណ្ដឹងថ្នាក់ខេត្តក្នុងគម្រោងដំណាក់កាលទី ៣<br>• ប្រសិនបើអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់កំណត់ថាចាំបាច់ នឹងមានការបង្កើតគណៈកម្មាធិការដោះស្រាយបណ្ដឹងពាក់ព័ន្ធនឹងលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ |
| ១០ | ការពិគ្រោះយោបល់ | • ការពិគ្រោះយោបល់ជាមួយជនរងផលប៉ះពាល់នៅថ្នាក់ឃុំដើម្បី ជូនដំណឹងពីសិទ្ធិទទួលបាន និងមធ្យោបាយគណនាសំណង និងនីតិវិធីក្នុងយន្តការដោះស្រាយបណ្ដឹងតវ៉ា<br>• ការពិគ្រោះយោបល់ជាមួយជនរងផលប៉ះពាល់ដែលមានលក្ខណៈសម្បត្តិសម្រាប់ការផ្លាស់ទីតាំងនៅទីតាំងសម្រាប់ការតាំងទីលំនៅឡើងវិញនៅថ្នាក់ឃុំ/ភូមិ<br>• ការពិគ្រោះយោបល់តាមខ្នងផ្ទះដើម្បីបញ្ជាក់ពីការអង្កេតវាស់វែងក្នុងពេលអង្កេតវាស់វែងលម្អិត។ | • ក្រុមការងាររបស់អនុគណៈកម្មាធិការថ្នាក់ខេត្តដោះស្រាយផលប៉ះពាល់<br>• ក្រុមគម្រោងថ្នាក់ខេត្ត<br>• អាជ្ញាធរស្រុក<br>• អាជ្ញាធរឃុំ<br>• អង្គការមិនមែនរដ្ឋាភិបាល<br>• ជនរងផលប៉ះពាល់ដោយសារគម្រោង<br>• អ្នកពាក់ព័ន្ធផ្សេងទៀត |
| ១១ | ការពិនិត្យតាមដាន និងរាយការណ៍ | • ការរៀបចំ តួនាទី និងការទទួលខុសត្រូវលើការពិនិត្យតាមដាន និងរាយការណ៍ពីការអនុវត្តផែនការដោះស្រាយផលប៉ះពាល់ថ្នាក់ស្រុក និងលក្ខខណ្ឌតម្រូវឱ្យមានការរាយការណ៍<br>• វិសាលភាពនៃការពិនិត្យតាមដានបណ្ដោះអាសន្ន<br>• វិសាលភាពនៃការពិនិត្យតាមដានខាងក្រៅ ទៅតាមភាពចាំបាច់ | • អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់មានអាណត្តិពិនិត្យតាមដានសកម្មភាពតាំងទីលំនៅឡើងវិញ<br>• ក្រុមការងាររបស់គណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ និងក្រុមការងាររបស់អនុគណៈកម្មាធិការខេត្តដោះស្រាយផលប៉ះពាល់ដាក់របាយការណ៍ប្រចាំខែទៅ DIMDM<br>• DIMDM ចែករំលែករបាយការណ៍ជាមួយក្រសួងរៀបចំដែនដី<br>• ក្រសួងរៀបចំដែនដីបូកសរុបរបាយការណ៍ប្រចាំត្រីមាសដាក់ជូនធនាគារពិភពលោក |

| | | | |
|---|---|---|---|
| ១២ | ការបង្កើតថវិកា | • រៀបចំថវិកាប៉ាន់ស្មានសម្រាប់រួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹម ១) ទ្រព្យសម្បត្តិ និងការខាតបង់ផ្នែកសេដ្ឋកិច្ចដោយផ្អែកលើតម្លៃជំនួស ២)ចំណាយលើលទ្ធកម្ម និងការអភិវឌ្ឍទីតាំងថ្មីសម្រាប់ការតាំងទីលំនៅឡើងវិញ ទៅតាមភាពចាំបាច់ ៣)ចំណាយលើការទ្រទ្រង់ដល់ការបាត់បង់ប្រាក់ចំណូលបណ្ដោះអាសន្ន ៤)ចំណាយលើការផ្ដល់ជំនួយបន្ថែមដល់ក្រុមក្រីក្រ និងងាយរងគ្រោះសម្រាប់ការស្ដាររបរចិញ្ចឹមជីវិតឡើងវិញ ៥) ចំណាហលើការពិនិត្យតាមដានខាងក្រៅ ៦) ចំណាយលើ SES, RCS និងការអង្កេតផ្សេងទៀត ៧) ចំណាយរដ្ឋបាល ប្រតិបត្តិការ និងចំណាយទូទៅ និង ៧) ចំណាយផ្សេងទៀតដែលពាក់ព័ន្ធនឹងលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ។ | • ថវិកាត្រូវអនុម័តដោយអគ្គនាយកដ្ឋានកិច្ចសហប្រតិបត្តិការផ្ទៃក្នុង និងគ្រប់គ្រងបំណុលរបស់ក្រសួងសេដ្ឋកិច្ច |

129. ការអង្កេតវាស់វែងលម្អិតគឺជាការអង្កេតតាមគ្រួសារជាមួយគ្រួសារទាំងអស់ដែលដែលកាន់កាប់លើដី ដែលត្រូវធ្វើលទ្ធកម្ម។ ទម្រង់ស្តង់ដារសម្រាប់ការអង្កេតនេះមានបង្ហាញក្នុងអនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ។ ក្នុងគម្រោងដំណាក់កាលទី៣ អនុគណៈកម្មាធិការខេត្តដោះស្រាយផលប៉ះពាល់នឹង ១)ចាត់វិធានការកំណត់អត្តសញ្ញាណគ្រួសារដែលបរចិញ្ចឹមជីវិតពឹងផ្អែកមួយផ្នែកធំពីធនធានទ្រព្យសម្បត្តិរួម ដូចជា វាលស្មៅសម្រាប់សត្វស៊ី អនុផលព្រៃឈើ នេសាទ។ល។ លើដីដែលរងផលប៉ះពាល់ និង ២) រួមបញ្ចូលគ្រួសារក្នុងការអង្កេតវាស់វែងលម្អិត និងសំណាងជាបន្តបន្ទាប់ និងផែនការទ្រទ្រង់បរចិញ្ចឹមជីវិត (ដំណើរការអង្កេតវាស់វែងលម្អិត និងការពិគ្រោះយោបល់ជាមួយគ្រួសាររងផលប៉ះពាល់ស្តីពីកិច្ចសន្យាការអង្កេតវាស់វែងលម្អិតមានបង្ហាញក្នុងផ្នែក ៩.៦.២ ខាងក្រោម)។

130. ការអង្កេតគ្រួសារនឹងកំណត់ថាតើជនរងផលប៉ះពាល់ទាំងអស់មានអត្តសញ្ញាណប័ណ្ណសម្រាប់យកមកបង្ហាញនៅពេលទាមទារសំណង។ ក្នុងករណីដែលជនរងផលប៉ះពាល់ដែលត្រូវបានកំណត់អត្តសញ្ញាណ គ្មានអត្តសញ្ញាណប័ណ្ណ ប៉ុន្តែមានសិទ្ធិទទួលបានអត្តសញ្ញាណប័ណ្ណ គម្រោងនឹងជួយដល់ពួកគេឱ្យទទួលបានអត្តសញ្ញាណប័ណ្ណ។ គ្មានជនរងផលប៉ះពាល់ណាម្នាក់នឹងត្រូវបានផាត់ចេញពីការផ្តល់សំណងដោយសារគ្មានអត្តសញ្ញាណប័ណ្ណឡើយ។ ប្រសិនបើចាំបាច់ មធ្យោបាយជាជម្រើសក្នុងការផ្ទៀងផ្ទាត់អត្តសញ្ញាណនឹងត្រូវបានបង្កើតឡើង។

131. ការសិក្សាតម្លៃជំនួស នឹងកំណត់ពីមូលដ្ឋានសម្រាប់ការវាយតម្លៃជំនួសទ្រព្យសម្បត្តិ ហើយនឹងកំណត់ពីមូលដ្ឋានសម្រាប់ចំណាយលើសិទ្ធិទទួលបានផ្សេងទៀតដូចជាការធ្វើដំណើរ។ ការសិក្សានេះត្រូវបានធ្វើឡើងទន្ទឹមគ្នានឹងការអង្កេតវាស់វែងលម្អិតដោយទីប្រឹក្សាជាតិឯករាជ្យ (បុគ្គល ឬក្រុមហ៊ុន) ដែលមានបទពិសោធន៍ចាំបាច់ក្នុងការវាយតម្លៃទ្រព្យសម្បត្តិ។ ការជ្រើសរើសទីប្រឹក្សាសម្រាប់ការសិក្សានេះនឹងធ្វើឡើងដោយអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់។ ការវាយតម្លៃការជំនួសដូចការកំណត់ក្នុងការសិក្សានេះមានសុពលភាពរយៈពេលមួយឆ្នាំចាប់ពីកាលបរិច្ឆេទអនុម័តការសិក្សានេះដោយគណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់។

132. ការសិក្សាយេនឌ័រគួររួមបញ្ចូលការវាយតម្លៃដោយផ្អែកលើកិច្ចពិភាក្សាក្រុមគោលដៅស្តីពីផលប៉ះពាល់ផ្សេងៗនៃលទ្ធកម្មដីធ្លីលើបុរស និងស្ត្រី និងថាតើទស្សនៈរបស់ស្ត្រីខុសគ្នាខ្លាំងពីទស្សនៈរបស់បុរសស្តីពីការរៀបចំផ្តល់សំណងគ្រប់គ្រាន់ ឬទេ។

133. ក្នុងគម្រោងដំណាក់កាលទី៣ ការកំណត់អត្តសញ្ញាណក្រុមក្រីក្រ និងងាយរងគ្រោះ ក្នុងការអង្កេតវាស់វែងលម្អិតនឹងត្រូវបានផ្ទៀងផ្ទាត់ជាមួយការកំណត់អត្តសញ្ញាណការអង្កេតគ្រួសារក្រីក្រ។

134. សិទ្ធិទទួលបានសំណង នឹងត្រូវបានគណនាដោយអនុលោមតាមផ្នែក ៩.៣ ខាងលើ និងបទប្បញ្ញត្តិក្នុងអនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ (ផ្នែក ៩.៣ ខាងលើត្រូវបានកំណត់ជាអាទិភាពប្រសិនបើមានភាពខុសប្លែកគ្នា)។

## ៨.៦ ការពិគ្រោះយោបល់ជាសាធារណៈ ការចូលរួម និងការផ្សព្វផ្សាយព័ត៌មាន

135. ការពិគ្រោះយោបល់ជាសាធារណៈ ការចូលរួម និងការផ្សព្វផ្សាយព័ត៌មាន ដែលកំណត់ដោយអនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ មានសង្ខេបក្នុងកថាខណ្ឌខាងក្រោម។

### ៨.៦.១ ការផ្សព្វផ្សាយព័ត៌មាន

136. ផែនការដោះស្រាយផលប៉ះពាល់ (ជាភាសាអង់គ្លេស និងភាសាខ្មែរ) ក្នុងគេហទំព័ររបស់ស្ថាប័នដឹកនាំការអនុវត្ត និងគេហទំព័ររបស់ធនាគារពិភពលោក និងជាភាសាខ្មែរនៅសាលាឃុំ ក្រោយការអនុម័តដោយគណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ និងគ្មានការជំទាស់ពីធនាគារពិភពលោក។

137. ព័ត៌មានទូទៅដែលត្រូវបានផ្សព្វផ្សាយដល់ជនដែលរងផលប៉ះពាល់ដោយសារគម្រោង រួមមាន ១) សាវតាគម្រោង និងទីតាំង (ផែនទី) ២) គោលបំណង ការពិពណ៌នា និងអត្ថប្រយោជន៍ដែលអាចផ្តល់ជូន ៣) វិសាលភាពនៃលទ្ធកម្មដីធ្លី និងផលប៉ះពាល់ដែលអាចកើតឡើង ៤) ព័ត៌មានទូទៅស្តីពីគោលនយោបាយផ្តល់សំណង និងលក្ខណៈវិនិច្ឆ័យនៃលក្ខណៈសម្បត្តិ ៥) វិធីសាស្ត្រសម្រាប់ការគណនាអត្រាផ្តល់សំណង (តាមរយៈការសិក្សាតម្លៃជំនួស) និង ៦) បុគ្គលទំនាក់ទំនងក្នុងក្រុមការងារគណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់។

138. ខិតប័ណ្ណព័ត៌មានគម្រោង ២ ប្រភេទ នឹងត្រូវបានរៀបចំឡើង និងចែកចាយ។ ខិតប័ណ្ណទី ១ មានព័ត៌មានទូទៅ (ខាងលើ)។ ខិតប័ណ្ណទី ២ (លម្អិត) បង្ហាញព័ត៌មានជាក់លាក់ស្តីពី ១) សិទ្ធិទទួលបាន និងសំណង ២) ការផ្លាស់ទីកន្លែង និងទីតាំងដែលអាចមាន និង ៣) យន្តការដោះស្រាយបណ្តឹងតវ៉ា។ ខិតប័ណ្ណបច្ចុប្បន្នភាពនឹងត្រូវបានចែករំលែក និងផ្សព្វផ្សាយដល់សហគមន៍រងផលប៉ះពាល់មុនចាប់ផ្តើមការអង្កេតវាស់វែងលម្អិត។

139. ការចែកចាយខិតប័ណ្ណទាំងនេះនឹងមិនគ្រប់គ្រាន់ឡើយក្នុងករណីដែលជនរងផលប៉ះពាល់រួមបញ្ចូលទាំងអ្នកមិនចេះអក្សរ និងអ្នកដែលមិននិយាយភាសាខ្មែរ (ដូចជា សហគមន៍ជនជាតិដើមភាគតិច)។ គម្រោងដំណាក់កាលទី ៣ នឹងផ្តល់ការទ្រទ្រង់បន្ថែមដើម្បីធានាថា ជនរងផលប៉ះពាល់មានលទ្ធភាពទទួលបានការណែនាំ និងការពន្យល់ពីខិតបណ្ណនេះក្នុងភាសារបស់ពួកគេ។

### ៨.៦.២ កិច្ចប្រជុំពិគ្រោះយោបល់

140. ជនរងផលប៉ះពាល់នឹងត្រូវបានពិគ្រោះយោបល់តាមរយៈកិច្ចប្រជុំពិគ្រោះយោបល់ជាបន្តបន្ទាប់។ កិច្ចប្រជុំទាំងនេះអនុវត្តតាមដំណើរការដែលមានរៀបរាប់ក្នុងអនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់

លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ។ ក្នុងគម្រោងដំណាក់កាលទី ៣ អ្នកប្រើប្រាស់ដីដែលមិនមែនជាម្ចាស់ ឬជាអ្នកកាន់កាប់ផ្ទាល់ (ឧ. និយោជិតនៅលើដី អ្នកដែលប្រើប្រាស់ដីសម្រាប់គោលបំណងធនធានទ្រព្យសម្បត្តិរួម។ល។) នឹងត្រូវបានដាក់បញ្ចូលក្នុងការពិគ្រោះយោបល់។ ជនរងផលប៉ះពាល់នឹងទទួលបានជម្រើសសំណងផ្សេងៗ (ឧ. ដីជំនួស ឬសំណងជាប្រាក់) សម្រាប់ឱ្យពួកគេយកទៅពិចារណា។ ការពិគ្រោះយោបល់នឹងរួមមានការស្វែងយល់ពីទស្សនៈវិស័យផ្សេងៗរបស់ក្រុមសង្គមផ្សេងៗ ជាពិសេសស្ត្រីដែលអាចមានការព្រួយបារម្ភ ឬការចង់បានខុសពីបុរស។

141. កិច្ចប្រជុំពិគ្រោះយោបល់ទី ១ ធ្វើឡើងមុនការរៀបចំក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់។ ក្នុងគម្រោងដំណាក់កាលទី ៣ ដំណើរការពិគ្រោះយោបល់នេះរួមមាន ១) ការពិគ្រោះយោបល់អ្នកពាក់ព័ន្ធដែលធ្វើឡើងក្នុងពេលរៀបចំគម្រោង រួមទាំងការផ្សព្វផ្សាយពីក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម ក្របខណ្ឌបរិស្ថាន និងសង្គម និងក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់ និង ២) កិច្ចប្រជុំដោយមានការចូលរួមដែលធ្វើឡើងក្នុងដំណើរការកំណត់អត្តសញ្ញាណ និងរៀបចំផែនការដីសម្រាប់សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។

142. កិច្ចប្រជុំពិគ្រោះយោបល់ទី ១ ធ្វើឡើងនៅថ្នាក់ឃុំ ឬភូមិ មុនការអង្កេតវាស់វែងលម្អិត។ ខិតប័ណ្ណព័ត៌មានគម្រោងនឹងត្រូវបានបង្ហាញជូន និងពន្យល់ដល់សហគមន៍រងផលប៉ះពាល់។ ការអង្កេតវាស់វែងលម្អិតត្រូវបានពន្យល់ និងចែករំលែក។ ក្នុងការអង្កេតនេះ គ្រួសារនឹងមានឱកាសទទួលបានការពន្យល់ផ្ទាល់បន្ថែមទៀតស្តីពីព័ត៌មានក្នុងខិតប័ណ្ណទាំងនេះ។ ក្នុងកិច្ចប្រជុំនេះ នឹងមានការលើកឡើង និងពិភាក្សាពីជម្រើសសំណងផ្សេងៗ។ វិធីសាស្ត្រកិច្ចប្រជុំនឹងរួមមានអនុក្រុម (ស្ត្រី បុរស ក្រុមក្រីក្រ និងងាយរងគ្រោះ ជនជាតិដើមភាគតិចទៅតាមភាពពាក់ព័ន្ធ) ដើម្បីធានាការរួមបញ្ចូលទស្សនៈទាំងអស់។

143. កិច្ចប្រជុំពិគ្រោះយោបល់ទី ៣ ត្រូវបានធ្វើឡើងមុនការចុះហត្ថលេខាលើកិច្ចសន្យា/កិច្ចព្រមព្រៀងសម្រាប់កញ្ចប់សំណង និងធ្វើឡើងរួមគ្នាដោយក្រុមការងាររបស់គណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ និងក្រុមការងាររបស់អនុគណៈកម្មាធិការខេត្តដោះស្រាយផលប៉ះពាល់។ នៅដំណាក់កាលនេះ ការអង្កេតវាស់វែងលម្អិត និងការសិក្សាតម្លៃជំនួសបានបញ្ចប់សព្វគ្រប់ ហើយកញ្ចប់សំណងសម្រាប់គ្រួសាររងផលប៉ះពាល់នីមួយៗត្រូវបានដឹងលឺ និងបានរៀបចំពង្រាកិច្ចសន្យា។ កិច្ចប្រជុំនេះត្រូវបានធ្វើឡើងជាពីរផ្នែក និងមានការជូនដំណឹងជាមុនអំពីកិច្ចប្រជុំនេះដល់គ្រួសាររងផលប៉ះពាល់តាមរយៈការិយាល័យក្រុមប្រឹក្សាឃុំ/ភូមិ។ ក្នុងផ្នែកទី ១ កិច្ចប្រជុំសាធារណៈត្រូវបានធ្វើឡើងនៅថ្នាក់ឃុំ/ភូមិសម្រាប់គ្រួសាររងផលប៉ះពាល់ទាំងអស់ ហើយតំណាងឃុំ/ភូមិ និងខិតប័ណ្ណព័ត៌មានគម្រោងសម្រាប់កញ្ចប់សំណងត្រូវបានផ្តល់ជូន និងពន្យល់ដល់ជនបាត់បង់ទីលំនៅទាំងអស់។ កាលវិភាគសម្រាប់ការចុះហត្ថលេខាលើកិច្ចសន្យាជនបាត់បង់ទីលំនៅ (ដោយមានកាលបរិច្ឆេទកំណត់) និងលក្ខខណ្ឌផ្លូវច្បាប់ក្នុងការទទួលបានសំណង (អត្តសញ្ញាណប័ណ្ណ ភស្តុតាងបង្ហាញពីកម្មសិទ្ធិដី) ក៏នឹងត្រូវបានពន្យល់ផងដែរ។ ក្នុងផ្នែកទី ២ គ្រួសាររងផលប៉ះពាល់នីមួយៗទទួលបានពង្រាងកិច្ចសន្យា ហើយទំហំសំណងត្រូវបានពន្យល់ទៅតាមបំណងរបស់គ្រួសារនីមួយៗ។ អាចការរកឃើញ និងកែតម្រូវកំហុសឆ្គងភ្លាមៗ។ ប៉ុន្តែគ្រួសាររងផលប៉ះពាល់នឹងមិនត្រូវបានតម្រូវ ឬអនុញ្ញាតឱ្យចុះហត្ថលេខាលើកិច្ចសន្យា

ដោយផ្ទាល់ក្នុងកិច្ចប្រជុំនេះទេ (ចំណុចនេះប្រាសចាកពីដំណើរការដែលរៀបរាប់ក្នុងអនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ)។ ពង្រាងកិច្ចសន្យានឹងត្រូវបានរក្សាទុកជាមួយក្រុមការងាររបស់អនុគណៈកម្មាធិការខេត្តដោះស្រាយផលប៉ះពាល់។ គ្រួសាររងផលប៉ះពាល់នឹងទទួលសំណៅឯកសារមួយច្បាប់នៃខ្លឹមសារសង្ខេបទម្រង់ផ្តល់សំណង។

144. គ្រួសាររងផលប៉ះពាល់នឹងត្រូវបានស្នើឱ្យពិចារណាពីកិច្ចសន្យាដែលស្នើឡើង និងពិភាក្សាក្នុងគ្រួសាររបស់ខ្លួន។ គ្រួសារទាំងនោះនឹងត្រូវបានតម្រូវឱ្យមកកាន់សាលាឃុំក្នុងរយៈពេល ៧ ថ្ងៃដើម្បីចុះហត្ថលេខាលើកិច្ចសន្យា ឬជូនដំណឹងដល់អាជ្ញាធរឃុំពីការសម្រេចចិត្តមិនចុះកិច្ចសន្យា ដោយផ្តល់ហេតុផល (មើលផ្នែក ៩.៨.១ ខាងក្រោម)។

145. កិច្ចប្រជុំពិគ្រោះយោបល់ទី ៤ ត្រូវបានធ្វើឡើងនៅពេលត្រៀមការទូទាត់ជាស្រេច និងធ្វើឡើងរួមគ្នាដោយក្រុមការងាររបស់គណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ និងក្រុមការងាររបស់អនុគណៈកម្មាធិការខេត្តដោះស្រាយផលប៉ះពាល់។ កាលវិភាគសម្រាប់ការទូទាត់សំណងនឹងត្រូវបានផ្សព្វផ្សាយដល់ជនបាត់បង់ទីលំនៅក្នុងរយៈពេលយ៉ាងតិច ១ សប្តាហ៍ជាមុននៅសាលាឃុំ និងភូមិ។ កិច្ចប្រជុំនេះធ្វើឡើងក្នុងឃុំ ឬភូមិ និងមុនការចាប់ផ្តើមការទូទាត់សំណង ហើយគ្រួសាររងផលប៉ះពាល់បានដឹងពីយន្តការដោះស្រាយបណ្តឹងតវ៉ា និងនីតិវិធីដែលត្រូវអនុវត្តក្នុងករណីដែលពួកគេមានបណ្តឹងពាក់ព័ន្ធនឹងការទូទាត់សំណង។ ការទូទាត់សំណងធ្វើឡើងតាមគ្រួសារ ហើយគ្រួសាររងផលប៉ះពាល់នីមួយៗមានឱកាសស្វែងរកការបញ្ជាក់ពីកញ្ចប់សំណងមុននឹងទទួលបានសំណង។

146. អនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញក៏ចែងពីការពិគ្រោះយោបល់ជាមួយគ្រួសាររងផលប៉ះពាល់ដែលត្រូវបានផ្លាស់ទីតាំងទីកាន់ទីតាំងសម្រាប់ការតាំងទីលំនៅឡើងវិញ រួមមានការផ្តល់មន្ត្រីអភិវឌ្ឍន៍សហគមន៍ដែលនឹងផ្តល់ការណែនាំ និងជំនួយដល់គ្រួសារទាំងនោះ។ ក្នុងគម្រោងជំណាក់កាលទី៣ ប្រសិនបើចាំបាច់ត្រូវមានការតាំងទីលំនៅឡើងវិញរបស់គ្រួសាររងផលប៉ះពាល់ ចំណុះនេះតែងធ្វើឡើងនៅទីតាំងសម្រាប់សម្បទានដីសង្គមកិច្ច ឬទីតាំងផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ដែលគ្រួសារទាំងនោះនឹងទទួលបានអត្ថប្រយោជន៍ពីជំនួយសម្រាប់ការតាំងទីលំនៅដែលផ្តល់ដោយគម្រោង។

# ៩.ការអនុវត្តផែនការដោះស្រាយផលប៉ះពាល់

## ៩.១ ទម្រង់កិច្ចសន្យាការអង្កេតវាស់វែងលម្អិតសម្រាប់សំណង

147. ជនដែលរងផលប៉ះពាល់ ទទួលបានកញ្ចប់សំណង់តាមរយៈកិច្ចសន្យាការអង្កេតវាស់វែងលម្អិតផ្លូវការ និងចងកាតព្វកិច្ចរវាងក្រុមការងាររបស់គណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ និងជន/គ្រួសារដែលរងផលប៉ះពាល់។ ពង្រាងកិច្ចសន្យាការអង្កេតវាស់វែងលម្អិតត្រូវបានរៀបចំឡើងដោយក្រុមការងាររបស់គណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ដោយផ្អែកលើការគណនាសំណងដោយនាយកដ្ឋានត្រួត

ពិនិត្យផ្ទៃក្នុង និងគ្រប់គ្រងទិន្នន័យ ដែលនឹងរួមមានទម្រង់សំណងសង្ខេបដែលបង្ហាញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិដែលបាត់បង់ ការវាស់វែង និងការគណនាលម្អិតពីសំណងសម្រាប់ប្រភេទនៃទ្រព្យសម្បត្តិនីមួយៗដែលបាត់បង់ និងឯកសារទ្រទ្រង់ផ្សេងទៀត។

148. ដូចការរៀបរាប់ខាងលើ ជនរងផលប៉ះពាល់នឹងត្រូវបានស្នើឱ្យចុះហត្ថលេខាលើកិច្ចសន្យាការអង្កេតវាស់វែងលម្អិតនៅសាលាឃុំក្នុងរយៈពេល ៧ ថ្ងៃនៃកាលបរិច្ឆេទកិច្ចប្រជុំពិគ្រោះយោបល់ទី ៣។ តំណាងក្រុមការងាររបស់អនុគណៈកម្មាធិការខេត្តដោះស្រាយផលប៉ះពាល់នឹងមានវត្តមាននៅសាលាឃុំក្នុងម៉ោងការងារនៅអំឡុងពេលនេះដើម្បីផ្តល់ពង្រាកិច្ចសន្យាសម្រាប់ចុះហត្ថលេខា។ ក្រោយការចុះហត្ថលេខា ជនដែលរងផលប៉ះពាល់នឹងទទួលបានសំណៅមួយច្បាប់នៃខ្លឹមសារសង្ខេបស្តីពីទម្រង់ផ្តល់សំណង ហើយជនដែលរងផលប៉ះពាល់ត្រូវបង្ហាញទម្រង់នេះនៅដំណាក់កាលទូទាត់។

149. ក្រៅពីនេះ ជនដែលរងផលប៉ះពាល់មានសិទ្ធិ ៖

- បដិសេធមិនចុះហត្ថលេខាលើកិច្ចសន្យា។ ក្នុងករណីនេះ ជនដែលរងផលប៉ះពាល់នឹងត្រូវបានស្នើឱ្យបំពេញទម្រង់បណ្តឹង ដែលបញ្ជាក់ពីមូលហេតុនៃការមិនចុះហត្ថលេខា។ ចំណុចនេះត្រូវបានចាត់ទុកជាការជូនដំណឹងពីបណ្តឹងតវ៉ាដែលត្រូវដោះស្រាយតាមរយៈយន្តការដោះស្រាយបណ្តឹងតវ៉ា
- ចុះហត្ថលេខាលើកិច្ចសន្យា និងបំពេញទម្រង់ពាក្យបណ្តឹងដែលត្រូវដោះស្រាយតាមរយៈយន្តការដោះស្រាយបណ្តឹងតវ៉ា។

150. ជនរងផលប៉ះពាល់ដែលមិនយល់ព្រមចុះហត្ថលេខាលើកិច្ចសន្យា និងមិនបានដាក់បណ្តឹងរកដំណោះស្រាយក្រោមដំណើរការយន្តការដោះស្រាយបណ្តឹងតវ៉ា ក្នុងរយៈពេល ១ ខែ ចាប់ពីកាលបរិច្ឆេទផ្តល់ជូន (លើកលែងតែករណីដែលមិនអាចចុះកិច្ចសន្យាបានដោយអាជ្ញាធរមូលដ្ឋាន) នឹងត្រូវបានចាត់ចូលជាស្វ័យប្រវត្តិថាបានដាក់បណ្តឹង ហើយករណីនេះនឹងត្រូវបានដាក់បញ្ចូលក្នុងយន្តការដោះស្រាយបណ្តឹងតវ៉ា។ ការមិនបានចុះហត្ថលេខា ឬដាក់បណ្តឹងផ្លូវការនឹងមិនបណ្តាលឱ្យបាត់បង់សិទ្ធិទទួលបានសំណងដោយស្វ័យប្រវត្តិឡើយ។

151. ក្នុងករណីដែលជនរងផលប៉ះពាល់មិនអាចទាក់ទងបាន ឬមិនអាចចូលរួមចុះហត្ថលេខាលើកិច្ចសន្យា ក្រុមការងាររបស់គណៈកម្មាធិការអន្តរក្រសួងក្រោយជំនួយរបស់ក្រុមការងាររបស់អនុគណៈកម្មាធិការខេត្ត នឹងអនុវត្តជំហានដូចខាងក្រោម ៖

- ការជូនដំណឹងទូទៅនៅសាលាឃុំ និងភូមិ ឬនៅរោងសហគមន៍ ប្រសិនបើមាន
- អាជ្ញាធរឃុំ និងភូមិនឹងត្រូវបានស្នើឱ្យកំណត់ទីកន្លែងរបស់ជនរងផលប៉ះពាល់តាមរយៈមិត្តភក្តិ និងគ្រួសារក្នុងសហគមន៍រងផលប៉ះពាល់
- ប្រសិនបើមិនបានកំណត់ទីតាំងរបស់ជនដែលរងផលប៉ះពាល់ក្នុងរយៈពេល ១៥ ថ្ងៃក្រោយការបិទបង្ហាញការជូនដំណឹងក្នុងសាលាឃុំ និងភូមិ នឹងមានការផ្សព្វផ្សាយក្នុងកាសែតក្នុងស្រុកដោយមានកាលបរិច្ឆេទកំណត់ ៣០ ថ្ងៃចាប់ពីកាលបរិច្ឆេទផ្សព្វផ្សាយ។ ប្រសិនបើជនដែលរងផលប៉ះ

ពាល់មិនឆ្លើយតប ឬបង្ហាញខ្លួនមុនកាលបរិច្ឆេទកំណត់ នឹងគ្មានការប៉ុនប៉ងបន្ថែមទៀតដើម្បីទាក់ទងពួកគេពាក់ព័ន្ធនឹងការផ្តល់សំណងឡើយ។

152. សំណងនឹងត្រូវបានទូទាត់តាមរយៈគណនីរបស់គម្រោងដែលបង្កើតឡើងសម្រាប់គោលបំណងនៃដោយអនុគណៈកម្មាធិការខេត្ត។ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ត្រូវជានាតម្លាភាព និងសុចរិតភាពក្នុងការចំណាយថវិកា និងការទូទាត់សំណង ដែលផ្អែកតាមគោលការណ៍ដូចខាងក្រោម ៖

- ការទូទាត់សំណងពេញលេញត្រូវផ្តល់ជូនជនរងផលប៉ះពាល់ទាំងអស់មុនធ្វើលទ្ធកម្មដីធ្លី
- ការទូទាត់ប្រាក់ឧបត្ថម្ភទាំងអស់ត្រូវបញ្ចប់មុនពេលផ្លាស់ទៅទីតាំងថ្មី ឬផ្លាស់ទីតាំងដោយខ្លួនឯង
- ការទូទាត់នឹងធ្វើឡើងក្រោមឈ្មោះរួមគ្នារបស់ប្តី/ប្រពន្ធ ឬមេគ្រួសារតែម្នាក់របស់គ្រួសាររងផលប៉ះពាល់ ក្នុងករណីដែលអាចអនុវត្តបាន ឬមនុស្សពេញវ័យណាម្នាក់ក្នុងករណីប្តី/ប្រពន្ធមិនអាចទទួលការទូទាត់បាន។
- ការទូទាត់គួរធ្វើឡើងតាមធនាគារ។ ប៉ុន្តែក្នុងករណីដែលគ្មានលទ្ធភាពប្រើប្រាស់សេវាធនាគារ ឬមានការលំបាក ការទូទាត់ប្រាក់អាចធ្វើឡើងដោយមានការធានាសុវត្ថិភាពចាំបាច់សម្រាប់ជនរងផលប៉ះពាល់ដើម្បីផ្ទៀងផ្ទាត់ថា ពួកគេបានទទួលការទូទាត់។
- ការទូទាត់ទាំងអស់គួរធ្វើឡើងនៅទីសាធារណៈតាមដែលអាចធ្វើទៅបាន និងដឹងលឺដោយតំណាងម្នាក់របស់អាជ្ញាធរមូលដ្ឋាន និងយ៉ាងហោចណាស់មានសាក្សីម្នាក់ដែលមិនមែនជាមន្ត្រីគម្រោង ឬមន្ត្រីអាជ្ញាធរមូលដ្ឋាន។

153. មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើរតួនាទីយ៉ាងសំខាន់ក្នុងក្រុមការងាររបស់អនុគណៈកម្មាធិការខេត្ត ក្នុងការបែងចែកការទូទាត់។ DIMDM ទទួលខុសត្រូវលើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ដំណើរការទូទាត់។ ក្រុមការងាររបស់អនុគណៈកម្មាធិការខេត្តនឹងជូនដំណឹងដល់អាជ្ញាធរឃុំ និងភូមិទៅតាមកាលបរិច្ឆេទកំណត់សម្រាប់ការចាប់ផ្តើមការទូទាត់ យ៉ាងហោចណាស់ ៣ ថ្ងៃមុន។ ការជូនដំណឹងនឹងធ្វើឡើងនៅសាលាឃុំ និងភូមិ និងរោងសហគមន៍ក្នុងពេលដំណាលគ្នា ប្រសិនបើអាច។ អាជ្ញាធរឃុំ និងភូមិនឹងខិតខំអស់ពីសមត្ថភាពក្នុងការជូនដំណឹងដល់ជនរងផលប៉ះពាល់ស្តីពីកាលបរិច្ឆេទកំណត់សម្រាប់ការចាប់ផ្តើមការទូទាត់។ នៅកាលបរិច្ឆេទទូទាត់ នឹងមានកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈដើម្បីពន្យល់ពីនីតិវិធីដែលត្រូវអនុវត្តមុនពេលចាប់ផ្តើមការទូទាត់សម្រាប់ជនរងផលប៉ះពាល់ម្នាក់ៗ។ ការទូទាត់ជាក់ស្តែងធ្វើឡើងនៅទីសាធារណៈដោយក្រុមការងាររបស់អនុគណៈកម្មាធិការខេត្តក្រោមកិច្ចសហការជាមួយក្រុមការងាររបស់គណៈកម្មាធិការអន្តរក្រសួង។

## ៩.២ សកម្មភាពកម្មវិធីស្តារប្រាក់ចំណូលឡើងវិញ

154. សកម្មភាពក្នុងកម្មវិធីស្តារប្រាក់ចំណូលឡើងវិញ នឹងត្រូវបានអនុវត្តតាមរយៈយន្តការធម្មតាសម្រាប់ការអនុវត្តអនុគម្រោងរបរចិញ្ចឹមជីវិតក្នុងគម្រោងដំណាក់កាលទី ៣។

155.	សកម្មភាពស្តារប្រាក់ចំណូលឡើងវិញគួរចាប់ផ្តើមឡើងនមុនកាលបរិច្ឆេទផ្លាស់ទីលំនៅចេញពីដីធ្លី ឬភ្លាមៗក្រោយការផ្លាស់ទីលំនៅចេញ។

156.	នៅពេលទូទាត់សំណង ក្រុមគម្រោងនឹងរៀបចំបញ្ជីឈ្មោះអ្នកចូលរួមក្នុងសកម្មភាពនីមួយៗនៃកម្មវិធីស្តារប្រាក់ចំណូលឡើងវិញ ដោយមានព័ត៌មានទំនាក់ទំនងបច្ចុប្បន្នភាព ដើម្បីឱ្យអ្នកចូលរួមបានដឹងពីរបៀបពេលវេលា និងទីកន្លែងចូលរួមក្នុងសកម្មភាពទាំងនេះ។

## ៩.៣ កាលបរិច្ឆេទផ្លាស់ទីលំនៅចេញពីដី

157.	ម្ចាស់ និង/ឬអ្នកមានសិទ្ធិពិតប្រាកដលើអចលនវត្ថុមិនត្រូវកាន់កាប់អចលនវត្ថុលើពី ១ ខែក្រោយពេលដែលគណៈកម្មាធិការអស្សាមិករណ៍បានផ្តល់សំណងពេញលេញ ឬផ្តល់សំណងពេញលេញក្នុងករណីជនបាត់បង់ទីលំនៅដែលបដិសេធមិនទទួលយក។

158.	ជនដែលរងផលប៉ះពាល់នឹងបានដឹងថា ក្រោមច្បាប់ស្តីពីអស្សាមិករណ៍ ការដកហូតដីធ្លី និងទ្រព្យសម្បត្តិរបស់ពួកគេនៅតែធ្វើឡើង ទោះបីជាមានវិវាទដែលមិនទាន់បានដោះស្រាយក្តី។

159.	ក្នុងករណីដែលម្ចាស់ និង/ឬអ្នកមានសិទ្ធិពិតប្រាកដលើអចលនវត្ថុដែលត្រូវបានដកហូត បដិសេធមិនផ្លាស់ទីកន្លែង គណៈកម្មាធិការអស្សាមិករណ៍អាចស្នើឱ្យស្ថាប័នមានសមត្ថកិច្ច ឬអាជ្ញាធរសាធារណៈចាត់វិធានការផ្លាស់ទីតាំងចេញពីអចលនវត្ថុដែលបានដកហូត។ អាជ្ញាធរពាក់ព័ន្ធនៅថ្នាក់ខេត្តនឹងទទួលខុសត្រូវលើការធានាថា អចលនវត្ថុដែលត្រូវបានដកហូតត្រូវបានផ្លាស់ទីតាំងមុនកាលបរិច្ឆេទកំណត់រយៈពេល ១ ខែ។

## ៩.៤ ការពិនិត្យតាមដានផែនការដោះស្រាយផលប៉ះពាល់

160.	ការទទួលខុសត្រូវបឋមលើការប្រមូលទិន្នន័យ និងព័ត៌មានស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការដោះស្រាយផលប៉ះពាល់ក្នុងអនុគម្រោងនៅតាមមូលដ្ឋាន ជាបន្ទុករបស់ក្រុមការងារគណៈកម្មាធិការអន្តរក្រសួង និងក្រុមការងារអនុគណៈកម្មាធិការខេត្ត ដែលនឹងដាក់របាយការណ៍ប្រចាំខែទៅអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់។ អគ្គនាយកដ្ឋាននេះនឹងរៀបចំរបាយការណ៍ចុះវាល និងរៀបចំរបាយការណ៍បូកសរុបសម្រាប់គម្រោងជារៀងរាល់ខែ។ របាយការណ៍នេះនឹងត្រូវដាក់ជូន DIMDM ដែលទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង។ ការទទួលខុសត្រូវរបស់ DIMDM រួមមាន ១) ពិនិត្យឡើងវិញលើរបាយការណ៍វឌ្ឍនភាពប្រចាំខែ រួមទាំងការចុះបេសកកម្មតាមវាលដើម្បីផ្ទៀងផ្ទាត់វឌ្ឍនភាព និងសុពលភាពព័ត៌មាន និងទិន្នន័យ ប្រសិនបើចាំបាច់ និង ២) រៀបចំរបាយការណ៍ពិនិត្យតាមដានប្រចាំត្រីមាសសម្រាប់ដាក់ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់។ ក្រោយការអនុម័តរបាយការណ៍ប្រចាំត្រីមាសដោយអគ្គនាយកដ្ឋាន របាយការណ៍នោះនឹងត្រូវបានដាក់ជូនដៃគូអភិវឌ្ឍន៍ក្នុងករណីចាំបាច់។

161. ក្នុងគម្រោងដំណាក់កាលទី ៣ ពង្រាងរបាយការណ៍នេះនឹងត្រូវបានដាក់ជូនក្រសួងរៀបចំដែនដីពិនិត្យ និងអនុម័ត។

162. ក្រសួងរៀបចំដែនដីនឹងដាក់របាយការណ៍សង្ខេបស្តីពីវឌ្ឍនភាពផែនការដោះស្រាយផលប៉ះពាល់តាមអនុគម្រោង និងរបាយការណ៍វឌ្ឍនភាពរួមទៅធនាគារពិភពលោក និងធ្វើបច្ចុប្បន្នភាពជាប្រចាំជូនប្រធានក្រុមការងារធនាគារពិភពលោកស្តីពីការអនុវត្តផែនការដោះស្រាយផលប៉ះពាល់ និងបញ្ហាប្រឈមនានា។ទម្រង់របាយការណ៍វឌ្ឍនភាពផែនការដោះស្រាយផលប៉ះពាល់តាមអនុគម្រោងមានបង្ហាញក្នុងឧបសម្ព័ន្ធ ៤ ចំណែករបាយការណ៍វឌ្ឍនភាពរួមមានបង្ហាញក្នុងឧបសម្ព័ន្ធ ៥។

163. ទម្រង់សម្រាប់របាយការណ៍វឌ្ឍនភាពនឹងរួមមាន ១) ការកំណត់ការរៀបចំផ្នែកស្ថាប័ន ២) ការទូទាត់សំណងសម្រាប់សិទ្ធិទទួលបាន ៣) ការអភិវឌ្ឍទីតាំងសម្រាប់ការតាំងទីលំនៅឡើងវិញ និងការផ្លាស់ទីតាំងប្រសិនបើមាន ៤) ការដោះស្រាយបណ្តឹងតវ៉ា ៥) ការពិគ្រោះយោបល់ជាសាធារណៈ ៦) ចំណាយថវិកា ៧) កម្មវិធីទ្រទ្រង់របរចិញ្ចឹមជីវិត តាមដែលអាចអនុវត្តបាន ៨) វឌ្ឍនភាពជារួមធៀបនឹងកាលវិភាគអនុវត្តន៍ដែលបានព្រមព្រៀង ៩) បញ្ហាសំខាន់ៗ និង ១០) វិធានការដោះស្រាយដែលលើកឡើង។

164. ការត្រួតពិនិត្យខាងក្រៅ ៖ អនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ ចែងពីការពិនិត្យតាមដានខាងក្រៅលើលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ សម្រាប់គម្រោងដែលបង្កផលប៉ះពាល់ធ្ងន់ធ្ងរជាការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត និងការតាំងទីលំនៅឡើងវិញទ្រង់ទ្រាយធំដែលពាក់ព័ន្ធនឹងជនបាត់បង់ទីលំនៅលើស ២០០ នាក់។ ខណៈដែលវិសាលភាពនៃផលប៉ះពាល់ហាក់មិនលេចឡើងក្នុងគម្រោងដំណាក់កាលទី ៣ គម្រោងនៅតែប្រឈមនឹងហានិភ័យធ្ងន់ធ្ងរពាក់ព័ន្ធនឹងការទន្ទ្រានកាន់កាប់ក្នុងតំបន់សម្រាប់សម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងបញ្ហាពាក់ព័ន្ធនឹងលទ្ធកម្មដីធ្លី ហើយនឹងចាប់ផ្តើមកំណត់បទពិសោធន៍ពាក់ព័ន្ធនឹងការរៀបចំ និងអនុវត្តការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងផែនការដោះស្រាយផលប៉ះពាល់ ពាក់ព័ន្ធ។ ដូច្នេះ ការត្រួតពិនិត្យខាងក្រៅដើម្បីកំណត់រក និងរៀបរាប់ពីបញ្ហាប្រឈម និងឱកាសក្នុងការដោះស្រាយបញ្ហាទាំងនេះនឹងជួយឱ្យគម្រោងទាញយកមេរៀនបានឆាប់រហ័ស។ ដូច្នេះ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់នឹងជ្រើសរើសទីភ្នាក់ងារខាងក្រៅក្នុងស្រុកដែលមានបទពិសោធន៍ (ក្រុមហ៊ុនក្នុងស្រុក ឬបុគ្គល) ដើម្បីផ្ទៀងផ្ទាត់របាយការណ៍ត្រួតពិនិត្យផ្ទៃក្នុង និងផ្តល់យោបល់ជូនអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ស្តីពីបញ្ហានៃការអនុលោមតាមការធានាសុវត្ថិភាពធៀបនឹងលក្ខខណ្ឌយោងដែលត្រូវសម្រេចយកដោយអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ ក្រសួងរៀបចំដែនដី និងធនាគារពិភពលោក ក្នុងករណីដែលផែនការដោះស្រាយផលប៉ះពាល់ត្រូវបានរៀបចំឡើងក្រោមគម្រោងដំណាក់កាលទី ៣។

## ១០.យន្តការដោះស្រាយបណ្ដឹងតវ៉ា

### ១០.១ គម្រោងដំណាក់កាលទី ៣ និងយន្តការដោះស្រាយបណ្ដឹងតវ៉ាក្នុងនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ

165. គម្រោងដំណាក់កាលទី ៣ នឹងបង្កើតយន្តការដោះស្រាយបណ្ដឹងតវ៉ាក្នុងគម្រោង ដូចមានរៀបរាប់ក្នុងផែនការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ។ អ្នកពាក់ព័ន្ធទាំងអស់ក្នុងគម្រោងដំណាក់កាលទី ៣ នឹងអាចប្រើប្រាស់យន្តការនេះ និងអាចដាក់បណ្ដឹងតាមរយៈបណ្ដាញផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ ដោយមិនបង្ហាញអត្តសញ្ញាណ។ រាល់បណ្ដឹងដែលទទួលបាននឹងត្រូវបានកត់ត្រាទុក និងធ្វើការពិនិត្យបឋម។ បណ្ដឹងដែលមិនអាចដោះស្រាយបានភ្លាមៗនឹងត្រូវបញ្ជូនទៅគណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ា ដែលនឹងធ្វើការស៊ើបអង្កេត និងផ្ដល់អនុសាសន៍លើចំណាត់ការ។ ការស៊ើបអង្កេតបណ្ដឹងនឹងត្រូវបញ្ចប់ក្នុងរយៈពេល ៣០ ថ្ងៃតាមដែលអាចធ្វើទៅបាន ហើយក្នុងករណីដែលមិនអាចបញ្ចប់បាន នឹងមានការជូនដំណឹងដល់អ្នកដាក់បណ្ដឹងពីមូលហេតុ។ អ្នកដាក់បណ្ដឹងនឹងទទួលបានដំណឹងស្ដីពីវឌ្ឍនភាព និងលទ្ធផល។ មិនអនុញ្ញាតឱ្យមានការដាក់ទណ្ឌកម្មលើអ្នកដាក់បណ្ដឹងទៅយន្តការដោះស្រាយបណ្ដឹងតវ៉ាឡើយ ហើយក៏មិនប៉ះពាល់ដល់សិទ្ធិរបស់អ្នកដាក់បណ្ដឹងក្នុងការទទួលបានដំណោះស្រាយពីតុលាការ ឬដំណោះស្រាយផ្សេងទៀតដែរ។

166. ក្នុងករណីដែលត្រូវមានការរៀបចំផែនការដោះស្រាយផលប៉ះពាល់ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់នឹងពិចារណាថាតើយន្តការដោះស្រាយផលប៉ះពាល់របស់គម្រោង អាចបំពេញលក្ខខណ្ឌតម្រូវនៃយន្តការដោះស្រាយផលប៉ះពាល់ដែលត្រូវបានកំណត់ក្នុងអនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ។ ការសម្រេចលើបញ្ហានេះនឹងពិចារណាពីវិសាលភាពនៃការតាំងទីលំនៅឡើងវិញចាំបាច់។ ប្រសិនបើអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់យល់ថាមានភាពចាំបាច់ក្នុងការបំពេញលក្ខខណ្ឌតម្រូវនៃអនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ បុគ្គលិកក្នុងយន្តការដោះស្រាយបណ្ដឹងតវ៉ានឹងត្រូវបានពង្រឹងសមត្ថភាពក្នុងការដោះស្រាយបញ្ហាបន្ទុកករណីបណ្ដឹង។

167. ក្នុងករណីដែលអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់កំណត់ថា មានភាពចាំបាច់ក្នុងការបង្កើតយន្តការដោះស្រាយផលប៉ះពាល់ដាច់ដោយឡែកដូចមានចែងក្នុងនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ (យន្តការដោះស្រាយបណ្ដឹងតវ៉ាសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ) យន្តការដោះស្រាយបណ្ដឹងតវ៉ាក្នុងគម្រោងដំណាក់កាលទី ៣ នឹងនៅតែអាចប្រើប្រាស់សម្រាប់ជនដែលរងផលប៉ះពាល់ដោយសារគម្រោង និងអ្នកពាក់ព័ន្ធ។ ក្នុងករណីនោះ បណ្ដឹងនឹងត្រូវបានពិចារណាដំបូងគេដោយគណៈកម្មាធិការខេត្តដោះស្រាយបណ្ដឹងតវ៉ាក្នុងគម្រោងដំណាក់កាលទី ៣។ ប្រសិនបើគណៈកម្មាធិការនេះសម្រេចថា ករណីនេះត្រូវមានអន្តរាគមន៍ពីអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ គណៈកម្មាធិការនឹងបញ្ជូនករណីនេះបូករួមនឹងភស្តុតាងប្រមូលបាន ទៅយន្តការដោះស្រាយបណ្ដឹងតវ៉ាសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ។ អ្នកដាក់បណ្ដឹងនឹងត្រូវបានជូនដំណឹងពីការបញ្ជូនបណ្ដឹងរបស់ខ្លួនទៅយន្តការដោះស្រាយបណ្ដឹងតវ៉ាសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ។ បណ្ដឹងនេះ និងសេចក្ដីសម្រេចបញ្ជូនករណី នឹង

ត្រូវបានកត់ត្រាក្នុងសៀវភៅបញ្ជីបណ្តឹងរបស់យន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងគម្រោងដំណាក់កាលទី ៣។ អ្នកដាក់បណ្តឹងនឹងមានជម្រើសក្នុងការដាក់បណ្តឹងដោយផ្ទាល់ទៅយន្តការដោះស្រាយបណ្តឹងតវ៉ាសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ។

## ១០.២ ការពិពណ៌នាពីយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងគម្រោងដំណាក់កាលទី ៣

168. យន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងគម្រោងដំណាក់កាលទី ៣ ត្រូវបានកំណត់ និងរៀបរាប់ក្នុងផែនការជំរុញការចូលរួមរបស់គម្រោងដំណាក់កាលទី ៣។ យន្តការនេះនឹងត្រូវបានដាក់ឱ្យប្រើប្រាស់សម្រាប់ជនរងផលប៉ះពាល់ទាំងអស់ និងអ្នកពាក់ព័ន្ធផ្សេងទៀត សម្រាប់បណ្តឹងដែលពាក់ព័ន្ធនឹងផ្នែកនានានៃគម្រោងដំណាក់កាលទី ៣ ដូចជា បញ្ហាដែលកំណត់ក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ១-១០។ ប៉ុន្តែគម្រោងនឹងបង្កើតយន្តការដោះស្រាយបណ្តឹងដោយឡែកមួយសម្រាប់កម្មករធ្វើការក្នុងគម្រោង ទៅតាមលក្ខខណ្ឌតម្រូវក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ២។

169. យន្តការនេះនឹងទទួល កត់ត្រា និងពិនិត្យឡើងវិញលើបណ្តឹងដែលពាក់ព័ន្ធនឹងគម្រោង និងផលប៉ះពាល់របស់គម្រោងប្រកបដោយយុត្តិធម៌ និងតម្លាភាព និងផ្តល់ដំណោះស្រាយសមស្រប។ យន្តការនេះនឹងរក្សាការសម្ងាត់ និងទទួលយកបណ្តឹងដែលបានដាក់ជាអនាមិក។ អ្នកពាក់ព័ន្ធទាំងអស់នឹងបានដឹងច្បាស់ពីយន្តការនេះ ដូចជា របៀបដាក់បណ្តឹង នីតិវិធីដោះស្រាយបណ្តឹង និងថិរវេលានៃការចេញសេចក្តីសម្រេច។ យន្តការនេះនឹងផ្សារភ្ជាប់នឹងយន្តការបណ្តឹងមានស្រាប់ (ប្រព័ន្ធការិយាល័យប្រជាពលរដ្ឋ និងគណៈកម្មការសុរិយោដី)។ ការប្រើប្រាស់យន្តការនេះនឹងមិនប៉ះពាល់ដល់លទ្ធភាពរបស់អ្នកដាក់បណ្តឹងក្នុងការទទួលបានដំណោះស្រាយផ្លូវតុលាការ ឬដំណោះស្រាយរដ្ឋបាលជាជម្រើស។

170. គោលការណ៍សំខាន់នៃ ១) ភាពបើកចំហរ និងតម្លាភាព ២) យុត្តិធម៌ ៣) ភាពអាចប្រើប្រាស់បាន ៤) ភាពឆ្លើយតប និងប្រសិទ្ធភាព និង ៥) អនាមិកភាព និងការសម្ងាត់ ជាមូលដ្ឋាននៃការរៀបចំយន្តការដោះស្រាយបណ្តឹងតវ៉ានេះ។

171. ក្រសួងរៀបចំដែនដីដែលជាស្ថាប័នដឹកនាំការអនុវត្តគម្រោង នឹងទទួលខុសត្រូវរួមលើយន្តការនេះ ៖ ១) ការចុះបញ្ជីបណ្តឹងទាំងអស់ដែលបានដាក់ និងលទ្ធផល ២) ការកសាងសមត្ថភាព និងការផ្តល់ជំនួយគាំទ្រ និងការណែនាំដល់ស្ថាប័នអនុវត្តន៍ និងដៃគូទាំងអស់ និង ៣) ការធ្វើអន្តរាគមន៍ផ្ទាល់ដើម្បីគាំទ្រដល់ដំណោះស្រាយបណ្តឹងក្នុងករណីចាំបាច់។

172. គម្រោងនឹងបង្កើតគណៈកម្មាធិការដោះស្រាយបណ្តឹង នៅថ្នាក់ជាតិ ដែលធ្វើជាប្រធានដោយប្រធានគម្រោង និងរួមបញ្ចូលមន្ត្រីបង្គោលយន្តការដោះស្រាយបណ្តឹងតវ៉ាមកពីស្ថាប័នអនុវត្តថ្នាក់ជាតិនីមួយៗ។ យន្តការនេះក៏នឹងចូលរួមដោយអង្គការមិនមែនរដ្ឋាភិបាលផងដែរ។ គម្រោងនឹងបង្កើតគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាថ្នាក់ខេត្តនៅតាមខេត្តនីមួយៗដែលមានសម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព

របស់សហគមន៍ជនជាតិដើមភាគតិច។ គណៈកម្មាធិការនេះនឹងធ្វើជាប្រធានដោយប្រធានក្រុមគម្រោងថ្នាក់ខេត្ត និងរួមបញ្ចូលតំណាងមកពីស្ថាប័នអនុវត្តន៍នីមួយៗ និងសមាជិកម្នាក់មកពីអង្គភាពត្រួតពិនិត្យបណ្តឹងរដ្ឋបាលថ្នាក់ខេត្ត។ គណៈកម្មាធិការទទួលបន្ទុកអ្នកទទួលបានដីធ្លីពីសម្បទានដីសង្គមកិច្ច និងគណៈកម្មាធិការគ្រប់គ្រងដីធ្លីសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនីមួយៗ នឹងជ្រើសរើសតំណាងមួយរូប ដែលនឹងត្រូវបានបណ្តុះបណ្តាលពីការដំណើរការយន្តការដោះស្រាយផលប៉ះពាល់ ហើយនឹងចូលរួមជាសមាជិករបស់គណៈកម្មាធិការដោះស្រាយបណ្តឹងថ្នាក់ខេត្ត នៅពេលមានការពិចារណាពីបណ្តឹងពាក់ព័ន្ធនឹងសម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចដែលពួកគេធ្វើជាតំណាង។




*រូប ១ ៖ ការទទួលខុសត្រូវតាមស្ថាប័នក្នុងយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងគម្រោងដំណាក់កាលទី ៣*

173. អ្នកពាក់ព័ន្ធអាចដាក់បណ្តឹងតាមមធ្យោបាយសមស្រប។ អ្នកដាក់បណ្តឹងអាចស្នើសុំមិនបង្ហាញអត្តសញ្ញាណ ពោលគឺគ្មានការបង្ហាញឈ្មោះពួកគេជាសាធារណៈ។ ក្រៅពីនេះ មានការសង្កេតមើលការរក្សាការសម្ងាត់ក្នុងអំឡុងពេលដែលយន្តការដោះស្រាយបណ្តឹងតវ៉ាកំពុងពិចារណាពីករណីមួយ។

174. បុគ្គលិកគម្រោងនឹងត្រូវបានបណ្តុះបណ្តាលពីការចាត់វិធានការនានា ប្រសិនបើពួកគេបានដឹងពីបណ្តឹងណាមួយ ដូចជា ១) របៀបពន្យល់ពីសិទ្ធិរបស់អ្នកពាក់ព័ន្ធដែលដាក់បណ្តឹង ដំណើរការបណ្តឹង និងជម្រើសរក្សាអនាមិកភាព ២) ការកត់ត្រាបណ្តឹងក្នុងទម្រង់ស្តង់ដារ (ឧបសម្ព័ន្ធ ៩) និង ៣) ការបញ្ជូនទម្រង់ពាក្យបណ្តឹងដែលបំពេញរួមបូករួមនឹងបណ្តឹងជាលាយលក្ខណ៍អក្សរ ឬភស្តុតាងឯកសារផ្សេងទៀតទៅលេខាគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាថ្នាក់ខេត្ត។

175. ក្រោយត្រូវបានជូនដំណឹងពីបណ្តឹង លេខាគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាថ្នាក់ខេត្តនឹង ១) បញ្ចូលព័ត៌មានលម្អិតក្នុងបញ្ជីពាក្យបណ្តឹង ដែលត្រូវបានបូកសរុបនៅថ្នាក់ជាតិ ២) ចម្លងបញ្ជីបច្ចុប្បន្នភាពដាក់ជូនប្រធានក្រុមគម្រោងថ្នាក់ខេត្ត ៣) សហការជាមួយបុគ្គលិកដែលត្រូវបានបណ្តុះបណ្តាលម្នាក់ ដើម្បីពិនិត្យបឋមលើបណ្តឹងដើម្បីកំណត់ថាតើវាពាក់ព័ន្ធនឹងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ឬទេ និងពាក់ព័ន្ធនឹងសារជាតុដែលអាចស៊ើបអង្កេត និង ៤) ជូនដំណឹងដល់អ្នកដាក់បណ្តឹងជាលាយលក្ខណ៍អក្សរថាបានទទួលស្គាល់បណ្តឹង បញ្ជាក់ពីចំណាត់ការតាមដានបន្តដែលនឹងធ្វើឡើង និងសិទ្ធិរបស់អ្នកដាក់បណ្តឹង។

176. ប្រធានគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាថ្នាក់ខេត្តនឹងចាត់តាំងមន្ត្រីគម្រោង ២ នាក់ដែលមានការបណ្តុះបណ្តាលសមស្រប ដើម្បីស៊ើបអង្កេតបណ្តឹង រួមទាំងការសួរចម្លើយអ្នកដាក់បណ្តឹង និងអ្នកពាក់ព័ន្ធផ្សេងទៀត ការពិនិត្យមើលឯកសារ និងការត្រួតពិនិត្យភស្តុតាងរូបវន្ត។ នឹងមានការផ្តោតអាទិភាពលើការរក្សាអនាមិកភាពរបស់អ្នកដាក់បណ្តឹង ទៅតាមការស្នើសុំ។ ក្រុមស៊ើបអង្កេតនឹងរាយការណ៍ទៅគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាថ្នាក់ខេត្ត។

177. គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាថ្នាក់ខេត្តអាចសម្រេច ១) មិនចាំបាច់ចាត់វិធានការ ២) ចាត់វិធានការសមស្របដើម្បីដោះស្រាយបណ្តឹង ឬ ៣) បញ្ជូនបណ្តឹងពីគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាថ្នាក់ខេត្តទៅគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ានៅថ្នាក់ជាតិ។ អ្នកដាក់បណ្តឹងនឹងត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរពីសេចក្តីសម្រេចរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាថ្នាក់ខេត្ត។




*រូប ២ ៖ ដ្យាក្រាមយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងគម្រោង*

178. ជនជាតិដើមភាគតិចនឹងទទួលបានជំនួយបន្ថែមដើម្បីឱ្យពួកគេមានលទ្ធភាពប្រើប្រាស់យន្តការដោះស្រាយបណ្តឹងដោយស្មើភាព។ គម្រោងនឹងគាំទ្រ និងរ៉ាប់រងចំណាយលើអ្នកសម្របសម្រួលដែលជ្រើសរើសដោយជនជាតិដើមភាគតិច និងយល់ច្បាស់ពីភាសា ឬគ្រាមភាសារបស់ជនជាតិដើមភាគតិច ដើម្បីដើរតួនាទីជាមេធាវីរបស់អ្នកដាក់បណ្តឹង។ បណ្តឹងដែលពាក់ព័ន្ធនឹងបញ្ហាផ្ទៃក្នុងរបស់សហគមន៍ជនជាតិដើមភាគតិចនឹងត្រូវបានដោះស្រាយដំបូងបង្អស់ក្នុងសហគមន៍នោះផ្ទាល់ ដោយអនុវត្តតាមដំណើរការដោះស្រាយវិវាទដែលអាចទទួលយកបានក្នុងវប្បធម៌។

## ១០.៣ ការពិពណ៌នាពីយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ

179. យន្តការដោះស្រាយបណ្តឹងតវ៉ាសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញត្រូវបានបង្កើតឡើងជាការរៀបចំនៅតាមមូលដ្ឋាននៅថ្នាក់ខេត្តសម្រាប់ការទទួល កត់ត្រា វាយតម្លៃ និងសម្របសម្រួលដំណោះស្រាយបណ្តឹង និងបណ្តឹងសាទុក្ខដែលដាក់ដោយជនដែលរងផលប៉ះពាល់អវិជ្ជមាន ពាក់ព័ន្ធនឹងសំណង និងសិទ្ធិទទួលបានរបស់ពួកគេសម្រាប់ការដកហូតដីធ្លី និងអចលនវត្ថុផ្សេងទៀតក្រោមច្បាប់ស្តីពីអស្សាមិករណ៍។

180. យន្តការនេះបំពេញបន្ថែម និងមិនជំនួសឱ្យយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងគម្រោង ដែលមានរៀបរាប់ក្នុងក្របខណ្ឌជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធឡើយ។ ជនដែលរងផលប៉ះពាល់គ្រប់រូបមានសិទ្ធិដាក់បណ្តឹងទៅយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងគម្រោងដំណាក់កាលទី ៣ លើបញ្ហាអ្វីក៏បាន រួមទាំងលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ ទៅតាមបំណងរបស់ខ្លួន។

181. ក្រសួងសេដ្ឋកិច្ចនឹងសម្របសម្រួលការបង្កើតគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាថ្នាក់ខេត្ត ដែលមានសមាសភាគដូចខាងក្រោម ៖

- អភិបាលខេត្ត ៖ ប្រធាន
- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៖ អនុប្រធាន
- ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៖ សមាជិក
- ប្រធានការិយាល័យច្បាប់ និងសន្តិសុខសាធារណៈ ៖ សមាជិក
- អភិបាលស្រុក ៖ សមាជិក
- តំណាងមួយរូបរបស់អង្គការសង្គមស៊ីវិលនៅមូលដ្ឋាន ៖ សមាជិក

182. យន្តការដោះស្រាយបណ្តឹងតវ៉ាសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ ដំណើរការតាមរយៈជំហានបន្តបន្ទាប់ដូចខាងក្រោម ៖

- ការសម្របសម្រួលព័ត៌មាននៅថ្នាក់ឃុំ
- ជំហានទី ១ ៖ បណ្តឹងផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរ ដោយមានការផ្សះផ្សារនៅកម្រិតអាជ្ញាធរស្រុក

- ជំហានទី ២ ៖ បណ្តឹងជាលាយលក្ខណ៍អក្សរត្រូវបានដាក់ជូនអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ និងបន្ទាប់មកត្រូវបានពិនិត្យឡើងវិញដោយនាយកដ្ឋានត្រួតពិនិត្យផ្ទៃក្នុង និងគ្រប់គ្រងទិន្នន័យ។ ការពិនិត្យឡើងវិញនេះមានគោលបំណងកំណត់ថាតើបណ្តឹងកើតចេញពីកំហុសឆ្គងផ្នែករដ្ឋបាល ដូចជា ការគណនាទំហំសំណង ឬយ៉ាងណា
- ជំហានទី ៣ ៖ បណ្តឹងជាលាយលក្ខណ៍អក្សរត្រូវបានដាក់ជូនគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាថ្នាក់ខេត្តតាមរយៈការិយាល័យអភិបាលខេត្ត និងមានកិច្ចប្រជុំពិនិត្យឡើងវិញដែលអ្នកដាក់បណ្តឹងអាចបង្ហាញករណីរបស់ខ្លួន។ តំណាងរបស់អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់នឹងចូលរួមពន្យល់ពីមូលហេតុដែលបណ្តឹងត្រូវបានបដិសេធចោលនៅជំហានទី ២។ គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាថ្នាក់ខេត្ត ត្រូវធ្វើសេចក្តីសម្រេចក្នុងរយៈពេល ៤០ ថ្ងៃក្រោយការទទួលបណ្តឹង។

183. សេចក្តីសម្រេចរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាថ្នាក់ខេត្ត ត្រូវបានបញ្ជូនតាមរយៈអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ទៅគណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់អនុម័ត មុនចាត់វិធានការដោះស្រាយ។ ក្នុងករណីដែលបណ្តឹងត្រូវបានបដិសេធចោល អ្នកដាក់បណ្តឹងមានសិទ្ធិដាក់បណ្តឹងទៅតុលាការ ស្របតាមច្បាប់ស្តីពីអស្សាមិករណ៍។

184. អនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ ចែងពីដំណើរការដោយឡែកសម្រាប់ការដោះស្រាយបណ្តឹងជាក្រុមដែល "មិនពាក់ព័ន្ធនឹងការទាមទាររបស់បុគ្គល ប៉ុន្តែជាបណ្តឹងដែលមានលក្ខណៈជារួមសម្រាប់ជនបាត់បង់ទីលំនៅទាំងអស់ ឬមួយក្រុម"។ បណ្តឹងទាំងនេះត្រូវដាក់ទៅអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ និងត្រូវបានស៊ើបអង្កេតដោយនាយកដ្ឋានត្រួតពិនិត្យផ្ទៃក្នុង និងគ្រប់គ្រងព័ត៌មានតាមរយៈជំហានខាងក្រោម ៖

- ការផ្ទៀងផ្ទាត់ថា បណ្តឹងមានលក្ខណៈសម្បត្តិដែលអាចចាត់ចូលជាបណ្តឹងជាក្រុម ក្នុងរយៈពេល ១០ ថ្ងៃធ្វើការចាប់ពីថ្ងៃទទួលបណ្តឹង
- នាយកដ្ឋានត្រួតពិនិត្យផ្ទៃក្នុង និងគ្រប់គ្រងព័ត៌មានស៊ើបអង្កេត និងរាយការណ៍ដោយផ្តល់អនុសាសន៍ទៅនាយកអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ ក្នុងរយៈពេល ៣០ ថ្ងៃធ្វើការ ចាប់ពីថ្ងៃទទួលបណ្តឹង
- អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ចេញសេចក្តីសម្រេចក្នុងរយៈពេល ៥ ថ្ងៃធ្វើការ និងផ្សព្វផ្សាយសេចក្តីសម្រេចរបស់ខ្លួនក្នុងរយៈពេល ៥ ថ្ងៃធ្វើការបន្ទាប់។

185. ក្នុងករណីដែលបណ្តឹងជាក្រុមត្រូវបានបដិសេធដោយអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ ក្រុមអាចដាក់បណ្តឹងទៅគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាថ្នាក់ខេត្ត ដែលនឹងដោះស្រាយបណ្តឹងទៅតាមជំហានទី ៣ ខាងលើ។

### ១០.៤ សេវាដោះស្រាយបណ្តឹងរបស់ធនាគារពិភពលោក

186. សហគមន៍ និងបុគ្គលដែលជឿថា ពួកគេរងផលប៉ះពាល់អវិជ្ជមានដោយសារគម្រោងគាំទ្រដោយធនាគារពិភពលោក អាចដាក់បណ្តឹងទៅយន្តការដោះស្រាយបណ្តឹងតវ៉ាមានស្រាប់នៅកម្រិតគម្រោង ឬសេវាដោះស្រាយបណ្តឹងរបស់ធនាគារពិភពលោក។ សេវានេះធានាថា បណ្តឹងដែលទទួលបាន ត្រូវបានពិនិត្យមើលភ្លាមៗដើម្បីដោះស្រាយការព្រួយបារម្ភពាក់ព័ន្ធនឹងគម្រោង។ សហគមន៍ និងជនដែលរងផលប៉ះពាល់ដោយសារគម្រោង អាចដាក់បណ្តឹងទៅគណៈអធិការកិច្ចឯករាជ្យរបស់ធនាគារពិភពលោក ដែលកំណត់ថាតើមានផលប៉ះពាល់ ឬអាចមានផលប៉ះពាល់ ដោយសារធនាគារពិភពលោកមិនអនុលោមតាមគោលនយោបាយ និងនីតិវិធីរបស់ខ្លួន ឬយ៉ាងណា។ បណ្តឹងអាចត្រូវបានដាក់គ្រប់ពេលបន្ទាប់ពីបានបង្ហាញការព្រួយបារម្ភដោយផ្ទាល់ទៅធនគារពិភពលោក ហើយគណៈគ្រប់គ្រងរបស់ធនាគារពិភពលោក មានឱកាសឆ្លើយតប។ សម្រាប់ព័ត៌មានបន្ថែមស្តីពីរបៀបដាក់បណ្តឹងទៅសេវាដោះស្រាយបណ្តឹងតវ៉ារបស់ធនាគារពិភពលោក សូមចូលទៅកាន់ ៖ http://www.worldbank.org/en/projects-operations/products-and-services/grievance-redress-service។ សម្រាប់ព័ត៌មានស្តីពីរបៀបដាក់បណ្តឹងទៅគណៈអធិការកិច្ចរបស់ធនាគារពិភពលោក សូមចូលទៅកាន់ ៖ www.inspectionpanel.org។

## ១១.ការរៀបចំផ្តល់មូលនិធិ

187. ផ្នែកនេះពាក់ព័ន្ធតែនឹងលទ្ធកម្មដីធ្លីប៉ុណ្ណោះ។ ថវិកាសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ ត្រូវបានរៀបចំឡើងក្រោយការអង្កេតវាស់វែងលម្អិតត្រូវបានបញ្ចប់ និងដាក់បញ្ចូលក្នុងផែនការដោះស្រាយផលប៉ះពាល់អនុវត្តគម្រោង។ ថវិកាសម្រាប់ផែនការដោះស្រាយផលប៉ះពាល់ទទួលបានហិរញ្ញប្បទានពីមូលនិធិបដិភាគពីថវិកាជាតិ តាមរយៈគណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់។ គ្មានហិរញ្ញបប្បទានសម្រាប់លទ្ធកម្មដីធ្លីពីហិរញ្ញប្បទានរបស់ធនាគារពិភពលោកសម្រាប់គម្រោងដំណាក់កាលទី ៣ ឡើយ។

188. អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់នឹងទទួលខុសត្រូវលើមុខងារគ្រប់គ្រងហិរញ្ញវត្ថុទាំងអស់ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ថវិកា។ រដ្ឋាភិបាលនឹងបង្កើតគណនីមួយ ( គណនីមូលនិធិបដិភាគ ) សម្រាប់គម្រោងក្នុងធនាគារជាតិនៃកម្ពុជា ដែលត្រូវបានប្រើប្រាស់សម្រាប់ចំណាយលើការអនុវត្តផែនការដោះស្រាយផលប៉ះពាល់អនុគម្រោង។ មូលនិធិសម្រាប់លទ្ធកម្មដីធ្លីត្រូវបានផ្តល់ជូនអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ពីគណនមូលនិធិបដិភាគ។ ថវិកានេះត្រូវបានរៀបចំឡើងដោយអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ និងដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអនុម័ត បន្ទាប់ពីគម្រោងត្រូវបានអនុម័តដោយធនាគារពិភពលោក។ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ នឹងដាក់សំណើសុំឱ្យផ្តល់កញ្ចប់ថវិកាដល់អគ្គនាយកដ្ឋានកិច្ចសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល ដែលនឹងដំណើរការសំណើនោះរួចដាក់ជូនអគ្គនាយកដ្ឋានរតនាគារជាតិ។ មូលនិធិត្រូវបានផ្តល់ និងដាក់បញ្ចូលក្នុងគណនីមួយដែលត្រូវបានបង្កើតឡើងសម្រាប់គម្រោង តាមរយៈអនុគណៈកម្មាធិការដោះស្រាយផលប៉ះពាល់ថ្នាក់ខេត្ត សម្រាប់គម្រោង ក្នុងធនាគារជាតិនៃកម្ពុជា។ មូលនិធិត្រូវបានផ្តល់ជូនពីគណនីមួយដែលត្រូវបានបង្កើតឡោះងសម្រាប់គម្រោង ហើយនៅពេលចាំបាច់ ត្រូវបានផ្ត

ល់ជូនអនុគណៈកម្មាធិការដោះស្រាយផលប៉ះពាល់ថ្នាក់ខេត្តដែលទទួលខុសត្រូវលើការទូទាត់ដល់គ្រួសារដែលរងផលប៉ះពាល់។

189. កម្មវិធីស្តារប្រាក់ចំណូលឡើងវិញ និងកម្មវិធីគាំទ្រសម្រាប់គ្រួសារដែលរងផលប៉ះពាល់នឹងត្រូវបានអនុវត្តក្នុងក្របខណ្ឌអនុគម្រោងទ្រទ្រង់របរចិញ្ចឹមជីវិតក្នុងគម្រោងដំណាក់កាលទី ៣។ ចំណុចនេះអាចរួមបញ្ចូលអនុគម្រោងដែលត្រូវបានអនុវត្តក្នុងផែនការការងារ និងថវិការបស់សម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ប៉ុន្តែស្ថិតនៅក្រៅសម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងត្រូវបានរៀបចំឡើងសម្រាប់ផ្តើមសំណងដល់អ្នកប្រើប្រាស់ដីដែលរងផលប៉ះពាល់។ ចំណាយលើអនុគម្រោងទាំងនេះនឹងត្រូវបានផ្តល់ហិរញ្ញប្បទានតាមរយៈផែនការការងារ និងថវិកាប្រចាំឆ្នាំរបស់គម្រោងដំណាក់កាលទី ៣។

190. ផែនការការងារ និងថវិកាប្រចាំឆ្នាំនឹងផ្តល់ហិរញ្ញប្បទានដល់ការផ្សព្វផ្សាយព័ត៌មានស្តីពីដំណើរក្នុងតំបន់សម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងការជំរុញការចូលរួមរបស់ស្ថាប័នមិនមែនរដ្ឋាភិបាលដើម្បីជួយសម្របសម្រួលដំណើរការសម្បទានដីសង្គមកិច្ចក្នុងឃុំមួយចំនួន និងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងសហគមន៍ជនជាតិដើមភាគតិចមួយចំនួន។

191. ចំណាយលើយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងគម្រោងដំណាក់កាលទី ៣ នឹងត្រូវបានផ្តល់ជូនតាមរយៈផែនការការងារ និងថវិកាប្រចាំឆ្នាំរបស់គម្រោងដំណាក់កាលទី ៣។ ការប៉ាន់ស្មានចំណាយលើយន្តការនេះមានបង្ហាញក្នុងផែនការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ។

## ១២.ការពិគ្រោះយោបល់អ្នកពាក់ព័ន្ធ និងការផ្សព្វផ្សាយពីក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់

192. ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធស្តីពីឧបករណ៍ក្របខណ្ឌបរិស្ថាន និងសង្គមក្នុងគម្រោងដំណាក់កាលទី៣ រួមទាំងក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់នេះ នឹងត្រូវបានធ្វើឡើងទន្ទឹមគ្នានឹងការវាយតម្លៃ បន្ទាប់ពីឯកសារទាំងនេះត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅចុងខែ មេសា ឆ្នាំ ២០២០។ ការផ្សព្វផ្សាយ និងការពិគ្រោះយោបល់នឹងត្រូវគ្រោងធ្វើឡើងជាមួយភាគីមានចំណាប់អារម្មណ៍ និងភាគីរងផលប៉ះពាល់ក្នុងបណ្តាខេត្តភាគឦសាន (ជាទីដែលសំបូរដោយសហគមន៍ជនជាតិដើមភាគតិច រួមទាំងជនជាតិដើមភាគតិចទាំងអស់ដែលបានទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចមកទល់បច្ចុប្បន្ន និងជាទីដែលសំបូរដោយទីតាំងសម្បទានដីសង្គមកិច្ច) និងក្នុងទីក្រុងភ្នំពេញ។ ផ្អែកតាមវិធានការរបស់រដ្ឋាភិបាលក្នុងការបញ្ចៀសការឆ្លងរីករាលដាលជំងឺ COVID-19 ចាំបាច់ត្រូវប្តូរការពិគ្រោះយោបល់ផ្ទាល់ទៅជាការពិគ្រោះយោបល់អនឡាញទៅតាមភាពសមស្រប និងអាចធ្វើទៅបាន។ ពិគ្រោះយោបល់ដែលលើកឡើងសម្រាប់គម្រោងដំណាក់កាលទី ៣ ក្នុងពេលកើតមានជំងឺ COVID-19 នឹងត្រូវបានរៀបចំឡើងដោយអនុ

រត្តតាមវិធីសាស្ត្រ ៣ វិធីសម្រាប់គម្រោងដែលផ្តល់ហិរញ្ញប្បទានដោយធនាគារពិភពលោក ដូចជា អនឡាញ ទូរស័ព្ទ/អ៊ីមែល និងសាលាឃុំ។

## ក.អនឡាញ ៖

- ស្ថាប័នអនុវត្តន៍ រួមមានក្រសួងរៀបចំដែនដី និងក្រសួងកសិកម្ម ប្រកាសថា ឯកសារទាំងនេះអាចរកបានក្នុងគេហទំព័ររបស់ខ្លួន និងប្រភពអនឡាញផ្សេងទៀត ( ដូចជា ទំព័រ Facebook ) ដោយផ្តល់តំណភ្ជាប់នៃឯកសារ។ ចំណុចនេះក៏រួមបញ្ចូលការបកប្រែជាភាសាខ្មែរនូវសេចក្តីសង្ខេបរបស់ឯកសារ យន្តការដោះស្រាយបណ្តឹងតវ៉ា និងតារាង ១០ ស្តីពីក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម ( សេចក្តីសង្ខេបស្តីពីហានិភ័យ/ផលប៉ះពាល់ និងវិធានការកាត់បន្ថយ)។ ក្រសួងរៀបចំដែនដីផលិតវីដេអូខ្លីមួយ ( ៥-១០ នាទី )( ឬសំឡេង ) ដោយពន្យល់ពីគម្រោង ផលប៉ះពាល់ វិធានការកាត់បន្ថយ យន្តការដោះស្រាយបណ្តឹងតវ៉ា ដែលគេអាចរកបានឯកសារតាមអនឡាញ និងរបៀបចែករំលែកក្តីកង្វល់/មតិយោបល់/សំណួរ។

## ខ.ទូរស័ព្ទចូល

- ស្ថាប័នអនុវត្តន៍គម្រោង ចាត់តាំងបុគ្គលិក SEO ដើម្បីរៀបំបញ្ជីឈ្មោះអ្នកចូលរួម/អ្នករងផលប៉ះពាល់ក្នុងតំបន់គម្រោង និងលេខទូរស័ព្ទរបស់ពួកគេ ដោយធានាថា មានសមាសភាគស្ត្រីសមស្របក្នុងបញ្ជីឈ្មោះនោះ។
- នៅពេលទូរស័ព្ទចូល ក្រុម SEO អាចពន្យល់សង្ខេបដល់អ្នកចូលរួមម្នាក់ៗពីគម្រោង ផលប៉ះពាល់ និងហានិភ័យដែលអាចកើតឡើង និងវិធានការកាត់បន្ថយ ការដោះស្រាយបណ្តឹងតវ៉ា និងព័ត៌មានទំនាក់ទំនង រួចសុំយោបល់ត្រឡប់។ ក្រៅពីនេះ ពួកគេអាចផ្ញើតំណភ្ជាប់តាម SMS បន្ទាប់ពីការទូរស័ព្ទចូល ជាមួយនឹងទំព័រ Facebook និង YouTube ( ប្រសិនបើមាន ) និងតំណភ្ជាប់ឯកសារ ។ អ្នកចូលរួមក៏អាចនឹងត្រូវបានស្នើឱ្យបញ្ជូនព័ត៌មានបន្តទៅអ្នកជិតខាងរបស់ខ្លួនផងដែរ។

## គ.សាលាឃុំ

- រាល់ឯកសារដែលបានបកប្រែ ដូចជា យន្តការដោះស្រាយបណ្តឹងតវ៉ា និងតារាង ១០ នៃក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម ( សេចក្តីសង្ខេបពីហានិភ័យ/ផលប៉ះពាល់ និងវិធានការកាត់បន្ថយ) ត្រូវតែអាចរកបាននៅសាលាឃុំ។ អាចដាក់ផ្ទាំងបដាបង្ហាញពីឯកសារនៅទីតាំងចេញចូល ដូចជាខាងក្រៅសាលារៀន វត្តអារ៉ាម និងផ្សារ។

**ឃ.ការចងក្រងឯកសារ និងព័ត៌មានត្រឡប់**

ក. ក្នុងការទូរស័ព្ទចូល និង Facebook/គេហទំព័រ ស្ថាប័នអនុវត្តន៍គម្រោងត្រូវកំណត់កាលបរិច្ឆេទកំណត់ច្បាស់លាស់ក្នុងការទទួលព័ត៌មានត្រឡប់ស្តីពីពង្រាងឯកសារ
ខ. បន្ទាប់ពីបានបង្ហោះមតិយោបល់/សំណួរ ត្រូវដាក់បញ្ចូលក្នុងទំព័រ Facebook ដើម្បីឱ្យអ្នកផ្សេងអាចមើលឃើញ (ព្រោះក្នុងការពិគ្រោះយោបល់ គេនឹងស្តាប់លឺអ្នកផ្សេងទៀតសួរសំណួរ)
គ. ផ្អែកលើព័ត៌មានត្រឡប់ សូមរៀបចំរបាយការណ៍ពិគ្រោះយោបល់ ដោយកត់សម្គាល់ពីមធ្យោបាយប្រើប្រាស់ និងមតិយោបល់/សំណួរដែលទទួលបាន។

193. កំណត់ត្រាស្តីពីការពិគ្រោះយោបល់ជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ និងបញ្ហាសំខាន់ៗមានបង្ហាញក្នុងឧបសម្ព័ន្ធ ១១ នៃផែនការជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធ។

194. ការពិគ្រោះយោបល់អ្នកពាក់ព័ន្ធក្នុងពេលអនុវត្តគម្រោង រួមទាំងនីតិវិធីស្តីពីការពិគ្រោះយោបល់អ្នកពាក់ព័ន្ធ ដែលមានរៀបរាប់ក្នុងផ្នែក ១-១០ ខាងលើ នឹងធ្វើឡើងតាមរយៈជំនួបផ្ទាល់។ ការប្រើប្រាស់មធ្យោបាយពិគ្រោះយោបល់អ្នកពាក់ព័ន្ធពីចម្ងាយក្នុងការរៀបចំផែនការដោះស្រាយផលប៉ះពាល់នឹងមិនអាចធ្វើបានក្នុងសហគមន៍រងផលប៉ះពាល់ដោយសារគម្រោង និងទំនងជាមិនអាចសម្រេចបានស្តង់ដារលទ្ធផលដែលអាចទទួលយកបានឡើយ។ ដូច្នេះ សកម្មភាពអនុវត្តន៍គម្រោងដែលតម្រូវឱ្យមានការពិគ្រោះយោបល់អ្នកពាក់ព័ន្ធ រួមទាំងការរៀបចំផែនការដោះស្រាយផលប៉ះពាល់ នឹងមិនអាចចាប់ផ្តើមឡើងបានទេ លុះត្រាតែវិធានការអាសន្នដើម្បីទប់ស្កាត់ការចម្លងជំងឺកូវីដ ១៩ ត្រូវបានដក។

## ឧបសម្ព័ន្ធ ១ ៖ បទប្បញ្ញត្តិបន្ថែមលើអនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ

1. បទប្បញ្ញត្តិខាងក្រោមនឹងអនុវត្តចំពោះការរៀបចំ និងអនុវត្តផែនការដោះស្រាយផលប៉ះពាល់ក្នុងគម្រោងដំណាក់កាលទី ៣ បន្ថែមលើបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ។

2. ស្របតាមលក្ខខណ្ឌតម្រូវក្នុងបទដ្ឋានបរិស្ថាន និងសង្គមទី ១ និងទី ៥ ជនរងផលប៉ះពាល់ទាំងអស់ដែលកាន់កាប់ដី ឬប្រកបរបរចិញ្ចឹមជីវិតលើដីនោះ មុនកាលបរិច្ឆេទឱសានវាទ អាចមានលក្ខណៈសម្បត្តិទទួលបានសំណង និងការកែលម្អ ឬការស្តារបរចិញ្ចឹមជីវិតឡើងវិញពេញលេញ។

3. ជនដែលរងផលប៉ះពាល់នឹងរួមបញ្ចូល ៖

- អ្នកដែលមានប័ណ្ណកម្មសិទ្ធិដីផ្លូវការ "ប្លង់រឹង"
- អ្នកដែលមាន "ប្លង់ទន់" ពោលគឺប្រភេទឯកសារដែលចេញដោយអាជ្ញាធរមូលដ្ឋាន ដែលទទួលស្គាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដីធ្លី និងមិនបញ្ជាក់ច្បាស់លាស់ថា ដីនោះនឹងត្រូវផ្លាស់ទីកន្លែងនៅពេលចាំបាច់សម្រាប់ប្រយោជន៍សាធារណៈនោះទេ
- បុគ្គលផ្សេងទៀតដែលអាចបង្ហាញការទាមទារដែលមានសុពលភាពលើការកាន់កាប់ ឬគ្រប់គ្រងដីស្របតាមច្បាប់ភូមិបាលឆ្នាំ ២០០១ និងបទប្បញ្ញត្តិផ្សេងទៀត
- បុគ្គលដែលកាន់កាប់/ជាអ្នកកាន់កាប់ខុសច្បាប់លើដីរដ្ឋមុនកាលបរិច្ឆេទឱសានវាទ។

4. ជនរងផលប៉ះពាល់ដែលមានសិទ្ធិស្របច្បាប់លើដីធ្លី និងត្រូវបានផ្លាស់ទីតាំងចេញពីដីនោះ និងមានសិទ្ធិទទួលបានលំនៅដ្ឋានគ្រប់គ្រាន់ដោយមានសន្តិសុខសិទ្ធិកាន់កាប់ ក្រៅពីសំណងសម្រាប់ការបាត់បង់ដំណាំ និងការកែលម្អដែលពួកគេបានធ្វើនៅលើដីនោះ។

5. អ្នកដែលរបរចិញ្ចឹមជីវិតមួយផ្នែកពឹងផ្អែកលើធនធានទ្រព្យសម្បត្តិរួម ដូចជា អនុផលព្រៃឈើ វាលស្មៅសម្រាប់សត្វស៊ី នេសាទ។ល។ នៅលើដីនោះ មានសិទ្ធិទទួលបានសំណងដោយសារការបាត់បង់របរចិញ្ចឹមជីវិតរបស់ខ្លួន។

6. បទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ២២/នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ កថាខណ្ឌ ១០៤ "គ្មានសំណងសម្រាប់អ្នករស់នៅបែបអាណាធិបតេយ្យលើដីចំណីផ្លូវមានស្រាប់" នឹងអនុវត្តតែក្នុងករណីណាមួយខាងក្រោម ៖

- មានការចងក្រងឯកសារថា អ្នកកាន់កាប់ត្រូវបានណែនាំឱ្យរើចេញពីដីចំណីផ្លូវ មុនកាលបរិច្ឆេទឱសានវាទ និងសម្រាប់មូលហេតុដែលមិនពាក់ព័ន្ធផ្ទាល់នឹងសកម្មភាពគម្រោងដែលស្នើឡើង និង

- ជនដែលរងផលប៉ះពាល់កំពុងប្រើប្រាស់ដីចំណីផ្លូវជាបណ្តោះអាសន្ន និង/ឬក្រោមការរឹតត្បិតស្របតាមកិច្ចព្រមព្រៀងដែលបានចងក្រងទុក ដែលចែងថា ពួកគេត្រូវរើចេញពីដីនោះប្រសិនបើជាការចាំបាច់សម្រាប់ប្រយោជន៍សាធារណៈ។

7. សម្រាប់គម្រោងដំណាក់កាលទី ៣ "កម្មសិទ្ធិបែបទំនៀមទំលាប់" នឹងសំដៅលើដីដែលស្ថិតក្រោមប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ឬដីដែលស្ថិតក្រោមសំណើធ្វើចំណាត់ថ្នាក់ជាដីសម្រាប់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចដោយសហគមន៍ជនជាតិដើមភាគតិចដែលទទួលស្គាល់ដោយក្រសួងអភិវឌ្ឍន៍ជនបទ។ ជនជាតិដើមភាគតិច និងគ្រួសាររបស់ពួកគេនឹងមានសិទ្ធិដូចអ្នកផ្សេងទៀតក្នុងការកាន់កាប់ដីធ្លីជាលក្ខណៈបុគ្គល និងទទួលបានសំណងជាសាច់ប្រាក់ប្រសិនបើមានលក្ខណៈសម្បត្តិ។

8. សិទ្ធិទទួលបានសំណងសម្រាប់ការបាត់បង់ដីសម្រាប់គោលបំណងកសិកម្ម ឬសម្រាប់អាជីវកម្ម (ក្រៅពីសកម្មភាពខុសច្បាប់ ដូចជា ល្បែងស៊ីសង ពេស្យាចារ គ្រឿងញៀន ឬសកម្មភាពដែលមានលក្ខណៈស្រដៀងគ្នា) នឹងមិនរងផលប៉ះពាល់ដោយសារស្ថានភាពស្របច្បាប់នៃការកាន់កាប់ដីធ្លីឡើយ។

9. ការជំរឿនអ្នកប្រើប្រាស់ដីនឹងរួមបញ្ចូលអ្នកប្រើប្រាស់ដីដែលគ្មានការកាន់កាប់ (អ្នកប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួម។ល។) ដែលត្រូវដាក់បញ្ចូលក្នុងដំណើរការពិគ្រោះយោបល់ និងត្រូវបានពិចារណាសម្រាប់ការទទួលបានសំណង។

10. ជំរឿងនឹងផ្ទៀងផ្ទាត់ថាតើជនដែលរងផលប៉ះពាល់ទាំងអស់មានអត្តសញ្ញាណប័ណ្ណ ឬទេ (ចាំបាច់ត្រូវមាន ដើម្បីទាមទារសំណង)។ គម្រោងនឹងជួយដល់ជនរងផលប៉ះពាល់ដែលគ្មានអត្តសញ្ញាណប័ណ្ណឱ្យទទួលបានអត្តសញ្ញាណប័ណ្ណ និង/ឬ ពួកគេនឹងមិនត្រូវបានផាត់ចេញពីសំណងទេ។

11. គម្រោងដំណាក់កាលទី ៣ នឹងគាំទ្រវិធានការបន្ថែមក្នុងការធ្វើយ៉ាងណាឱ្យជនរងផលប៉ះពាល់បានដឹងច្បាស់ពីគម្រោងដែលស្នើឡើង ផែនការដោះស្រាយផលប៉ះពាល់ និងសិទ្ធិរបស់ពួកគេ ជាពិសេសក្នុងករណីដែលជនរងផលប៉ះពាល់មិនសូវចេះអក្សរ ឬនិយាយភាសាកំណើតមិនមែនភាសាខ្មែរ។

12. ការពិគ្រោះយោបល់ជាមួយជនរងផលប៉ះពាល់ នឹងរួមបញ្ចូលការអនុញ្ញាតឱ្យពួកគេរើសយកជម្រើសសំណងផ្សេងៗ។

13. ការពិគ្រោះយោបល់ជាមួយជនរងផលប៉ះពាល់ នឹងរួមបញ្ចូលការធានាថា ទស្សនៈរបស់ក្រុមផ្សេងៗក្នុងសហគមន៍ និងគ្រួសារ (ឧ.ទស្សនៈរបស់ស្ត្រី) ត្រូវបានដឹងលឺ និងយកទៅពិចារណា។

14. កិច្ចសន្យាសម្រាប់ទទួលបានសំណងនឹងមិនត្រូវបានចុះហត្ថលេខាភ្លាមៗបន្ទាប់ពីត្រូវបានបង្ហាញ និង ពន្យល់នៅកិច្ចប្រជុំពិគ្រោះយោបល់លើកទី ៣ ឡើយ។ ផ្ទុយទៅវិញ ជនរងផលប៉ះពាល់នឹងត្រូវបានស្នើឱ្យចុះ ហត្ថលេខាលើកិច្ចសន្យានៅសាលាឃុំក្នុងរយៈពេល ៧ ថ្ងៃ ឬត្រូវដាក់បណ្តឹង។

15. ជនរងផលប៉ះពាល់ដែលមិនចុះហត្ថលេខាលើកិច្ចសន្យា ឬដាក់បណ្តឹងផ្លូវការក្នុងរយៈពេល ៣ ខែ ក្រោយការបង្ហាញកិច្ចសន្យា នឹងមិនបាត់បង់សិទ្ធិទទួលបានសំណងដោយស្វ័យប្រវត្តិឡើយ។ ផ្ទុយទៅវិញ ពួក គេនឹងត្រូវបានចាត់ទុកថាបានដាក់បណ្តឹង។

16. ក្រៅពីយន្តការដោះស្រាយបណ្តឹងតវ៉ាដែលត្រូវបង្កើតឡើងដោយអគ្គនាយកដ្ឋានដោះស្រាយផលប៉ះ ពាល់ក្រោមផែនការដោះស្រាយផលប៉ះពាល់ ជនរងផលប៉ះពាល់មានសិទ្ធិដាក់បណ្តឹងតាមរយៈយន្តការដោះ ស្រាយបណ្តឹងតវ៉ារបស់គម្រោងដំណាក់កាលទី ៣។

17. កម្មវិធីស្តារប្រាក់ចំណូលឡើងវិញ/កម្មវិធីគាំទ្រសម្រាប់ជនរងផលប៉ះពាល់ នឹងត្រូវបានអនុវត្តក្នុងក្រប ខណ្ឌនៃអនុគម្រោងទ្រទ្រង់របរចិញ្ចឹមជីវិតរបស់គម្រោងដំណាក់កាលទី ៣។ គម្រោងដំណាក់កាលទី ៣ នឹង ខិតខំធ្វើយ៉ាងណាឱ្យជនរងផលប៉ះពាល់ដែលក្រីក្រ និងងាយរងគ្រោះអាចទទួលបានអត្ថប្រយោជន៍ពី សកម្មភាពគម្រោង។ ក្នុងករណីចាំបាច់ ប្រហែលជាមានការអនុវត្តអនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ ឬអនុគម្រោង ទ្រទ្រង់របរចិញ្ចឹមជីវិតបន្ថែមនៅក្រៅតំបន់សម្បទានដីសង្គមកិច្ច ឬតំបន់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់ សហគមន៍ជនជាតិដើមភាគតិច ក្រោមផែនការការងារ និងថវិកាសម្រាប់សម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណ កម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច សម្រាប់ជនរងផលប៉ះពាល់ដែលមិនមែនជាអ្នក ទទួលផលពីសម្បទានដីសង្គមកិច្ច ឬ ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគ តិច។

18. ផែនការដោះស្រាយផលប៉ះពាល់ នឹងត្រូវបានដាក់ជូនធនាគារពិភពលោក ដើម្បីទទួលបានការមិន ជំទាស់។

19. ពង្រាងរបាយការណ៍វឌ្ឍនភាពស្តីពីលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ នឹងត្រូវបានដាក់ជូន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ផ្តល់មតិយោបល់ និងសម្រេចយក។ របាយការណ៍ទាំងអស់ស្តី ពីលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ នឹងត្រូវបានបង្ហាញជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់។

20. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងទទួលខុសត្រូវលើការចែករំលែករបាយការណ៍ និង ព័ត៌មានស្តីពីការតាំងទីលំនៅឡើងវិញជាមួយធនាគារពិភពលោក។

21. សម្រាប់ផែនការដោះស្រាយផលប៉ះពាល់ ដែលរៀបចំឡើងដោយអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ ពាក់ព័ន្ធនឹងគម្រោងដំណាក់កាលទី ៣ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់នឹងជួលទីប្រឹក្សាត្រួតពិនិត្យខាងក្រៅ ដោយមានលក្ខខណ្ឌយោងដែលព្រមព្រៀងដោយអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងធនាគារពិភពលោក។

## ឧបសម្ព័ន្ធ ២ ៖ ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច

| ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច | | | |
| --- | --- | --- | --- |
| ដំណាក់កាលទី ១ | ដំណាក់កាលទី ២ | ដំណាក់កាល ២.៥ | ដំណាក់កាលទី ៣ |
| ក្រសួងអភិវឌ្ឍន៍ជនបទ ៖ ដំណើរការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច | ក្រសួងមហាផ្ទៃ ៖ ការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជាផ្លូវការជា "នីតិបុគ្គល" | សហគមន៍ជនជាតិដើមភាគតិច ៖ ការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៖ វាស់វែង ផ្សព្វផ្សាយព័ត៌មានជាសាធារណៈ បែងចែកប្រភេទដីឡើងវិញ និងចេញប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច |
| ជំហានទី ១ ៖ ការកសាងការយល់ដឹងជាសាធារណៈក្នុងចំណោមអាជ្ញាធរខេត្ត (មន្ទីរពាក់ព័ន្ធ) និងអាជ្ញាធរនៅថ្នាក់ស្រុក ឃុំ និងភូមិ និងសហគមន៍ជនជាតិដើមភាគតិច។ | ជំហានទី ១ ៖ សហគមន៍ជនជាតិដើមភាគតិចត្រូវព្រាងលក្ខន្តិកៈក្នុងសហគមន៍ និងរៀបចំគណៈកម្មាធិការតំណាងសហគមន៍ | ជំហានទី ១ ៖ ប្រមូលទិន្នន័យ និងផលិតផែនទីបឋមដោយកំណត់ព្រំប្រទល់នៃប្រភេទដីសហគមន៍ដែលចូលរួមដោយម្ចាស់ដីទាំងអស់ (នៅចំណុចនេះ ត្រូវផ្តោតសំខាន់លើការយល់ព្រមដោយសេរី ជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ) | ជំហានទី ១ ៖ ការវាស់វែង និងការប្រមូលទិន្នន័យស្តីពីព្រំប្រទល់ដី ទៅតាមប្រភេទនៃការប្រើប្រាស់ ការកំណត់ព្រំប្រទល់ និងការកំណត់អត្តសញ្ញាណដីរដ្ឋ (នៅចំណុចនេះត្រូវផ្តោតសំខាន់លើការយល់ព្រមដោយសេរីជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ)។ |
| ជំហានទី ២ ៖ សហគមន៍ជនជាតិដើមភាគតិចបង្ហាញឆន្ទៈក្នុងការផ្តួចផ្តើមដំណើរការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច | ជំហានទី ២ ៖ ការពិនិត្យឡើងវិញលើការប្តេជ្ញាចិត្ត និងគោលបំណងរបស់សមាជិកសហគមន៍ | ជំហានទី ២ ៖ សហគមន៍ជនជាតិដើមភាគតិចបង្កើតវិធានផ្ទៃក្នុង ក្រោមការសម្របសម្រួលដោយអង្គការមិនមែនរដ្ឋាភិបាល (ព្រាងដោយក្រសួងមហាផ្ទៃ) | ជំហានទី ២ ៖ ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈនូវឯកសារវាយតម្លៃដីធ្លី និងបណ្តឹងតវ៉ា |
| ជំហានទី ៣ ៖ ការកសាងការយល់ដឹងពីដំណើរការនេះដល់សហគមន៍គោលដៅ | ជំហានទី ៣ ៖ សហគមន៍ជនជាតិដើមភាគតិចត្រូវរៀបចំសមាជសហគមន៍ដើម្បីធ្វើការអនុម័តជាផ្លូវការលើ "លក្ខន្តិកៈសហគមន៍" និងគណៈកម្មាធិការរបស់សហគមន៍" | ជំហានទី ៣ ៖ សហគមន៍ជនជាតិដើមភាគតិចត្រូវដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជំហានទី ៣ ៖ ការរាយការណ៍ពីលទ្ធផលចេញពីការផ្សព្វផ្សាយឯកសារវាយតម្លៃដីធ្លី |
| ជំហានទី ៤ ៖ សហគមន៍ជនជាតិដើមភាគតិចត្រូវជ្រើសរើសតំណាងគណៈកម្មការសហគមន៍ និងធ្វើការកំណត់អត្តសញ្ញាណដោយខ្លួនឯងជា "ជនជាតិដើមភាគតិច" | ជំហានទី ៤ ៖ សហគមន៍ជនជាតិដើមភាគតិចត្រូវដាក់ពាក្យសុំចុះបញ្ជីជានីតិបុគ្គលទៅក្រសួងមហាផ្ទៃ | | ជំហានទី ៤ ៖ កិច្ចប្រជុំជាមួយ PSLC ដើម្បីសម្រេចយករបាយការណ៍ចេញពីលទ្ធផលនៃការផ្សព្វផ្សាយជាសាធារណៈស្តីពីការវាយតម្លៃដីធ្លី និងការស្នើឱ្យក្រសួងរៀបចំដែនដី ចេញប័ណ្ណកម្មសិទ្ធិដីដល់សហគមន៍ជនជាតិដើមភាគតិច |
| *ជំហានទី ៥ ៖ ក្រសួងអភិវឌ្ឍន៍ជនបទចេញវិញ្ញាបនបត្រអត្តសញ្ញាណដល់សហគមន៍ជនជាតិដើមភាគតិច* | *ជំហានទី ៥ ៖ ក្រសួងមហាផ្ទៃត្រូវចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជា "នីតិបុគ្គល"* | | ជំហានទី៥ ៖ ក្រសួងរៀបចំដែនដីផ្ញើលិខិតទៅក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសុំឱ្យមានការពិនិត្យ និងអនុម័តដីធ្លីពាក់ព័ន្ធ។ |

| ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច | | | |
|---|---|---|---|
| ដំណាក់កាលទី ១ | ដំណាក់កាលទី ២ | ដំណាក់កាល ២.៥ | ដំណាក់កាលទី ៣ |
| ក្រសួងអភិវឌ្ឍន៍ជនបទ ៖ ដំណើរការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច | ក្រសួងមហាផ្ទៃ ៖ ការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជាផ្លូវការជា "នីតិបុគ្គល" | សហគមន៍ជនជាតិដើមភាគតិច ៖ ការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ទៅក្រសួងរៀបចំដែនដី<br>នគរូបនីយកម្ម និងសំណង់ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៖ វាស់វែង ផ្សព្វផ្សាយព័ត៌មានជាសាធារណៈ បែងចែកប្រភេទដីឡើងវិញ និងចេញប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច |
| | | | <u>ជំហានទី ៦ ៖</u> ក្រសួងរៀបចំដែនដីផ្ញើលិខិតទៅគណៈរដ្ឋមន្ត្រីដើម្បីស្នើឱ្យមានការបែងចែកប្រភេទដីធ្លីដែលត្រូវចុះបញ្ជីជាដីសមូហភាពឡើងវិញ ដោយផ្អែកតាមសេចក្តីសម្រេចរបស់ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម។ |
| | | | ជំហានទី ៧ ៖ ចេញប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច |

## ឧបសម្ព័ន្ធ ៣៖ ទម្រង់ការផ្តល់អំណោយទ្រព្យសម្បត្តិដោយស្ម័គ្រចិត្ត

| | | |
|---|---|---|
| ខេត្ត | | |
| ស្រុក | | |
| ឃុំ/សង្កាត់ | | |
| ភូមិ | | |
| ប្រភេទហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធនឹងការផ្តល់អំណោយ | | |
| ឈ្មោះអ្នកផ្តល់អំណោយ | | លេខអត្តសញ្ញាណប័ណ្ណ |
| ភេទ | | |
| តើទ្រព្យសម្បត្តិដែលបានផ្តល់អំណោយ កំពុងត្រូវបានប្រើប្រាស់ដោយនរណាម្នាក់ក្រៅពីម្ចាស់ ឬទេ? សូមបញ្ជាក់លម្អិត៖ | | |
| ប្រភេទទ្រព្យដែលបានផ្តល់អំណោយ | ព័ត៌មានលម្អិត (ឧ. ទំហំដី និងការប្រើប្រាស់ ប្រភេទដំណាំដែលបានដាំ ចំនួនដើមឈើ) | អ្វីដែលបន្សល់ទុកសម្រាប់អ្នកផ្តល់អំណោយ |
| ដី (បញ្ជាក់ប្រភេទដីដែលត្រូវបានប្រើប្រាស់) | | |
| ដើមឈើ (ដូចជា ផ្លែឈើ ឈើមូល ដើមឈើឱសថ ដើមឈើម្លប់។ល។) | | |
| ទ្រព្យសម្បត្តិ (ដូចជា ផ្នែកនៃសំណង់ អណ្តូង របង។ល។) | | |
| ផ្សេងៗ | | |
| ប្រសិនបើទ្រព្យសម្បត្តិដែលបានផ្តល់អំណោយកំពុងត្រូវបានប្រើប្រាស់ដោយនរណាម្នាក់ក្រៅពីម្ចាស់ សូមរៀបរាប់ពីទ្រព្យសម្បត្តិនៅសល់របស់បុគ្គលនោះ និង/ឬរៀបរាប់ពីមូលហេតុដែលការផ្តល់អំណោយមិនធ្វើឱ្យប៉ះពាល់ដល់របរចិញ្ចឹមជីវិតរបស់គាត់។ | | |

តាមរយៈការចុះហត្ថលេខា ឬផ្តិតមេដៃលើទម្រង់នេះ អ្នកប្រើប្រាស់ដី និង/ឬម្ចាស់ដី យល់ព្រមផ្តល់អំណោយទ្រព្យសម្បត្តិនេះសម្រាប់ការស្តារផ្លូវថ្នល់។ ការផ្តល់អំណោយនេះត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត ហើយជនដែលរងផលប៉ះពាល់យល់ថា ពួកគេអាចបដិសេធ ឬមានជម្រើសស្វែងរកសំណង ប៉ុន្តែពួកគេសម្រេចចិត្តផ្តល់អំណោយ។ ប្រសិនបើអ្នកប្រើប្រាស់ និង/ឬម្ចាស់ដី មិនចង់ផ្តល់អំណោយទ្រព្យសម្បត្តិរបស់ខ្លួនជាអំណោយទៅឱ្យគម្រោង គាត់អាចបដិសេធមិនចុះហត្ថលេខា ឬផ្តិតមេដៃ និងស្នើសុំសំណងវិញ។

កាលបរិច្ឆេទ

កាលបរិច្ឆេទ

ហត្ថលេខារបស់តំណាងមន្ទីររៀបចំដែនដី

ហត្ថលេខារបស់អ្នកផ្តល់អំណោយ
(ទាំងប្តី និងប្រពន្ធ ប្រសិនបើអាច)

ធ្វើជាសាក្សីដោយអាជ្ញាធរភូមិ/ឃុំ ៖

## ឧបសម្ព័ន្ធ ៤ ៖ ទម្រង់រាយការណ៍សម្រាប់ផែនការដោះស្រាយផលប៉ះពាល់ក្នុងអនុគម្រោង

ខេត្ត ៖ ____________ ស្រុក ៖ __________ ឃុំ ៖ _________ ភូមិ ៖ _________

អនុគម្រោងសម្បទានដីសង្គមកិច្ច ឬការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ៖ _______________
អំឡុងពេលរាយការណ៍ ៖ __________________________

| ស្ថានភាពនៃដំណើរការអង្កេតវាស់វែងលម្អិត | | | |
|---|---|---|---|
| ១ | បញ្ចប់ការសិក្សាតម្លៃជំនួស | កាលបរិច្ឆេទ | |
| ២ | ការពិគ្រោះយោបល់ក្នុងភូមិ/ឃុំស្តីពីការអង្កេតវាស់វែងលម្អិតមុនពេលអនុវត្តជាក់ស្តែង | កាលបរិច្ឆេទ | |
| ៣ | បានធ្វើការអង្កេតវាស់វែងលម្អិត និងបានរៀបចំកិច្ចសន្យាការអង្កេតវាស់វែងលម្អិត | កាលបរិច្ឆេទ | |
| | | # គ្រួសាររងផលប៉ះពាល់ដែលបានកំណត់ទីតាំង | |
| | | # គ្រួសាររងផលប៉ះពាល់ដែលមិនទាន់បានកំណត់ទីតាំង[14] | |
| ៤ក | ការពិគ្រោះយោបល់ជាមួយភូមិ/ឃុំស្តីពីលទ្ធផលនៃការអង្កេតវាស់វែងលម្អិត | កាលបរិច្ឆេទ | |
| ៤ខ | ការពិគ្រោះយោបល់ជាមួយគ្រួសាររងផលប៉ះពាល់ដើម្បីផ្ទៀងផ្ទាត់ផលប៉ះពាល់ និងសំណង ឬជំនួយក្នុងកិច្ចសន្យាការអង្កេតវាស់វែងលម្អិត | កាលបរិច្ឆេទ | |

| ប្រភេទនៃការបាត់បង់ និងចំនួនគ្រួសាររងផលប៉ះពាល់ដែលមានលក្ខណៈសម្បត្តិ | | |
|---|---|---|
| ប្រភេទនៃការបាត់បង់ | ប្រភេទជន/គ្រួសាររងផលប៉ះពាល់ដែលមានលក្ខណៈសម្បត្តិ | #ជន/គ្រួសារដែលរផលរងប៉ះពាល់ |
| ដី | ម្ចាស់ស្របច្បាប់ ឬអ្នកផ្សេងទៀតដែលមានការទាមទារតាមផ្លូវច្បាប់ | |
| ដី | ម្ចាស់បែបទំនៀមទំលាប់ (ជនជាតិដើមភាគតិច | |
| ដី | អ្នករស់នៅលើដីដែលគ្មានការទាមទារដីតាមផ្លូវច្បាប់ | |
| ការប្រើប្រាស់ដី | ជនរងផលប៉ះពាល់ដែលពាក់ព័ន្ធក្នុងកសិកម្ម ៖ ម្ចាស់ស្របច្បាប់ អ្នកជួល | |
| | ម្ចាស់អាជីវកម្ម ៖ ម្ចាស់ស្របច្បាប់ អ្នកជួល | |
| ផ្ទះសម្បែង និងសំណង់ | ម្ចាស់ស្របច្បាប់ | |
| | អ្នកជួលដែលមានការវិនិយោគលើផ្ទះសម្បែង ឬសំណង់ | |
| | អ្នកជួល និងនិយោជិតដែលគ្មានការវិនិយោគលើផ្ទះសម្បែង ឬសំណង់ | |
| | អ្នករស់នៅលើដីដែលគ្មានការទាមទារដីតាមផ្លូវច្បាប់ | |

[14] សម្រាប់គ្រួសាររងផលប៉ះពាល់ដែលមិនអាចកំណត់ទីតាំងបាន សូមរៀបរាប់ពីជំហាននានាក្នុងការកំណត់ទីតាំងរបស់ពួកគេ (ឧ. ក្រោមការផ្តល់មតិយោបល់)។

| | | | |
|---|---|---|---|
| | | # គ្រួសាររងផលប៉ះពាល់ | |
| 5 | គ្រួសាររងផលប៉ះពាល់ដែលចុះហត្ថលេខា ឬបដិសេធកិច្ចសន្យាការអង្កេតវាស់វែងលម្អិតក្នុងរយៈពេល ៧ ថ្ងៃក្រោយការពិគ្រោះយោបល់ ដើម្បីផ្ទៀងផ្ទាត់ការអង្កេតវាស់វែងលម្អិត | កាលបរិច្ឆេទ | |
| | | # គ្រួសាររងផលប៉ះពាល់ដែលបានចុះហត្ថលេខា | |
| | | # គ្រួសាររងផលប៉ះពាល់ដែលបដិសេធ[15] | |
| ៦ក | ការអង្កេតវាស់វែងលម្អិត ៖ ការទូទាត់សំណងជាប្រាក់ និងប្រាក់ឧបត្ថម្ភ | កាលបរិច្ឆេទចាប់ផ្តើម | |
| | | កាលបរិច្ឆេទបញ្ចប់ | |
| | | # គ្រួសាររងផលប៉ះពាល់ | |
| 6b | ការអង្កេតវាស់វែងលម្អិត ៖ ការផ្តល់ដីជំនួស ឬក្បាលដីសម្រាប់សង់ផ្ទះ | កាលបរិច្ឆេទ | |
| | | កាលបរិច្ឆេទបញ្ចប់ | |
| | | # គ្រួសាររងផលប៉ះពាល់ | |
| 6c | ការអង្កេតវាស់វែងលម្អិត ៖ ការផ្តល់ជំនួយដល់ការស្តាររបរចិញ្ចឹមជីវិតឡើងវិញ (សមាសភាគទី ៣) | កាលបរិច្ឆេទចាប់ផ្តើម | |
| | | កាលបរិច្ឆេទបញ្ចប់ | |
| | | # គ្រួសាររងផលប៉ះពាល់ | |
| មតិយោបល់ (ប្រើចន្លោះបន្ថែមប្រសិនបើចាំបាច់) | | | |

| | | |
|---|---|---|
| របរចិញ្ចឹមជីវិត | គ្រួសាររងផលប៉ពាល់ដែលបាត់បង់ទីលំនៅ ដែលបាត់បង់របរចិញ្ចឹមជីវិតក្នុងអំឡុងពេលអន្តរកាល | |
| | គ្រួសាររងផលប៉ះពាល់ដែលក្រីក្រ/ងាយរងគ្រោះ ដែលបាត់បង់របរចិញ្ចឹមជីវិតក្នុងអំឡុងពេលអន្តរកាល | |
| | គ្រួសាររងផលប៉ពាល់ដែលបាត់បង់ទីលំនៅ ដែលបាត់បង់របរចិញ្ចឹមជីវិតជាអចិន្ត្រៃយ៍ | |
| | គ្រួសាររងផលប៉ះពាល់ដែលក្រីក្រ/ងាយរងគ្រោះ ដែលបាត់បង់របរចិញ្ចឹមជីវិតជាអចិន្ត្រៃយ៍ | |
| របរចិញ្ចឹមជីវិត | គ្រួសាររងផលប៉ះពាល់ដែលបាត់បង់លទ្ធភាពប្រើប្រាស់ធនធានទ្រព្យសម្បត្តិរួម | |
| **ការផ្តល់អំណោយដីដោយស្ម័គ្រចិត្តសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ** | | |
| # ជន/គ្រួសារដែលបានផ្តល់អំណោយដី | | |
| # ការផ្តល់អំណោយដោយស្ម័គ្រចិត្តក្នុងតំបន់សម្បទានដីសង្គមកិច្ច/ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច | | |
| # ការផ្តល់អំណោយដោយស្ម័គ្រចិត្តក្រៅតំបន់សម្បទានដីសង្គមកិច្ច/ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច | | |
| **យន្តការដោះស្រាយបណ្តឹងតវ៉ា** | | |
| # បណ្តឹងដែលបានដាក់ | | |
| # បណ្តឹងដែលត្រូវបានដោះស្រាយ និងទទួលយកដោយគ្រួសាររងផលប៉ះពាល់ | | |
| # បណ្តឹងដែលត្រូវបានដោះស្រាយ ប៉ុន្តែមិនទទួលយកដោយគ្រួសាររងផលប៉ះពាល់ | | |
| **ថវិកា និងការចំណាយ** | | |
| ថវិកាសំណង (ដី ផ្ទះសម្បែង/សំណង់។ល។) | | |
| ការចំណាយធៀបនឹងថវិកាសំណង | | |

[15] ការបដិសេធមិនចុះហត្ថលេខាលើកិច្ចសន្យាការអង្កេតវាស់វែងលម្អិត ស្មើនឹងការដាក់បណ្តឹងតាមរយៈយន្តការដោះស្រាយបណ្តឹងតវ៉ា។

ក្នុងពេលអនុវត្តផែនការដោះស្រាយផលប៉ះពាល់ ក្រសួងរៀបចំដែនដី នឹងរៀបចំ និងដាក់របាយការណ៍ប្រចាំត្រីមាសទៅធនាគារពិភពលោក ដោយផ្អែកលើគំរូឯកសារខាងក្រោម ៖

| ចំណងជើងផ្នែក | ការពិពណ៌នាសង្ខេប |
| --- | --- |
| ១.កំណត់ការរៀបចំផ្នែកស្ថាប័ន | រៀបរាប់ពីការរៀបចំផ្នែកស្ថាប័នជាក់ស្តែងសម្រាប់ការអនុវត្តផែនការដោះស្រាយផលប៉ះពាល់ |
| ២.ការទូទាត់សំណងសម្រាប់សិទ្ធិទទួលបាន | ខ្លឹមសារសង្ខេប និងតារាងសំណងដែលបានទូទាត់ |
| ៣.ការអភិវឌ្ឍទីតាំងសម្រាប់ការតាំងទីលំនៅឡើងវិញ និងការផ្លាស់ទីតាំង | ប្រសិនបើអាច សូមរៀបរាប់ពីវឌ្ឍនភាពស្តីពីការអភិវឌ្ឍទីតាំងសម្រាប់ការតាំងទីលំនៅឡើងវិញ និងការផ្លាស់ទីតាំងប្រជាជនដែលគ្រោងឡើងក្នុងផែនការដោះស្រាយផលប៉ះពាល់ |
| ៤.ការដោះស្រាយបណ្តឹងតវ៉ា | ចំនួន និងប្រភេទបណ្តឹងដែលបានដាក់ ដំណើរការដោះស្រាយដែលបានអនុវត្ត លទ្ធកម្ម ពេលវេលាចាំបាច់ បញ្ហានានា |
| ៥.ការពិគ្រោះយោបល់ជាសាធារណៈ | ខ្លឹមសារលម្អិតខ្លីស្តីពីកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈ ៖ កាលបរិច្ឆេទ ទីកន្លែង ចំនួនអ្នកចូលរួម ប្រធានបទនៃការពិគ្រោះយោបល់ យោបល់គ្រឡប់សំខាន់ៗ |
| ៦.ការចំណាយថវិកា | ខ្លឹមសារសង្ខេបពីចំណាយលើការអនុវត្តកម្មវិធីតាំងទីលំនៅឡើងវិញ |
| ៧.កម្មវិធីទ្រទ្រង់របរចិញ្ចឹមជីវិត | វឌ្ឍនភាពនៃការអនុវត្តកម្មវិធីទ្រទ្រង់របរចិញ្ចឹមជីវិត ដែលបង្កើតឡើងក្រោមផែនការដោះស្រាយផលប៉ះពាល់ រួមទាំងការចូលរួមរបស់ជនរងផលប៉ះពាល់ដោយសារគម្រោងក្នុងអនុគម្រោងរបរចិញ្ចឹមជីវិតរបស់គម្រោងដំណាក់កាលទី ៣ (ចំនួន និងប្រភេទសកម្មភាព អ្នកចូលរួម។ល។) |
| ៨.វឌ្ឍនភាពជារួមធៀបនឹងកាលវិភាគអនុវត្តន៍ | វឌ្ឍនភាពធៀបនឹងកាលវិភាគអនុវត្តន៍ កំណត់រកការពន្យារពេលដោយផ្តល់ហេតុផល ការយោងតាមកាលវិភាគអនុវត្តន៍បច្ចុប្បន្នភាព (ឧបសម្ព័ន្ធ) |
| ៩.បញ្ហាសំខាន់ៗ | បញ្ហាប្រឈមសំខាន់ៗក្នុងការអនុវត្តផែនការដោះស្រាយផលប៉ះពាល់ |
| ១០.វិធានការដោះស្រាយដែលស្នើឡើង | វិធានការស្នើឡើងដើម្បីដោះស្រាយបញ្ហាដែលបានរកឃើញក្នុងផ្នែកមុន |
| ឧបសម្ព័ន្ធ ៖ កាលវិភាគអនុវត្តន៍បច្ចុប្បន្នភាព | |

## ឧបសម្ព័ន្ធ ៥ ៖ របាយការណ៍រួមស្តីពីការអនុវត្តផែនការដោះស្រាយផលប៉ះពាល់

**អំឡុងពេលរាយការណ៍ ៖ ________________________________**

| ស្ថានភាពរួមនៃការអង្កេតវាស់វែងលម្អិត | # អនុគម្រោងក្នុងសម្បទានដីសង្គមកិច្ច | # ចំនួនអនុគម្រោងក្នុងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច | សរុប |
|---|---|---|---|
| ចំនួនអនុគម្រោងដែលទទួលបានជំនួយក្រោមគម្រោងដំណាក់កាលទី ៣ | | | |
| ចំនួនអនុគម្រោងដែលត្រូវមានផែនការដោះស្រាយផលប៉ះពាល់ (ត្រូវរៀបចំឡើង កំពុងរៀបចំ កំពុងអនុវត្ត និងបញ្ចប់) | | | |
| អនុគម្រោងដែលកំពុងរៀបចំផែនការដោះស្រាយផលប៉ះពាល់ | | | |
| អនុគម្រោងដែលបានរៀបចំផែនការដោះស្រាយផលប៉ះពាល់ (ដូចជា ការអង្កេតវាស់វែងលម្អិត) និងអនុម័តដោយធនាគារពិភពលោក | | | |
| អនុគម្រោងដែលកំពុងអនុវត្តផែនការដោះស្រាយផលប៉ះពាល់ | | | |
| អនុគម្រោងដែលបញ្ចប់ការអនុវត្តផែនការដោះស្រាយផលប៉ះពាល់ | | | |

| ការសិក្សាតម្លៃជំនួស | |
|---|---|
| ចំនួនការសិក្សាតម្លៃជំនួសដែលបានគ្រោង (ត្រូវគ្របដណ្តប់លើបម្រែបម្រួលតម្លៃជំនួសក្នុងតំបន់) | |
| ចំនួនការសិក្សាតម្លៃជំនួសដែលបានបញ្ចប់ | |

| ស្ថានភាពរួមនៃការអង្កេតវាស់វែងលម្អិត | | |
|---|---|---|
| ការអង្កេតវាស់វែងលម្អិតដែលបានបញ្ចប់ រួមទាំងការពិគ្រោះយោបល់ចាំបាច់ និងការរៀបចំពង្រាងកិច្ចសន្យាការអង្កេតវាស់វែងលម្អិត | ចំនួនផែនការដោះស្រាយផលប៉ះពាល់ដែលបញ្ចប់ការអង្កេតវាស់វែងលម្អិត និងកិច្ចព្រមព្រៀងការអង្កេតវាស់វែងលម្អិតជាមួយគ្រួសាររងផលប៉ះពាល់ | |
| | ចំនួនគ្រួសាររងផលប៉ះពាល់ដែលបានកំណត់អត្តសញ្ញាណក្នុងផែនការដោះស្រាយផលប៉ះពាល់ដែលបញ្ចប់ការអង្កេតវាស់វែងលម្អិត | |
| | ចំនួនគ្រួសាររងផលប៉ះពាល់ក្នុងអនុគម្រោងសម្បទានដីសង្គមកិច្ចដែលបញ្ចប់ការអង្កេតវាស់វែងលម្អិត | |
| | ចំនួនគ្រួសាររងផលប៉ះពាល់ក្នុងអនុគម្រោងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចដែលបញ្ចប់ការអង្កេតវាស់វែងលម្អិត | |
| ស្ថានភាពនៃការចុះហត្ថលេខាលើកិច្ចសន្យាការអង្កេតវាស់វែងលម្អិត | ចំនួនអនុគម្រោងដែលកិច្ចសន្យាការអង្កេតវាស់វែងលម្អិតត្រូវបានចុះហត្ថលេខា (ភាគច្រើន) | |
| | ចំនួនគ្រួសាររងផលប៉ះពាល់ក្នុងផែនការដោះស្រាយផលប៉ះពាល់ដែលបានចុះហត្ថលេខាលើកិច្ចសន្យាការអង្កេតវាស់វែងលម្អិត | |
| | ចំនួនគ្រួសាររងផលប៉ះពាល់ក្នុងផែនការដោះស្រាយផលប៉ះពាល់ដែលបដិសេធមិនចុះហត្ថលេខា និងដាក់បណ្តឹងតាមរយៈយន្តការដោះស្រាយផលប៉ះពាល់ | |
| | ចំនួនគ្រួសាររងផលប៉ះពាល់ក្នុងផែនការដោះស្រាយផលប៉ះពាល់ដែលមិនទាន់អាចកំណត់ទីតាំង/ទាក់ទង | |
| ផលប៉ះពាល់ | ចំនួនគ្រួសាររងផលប៉ះពាល់ក្នុងផែនការដោះស្រាយផលប៉ះពាល់ដែលត្រូវបានផ្លាស់ទីលំនៅដោយសារការបាត់បង់ដីធ្លី/ផ្ទះសម្បែង | |
| | ចំនួនគ្រួសាររងផលប៉ះពាល់ក្នុងផែនការដោះស្រាយផលប៉ះពាល់ដែលប្រឈមនឹងការបាត់បង់របរចិញ្ចឹមជីវិត (បណ្តោះអាសន្ន ឬអចិន្ត្រៃយ៍) | |
| | ចំនួនគ្រួសាររងផលប៉ះពាល់ក្នុងផែនការដោះស្រាយផលប៉ះពាល់ដែលក្រីក្រ/ងាយរងគ្រោះ | |

| ស្ថានភាពរួមនៃលទ្ធកម្មដីធ្លី និងការផ្តល់សំណង និងជំនួយសម្រាប់ការតាំងទីលំនៅឡើងវិញ | | |
|---|---|---|
| ការផ្តល់ដីជំនួស ឬក្បាលដីសង់ផ្ទះ | ចំនួនអនុគម្រោង/ផែនការដោះស្រាយផលប៉ះពាល់ដែលផ្តល់ដីជំនួសសម្រាប់ធ្វើកសិកម្ម ឬក្បាលដីសង់ផ្ទះដល់គ្រួសាររងផលប៉ះពាល់ | |
| | ចំនួនគ្រួសាររងផលប៉ះពាល់ដែលទទួលបានដីជំនួស/ក្បាលដីសង់ផ្ទះ | |
| ការទូទាត់សំណងជាប្រាក់ និងប្រាក់ឧបត្ថម្ភ | ចំនួនអនុគម្រោង/ផែនការដោះស្រាយផលប៉ះពាល់ដែលទទួលបានសំណងជាប្រាក់ និងប្រាក់ឧបត្ថម្ភ | |
| | ចំនួនគ្រួសាររងផលប៉ះពាល់ដែលទទួលបានសំណងជាប្រាក់ និងប្រាក់ឧបត្ថម្ភ | |
| ការផ្តល់ជំនួយដល់ការស្តារបរចិញ្ចឹមជីវិតឡើងវិញ ( សមាសភាគទី ៣ ) | ចំនួនអនុគម្រោង/ផែនការដោះស្រាយផលប៉ះពាល់ដែលផ្តល់ជំនួយដល់ការស្តារបរចិញ្ចឹមជីវិតឡើងវិញ | |
| | ចំនួនគ្រួសាររងផលប៉ះពាល់ដែលផ្តល់ជំនួយដល់ការស្តារបរចិញ្ចឹមជីវិតឡើងវិញ | |

| ស្ថានភាពរួមនៃការផ្តល់អំណោយដីដោយស្ម័គ្រចិត្តសម្រាប់ហេដ្ឋារចនាសម្ព័ន្ធក្នុងសម្បទានដីសង្គមកិច្ច និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច | |
|---|---|
| ចំនួនអនុគម្រោងសម្បទានដីសង្គមកិច្ច/ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចដែលមានការផ្តល់អំណោយដីដោយស្ម័គ្រចិត្ត | |
| ចំនួនជន/គ្រួសារដែលបានផ្តល់អំណោយដីដោយស្ម័គ្រចិត្ត | |
| ចំនួននៃការផ្តល់អំណោយដីដោយស្ម័គ្រចិត្តសម្រាប់ហេដ្ឋារចនាសម្ព័ន្ធដែលស្ថិតនៅក្រៅតំបន់សម្បទានដីសង្គមកិច្ច/ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច | |
| ចំនួននៃការផ្តល់អំណោយដីដោយស្ម័គ្រចិត្តសម្រាប់ហេដ្ឋារចនាសម្ព័ន្ធដែលស្ថិតនៅក្នុងតំបន់សម្បទានដីសង្គមកិច្ច/ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច | |

| ស្ថានភាពរួមនៃយន្តការដោះស្រាយបណ្តឹងតវ៉ា | |
|---|---|
| ចំនួនបណ្តឹងដែលបានដាក់ | |
| ចំនួនបណ្តឹងពាក់ព័ន្ធនឹងការអង្កេតវាស់វែងលម្អិត ( វិសាលភាព ឬការវាយតម្លៃការបាត់បង់ ) | |
| ចំនួនបណ្តឹងដែលបានដោះស្រាយ និងទទួលយកដោយគ្រួសាររងផលប៉ះពាល់ | |
| ចំនួនបណ្តឹងដែលបានដោះស្រាយ ប៉ុន្តែមិនទទួលយកដោយគ្រួសាររងផលប៉ះពាល់ | |

| ថវិកាដុល និងការចំណាយក្នុងផែនការដោះស្រាយផលប៉ះពាល់ | |
|---|---|
| ថវិកាសំណងដុល ( ដី ផ្ទះសម្បែង/សំណង់ ដំណាំ/ដើមឈើ ប្រាក់ឧបត្ថម្ភ ) | |
| ការចំណាយដុលធៀបនឹងថវិកាសំណង | |

បន្ថែមការពិពណ៌នាពីបញ្ហាធំៗបូករួមនឹងវិធានការដោះស្រាយដែលស្នើឡើង។